ព្រះរាជាណាចក្រកម្ពុជា

# យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម កម្ពុជា ២០១៤-២០១៨

## សង្ខេបប្រតិបត្តិ

ភ្នំពេញ, មករា ឆ្នាំ២០១៤

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាពិសេសដល់ ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ចំពោះការប្តេជ្ញាចិត្តដ៏ខ្លាំងក្លាក្នុងការបញ្ចប់ការងារនេះនិង ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបានត្រួតពិនិត្យមើលដំណាក់កាលដំបូងៗនៃការរៀបចំការសិក្សានេះ។ សូមថ្លែងអំណរគុណជាពិសេសដល់ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មប្រធាន*គណៈកម្មការអន្តរក្រសួងរៀបចំធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៤-២០១៨*និងអតីតមន្ត្រីបង្គោល EIF សម្រាប់កម្ពុជា, លោកជំទាវ តឹក រ៉េតកំរង រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្មនិងជាមន្ត្រីបង្គោល EIF សម្រាប់កម្ពុជា, ឯកឧត្តម សុខ សុភ័ក្រ្ត អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្មលោក ស៊ឹម សុខេង ប្រធានស្តីទីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម ក៏ដូចជាសមាជិកនៃ*គណៈកម្មការអន្តរក្រសួងរៀបចំធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសមាហរណ-កម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៣-២០១៨* ដែលបានគាំទ្រដល់ក្រុមការងារនៅទូទាំងដំណើរការរៀបចំយុទ្ធសាស្ត្រនេះ។ ចុងក្រោយសូមថ្លែងអំណរគុណជាពិសេសដល់លោក សួន ប្រសិទ្ធ លោកស្រី នង រតនា និងលោក លី ប្រយុទ្ធ ដែលបានផ្តល់ការគាំទ្រផ្នែកភ័ស្តុភារយ៉ាងខ្លាំងក្លានៅក្នុងអំឡុងដំណើរការទាំងមូល។

## គណៈកម្មការអន្តរក្រសួង CTIS ២០១៣-២០១៨ (ក្រុមការងារ)

| | | | |
|---|---|---|---|
| ឯ.ឧ. | ប៉ាន | សូរស័ក្តិ | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនិងប្រធានគណៈកម្មាធិការអន្តរក្រសួង |
| ឯ.ឧ. | ហង្ស | ជួនណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា (អតីតរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអនុប្រធានគណៈកម្មាធិការអន្តរក្រសួង) |
| ឯ.ឧ. | តឹក | រ៉េតសំរេច | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រីជាអនុប្រធាន |
| ឯ.ឧ. | ហេង | សុខគង់ | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្មនិងសិប្បកម្មជាអនុប្រធាន |
| ឯ.ឧ. | ជួន | ឃិនស៊ីម | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល |
| ឯ.ឧ. | ទិត | ចន្ថា | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ |
| ឯ.ឧ. | គួ | ស៊ុមសារួត | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ |
| លោកជំទាវ តឹក | | រ៉េតកំរង | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម |
| ឯ.ឧ. | ហ៊ូ | វុឌ្ឍី | អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ឯ.ឧ. | រស់ | សីលវ៉ា | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ឯ.ឧ. | អ៊ុក | ប្រជា | អនុរដ្ឋលេខាធិការ ក្រសួងផែនការ |
| ឯ.ឧ. | សុខ | សុភ័ក្រ្ត | អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម |
| ឯ.ឧ. | ពេជ្រ | ឫទ្ធី | អគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស ក្រសួងពាណិជ្ជកម្ម |
| ឯ.ឧ. | វ៉ា | ស៊ឹមសុរិយា | អគ្គនាយករដ្ឋបាល ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ឯ.ឧ. | ម៉េង | សាក់ធារ៉ា | រដ្ឋលេខាធិការ ក្រសួងរ៉ែនិងថាមពល |
| ឯ.ឧ. | ជា | វុទ្ធី | អគ្គលេខាធិការរង CDC |
| ឯ.ឧ. | ឈីវ | ឃីស៊ាង | ប្រធានផ្នែកសិក្សានិងបណ្តុះបណ្តាលជាក់ស្តែង RSA |
| លោក | សេន | សុវណ្ណ | អគ្គលេខាធិការរង ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| លោក | ឈៀង | ពេជ្រ | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម |

| | | | |
|---|---|---|---|
| លោក | លី | សារុជ | អនុប្រធាននាយកដ្ឋានរដ្ឋបាល ក្រសួងអភិវឌ្ឍន៍ជនបទ |
| លោក | ថៃ | ឈុនហាក់ | អនុប្រធាននាយកដ្ឋាន ក្រសួងកិច្ចការនារី |
| លោក | ទី | សេរីវិទ្ធ | អគ្គលេខាធិការរងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| លោក | ស៊ឹម | សុខខេង | ប្រធានស្តីពីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម |
| លោក | វ៉ត្ត | សារ៉ាវុធ | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្មជាលេខាធិការ |
| លោក | ចាន់ | បុណ្ណារិទ្ធិ | មន្ត្រីសាលាភូមិន្ទរដ្ឋបាល |

## ក្រុមការងារ CTIS

| | | |
|---|---|---|
| Fabio | Artuso, | ទីប្រឹក្សាបច្ចេកទេសធនាគារពិភពលោក |
| Denis | Audet, | ទីប្រឹក្សាបច្ចេកទេសធនាគារអភិវឌ្ឍន៍អាស៊ី |
| Nick | Blong, | DEV advisory និងទីប្រឹក្សាបច្ចេកទេស UNDP |
| Peter | Brimble, | ធនាគារអភិវឌ្ឍន៍អាស៊ី - កម្ពុជាសេដ្ឋវិទូជាន់ខ្ពស់និងជាអនុប្រធាន |
| Sven | Callebaut, | ក្រសួងពាណិជ្ជកម្មទីប្រឹក្សាជាន់ខ្ពស់ផ្នែកជំនួយសម្រាប់ពាណិជ្ជកម្ម |
| Julian | Clarke, | ធនាគារពិភពលោក - កម្ពុជាសេដ្ឋវិទូជាន់ខ្ពស់ |
| Sandra | D'Amico, | HR Inc. Cambodia, អគ្គនាយកនិងជាទីប្រឹក្សាបច្ចេកទេស UNDP |
| Fabrice | Gregoire, | ទីប្រឹក្សាបច្ចេកទេស UNDP |
| Stefano | Inamo, | លេខាធិការដ្ឋាន UNCTAD |
| Pisey | Khin, | ទីប្រឹក្សាបច្ចេកទេស ធនាគារអភិវឌ្ឍន៍អាស៊ី |
| Roger | Lawrence, | ក្រសួងពាណិជ្ជកម្មទីប្រឹក្សាជាន់ខ្ពស់ផ្នែកពាណិជ្ជកម្ម |
| Sara | Núñez Évora, | ទីប្រឹក្សាបច្ចេកទេស |
| Gordon | Peters, | ដៃគូទទួលបន្ទុកគ្រប់គ្រង Emerging Market Consulting និងជាទីប្រឹក្សាបច្ចេកទេស ADB |
| Sam | Vichet, | អ្នកស្រាវជ្រាវ RULE និងជាទីប្រឹក្សាបច្ចេកទេស UNDP |
| Srun | Sopheak, | អ្នកស្រាវជ្រាវ RULE និងជាទីប្រឹក្សាបច្ចេកទេស UNDP |
| Sok | Cheyrotha, | អ្នកស្រាវជ្រាវ RULE និងជាទីប្រឹក្សាបច្ចេកទេស UNDP |
| Kees | Van Der Meer, | ទីប្រឹក្សាបច្ចេកទេស ធនាគារអភិវឌ្ឍន៍អាស៊ី |
| Matt | Van Roosmalen, | ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់ Emerging Market Consulting |
| Victor | Van Spengler, | ទីប្រឹក្សាបច្ចេកទេស UNDP |
| Va | Sothy, | BDLINK ( Cambodia ) Co., Ltd |
| | *និង* | |
| Thierry | Noyelle, | ទីប្រឹក្សាបច្ចេកទេស UNDP និងប្រធានក្រុម |

# មាតិកា

**អក្សរកាត់** ........ 7
**សារបក** ........ 11
CTIS 2014 - 2018 : គោលការណ៍ជាមូលដ្ឋាន ........ 13
ចំណុចរំលេចនិងរបកគំហើញសំខាន់ៗ ........ 15

ភាពប្រកួតប្រជែងនៃការនាំចេញនិងការអភិវឌ្ឍមនុស្ស ........ 16

សសរស្តម្ភទី១ ........ 35
លំនាំដែលកំពុងមានការផ្លាស់ប្តូរនៃពាណិជ្ជកម្មនិងការចូលទីផ្សារ........ 35
កិច្ចសម្រួលពាណិជ្ជកម្ម ........ 42
ភ័ស្តុភារពាណិជ្ជកម្ម ........ 45
វិធានការអនាម័យនិងភូតគាមអនាម័យ - ស្តង់ដារបច្ចេកទេស ........ 48
បរិយាកាសវិនិយោគសម្រាប់ការអភិវឌ្ឍពាណិជ្ជកម្ម ........ 52
កម្មសិទ្ធិបញ្ញា ........ 59

សសរស្តម្ភទី២ ........ 62
វិស័យសំលៀកបំពាក់ ........ 63
វិស័យស្បែកជើង ........ 66
ប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស ........ 69
វិស័យកម្មន្តសាលនិងដំឡើងធុនស្រាលនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ........ 72
វិស័យចំណីអាហារកែច្នៃ ........ 76
ផលិតផលជលផល ........ 79
វិស័យអង្ករ ........ 82
វិស័យដំឡូងមី ........ 85
វិស័យកៅស៊ូ ........ 88
វិស័យទេសចរណ៍ ........ 90
វិស័យផលិតផលសូត្រ ........ 93

សសរស្តម្ភទី៣ ........ 95
ការកិ្តតគម្លាតជំនាញនៅក្នុងវិស័យនាំចេញ ........ 95
ការបញ្ជ្រាបពាណិជ្ជកម្មការកៀងគរជំនួយសម្រាប់ពាណិជ្ជកម្មការចូលរួមរបស់វិស័យឯកជន ........ 99

ផែនទីបង្ហាញផ្លូវអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ២០១៤-២០១៨ ........ 105

# អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន |
| AfT | ជំនួយសម្រាប់ពាណិជ្ជកម្ម |
| AFTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BFC | គម្រោងរោងចក្រកាន់តែប្រសើរនៃកម្ពុជា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CIB | គណៈកម្មាធិការវិនិយោគកម្ពុជា |
| CoM | គណៈរដ្ឋមន្ត្រី |
| CTIS | យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា |
| DFQF | មិនគិតពន្ធនាំចូល មិនគិតកូតា ( Duty-Free Quota-Free ) |
| DICO | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| DP | ដៃគូអភិវឌ្ឍន៍ |
| DTIS | ការសិក្សាវិភាគអំពីយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម |
| EBA | អ្វីៗទាំងអស់លើកលែងតែអាវុធ ( Everything-but-Arms ) |
| EDC | អគ្គិសនីកម្ពុជា ( Electricité du Cambodge ) |
| EIF | កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម |
| EU | សហភាពអឺរ៉ុប |
| FDI | ការវិនិយោគទុនដោយផ្ទាល់ពីខាងក្រៅ |
| FiA | រដ្ឋបាលជលផល |
| FTA | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| GAP | ការប្រតិបត្តិកសិកម្មល្អ |
| GDCE | អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ( MEF ) |
| GDP | ផលទុនសរុបក្នុងស្រុក |
| GHP | ការប្រតិបត្តិសុខភាពល្អ |
| GMAC | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| GMP | ការប្រតិបត្តិល្អផ្នែកកម្មន្តសាល |
| GMS | មហាអនុតំបន់មេគង្គ |
| G-PSF | វេទិការាជរដ្ឋាភិបាល-វិស័យឯកជន |
| HACCP | ការវិភាគមុខសញ្ញាគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ៗ |

| | |
|---|---|
| HEI | គ្រឹះស្ថានឧត្តមសិក្សា |
| HRD | ការអភិវឌ្ឍធនធានមនុស្ស |
| IC (Trade SWAp) | គណៈកម្មាធិការអនុវត្តន៍អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម |
| IPA | ទីភ្នាក់ងារជំរុញការវិនិយោគ |
| IPR | កម្មសិទ្ធិបញ្ញា |
| LDC | ប្រទេសដែលមានការអភិវឌ្ឍតិចតួច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoC | ក្រសួងពាណិជ្ជកម្ម |
| MoCFA | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| MoE | ក្រសួងបរិស្ថាន |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoFA | ក្រសួងការបរទេស |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoIH | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MoPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MoT | ក្រសួងទេសចរណ៍ |
| MoU | អនុស្សរណៈនៃការយោគយល់គ្នា |
| MoWA | ក្រសួងកិច្ចការនារី |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NCIPR | គណៈកម្មាធិការជាតិកម្មសិទ្ធិបញ្ញា |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NSDP | កម្មវិធីយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSW | ច្រកចូលតែមួយថ្នាក់ជាតិ |
| PISC | អនុគណៈកម្មាធិការវិនិយោគខេត្ត |
| PSD | ការអភិវឌ្ឍវិស័យឯកជន |
| QIP | គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| RCEP | ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ |
| RDB | ធនាគារអភិវឌ្ឍន៍ជនបទ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RUA | សកលវិទ្យាល័យភូមិន្ទកសិកម្ម |

| | |
|---|---|
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| SMEs | សហគ្រាសខ្នាតតូចនិងមធ្យម |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SPS | អនាម័យ និងភូតគាមអនាម័យ |
| S-SC | អនុគណៈកម្មាធិការ |
| SWOT | ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង |
| TA | ជំនួយបច្ចេកទេស |
| TBT | របាំងផ្នែកបច្ចេកទេសចំពោះពាណិជ្ជកម្ម |
| TDSP | កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម |
| Trade SWAp | អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម |
| TPR | ការពិនិត្យឡើងវិញលើគោលនយោបាយពាណិជ្ជកម្ម |
| TRIPS | ពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា |
| TVET | ការអប់រំនិងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ |
| TWG | ក្រុមការងារបច្ចេកទេស |
| WCO | អង្គការគយពិភពលោក |
| WG | ក្រុមការងារ |
| WIPO | អង្គការកម្មសិទ្ធិបញ្ញាពិភពលោក |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក |

# សាវតារ

នៅក្នុងខែវិច្ឆិកាឆ្នាំ២០០១ កម្ពុជាបានធ្វើសុពលកម្ម*យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មបែបវិភាគ* (DTIS) លើកទី១ របស់ប្រទេស។ DTIS ឆ្នាំ២០០១ ត្រូវបានរៀបចំឡើងដោយមានការគាំទ្រផ្នែកថវិកាពីកម្មវិធី*ក្របខ័ណ្ឌសមាហរណកម្ម* (IF)។ កម្ពុជាត្រូវបានជ្រើសរើសដោយ IF ជាប្រទេសមួយក្នុងចំណោមប្រទេសសាកល្បងបីសម្រាប់កម្មវិធីថ្មីនេះ ដែលបានប្រកាសដាក់ឲ្យអនុវត្តដោយស្ថាប័នពហុភាគីចំនួន៦ - មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ (UNCTAD) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ធនាគារពិភពលោក (WB) និងអង្គការពាណិជ្ជកម្មពិភពលោក (WTO)។

នៅក្នុងខែធ្នូ ឆ្នាំ២០០៧នាយករដ្ឋមន្ត្រីកម្ពុជាបានប្រកាសដាក់ឲ្យអនុវត្ត DTIS ទីពីររបស់ប្រទេសគឺ*យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០០៧* (CTIS 2007)។ CTIS 2007 ទទួលអត្ថប្រយោជន៍ពីការគាំទ្រផ្នែកថវិការួមបញ្ចូលគ្នាពីកម្មវិធី IFពីដំបូង និង UNDP ក៏ដូចជាការរួមចំណែកផ្នែកបច្ចេកទេសពី EU, GIZ, IFC, IMF, ITC, UNCTAD, និងធនាគារពិភពលោក។ នៅពេលនោះកម្ពុជាគឺជាប្រទេសទីមួយដែលបានធ្វើបច្ចុប្បន្នកម្ម DTIS ដំបូងរបស់ខ្លួនក្រោម*កម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម* (EIF), ដែលបន្តពីកម្មវិធី IF។

យុទ្ធសាស្ត្រសមាហរណកម្មកម្ពុជាឆ្នាំ២០១៤-២០១៨ (CTIS 2014-2018) គឺជា DTIS ជំនាន់ទីបីរបស់ប្រទេស។ ជាថ្មីម្តងទៀតកម្ពុជាបាននាំមុខគេក្នុងចំណោមប្រទេស EIF ។ កម្ពុជាគឺជាប្រទេស EIF ទីមួយដែលបានធ្វើបច្ចុប្បន្នកម្ម DTIS ដំបូងរបស់ខ្លួនជាលើកទីពីរ។ CTIS 2014-2018 បានទទួលអត្ថប្រយោជន៍ពីការគាំទ្រផ្នែកថវិកាពី EIF, ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP), និងធនាគារពិភពលោក (WB)។

ចាប់តាំងពី DTIS ទីមួយក្នុងឆ្នាំ២០០១ការដឹកនាំដំណើរការតាក់តែង DTIS ក្នុងប្រទេសកម្ពុជា បានផ្លាស់ប្តូរយ៉ាងខ្លាំង។ នេះឆ្លុះបញ្ចាំងពីសមត្ថភាពដែលកំពុងតែកើនឡើងរបស់កម្ពុជាក្នុងការគ្រប់គ្រងដំណើរការ*ជំនួយសម្រាប់ពាណិជ្ជកម្ម*របស់ខ្លួន។ DTIS ទីមួយគឺភាគច្រើនផ្អែកលើស្ថាប័នដោយក្នុងនោះធនាគារពិភពលោកដឹកនាំក្រុមអ្នកជំនាញក្រោមថវិកា IF។ CTIS 2007 ត្រូវបានអនុវត្តក្រោមការដឹកនាំរួមរបស់ក្រសួងពាណិជ្ជកម្មនិង UNDP។ CTIS 2014-2018 គឺជាដំណើរការដែលដឹកនាំដោយពេញលេញដោយរដ្ឋាភិបាលនិងរដ្ឋាភិបាលជាម្ចាស់។

ក្រោមការដឹកនាំនិងការណែនាំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបច្ចុប្បន្ននិងពីមុននិងដោយមានការគាំទ្រផ្នែកប្រតិបត្តិការយ៉ាងខ្លាំងក្លាពីមន្ត្រីជាន់ខ្ពស់សំខាន់ៗនៅក្នុងក្រសួងក្រុមការងារបានជួបជុំគ្នាដើម្បីរៀបចំ CTIS 2014-2018 ដែលបានទទួលអត្ថប្រយោជន៍ពីធាតុចូលផ្នែកបច្ចេកទេសពី *គណៈកម្មការអន្តរក្រសួងរៀបចំធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៣-២០១៨*។ គណៈកម្មការអន្តរក្រសួងនេះត្រូវបានបង្កើតឡើងតាមរយៈប្រកាសមួយនិងមានសមាជិកជាមន្ត្រីជាន់ខ្ពស់មកពីក្រសួងពាណិជ្ជកម្មក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ ក្រសួងផែនការ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួង

រ៉ែនិងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងអប់រំយុវជននិងកីឡា ក៏ដូចជាទីស្តីការគណៈរដ្ឋមន្ត្រីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិងសាលាភូមិន្ទរដ្ឋបាល។ សមាជិករបស់គណៈកម្មាធិការអន្តរក្រសួងបានផ្តល់ដល់សមាជិកក្រុមការងារ DTIS នូវឱកាសដើម្បីជួបប្រជុំជាមួយមន្ត្រីនៅក្នុងក្រសួងរបស់ពួកគេពិនិត្យឡើងវិញលើឯកសារព្រាង និងបានជួបជាមួយក្រុមដើម្បីផ្តល់មតិយោបល់ព័ត៌មានត្រឡប់និងជាតុចូលដទៃទៀតអំពីឯកសារផ្សេងៗ។

សង្ខេបប្រតិបត្តិនេះ និងលទ្ធផលជាយុទ្ធសាស្ត្រទាំង ២០ ដែលត្រូវបានប្រើប្រាស់ដើម្បីរៀបចំការសិក្សា ត្រូវបានអនុម័តដោយ*អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្មនិងការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម*នៅក្នុងខែឧសភាឆ្នាំ ២០១៣។ បន្ទាប់មកក្រសួងពាណិជ្ជកម្មបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងផែនការនិង SNEC ដើម្បីធានាថាលទ្ធផលទាំង២០ត្រូវបានបញ្ជ្រាបក្នុង NSDP-IV ថ្មីនិងយុទ្ធសាស្ត្រចតុកោណទីIII របស់រដ្ឋាភិបាលថ្មី។ *របាយការណ៍ពេញលេញចុងក្រោយនិង ផែនទីបង្ហាញផ្លូវនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មឆ្នាំ២០១៤-២០១៨ ត្រូវបានអនុម័តដោយអនុគណៈកម្មាធិការដឹកនាំស្តីពីពាណិជ្ជកម្មនិងការវិនិយោគដែលទាក់ទងនឹងពាណិជ្ជកម្ម ដឹកនាំដោយទេសរដ្ឋមន្ត្រីក្នុងខែមករាឆ្នាំ២០១៤។*

## CTIS 2014-2018:គោលការណ៍ជាមូលដ្ឋាន

CTIS 2014-2018 ឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងដោយរាជរដ្ឋាភិបាលកម្ពុជាដើម្បីពិនិត្យឡើងវិញលើការវិវត្តសំខាន់ៗនៅក្នុងវិស័យពាណិជ្ជកម្មរបស់ប្រទេសចាប់តាំងពី DTIS លើកមុន (CTIS 2007)និងដើម្បីធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនិងទិសដៅរបស់កម្ពុជាសម្រាប់សមាហរណកម្មពាណិជ្ជកម្មទៅក្នុងទីផ្សារសកលនិងតំបន់។ CTIS 2014-2018 ត្រូវបានណែនាំដោយគោលការណ៍បី៖

1. **ធ្វើបច្ចុប្បន្នភាពនិងពង្រឹងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មកម្ពុជា**

   ចាប់ផ្តើមក្នុងឆ្នាំ២០០៨ និងផ្អែកលើទិសដៅជាយុទ្ធសាស្ត្រនិងសកម្មភាពដែលបានកំណត់ក្នុង CTIS 2007 រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការដឹកនាំរបស់ក្រសួងពាណិជ្ជកម្មនិង*អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្មនិងការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម* បានបង្កើតអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp)។ គោលបំណងនៃ Trade SWAp គឺដើម្បីផ្តល់ដល់រដ្ឋាភិបាលនូវឧបករណ៍នានាដើម្បីកែលម្អការសម្របសម្រួលរបស់ខ្លួននិងការគ្រប់គ្រងជារួមនៃជំនួយសម្រាប់ពាណិជ្ជកម្ម ក៏ដូចជាពិនិត្យតាមដានមើលវឌ្ឍនភាពធៀបនឹងគោលដៅជាយុទ្ធសាស្ត្រនិងសកម្មភាពរបស់ CTIS 2007 ។

   ឧបករណ៍មួយក្នុងចំណោមឧបករណ៍បែបនេះ គឺផែនទីបង្ហាញផ្លូវTrade SWAp ដែលត្រូវបានរៀបចំឡើងជុំវិញ "សសរស្តម្ភ"បី។ សសរស្តម្ភនីមួយៗគ្របដណ្តប់លើផ្នែកសំខាន់ៗសម្រាប់កំណែទម្រង់និងវឌ្ឍនភាពដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យពាណិជ្ជកម្មរបស់កម្ពុជា។ ផ្នែកជាអាទិភាពគឺស្របគ្នានឹង CTIS 2007 ហើយលទ្ធផលត្រូវបានត្រួតពិនិត្យតាមដានតាមរយៈទិន្នន័យដើមគ្រានិងគោលដៅចំណុចដែលមានរំលេចនៅក្នុងសូចនាករលទ្ធផលសំខាន់ៗ (KPIs) សម្រាប់ផ្នែកនីមួយៗ។

   CTIS 2014-2018 ពិនិត្យមើលកាលានុវត្តភាពថ្មីៗនិងបញ្ហាប្រឈមដែលបានកើតឡើងចាប់តាំងពីឆ្នាំ២០០៧មក។ បន្ថែមពីលើនេះ CTIS 2014-2018 ផ្តល់ដល់រដ្ឋាភិបាលនូវកាលានុវត្តភាពសម្រាប់ធ្វើបច្ចុប្បន្នភាពផែនទីបង្ហាញផ្លូវ Trade SWAp របស់រាជរដ្ឋាភិបាលកម្ពុជានិងកំណត់ពីទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗសម្រាប់វិស័យពាណិជ្ជកម្មរបស់កម្ពុជាសម្រាប់រយៈពេលប្រាំឆ្នាំបន្ទាប់ ២០១៤-២០១៨។ ទិសដៅទាំងនេះនឹងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ជំនួយបច្ចេកទេសបន្តនិងថ្មី និងសម្រាប់បញ្ជ្រាបអាទិភាពអភិវឌ្ឍន៍ពាណិជ្ជកម្មទៅក្នុង*ផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចថ្មី* (NSDP) *យុទ្ធសាស្ត្រចតុកោណបន្ទាប់* និង *ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៣០*។

2. **ដាក់បញ្ចូលសមត្ថភាពរដ្ឋាភិបាលដែលបានកសាងឡើងតាំងពីឆ្នាំ២០០៧ ដើម្បីដឹកនាំការធ្វើបច្ចុប្បន្នភាព CTIS និងផែនទីបង្ហាញផ្លូវ Trade SWAp**

   ជាលទ្ធផលនៃការអនុវត្ត Trade SWAp ចាប់តាំងពីពាក់កណ្តាលនិងចុងទសវត្សរ៍២០០០ មន្ត្រីរដ្ឋាភិបាល

កាន់តែច្រើនឡើងនៅក្នុងក្រសួងពាណិជ្ជកម្មនិងក្រសួងពាក់ព័ន្ធនឹងពាណិជ្ជកម្មដទៃទៀត បានយល់កាន់តែច្រើនអំពីដំណើរការតាក់តែងអនុវត្ត ត្រួតពិនិត្យតាមដាន និងវាយតម្លៃ*គម្រោងជំនួយសម្រាប់ពាណិជ្ជកម្មនីមួយៗ*។ អ្នកដទៃទៀតបានពាក់ព័ន្ធដោយផ្ទាល់ជាមួយយន្តការដែលបានបង្កើតឡើងដើម្បីត្រួតពិនិត្យមើលវឌ្ឍនភាពនៃ Trade SWAp ជារួមជានាថាគោលដៅត្រូវបានបំពេញនិងពិនិត្យឡើងវិញលើវឌ្ឍនភាពធៀបនឹងគោលដៅចំណុច។

សមត្ថភាពដែលបានបង្កើតឡើងថ្មីៗ ធ្វើឲ្យរដ្ឋាភិបាលអាចទទួលបន្ទុកលើការតាក់តែង CTIS 2014-2018 ក្រោមការដឹកនាំរបស់ក្រសួងពាណិជ្ជកម្ម។ ដំណើរការនៃការតាក់តែង CTIS 2014-2018 បានចាប់ផ្តើមជាមួយនឹងការកំណត់រកគោលរឿងសំខាន់ៗដែលត្រូវដាក់បញ្ចូលការតាក់តែងកំណត់សម្គាល់ទស្សនទានមួយដែលត្រូវបានពិនិត្យឡើងវិញនិងអនុម័តដោយគណៈកម្មការអន្តរក្រសួង Trade SWAp (IC) ក្រោមការណែនាំពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ការរៀបចំគណៈ*កម្មការអន្តរក្រសួងសម្រាប់ធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៣-២០១៨* ដើម្បីគាំទ្រដល់ការតាក់តែង CTIS 2014-2018 ថ្មីនិងបាននាំទៅរកជំហាននានាមួយចំនួនដើម្បីធានាថាលទ្ធផលការងារមានភាពជាម្ចាស់ពេញលេញនិងរួមគ្នា នឹងដាក់បញ្ចូលទៅក្នុងក្រសួងនិងស្ថាប័ននានារបស់រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការអនុវត្តជំនួយបច្ចេកទេសសម្រាប់ពាណិជ្ជកម្ម។

## 3. កំណត់រកបញ្ហាប្រឈមថ្មីនិងដាក់បញ្ចូលអាទិភាពថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍពាណិជ្ជកម្មទៅក្នុង Trade SWAp

ទោះបីជាCTIS 2014-2018 ត្រូវបានណែនាំភាគច្រើនដោយផ្អែកជាអាទិភាពដែលបានកំណត់នៅក្នុងឆ្នាំ២០០៧ និងឆ្លុះបញ្ចាំងនៅក្នុងផែនទីបង្ហាញផ្លូវនៃសសរស្តម្ភទាំងបីវាមិនមានន័យថាយុទ្ធសាស្ត្រនេះត្រូវតែប្រកាន់ខ្ជាប់តាមអាទិភាពទាំងនោះទេ។ CTIS 2014-2018 ទទួលស្គាល់ថា លក្ខខណ្ឌអាចមានការផ្លាស់ប្តូរ ហើយថា អាទិភាពនិងតម្រូវការថ្មីអាចលេចចេញឡើង។ ដូច្នេះ CTIS 2014-2018 ក៏ធានាផងដែរថា អាទិភាពថ្មីជាគន្លឹះដែលកំណត់ដោយរដ្ឋាភិបាលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឯកសារថ្មី ។

ជាពិសេស CTIS 2007 បានពិនិត្យយ៉ាងទូលំទូលាយលើសក្តានុពលនៃវិស័យនាំចេញសម្រាប់កម្ពុជាដោយបានកំណត់វិស័យចំនួន១៩ ដែលមានសក្តានុពលនាំចេញ។ បន្ទាប់ពីបានចំណាយពេលអស់ជាង៦ឆ្នាំដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្មមកវិស័យចំនួនដប់ក្នុងចំណោមវិស័យទាំងនេះត្រូវបានជ្រើសរើសជំបូងគេ។ CTIS 2014-2018 ផ្តោតលើវិស័យទាំងដប់នេះ។

បញ្ហាប្រទាក់ក្រឡាថ្មីពីរត្រូវបានលើកឡើងនៅក្នុង CTIS 2014-2018 ក្រោមសសរស្តម្ភទីមួយនិងទីបី៖ (១)ភ័ស្តុភារសម្រាប់ការដឹកជញ្ជូននិង (២)កង្វះខាតជំនាញសម្រាប់ការនាំចេញ។ ការអភិវឌ្ឍការនាំចេញដោយជោគជ័យក្នុងរយៈពេលពីរបីឆ្នាំកន្លងមកបានផ្តោតទៅលើសសរស្តម្ភទាំងពីរនេះ ថាជាបញ្ហាប្រឈមដែលអាចកើតឡើងនិងត្រូវការការយកចិត្តទុកដាក់ឲ្យបានជិតដល់។

# ចំណុចរំលេចនិងគំហើញសំខាន់ៗ

## សេចក្តីផ្តើម
## ភាពប្រកួតប្រជែងនៃការនាំចេញនិងការអភិវឌ្ឍមនុស្ស

កន្លងមកកម្ពុជាទទួលបានជោគជ័យយ៉ាងច្រើននៅក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចសកលតាមរយៈពាណិជ្ជកម្ម និងការវិនិយោគ។ គេសង្កេតឃើញមានវឌ្ឍនភាពយ៉ាងច្រើនចាប់តាំងពីពាក់កណ្តាលទសវត្សរ៍២០០០មក។ ប៉ុន្តែ ទីផ្សារពិភពលោកកំពុងតែមានការផ្លាស់ប្តូរ ដោយក្នុងនោះអ្នកប្រកួតប្រជែងថ្មីៗបន្តលេចចេញឡើងដើម្បីប្រជែង ជាមួយវិស័យនាំចេញរបស់កម្ពុជា។ បញ្ហាប្រឈមសម្រាប់ប្រទេសនេះ និងវិស័យនាំចេញរបស់ខ្លួនគឺត្រូវឆ្លើយតប ទៅនឹងការផ្លាស់ប្តូរដោយពង្រឹងភាពប្រកួតប្រជែងនៃវិស័យដែលមានស្រាប់ខណៈពេលជាមួយគ្នានោះក៏ត្រូវអភិវឌ្ឍ វិស័យថ្មីៗទៀតផងដែរ។

ភាពប្រកួតប្រជែងរបស់វិស័យពាណិជ្ជកម្មមានសារៈសំខាន់យ៉ាងខ្លាំងចំពោះកំណើននិងចំពោះការបង្កើតការងារថ្មី និងកាន់តែប្រសើរក៏ដូចជាប្រាក់ចំណូលដែលជាលក្ខខណ្ឌតម្រូវនៃការកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែ ការផ្សារភ្ជាប់ ការពង្រីកពាណិជ្ជកម្មទៅនឹងការកាត់បន្ថយភាពក្រីក្រសមភាពយេនឌ័រ និងភាពរួមបញ្ចូលកាន់តែធំនៅតែជាបញ្ហា ប្រឈមនៅឡើយ។ ជាមួយនឹងកំណើនយ៉ាងរហ័សនៅក្នុងវិស័យកសិកម្មដែលផ្តោតលើការនាំចេញនៅក្នុងតំបន់ ជនបទនិងពិពិធកម្មដែលកំពុងកើតឡើងនៅក្នុងចំនួនគោលដៅទេសចរណ៍កម្ពុជាបានធ្វើឲ្យមានវឌ្ឍនភាពយ៉ាង សំខាន់នៅក្នុងការដោះស្រាយភាពក្រីក្រតាមរយៈការបង្កើតការងារ និងប្រាក់ចំណូលកាន់តែច្រើនឡើងនៅតាម តំបន់នានាក្នុងប្រទេស។ ទោះបីជាយ៉ាងណាក្តី លក្ខខណ្ឌការងារនិងជីវភាពរស់នៅដែលពាក់ព័ន្ធនឹងការងារដែល ទាក់ទងនឹងការនាំចេញជាច្រើនត្រូវការការកែលម្អថែមទៀត។ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាននៃផលិត កម្មសម្រាប់នាំចេញខ្លះមកលើបរិស្ថានរូបវន្ត ត្រូវការការយកចិត្តទុកដាក់ថែមទៀត។ បន្ថែមពីលើនេះការបង្កើន ជំនាញរបស់កម្លាំងការងារគឺជាបញ្ហាប្រឈមធំបំផុតរបស់ប្រទេសនេះក្នុងការធ្វើដំណើរទៅមុខ ប្រសិនបើប្រទេស នេះចង់ទទួលបានជោគជ័យនៅក្នុងការប្រើប្រាស់ការពង្រីកពាណិជ្ជកម្ម ជាមធ្យោបាយមួយដើម្បីបង្កើតការងារ កាន់តែប្រសើរ ដែលមានជំនាញកាន់តែខ្ពស់ជាងមុនដែលនឹងបង្កើតប្រាក់ចំណូលបានកាន់តែច្រើន។

# ភាពប្រកួតប្រជែងនៃការនាំចេញ

ភាពប្រកួតប្រជែងនៃវិស័យពាណិជ្ជកម្ម គឺជាលទ្ធផលនៃអន្តរកម្មក្នុងចំណោមកត្តាមួយចំនួនដែលនៅក្នុងបរិបទកម្ពុជាអាចត្រូវបានបែងចែកចេញជាបួនអនុក្រុមៈ

- កែលម្អលទ្ធភាពចូលទីផ្សារ
- ពង្រឹងបរិយាកាសធុរកិច្ចក្នុងស្រុក
- បង្កើនកត្តាសរុប និងផលិតភាពពលកម្ម
- បង្កើនតម្លៃបន្ថែមក្នុងស្រុក

លទ្ធភាពចូលទីផ្សាររបស់កម្ពុជា បានវិវត្តយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងវិធានប្រភពដើមដែលគ្រប់គ្រងកម្មវិធី EBA របស់សហភាពអឺរ៉ុប អត្ថប្រយោជន៍ពីកម្មវិធីគ្មានពន្ធនាំចូលគ្មានកូតា (Duty-Free Quota-Free (DFQF)) មួយចំនួនរួមជាមួយនឹងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយដៃគូកិច្ចសន្ទនាអាស៊ានបានជំរុញឲ្យមានការកើនឡើងយ៉ាងខ្លាំងនូវការនាំចេញរបស់កម្ពុជា - រួមទាំងការនាំចេញសំលៀកបំពាក់ផងដែរ។ រួមជាមួយបរិយាកាសធុរកិច្ចអំណោយផលគួរសមនិងការចំណាយលើពលកម្មទាប លទ្ធភាពចូលទីផ្សារដែលកាន់តែប្រសើរជាងមុននេះ គឺជាកម្លាំងបឋមមួយដែលជំរុញការពង្រីកយ៉ាងខ្លាំងនូវការវិនិយោគនៅក្នុងវិស័យកម្មន្តសាល។ លទ្ធភាពចូលទីផ្សារក៏កំពុងតែចាប់ផ្តើមវិវត្តផងដែរទាក់ទងទៅនឹងផលិតផលកសិកម្ម។ ការពឹងផ្អែកលើប្រទេសជិតខាងជាទីផ្សារ និងជាអន្តរការីសម្រាប់ការនាំចេញផលិតផលកសិកម្មដែលមិនទាន់កែច្នៃក្រៅផ្លូវការ កំពុងតែចាប់ផ្តើមផ្តល់ជាហេតុផលសម្រាប់ការនាំចេញដោយផ្ទាល់ផ្លូវការទៅកាន់ទីផ្សារចុងក្រោយ ដែលជាទូទៅកម្ពុជាទទួលបានភាពអនុគ្រោះគ្មានពន្ធនាំចូល។ ដំណើរការនេះនៅតែស្ថិតនៅក្នុងដំណាក់កាលដំបូងប៉ុណ្ណោះ ហើយការបន្តទៅមុខទៀតគឺអាស្រ័យលើសមត្ថភាពរបស់កម្ពុជាក្នុងការឆ្លើយតបនឹងអនាម័យនិងភូតគាមអនាម័យនិងស្តង់ដារបច្ចេកទេសរបស់ប្រទេសដែលនាំចូល។ សម្រាប់ទាំងទំនិញកម្មន្តសាល និងទំនិញកសិកម្ម សេដ្ឋកិច្ចដែលកំពុងតែលូតលាស់យ៉ាងរហ័សរបស់អាស៊ីនិងទីផ្សារ "ដែលកំពុងតែលេចចេញថ្មីៗ" ផ្តល់នូវក្តីសង្ឃឹមយ៉ាងធំធេងក្នុងបណ្តាឆ្នាំខាងមុខ។

- ការនាំចេញទំនិញនិងសេវាកម្ម - ត្រូវបានកត់ត្រាទុកនិងក្រៅផ្លូវការ - ត្រូវបានប៉ាន់ស្មានថាបានកើនឡើងចំនួន៦៥% ពីឆ្នាំ២០០៧ ដល់ ២០១១ ពោលគឺពី $៤,៩៤៥ពាន់លានដុល្លារ ដល់ $៨,១៥៥ពាន់លានដុល្លារ
- ចំណែកទីផ្សាររបស់សហរដ្ឋអាមេរិកសម្រាប់ផលិតផលនាំចេញរបស់កម្ពុជាបានធ្លាក់ចុះពី៥៥ភាគរយមកត្រឹម៣៥ភាគរយក្នុងអំឡុងពេលនេះខណៈដែល EU ដៃគូសន្ទនាអាស៊ានថៃឡង់ដ៏វៀតណាមនិងគោលដៅដទៃទៀតដើរតួនាទីកាន់តែសំខាន់ឡើងៗ។
- ៨០%នៃកំណើនរបស់កម្ពុជានៅក្នុងការនាំចេញទំនិញដែលបានកត់ត្រាចាប់តាំងពីឆ្នាំ២០០៧ គឺជាចំណុចដៅនៃទីផ្សារនានាដែលផ្តល់លទ្ធភាពចូលដោយអនុគ្រោះ។

- ចំណែកនៃការនាំចេញក្រៅពីសំលៀកបំពាក់និងទេសចរណ៍ក្នុងអំឡុងរយៈពេលនេះបានកើនឡើងពី ១៨ ដល់ ២៩ ភាគរយ។ ទំនិញចម្បងៗរួមមានកង់សមាសភាគអេឡិចត្រូនិកនិងអគ្គិសនីស្បែកជើងកៅស៊ូ អង្ករនិងស្រូវដំឡូងមីពោតនិងសណ្តែកសៀង។

បរិយាកាសធុរកិច្ចរឹងមាំសម្រាប់ពាណិជ្ជកម្មមានលក្ខណៈសម្គាល់មួយចំនួន។ ក្របខ័ណ្ឌច្បាប់និងនិយ័តកម្មមួយដែលអាចព្យាករបាននិងផ្អែកលើបទដ្ឋានអន្តរជាតិគឺជាធាតុគោលមួយ។បរិយាកាសវិនិយោគអំណោយផលក៏ដូចជាកិច្ចសម្រួលពាណិជ្ជកម្មនិងការដឹកជញ្ជូនគឺជាកត្តាកំណត់សំខាន់ផ្សេងទៀតនៃភាពប្រកួតប្រជែង។ កិច្ចសម្រួលពាណិជ្ជកម្មនិងការដឹកជញ្ជូនពាណិជ្ជកម្មនឹងមានសារៈសំខាន់ ជាពិសេសសម្រាប់ការអភិវឌ្ឍវិស័យនាំចេញដូចជាសំលៀកបំពាក់ដែលមានគុណភាពខ្ពស់ឬធាតុចូលកម្រិតមធ្យមទៅក្នុងសង្វាក់ផលិតកម្មដែលក្នុងនោះកាលបរិច្ឆេទ "ផ្តល់ផលិតផលសម្រេច" ឬដឹកជញ្ជូនឲ្យមានសារៈសំខាន់ខ្លាំងបំផុត។កិច្ចការជាច្រើនត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងផ្នែកជាច្រើនក្នុងចំណោមផ្នែកទាំងនេះក្នុងរយៈពេលដប់ឆ្នាំកន្លងមកប៉ុន្តែ នៅមានកិច្ចការ ជាច្រើនទៀតដែលត្រូវធ្វើ។

- ការចំណាយលើកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់ការនាំចេញ និងការនាំចូល គឺ ១៣៦ភាគរយ លើសមធ្យមភាគអាស៊ាន៦ (the ASEAN-6 average)។ ពេលវេលាបញ្ចេញទំនិញជាមធ្យមគឺ២៤ថ្ងៃប្រៀបធៀបនឹង១៦ថ្ងៃសម្រាប់មធ្យមភាគអាស៊ាន៦ (ASEAN-6 average)។
- កម្ពុជាគម្រោងនឹងបញ្ចប់ការបង្កើតបញ្ជរជាតិតែមួយត្រឹមឆ្នាំ២០១៨ ដែលនឹងជួយបន្ទាបរង្វាល់សំខាន់ទាំងពីរនោះ។
- ទោះបីជាមានការកែលម្អយ៉ាងច្រើននៅក្នុងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ចាប់តាំងពីចុងទសវត្សរ៍២០០០ មកក៏ដោយនៅមានកិច្ចការជាច្រើនដែលត្រូវធ្វើ ដើម្បីកែលម្អប្រសិទ្ធភាពនៃភស្តុភារផ្នែកដឹកជញ្ជូននៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងអនុតំបន់ទាំងក្នុងការវិនិយោគនៅក្នុងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការកាត់បន្ថយវិធានមិនមែនពន្ធនានា ក្នុងគោលបំណងកាត់បន្ថយការចំណាយសំខាន់ៗលើការធ្វើធុរកិច្ច។

បច្ចុប្បន្ននេះផលិតភាពនៃកត្តាសរុបនិងផលិតភាពពលកម្ម ក៏ជាកត្តាកំណត់សំខាន់ដែរសម្រាប់ភាពប្រកួតប្រជែង។ កំណើននៅក្នុងផលិតភាពអនុញ្ញាតឲ្យប្រាក់ឈ្នួលដែលកាន់តែខ្ពស់ជាងមុន និងប្រកួតប្រជែងកាន់តែប្រសើរដើរទន្ទឹមគ្នា។ ផលិតភាពមានការកើនឡើងជាចម្បងតាមរយៈការវិនិយោគនៅក្នុងឧបករណ៍បរិក្ខារដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាខ្ពស់ជាងមុន។ ការប្រើឧបករណ៍បរិក្ខារបែបនេះ តម្រូវឲ្យមានកម្រិតជំនាញខ្ពស់ជាងមុន។ មានការព្រួយបារម្ភថាជំនាញកម្រិតមធ្យមនិងកម្រិតខ្ពស់ខ្សោយដែលគេត្រូវការសម្រាប់ដំណើរការផលិតកម្មស្មុគស្មាញនៅក្នុងប្រទេសកម្ពុជាកំពុងតែរាំងដល់ផលចំណេញផ្នែកផលិតភាពនិងការវិនិយោគដែលអាចនាំទៅរកតម្លៃបន្ថែមកាន់តែខ្ពស់។ មានការព្រួយបារម្ភកាន់តែច្រើន ដែលទាក់ទងនឹងកំណើនគ្រប់គ្រាន់នៃផលិតភាព សម្ពាធទាមទារប្រាក់ឈ្នួលខ្ពស់ជាងមុនអាចប៉ះឲ្យប៉ះពាល់ដល់ភាពប្រកួតប្រជែង។ ជំនាញប្រសើរជាងមុនដែលអនុញ្ញាត

ឲ្យជនជាតិកម្ពុជាអនុវត្តការងារដែលបច្ចុប្បន្នអនុវត្តដោយបុគ្គលិកបរទេស នឹងកាត់បន្ថយការចំណាយចំពោះសហគ្រាសនិងលើកកម្ពស់ភាពប្រកួតប្រជែងរបស់ពួកគេ។ ដោយសារតែហេតុផលទាំងនេះគេចាំបាច់ត្រូវតែដោះស្រាយចំណុចខ្វះខាតរវាងជំនាញ ដែលមានបច្ចុប្បន្ននៅក្នុងកម្លាំងការងារនិងជំនាញដែលចាំបាច់សម្រាប់ទីកន្លែងធ្វើការបច្ចុប្បន្ននិងអនាគត។

- កម្ពុជាខ្វះខាតប្រព័ន្ធ TVET ដ៏រឹងមាំមួយដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជនរួមទាំងវិស័យនាំចេញដើម្បីធានាថា តម្រូវការជំនាញត្រូវបានឆ្លើយតប។
- គ្រឹះស្ថានឧត្តមសិក្សារបស់កម្ពុជា បានលូតលាស់យ៉ាងរហ័សក្នុងរយៈពេលដប់ឆ្នាំកន្លងមក ដែលធ្វើឲ្យមានការកើនឡើងយ៉ាងរហ័សនូវនិស្សិតបញ្ចប់ការសិក្សាពីសកលវិទ្យាល័យ។ ទោះបីជាយ៉ាងក្ដី កម្មវិធីសិក្សានៅសកលវិទ្យាល័យនៅតែដាច់ចេញពីជំនាញដែលត្រូវការនៅក្នុងទីផ្សារហើយជារឿយៗការអប់រំមានគុណភាពខ្សោយ។
- មនុស្សវ័យក្មេងជាច្រើនបញ្ចប់ការសិក្សាពីការអប់រំបឋមសិក្សាមធ្យមសិក្សាឬសូម្បីតែឧត្តមសិក្សា ដែលមាន "មូលដ្ឋានគ្រឹះ" ខ្សោយលើជំនាញផ្នែកទន់ (soft skills) (ឧទា.អក្សរសាស្ត្រនិងលេខនព្វន្តការប្រាស្រ័យទាក់ទងការដោះស្រាយបញ្ហាការងារជាក្រុម។ល។)។ ជំនាញទន់ដែលជាមូលដ្ឋានគ្រឹះមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការសិក្សាមួយជីវិតនិងការបណ្ដុះបណ្ដាលឡើងវិញក្នុងពេលអនាគតនៅទីកន្លែងធ្វើការ។
- កម្ពុជាខ្វះខាតប្រព័ន្ធព័ត៌មានទីផ្សារការងារដែលមានតម្លាភាព ដើម្បីជួយដល់អ្នកអប់រំនិងអ្នកចូលទីផ្សារការងារថ្មីឲ្យយល់ថាតើការទាមទារចេញពីណាមកតើតម្រូវការជំនាញមានអ្វីខ្លះនិងតើត្រូវជួយនិយោជកកំណត់ពីទីកន្លែងដែលគេអាចស្វែងរកកម្មករថ្មីៗ។

ការនាំចេញទំនិញកម្មន្តសាលចម្បងរបស់កម្ពុជា - សំលៀកបំពាក់ ស្បែកជើងនិងកង់ - មានដំណើរការទៅស្ទើរតែផ្ដាច់មុខនៅក្នុងសង្វាក់តម្លៃសកលដោយដំឡើងវត្ថុធាតុដែលនាំចូល និងគ្រឿងបង្គុំទៅជាផលិតសម្រេចដែលបន្ទាប់មកត្រូវបាននាំចេញ។ ផលិតផលនាំចេញកសិកម្មរបស់កម្ពុជាភាគច្រើនគឺជាផលិតផលកសិកម្មមិនទាន់កែច្នៃ។ នៅក្នុងករណីទាំងពីរនេះតម្លៃបន្ថែមនៅក្នុងប្រទេសកម្ពុជាធម្មតាគឺជាបំណែកតូចមួយនៃតម្លៃរបស់ផលិតប្រើប្រាស់សម្រេច។ កម្ពុជាត្រូវតែប្រើប្រាស់លទ្ធភាពទាំងនេះសម្រាប់បន្ថែមតម្លៃបន្ថែមនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងករណីកសិកម្មកិច្ចការនេះរួមមានការធ្វើការកែច្នៃជាតុចេញនៅឯទ្វារបេងកសិដ្ឋាន - ដូចដែលកំពុងកើតឡើងរួចទៅហើយក្នុងករណីស្រូវ។ នៅក្នុងករណីសំលៀកបំពាក់ស្បែកជើងនិងកង់ គេត្រូវតែយកចិត្តទុកដាក់ទៅលើផលិតកម្មនៅក្នុងប្រទេសកម្ពុជានូវធាតុចូលដែលបច្ចុប្បន្ននេះត្រូវបាននាំចូលពីប្រទេសផ្សេង។

- ការបង្កើតទំនាក់ទំនងផ្គត់ផ្គង់រវាង SMEs របស់កម្ពុជានិងក្រុមហ៊ុននាំចេញមានសារៈសំខាន់ ហើយគួរតែត្រូវបានជំរុញ។ ការវិនិយោគដោយផ្ទាល់ពីបរទេសនៅក្នុងការផលិតធាតុចូលក្នុងស្រុកក៏ត្រូវតែលើកទឹកចិត្តផងដែរ។ ឧស្សាហកម្មនាំចេញគួរតែជាចំណុចកណ្ដាលមួយនៃការអភិវឌ្ឍផលិតកម្មក្នុងស្រុក។ ការ

ផលិតទំនិញនាំចេញគឺដូចជាវិស័យទេសចរណ៍ដូច្នេះដែរដែលក្នុងនោះ កាលានុវត្តភាពសម្រាប់ការតភ្ជាប់តែខ្លាំងទៅនឹងអ្នកផ្គត់ផ្គង់ក្នុងស្រុកគួរត្រូវបានលើកទឹកចិត្តផងដែរ។

- អ្នកនាំចេញកម្ពុជាទាំងអស់អាចនិងគួរតែខិតខំធ្វើដំណើរឆ្ពោះទៅរកផលិតផលដែលត្រូវការប្រតិបត្តិការដែលមានកាន់តែតម្លៃខ្ពស់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែកិច្ចការនេះនឹងអាស្រ័យយ៉ាងខ្លាំងទៅលើសមត្ថភាពរបស់វិស័យនាំចេញនិងគ្រឹះស្ថានអប់រំនិង TVET ក្នុងការស្វែងរកវិធីនានាដើម្បីដោះស្រាយកង្វះខាតជំនាញបច្ចុប្បន្ន។
- កិច្ចខិតខំប្រឹងប្រែងដើម្បីទាក់ទាញវិនិយោគិនថ្មីគួរពាក់ព័ន្ធទៅនឹងការផ្តោតគោលដៅលើផ្នែកផ្សេងៗដែលក្នុងនោះវិធានប្រភពដើមទំនិញដែលមានលក្ខណៈអំណាយផលផ្តល់នូវគុណប្រយោជន៍តែមួយគត់សម្រាប់កម្ពុជា ដើម្បីពង្រឹងមូលដ្ឋានគ្រឹះរបស់ខ្លួននៅក្នុងសង្វាក់តម្លៃសកល។
- គុណភាពដែលមានសង្គតិភាព មានសារៈសំខាន់យ៉ាងខ្លាំងចំពោះភាពប្រកួតប្រជែងរយៈពេលវែងរបស់ក្រុមហ៊ុន។ គុណភាពមិនស្របគ្នានៃធាតុចូលនានាឬគុណភាពមិនស្របគ្នានៅក្នុងដំណើរការផលិតកម្មនឹងបំផ្លាញដល់ភាពប្រកួតប្រជែងនៃសង្វាក់តម្លៃ។ ឧទាហរណ៍ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ/អ្នកនាំចេញកំពុងតែជួបការលំបាកក្នុងការធានាគុណភាពនៃផលិតផលនាំចេញរបស់ខ្លួន។ ផលិតករនៃផលិតផលសូត្រដែលមានតម្លៃខ្ពស់ត្រូវតែសិក្សាពីរបៀបគ្រប់គ្រងគុណភាពនៃអំបោះដែលនាំចូលឲ្យបានប្រសើរជាងមុន។
- នៅក្នុងវិស័យដែលពាក់ព័ន្ធនឹង SPS (ស្រូវ/អង្ករជំឡូងមីសណ្តែកសៀងវិស័យបដិសណ្ឋារកិច្ចអាហារកែច្នៃជលផល) ផលិតករចាំបាច់ត្រូវតែរក្សាស្តង់ដារនៃប្រព័ន្ធផលិតកម្មរបស់ខ្លួន ដើម្បីឆ្លើយតបនឹងលក្ខខណ្ឌតម្រូវអន្តរជាតិ។ រដ្ឋាភិបាលត្រូវតែដើរតួនាទីមួយផ្នែកផងដែរដោយរៀបចំឲ្យមាននូវប្រព័ន្ធតាមដាននិងអនុវត្តច្បាប់ដែលត្រូវការដើម្បីកំចាត់សមាសធាតុចង្រៃនិងជំងឺសត្វ ត្រួតពិនិត្យតាមដានការប្រើថ្នាំសម្លាប់សត្វល្អិតឬត្រួតពិនិត្យចំណីអាហារនិងផលិតផលនៅក្នុងទីផ្សាររបស់អ្នកប្រើប្រាស់។
- ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់អ្នកវិនិយោគិនដែលផ្តោតលើការនាំចេញតាមរយៈកម្មវិធីពាក់ព័ន្ធឬគ្រឹះស្ថានហិរញ្ញវត្ថុឯកទេស គឺជាផ្នែកមួយដែលបានទទួលការយកចិត្តទុកដាក់ពីរដ្ឋាភិបាលរួមទាំងបរិបទនៃ*ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ* ដែលបានចេញនៅក្នុងខែកក្កដាឆ្នាំ២០១០។ ទោះបីជាយ៉ាងណាក្តី គេចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមទៀតក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។
- បទពិសោធន៍ជាវិជ្ជមានរបស់*ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ* គួរតែចម្លងទៅវិស័យដទៃទៀតផងដែរ (កសិកម្មកម្មន្តសាលឬវិស័យដទៃទៀត) ដែលនឹងទទួលបានអត្ថប្រយោជន៍ពីការណែនាំផ្នែកគោលនយោបាយច្បាស់លាស់។

# ការអភិវឌ្ឍមនុស្សប្រកបដោយចីរភាពនិងកំណើននាំចេញ

ខណៈដែលការកំណត់ពីជោគជ័យអនាគតរបស់កម្ពុជា គឺជាកិច្ចការសំខាន់បំផុតនៅក្នុងការរំកិលចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុតទៅជាសេដ្ឋកិច្ចដែលមានប្រាក់ចំណូលមធ្យមគេមិនអាចសំឡឹងមើលភាពប្រកួតប្រជែងនៃការនាំចេញតែមួយមុខគត់បានទេ។ គេត្រូវតែពិចារណាភាពប្រកួតប្រជែងនៃការនាំចេញធៀបនឹងភាពប្រសើរនៅក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព។ តារាងទី១ សង្ខេបពីវិធានការអភិវឌ្ឍមនុស្សប្រកបដោយចីរភាពដែលបានប្រមូលក្នុងអំឡុងពេលរៀបចំជំពូកសម្រាប់វិស័យនីមួយៗ និងជំពូកអំពីជំនាញដែលបានបង្ហាញនៅក្នុងរបាយការណ៍។ ខណៈដែលទិន្នន័យរឹងនៅក្នុងប្រទេសកម្ពុជាមានកម្រិតដែលធ្វើឲ្យមានការពិបាកខ្លះក្នុងការវាយតម្លៃលទ្ធផលនិងវឌ្ឍនភាពក្នុងផ្នែកនេះ វិធានការដែលបង្ហាញក្នុងតារាង ទោះបីជាមានលក្ខណៈជាទូទៅក៏ដោយ គឺបង្ហាញពីផ្នែកនានាដែលមានវឌ្ឍនភាពចាប់តាំងពីឆ្នាំ២០០៧ ក៏ដូចជាបញ្ហាប្រឈមដែលនៅសេសសល់ ជាពិសេសទាក់ទងទៅនឹង ៖

- កាលានុវត្តភាពកំណើនការងារ
- គុណភាពនៃការងារ លក្ខខណ្ឌការងារ និងការរស់នៅ
- ការបែងចែកទៅតាមភូមិសាស្ត្រនៃអត្ថប្រយោជន៍ពីកំណើន
- ផលប៉ះពាល់បរិស្ថាន

## កាលានុវត្តភាពកំណើនការងារ

ជាមួយនឹងយុវជនពី៣០០.០០០ទៅ៤០០.០០០នាក់ដែលត្រូវបានព្យាករថាចូលទីផ្សារការងារជារៀងរាល់ឆ្នាំក្នុងរយៈពេលមួយទសវត្សរ៍បន្ទាប់បញ្ហាប្រឈមផ្នែកការអភិវឌ្ឍមនុស្សធំបំផុតរបស់កម្ពុជាគឺការបង្កើតការងារ។ តាមពិតទៅបញ្ហានេះបានក្លាយជាអាទិភាពដ៏ធំមួយរបស់រដ្ឋាភិបាល។ លើកលែងតែសូត្រចេញវិស័យ៩ផ្សេងទៀតមានសក្តានុពលរឹងមាំសម្រាប់កំណើនការងារជាបន្តទៀតក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ រួមគ្នាវិស័យទាំងនេះគួរបន្ថែមការងារថ្មីរាប់ម៉ឺនការងារជារៀងរាល់ឆ្នាំ ដែលនឹងរួមចំណែកយ៉ាងច្រើនដល់ការដោះស្រាយបញ្ហាប្រឈមនៃការបង្កើតការងារ។[1]

នៅក្នុងវិស័យកម្មន្តសាល - កាត់ដេរស្បែកជើងនិងកម្មន្តសាលធុនស្រាល - ក៏ដូចជានៅក្នុងវិស័យទេសចរណ៍ការបង្កើតការងារថ្មីជាច្រើនទំនងជានឹងកើតឡើងជាចម្បងនៅក្នុងវិស័យទាំងនោះដោយផ្ទាល់តែម្តងប៉ុន្តែអ្នកផ្តល់សេវា

[1]ជាការពិតអត្រាកំណើនគឺជាមុខងារមួយនៃទិន្នន័យដើមគ្រាដំបូងនៅក្នុងវិស័យនីមួយៗ ហើយនឹងមានល្បឿនយឺតជាងនេះ នៅក្នុងវិស័យធំៗដែលមានស្រាប់ដូចជា កាត់ដេរនិងទេសចរណ៍ទោះបីជាការងារជាច្រើននឹងត្រូវបានបង្កើតឡើងនៅក្នុងវិស័យទាំងនេះក៏ដោយ។

ឲ្យវិស័យទាំងនេះនឹងទទួលបានអត្ថប្រយោជន៍ពីឥទ្ធិពលចម្រុះតាមរយៈកំណើនតម្រូវការ។ ដូចដែលបានលើកឡើងក្នុងរបាយការណ៍ស្រាប់ អ្នកផ្គត់ផ្គង់ជាការប្រមូលផ្តុំក្នុងស្រុកខ្លាំងក្លាគួរតែលេចចេញឡើង ដើម្បីផ្តល់ជាតុចូលជាក់លាក់ដល់វិស័យខ្លះៗក្នុងចំណោមវិស័យទាំងឡាយដរាបណាមានគោលនយោបាយនិងគ្រឿងលើកទឹកចិត្តត្រឹមត្រូវ ។

នៅក្នុងវិស័យពាក់កណ្តាលកែច្នៃឬវិស័យកែច្នៃផលិតផលកសិកម្ម-ដូចជាអង្ករដំឡូមីពាក់កណ្តាលកែច្នៃផលិតផលជលផលចំណីអាហារកែច្នៃឬកៅស៊ូ - ឥទ្ធិពលលើការងារភាគច្រើនបំផុតនឹងបន្តមានយ៉ាងធំជានេះមកលើអ្នកដែលផលិតវត្ថុធាតុដើមៈកសិករដាំស្រូវ និងដំឡូងមី អ្នកនេសាទប្រុស-ស្រី កម្មករចម្ការកៅស៊ូ។ល។ ទោះបីជាយ៉ាងណាក្តីនៅពេលដែលវិស័យទាំងនេះវិវត្តទៅមុខឧទាហរណ៍ដូចជា ចំណីអាហារកែច្នៃទំនើបឬរោងចក្រកែច្នៃត្រីអាចបន្ថែមការងារថ្មីៗជាច្រើនទៀតនៅក្នុងនោះផងដែរ។

តាមពិតតម្លៃខាងក្នុងនៃវិស័យសូត្រគឺខុសគ្នាបន្តិច។ តម្លៃរបស់វាអាចមិនមានច្រើនទេនៅក្នុងចំនួនការងារដែលវាអាចបង្កើតឲ្យបានច្រើនដូចការរួមចំណែករបស់វាទៅលើ "រូបភាពវប្បធម៌" របស់កម្ពុជាដែលជាទ្រព្យសម្បត្តិពិបាកនឹងវាស់វែងប៉ុន្តែទោះជាយ៉ាងណាក្តីវាសំខាន់ខ្លាំងណាស់ចំពោះការលើកកម្ពស់ទេសចរណ៍និងរូបភាពក្នុងសកលលោករបស់កម្ពុជា។

## គុណភាពនៃការងារលក្ខខណ្ឌការងារនិងជីវភាពរស់នៅ

ដូចដែលបានលើកឡើងនៅក្នុងជំពូកទី១៧ នៃរបាយការណ៍ពេញលេញពលរដ្ឋកម្ពុជាវ័យក្មេងមិនគ្រាន់តែចង់បានតែការងារប៉ុណ្ណោះទេ។ ពួកគេចង់បានការងារល្អនិងការងារដែលមានប្រាក់ឈ្នួលខ្ពស់។ ដូច្នេះ គុណភាពនៃការងារគឺជាកូនសោ។ គុណភាពនៃការងារនិងការទទួលបានលក្ខខណ្ឌការងារនិងជីវភាពរស់នៅល្អ គឺជាលទ្ធផលនៃអន្តរកម្មក្នុងចំណោមអថេរផ្សេងៗជាច្រើនដែលស្ថិតក្រោមឥទ្ធិពលយ៉ាងច្រើនពីគោលនយោបាយរបស់រដ្ឋាភិបាលការមាន "ទំនិញសាធារណៈ" ក៏ដូចជាការទទួលបានប្រាក់ចំណូលល្អ។

របាយការណ៍នេះមិនវិភាគឥទ្ធិពលផ្នែកសង្គមទូលំទូលាយនៃកំណើននាពេលថ្មីៗមកលើមុខរបររបស់ប្រជាពលរដ្ឋកម្ពុជានោះទេ។នេះគឺជាប្រធានបទមួយដែលគួរតែទុកសម្រាប់វិភាគនៅក្នុង NSDP។ ទោះបីជាយ៉ាងណាក្តី របាយ-ការណ៍វេទិកាសេដ្ឋកិច្ចពិភពលោកចុងក្រោយបំផុតបង្ហាញថា ផ្អែកតាម ppp (purchasing (ទិញ) power (អំណាច) parity (យុគភាព)) ប្រាក់ចំណូលក្នុងមនុស្សម្នាក់ជាមធ្យមរបស់ពលរដ្ឋកម្ពុជាបានកើនឡើងពីប្រមាណ$១.០០០ដុល្លារ ក្នុងឆ្នាំ២០០០ ដល់$២.៥០០ដុល្លារក្នុងឆ្នាំ២០១២ - ដែលនេះគឺជាវឌ្ឍនភាពយ៉ាងខ្លាំង

មែនទែន[2]។ ជាការពិត ដោយសារតែរង្វាស់នេះគឺគ្រាន់តែជាមធ្យមភាគវាមិនបានបញ្ជាក់លម្អិតអំពីរបាយប្រាក់ចំណូលឡើយ។

ចំណុចផ្តោតនៃរបាយការណ៍នេះ គឺមានលក្ខណៈចង្អៀតនិងកម្រិតត្រឹមតែជប់វិស័យប៉ុណ្ណោះ។ ដូចបានបង្ហាញនៅក្នុងជំពូកទី៥ដែលផ្តោតលើបរិយាកាសវិនិយោគក៏ដូចជាជំពូកអំពីវិស័យនីមួយៗជាច្រើនផងដែរកត្តាគន្លឹះមួយដែលបានទាក់ទាញកំណើនថ្មីនៃការវិនិយោគក្នុងស្រុកនិងដោយផ្ទាល់ពីបរទេស គឺថ្លៃពលកម្មទាបគួរសមនៅក្នុងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក្តីដូចបង្ហាញនៅក្នុងជំពូកទី១៧ស្រាប់ ប្រាក់ឈ្នួលប្រចាំខែអប្បបរមាដែលមាននៅក្នុងវិស័យកម្មន្តសាលកម្ពុជាភាគច្រើនហាក់ដូចជាខ្ពស់ បើប្រៀបធៀបនឹងប្រទេសជិតខាងនិងគូប្រកួតប្រជែងផ្ទាល់។

លើកលែងតែវិស័យកាត់ដេរចេញដែលនិយោជកព្រួយបារម្ភថា កំណើនប្រាក់ឈ្នួលអាចដើរហួសផលិតភាព - ជាស្ថានភាពមួយដែលគ្មាននិរន្តរភាពក្នុងរយៈពេលវែង - ជាទូទៅវាហាក់ដូចជាថា ប្រាក់ឈ្នួលដែលកើនឡើងនៅក្នុងវិស័យកម្មន្តសាលត្រូវបានអមជាមួយផងដែរដោយផលចំណេញផ្នែកផលិតភាព។ ជាការច្បាស់ណាស់ នៅក្នុងវិស័យដែលអាស្រ័យលើផលិតផលកសិកម្មខ្លះដែលបានកំណត់នៅក្នុងការសិក្សានេះជារឿយៗ គេឃើញមានភ័ស្តុតាងអំពីកំណើនផលិតភាពយ៉ាងខ្លាំងក្លាក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនៅថ្នាក់ផលិតកម្មដូចដែលវាស់វែងដោយទិន្នផលក្នុងមួយហិកតា។ ជាទូទៅប្រាក់ចំណូលប្រចាំខែនៅក្នុងវិស័យក្រៅពីសំលៀកំពាក់ ច្រើនតែទាបជាងនិង/ឬកំណត់ដោយផ្អែកលើប្រាក់ឈ្នួលអប្បបរមារបស់វិស័យកាត់ដេរ។ នៅក្នុងរយៈពេលមធ្យមនិងវែងការព្រួយបារម្ភគឺថាតើកំណើននៅក្នុងផលិតភាព នឹងអាចរក្សាឆ្លុះបញ្ចាំងពីការទាមទាររកប្រាក់ឈ្នួលខ្ពស់ជាងមុនប្រសិនបើគម្លាតជំនាញនិងកង្វះខាតជំនាញមិនអាចក្តិតបាន។

ការត្រួតពិនិត្យតាមដានជាអន្តរជាតិនៃផលិតករជាច្រើនក្រោមកម្មវិធី*រោងចក្រកាន់តែប្រសើរនៃកម្ពុជា* (BFC)នៅតែជាគុណប្រយោជន៍ផ្នែកប្រកួតប្រជែងយ៉ាងសំខាន់សម្រាប់អ្នកនាំចេញនៅកម្ពុជាក្នុងវិស័យសំលៀកបំពាក់និងស្បែកជើង។ ទោះបីជាយ៉ាងណាក្តីមានភ័ស្តុតាងថ្មីៗខ្លះដែលថា ចាំបាច់ត្រូវមានការកែលម្អបន្ថែមទៀតនៅក្នុងសុវត្ថិភាពរោងចក្រនិងសង្វាក់ផលិតកម្ម (រួមទាំងសុវត្ថិភាពអគារ) និងភាពស្អាតនៃរោងចក្រ។ នេះគឺជាបញ្ហាសំខាន់មួយដែលកម្ពុជាគួរយកចិត្តទុកដាក់ជាពិសេសដោយសារតែមានការវិវត្តអវិជ្ជមានមួយចំនួនក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះនៅក្នុងប្រទេសមួយចំនួន ដូចជាបង់ក្លាដែសឬចិន។

ជារឿយៗគុណភាពទូទៅនៃជីវភាពរស់នៅគឺជាមុខងារមួយនៃទីកន្លែងធ្វើការរបស់បុគ្គលម្នាក់។ ជាទូទៅ ទិន្នន័យច្រើនតែបង្ហាញថាជីវភាពរស់នៅ (ជម្រកស្នាក់នៅល្អការទទួលបានបង្គន់ស្អាតនិងការទទួលបានទឹកស្អាត) ច្រើនតែធ្លាក់ចុះសម្រាប់កម្មករនៅជនបទជាច្រើនដែលផ្លាស់ប្តូរទីលំនៅមកកាន់តំបន់ទីប្រជុំជនធំៗ ដែលនៅទីនោះជីវភាពរស់នៅមានការលំបាកជាងមុននិងត្រូវចំណាយខ្ពស់ជាងមុន។ ទោះបីជាយ៉ាងណាក្តីនេះមិនសុទតែជាការ

[2] World Economic Forum, *The Global Competitiveness Report 2013-2014*, Davos: WEF, 2013, p.144

ពិតសម្រាប់កម្មករគ្រប់រូបនោះទេ ឧទាហរណ៍ដូចជាកម្មករដែលធ្វើការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និយោជកផ្តល់ដល់ពួកគេនូវលក្ខខណ្ឌជម្រកស្នាក់នៅល្អសមរម្យដែរ។

គុណភាពនៃការងារក៏ពាក់ព័ន្ធផងដែរទៅនឹងសមត្ថភាពរបស់បុគ្គល ក្នុងការកសាងមូលធនមនុស្សតាមរយៈការបណ្តុះបណ្តាលនិងឱកាសនានា ដើម្បីទទួលបានការដំឡើងឋានៈក្នុងការងារ។នេះគឺជាផ្នែកមួយដែលកម្ពុជាកំពុងតែជួបប្រទះបញ្ហាប្រឈមដ៏ធំមួយនៅក្នុងវិស័យទាំងដប់ដែលបានសិក្សានៅទីនោះ។ ចំណុចខ្សោយនៅក្នុងការអប់រំនៅបឋមសិក្សានិងមធ្យមសិក្សា ចំណុចខ្សោយនៅក្នុងការអប់រំថ្នាក់សកលវិទ្យាល័យក៏ដូចជាប្រព័ន្ធ TVET រឹងមាំដែលមានបន្តិចបន្តួច មានន័យថាកម្មករភាគច្រើនធ្វើការងារដោយមានកង្វះខាត (កម្លាត) ក្នុងផ្នែកជំនាញរឹង (មុខរបរ) និងជំនាញទន់ដែលជាមូលដ្ឋានគ្រឹះ។ កង្វះខាត ឬ "គម្លាត" នេះ គឺបញ្ហាមួយបន្ថែមលើនិយោជកដែលកំពុងតែប្រឈមមុខនឹងកង្វះខាតកម្មករ (ភាពមិនអាចស្វែងរកកម្មករឲ្យបានគ្រប់គ្រាន់ដើម្បីដាក់ពាក្យសុំការងារដាក់លាក់មួយចំនួន)ដូចដែលបានវិភាគនៅក្នុងជំពូកទី១៧។ កង្វះខាតមូលធនមនុស្ស និងគម្លាតទាំងនេះ គឺជាបញ្ហាប្រឈមធ្ងន់ធ្ងរមួយចំពោះនិរន្តរភាពនៃភាពប្រកួតប្រជែងរបស់កម្ពុជា។ ទោះបីជានេះមិនមែនជាបញ្ហាប្រឈមធំដុំក្នុងរយៈពេលកន្លងមកនៅពេលដែលចំណុចផ្តោតនៃកំណើននាំចេញផ្អែកទៅលើកត្តាជំនាញទាបនិងប្រាក់ឈ្នួលទាបប៉ុន្តែបច្ចុប្បន្ននេះ បញ្ហានេះត្រូវតែដោះស្រាយឲ្យបានហ្មត់ចត់ដោយរដ្ឋាភិបាល និងវិស័យឯកជនប្រសិនបើកម្ពុជាចង់រក្សាភាពទាក់ទាញរបស់ខ្លួនចំពោះការវិនិយោគថ្មីនិងចង់ទទួលបានជោគជ័យនៅក្នុងការវិវត្តរំកិលឡើងតាមសង្វាក់តម្លៃនៅក្នុងវិស័យនាំចេញមួយចំនួន។

ចុងក្រោយ របកគំហើញដ៏គួរឲ្យចាប់អារម្មណ៍មួយគឺថាខណៈដែលកំណើននាំចេញនៅក្នុងវិស័យកសិកម្មអាចទំនងជាផ្តល់អំណាយផ្តល់ដល់ការងាររបស់បុរសច្រើនជាងនោះ ស្ត្រីគឺជាអ្នកដែលបានទទួលអត្ថប្រយោជន៍ភាគច្រើនបំផុតពីកំណើននៅក្នុងការនាំចេញកម្មន្តសាលនិងទេសចរណ៍។ តុល្យភាពខ្លះក្នុងចំណោមតុល្យភាពទាំងនេះ អាចឬអាចមិនមានការផ្លាស់ប្តូរ ប្រសិនបើកម្ពុជាមានសមត្ថភាពរំកិលឡើងសង្វាក់តម្លៃនិងអភិវឌ្ឍវិស័យជំនាញខ្ពស់ជាងមុន។

## របាយភូមិសាស្ត្រនៃកំណើននាំចេញ

ប្រៀបធៀបនឹងឆ្នាំ២០០៧គេសង្កេតឃើញថាសកម្មភាពសេដ្ឋកិច្ចដែលពាក់ព័ន្ធនឹងកំណើននាំចេញបានចាប់ផ្តើមបំបែកចេញពីប៉ូលកំណើនបីដំបូងរបស់កម្ពុជា – ភ្នំពេញសៀមរាបនិងក្រុងព្រះសីហនុ។ នៅក្នុងវិស័យកម្មន្តសាលតំបន់សេដ្ឋកិច្ចពិសេសកំពុងតែចាប់ផ្តើមទាក់ទាញរោងចក្រដែលនៅជិតព្រំដែនថៃនិងវៀតណាមដែលមិនធ្លាប់មានកន្លងមក។ ប្រសិនបើអ្វីៗ មានដំណើរការទៅល្អការអភិវឌ្ឍទំនងជានឹងពង្រីកកាន់តែធំថែមទៀត។

នៅក្នុងវិស័យទេសចរណ៍ ការអភិវឌ្ឍទេសចរណ៍ដែលផ្តោតលើឆ្នេរសមុទ្រកំពុងតែចាប់ផ្តើមរីកសាយចេញពីក្រុងព្រះសីហនុទៅក្នុងខេត្តជាប់តំបន់ឆ្នេរជុំវិញនោះ។ ទេសចរណ៍ធម្មជាតិកំពុងតែពង្រីកខ្លួននៅក្នុងតំបន់ពាយព្យនិង

ជួរភ្នំក្រវាញនៃប្រទេស។ ការអភិវឌ្ឍទាំងនេះ ក៏ដូចជាការអភិវឌ្ឍដទៃទៀត កំពុងតែទាញកំណើនវិស័យបដិសណ្ឋារកិច្ចទៅក្នុងខេត្តនិងតំបន់ថ្មីៗ។ នៅក្នុងវិស័យដែលផ្តោតលើកសិកម្ម ចំណុចផ្តោតកាន់តែច្រើនឡើងទៅលើផលិតផលកសិកម្មពាក់កណ្តាលកែច្នៃ ឬចំណីអាហារកែច្នៃ កំពុងតែនាំមកនូវសកម្មភាពកែច្នៃទំនើបចូលទៅក្នុងតំបន់ថ្មី។

បន្ថែមពីលើនេះ ដោយមានកម្មករជាច្រើនដែលមកពីតំបន់ជនបទមកធ្វើការនៅក្នុងរោងចក្រកែច្នៃដែលស្ថិតនៅក្នុងឬក្បែរតំបន់ទីប្រជុំជនខេត្ត ដែលមានការអភិវឌ្ឍតិចជាងគេកំពុងតែទទួលបានអត្ថប្រយោជន៍ពីប្រាក់យ៉ាងច្រើនដែលកម្មករទាំងនោះបញ្ជូនមកផ្ទះ។

រួមគ្នាទំនោរទាំងនេះមានន័យថា អត្ថប្រយោជន៍នៃកំណើនពីការនាំចេញមានរបាយភូមិសាស្ត្រកាន់តែធំជាងមុននៅទូទាំងប្រទេស តាមរយៈទីតាំងភូមិសាស្ត្រកាន់តែធំនៃរោងចក្រដែលផ្តោតលើទំនិញនាំចេញតាមរយៈការបែងចែកឡើងវិញនូវប្រាក់ចំណូលដែលបញ្ជូនមកផ្ទះវិញនិងតាមរយៈឥទ្ធិពលដែលកំពុងសាយភាយ។

## ផលប៉ះពាល់ផ្នែកបរិស្ថាន

ភាគច្រើនបំផុតនៃវិស័យនាំចេញដែលកំពុងតែកើនឡើងយ៉ាងរហ័ស រួមទាំងវិស័យទាំង១០ដែលបានវិភាគនៅក្នុងការសិក្សានេះដែរគឺពឹងផ្អែកយ៉ាងខ្លាំងលើអគ្គិសនីដើម្បីផ្តល់ថាមពលសម្រាប់ដំណើរការឧបករណ៍ទំនើប។ តម្លៃអគ្គិសនីនៅក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ ហើយភាពអាចជឿទុកចិត្តបានមានកម្រិតទាប បើប្រៀបធៀបនឹងប្រទេសជិតខាង។នេះគឺជាផ្នែកមួយដែលប្រទេសនេះស្ថិតនៅក្នុងស្ថានភាពចាញ់ប្រៀបគេផ្នែកការប្រកួតប្រជែង។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ គឺថាកម្ពុជាមានជម្រើសតែមួយគត់ដើម្បីដោះស្រាយតម្រូវការទាំងនេះតាមរយៈដំណោះស្រាយផលិតផលថាមពលប្រកបដោយចីរភាព។ ដំណោះស្រាយនេះរួមមានចាប់ពីបន្ទះកម្តៅពន្លឺព្រះអាទិត្យដើម្បីផលិតទឹកក្តៅនៅក្នុងសណ្ឋាគារនិងភោជនីយដ្ឋាន (ដែលជាប្រភពដ៏ធំមួយនៃតម្រូវការអគ្គិសនីនៅក្នុងគ្រឹះស្ថានទាំងនោះ) ឧស្ម័ននីយកម្មជីវឥន្ធនៈដើម្បីផ្តល់ថាមពលដល់ម៉ាស៊ីនកិនស្រូវនិងវិស័យកែច្នៃដទៃទៀត បន្ទះអគ្គិសនីដែលដើរដោយពន្លឺ (photo-voltaic panels) ដើម្បីផលិតអគ្គិសនីនៅក្នុងការប្រើប្រាស់ជាគោលបំណងផ្សេងៗជាច្រើន ឬបច្ចេកវិទ្យាប្រកបដោយចីរភាពដទៃទៀតផងដែរ។ រហូតមកទល់ពេលនេះកម្ពុជាមានភាពស្ទាក់ស្ទើរក្នុងការជំរុញការអនុវត្តទូលំទូលាយនៃដំណោះស្រាយដែលចំណេញខាងសេដ្ឋកិច្ចទាំងនេះ។ ការពិតដែលថា សម្រាប់ពេលបច្ចុប្បន្ននេះអគ្គិសនីកម្ពុជា (EDC) មិនទិញអគ្គិសនីដែលលើសពីផលិតករតូចៗ គឺដោយសារតែការរំពឹងទុកពីគម្រោងបង្កើតឧស្ម័នជីវឥន្ធនៈនៅក្នុងវិស័យនានាដូចជាការកិនស្រូវឬការកែច្នៃជ័រកៅស៊ូ។ ទំនោរឆ្ពោះទៅរកតំបន់សេដ្ឋកិច្ចពិសេសដែលស្ថិតនៅជិតព្រំដែនវៀតណាមឬថៃ ដើម្បីពួកគេអាចប្រើប្រាស់បណ្តាញអគ្គិសនីតម្លៃថោករបស់ប្រទេសទាំងនោះ គឺជាដំណោះស្រាយជាក់ស្តែងមួយប៉ុន្តែមិនមែនល្អបំផុតនោះទេ។ វាអាចដោះស្រាយបញ្ហានានាដែលតំបន់អភិវឌ្ឍន៍សំខាន់ដទៃទៀតកំពុងប្រឈមដែលភាគច្រើននៃសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសនេះកំពុងកើតឡើង។

ការគ្រប់គ្រងសំណល់និងទឹកមិនបានល្អ គឺជាផ្នែកដែលត្រូវការការយកចិត្តទុកដាក់ខ្លាំងថែមទៀតដើម្បីកាត់បន្ថយទាន់ពេលវេលានូវផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានពីសកម្មភាពខ្លះដែលពាក់ព័ន្ធនឹងវិស័យនាំចេញផ្សេងៗជាច្រើន។ វិស័យកែច្នៃត្រីអាហារកែច្នៃ ស្បែកជើង និងវិស័យដទៃទៀត ត្រូវតែផ្តោតលើបញ្ហាទាំងនេះ។ ប្រតិបត្តិករខ្លះចង្អុលបង្ហាញពីកង្វះខាតបទប្បញ្ញត្តិផ្នែកបរិស្ថានថាជាកត្តាអវិជ្ជមានមួយមកលើការវិនិយោគបន្ថែមទៀតដោយហេតុថា វិនិយោគិនមិនអាចវាយតម្លៃបានពេញលេញចំពោះហានិភ័យផ្នែកហិរញ្ញវត្ថុដែលពាក់ព័ន្ធជាមួយគម្រោងថ្មីៗ។

សរុបមកការវិភាគដែលបានបង្ហាញនៅក្នុងជំពូកជាច្រើននិងសង្ខេបនៅក្នុងការសិក្សានេះបង្ហាញថា វឌ្ឍនភាពនៃការអភិវឌ្ឍមនុស្សដែលសម្រេចបានដោយសារតែកំណើននាំចេញយ៉ាងរហ័សចាប់តាំងពី DTIS ចុងក្រោយក៏ជួបប្រទះផងដែរនូវបញ្ហាប្រឈមថ្មីៗដែលត្រូវតែដោះស្រាយដោយរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធក្នុងវិស័យពាណិជ្ជកម្មកម្ពុជា។

### តារាងទី១៖ ផលប៉ះពាល់នៃការអភិវឌ្ឍមនុស្សប្រកបដោយនិរន្តរភាពក្នុងវិស័យនាំចេញទាំងដប់ប្រភេទ

| | សម្លៀកបំពាក់ | ស្បែកជើង | កម្មន្តសាលផុនស្រាល/SEZ | ចំណីអាហារកែច្នៃ |
|---|---|---|---|---|
| **ការបង្កើតការងារ** | | | | |
| • ការងារតាមវិស័យ (2012) | 370,000 | 64,200 | អាចដល់ទៅចំនួន 10,000 | 93,700 |
| • កំណើនតាមវិស័យនៅពេលអនាគត | 10% ឬច្រើនជាងនេះ | 15%- 20% ប្រចាំឆ្នាំ ផ្អែកតាមនិន្នាការបច្ចុប្បន្ន | ឆាប់រហ័ស ប្រចាំឆ្នាំ: 20% ទៅ 25% ឬ អាចខ្ពស់ជាងនេះ | អាចមានកំណើនជាដុំកំភួន |
| • ផលប៉ះពាល់ដោយប្រយោលសំខាន់ៗ | ប្រាក់បញ្ញើទៅតាមខេត្ត | ប្រាក់បញ្ញើទៅតាមខេត្ត | ប្រាក់បញ្ញើទៅតាមខេត្ត | ឥទ្ធិពលលើតម្រូវការក្នុងវិស័យកសិកម្ម |
| **សមធម៌យេនឌ័រ** | 80%-90% ជាស្ត្រី ពលកម្ម មិនទាន់គ្រប់អាហារ ជាបញ្ហាមួយ | 90% + ជាស្ត្រី ពលកម្ម មិនទាន់គ្រប់អាហារជាបញ្ហាមួយ។ បុរសមានចំនួនកាន់តែច្រើន | មិនដឹង | ស្ត្រីភាគច្រើននៅក្នុង SME។ មិនដឹង នៅតាមរោងចក្រធំៗ |
| **ប្រាក់ឈ្នួល និងម៉ោងធ្វើការ** | អប្បបរមា $100 ក្នុង១ខែ រហូតដល់ $180. 48 ម៉ោង+OT/សប្តាហ៍ | ប្រាក់ឈ្នួលខ្ពស់ជាងវិស័យសម្លៀកបំពាក់ បន្តិចៗ 48 ម៉ោង+OT/សប្តាហ៍ | ប្រាក់ឈ្នួលខ្ពស់ជាងវិស័យសម្លៀកបំពាក់ បន្តិចៗ 48 ម៉ោង+OT/សប្តាហ៍ | ប្រាក់ឈ្នួល និងការងារតាមវេន នៅតាមរោងចក្រធំៗ ស្រដៀងនឹងវិស័យសម្លៀកបំពាក់ដែរ |
| **លក្ខខណ្ឌការងារ** | | | | |
| • តំណាងកម្មករ | ភាគច្រើនបំផុតជាសហជីព | ភាគច្រើនបំផុតជាសហជីព | មានសហជីពមួយចំនួន | គ្មាន |
| • ការត្រួតពិនិត្យតាមដានតាមវិស័យ | ត្រួតពិនិត្យក្រោម BFC | ត្រួតពិនិត្យក្រោម BFC | គ្មាន | គ្មាន លើកលែងរោងចក្រមួយចំនួនតូច ដែលបំពេញតាមស្តង់ដា SPS អន្តរជាតិ |
| • អនាម័យនិងសុវត្ថិភាព | ថ្មីៗនេះ មានបញ្ហាពាក់ព័ន្ធនឹងសុវត្ថិភាពអគារ | គ្រោះថ្នាក់ការងារ គឺជាបញ្ហាមួយ ការប៉ះពាល់នឹងសារធាតុគីមីដែលមានគ្រោះថ្នាក់ គឺជាបញ្ហាមួយ | បញ្ហាសុវត្ថិភាពមានកម្រិត | បញ្ហាប្រឈម គឺអនាម័យផ្ទាល់ខ្លួនមិនល្អចំណែកឯការ ឈប់សម្រាកស្របតាមស្តង់ដារ SPS |
| **ការអភិវឌ្ឍជំនាញ** | | | | |

| | | | | |
|---|---|---|---|---|
| • ឱកាសបណ្តុះបណ្តាល | OTJ. គ្មាន TVET. ការរៀបចំផែនការ GMACមជ្ឈមណ្ឌល TVET | OTJ ជាដុំកំភួន គ្មាន TVET | OTJ. ក៏មានការបណ្តុះបណ្តាលខាងក្រៅ ផងដែរ រួមទាំងនៅបរទេសផង ដែរ។ TVET នៅមានកម្រិត | OTJ តាមគ្រឹះស្ថានធំៗ គ្មាន TVET |
| • ឱកាសការងារ | រាប់បញ្ចូលទាំងកម្មករ ថ្នាក់ក្រោម | រាប់បញ្ចូលទាំងកម្មករ ថ្នាក់ក្រោម | ជាដុំកំភួន រាប់បញ្ចូលទាំងកម្មករ ថ្នាក់ក្រោម | មានបន្តិចបន្តួច លើកលែងនៅតាមគ្រឹះស្ថានធំៗមួយចំនួនតូច |
| **លក្ខខណ្ឌរស់នៅ** | | | | |
| • ទីជម្រក | គុណភាពអាចមាន លក្ខណៈអន់ថយនៅ តាមមជ្ឈដ្ឋានក្រុង | គុណភាពអាចមាន លក្ខណៈអន់ថយ នៅតាមមជ្ឈដ្ឋានក្រុង | និយោជក SEZ មួយចំនួនផ្តល់ទីជម្រក ល្អ នៅតាមរោងចក្រ។ ក្រៅពីនេះ លទ្ធភាពមានទីជម្រកល្អប្រែប្រួលខុសគ្នា | ការរស់នៅតំបន់ជនបទ៖ លទ្ធភាពមានទីជម្រកល្អ |
| • អនាម័យបរិស្ថាន (ទឹក/បង្គន់អនាម័យ) | គុណភាពអាចមាន លក្ខណៈអន់ថយ នៅតាមមជ្ឈដ្ឋានក្រុង | គុណភាពអាចមាន លក្ខណៈអន់ថយ នៅតាមមជ្ឈដ្ឋានក្រុង | ជាទូទៅ ល្អ | លទ្ធភាពប្រើប្រាស់បង្គន់អនាម័យល្អ។ ទឹកៈ ប្រែប្រួល |
| **ផលប៉ះពាល់តាមតំបន់** | | | | |
| • កម្រិតបឋម | ភ្នំពេញ កណ្តាល | ភ្នំពេញ កំពង់ស្ពឺ កណ្តាល | ភ្នំពេញ ក្រុងព្រះសីហនុ ស្វាយរៀង (បាវិត) កោះកុង | ភ្នំពេញ កំពង់ចាម បាត់ដំបង សៀមរាប កណ្តាល |
| • កម្រិតមធ្យម | ស្វាយរៀង ក្រុងព្រះសីហនុ | អាចមានការពង្រីកតាមបណ្តោយព្រំដែនវៀតណាម | អាចមានការពង្រីកតាមបណ្តោយព្រំដែនវៀតណាម | តំបន់ជនបទជាច្រើន |
| **ផលប៉ះពាល់ផ្នែកបរិស្ថាន** | | | | |
| • ថាមពល | មានការប្រើប្រាស់អគ្គិសនី ច្រើន | មានការប្រើប្រាស់អគ្គិសនី | មានការប្រើប្រាស់អគ្គិសនីច្រើន | មានការប្រើប្រាស់អគ្គិសនីតិចតួច លើកលែងតែក្រុមហ៊ុនធំៗ |
| • ទឹក | មានការប្រើប្រាស់ទឹក ច្រើនសម្រាប់បោកគក់ និងអ៊ុតសម្លៀកបំពាក់ | ផលិតស្បែក និងលាបពណ៌ | មានប្រព្រឹត្តកម្មទឹកមិនគួរសមនៅតាម  SEZ | មានការប្រើប្រាស់ច្រើន។ ការគ្រប់គ្រងសំណល់ទឹកនៅមានកម្រិត |

| | | | | |
|---|---|---|---|---|
| • ដី | មិនដឹង | អាចមានផលប៉ះពាល់អវិជ្ជមានពីការគ្រប់គ្រងសំណល់ទឹកមិនបានល្អ | មិនដឹង | អាចប្រើប្រាស់ទឹកជាកំប៉ុស្ត ឬដី |
| • សំណល់ | ក្រណាត់ និង សារធាតុគីមី | កំណត់សំពត់ ជ័រកៅស៊ូ សារធាតុគីមី | មាន ប្រែប្រួលទៅតាមការផលិត | ការគ្រប់គ្រងសំណល់នៅមានកម្រិត |

| | ផលផល | អង្ករ | ជំឡូងមី |
|---|---|---|---|
| **ការបង្កើតការងារ** | | | |
| • ការងារតាមវិស័យ (2012) | 450,000 | ចំនួនរាប់ពាន់ក្នុងវិស័យអង្ករ | ការងារក្នុងផ្នែកពាក់កណ្ដាលកែច្នៃនៅមានកម្រិត |
| • កំណើនតាមវិស័យនៅពេលអនាគត | កំណើនយឺយ៉ាវ បើវិស័យវាវីរប្បកម្ម និងកែច្នៃមិនបោះជំហានទៅមុខទេ | មានកំណើនឆាប់រហ័ស | តម្រូវការ និងទីផ្សារសកល គ្មានស្ថេរភាព ពិបាកព្យាករណ៍ |
| • ផលប៉ះពាល់ដោយប្រយោលសំខាន់ៗ | ផលប៉ះពាល់យ៉ាងច្រើនខ្លះៗ ផលប៉ះពាល់ធំមកលើប្រភពប្រូតេអ៊ីនចម្បងសម្រាប់ពលរដ្ឋកម្ពុជា | កសិករជាច្រើនលាននាក់ដាំស្រូវ | កសិកររាប់ម៉ឺននាក់ជាប់ជំឡូងមី |
| **សមភាពយេនឌ័រ** | មានតុល្យភាព | ភាគច្រើនជាបុរស | មានតុល្យភាព |
| **ប្រាក់ឈ្នួល និងម៉ោងធ្វើការ** | ប្រហាក់ប្រហែលនឹងប្រាក់ឈ្នួលអប្បបរមា។ ប្រែប្រួលទៅតាមរដូវកាល។ ម៉ោងធ្វើការប្រែប្រួលទៅតាមរដូវកាល។ | ប្រហាក់ប្រហែលនឹងប្រាក់ឈ្នួលអប្បបរមា។ ប្រែប្រួលទៅតាមរដូវកាល។ ម៉ោងធ្វើការប្រែប្រួលទៅតាមរដូវកាល។ | ប្រហាក់ប្រហែលនឹងប្រាក់ឈ្នួលអប្បបរមា។ ប្រែប្រួលទៅតាមរដូវកាល។ ម៉ោងធ្វើការប្រែប្រួលទៅតាមរដូវកាល។ |
| **លក្ខខណ្ឌការងារ** | | | |
| • តំណាងកម្មករ | គ្មាន | គ្មាន | គ្មាន |
| • កាតត្រួតពិនិត្យតាមវិស័យ | គ្មាន លើកលែងតែរោងចក្រមួយចំនួនតូចដែលបំពេញតាមស្តង់ដាអន្តរជាតិS PS | គ្មាន ប៉ុន្តែ រោងម៉ាស៊ីនកិនស្រូវក្នុងពេលឆាប់ៗ នេះ នឹងត្រូវបំពេញតាមស្តង់ដាអន្តរជាតិ SPS | សម្ពាធលើអ្នកកែច្នៃឱ្យបំពេញតាមស្តង់ដាអន្តរជាតិ SPS |
| • អនាម័យ និងសុវត្ថិភាព | ភាគច្រើនបំផុតមាន SPS អន់ខ្លាំង លើកលែងតែរោងចក្រធំៗ | សូមមើលផ្នែកខាងលើ។ រោងម៉ាស៊ីនកិនស្រូវ ផ្ដោតលើការនាំចេញមានលក្ខណៈទំនើប។ អនាម័យល្អ | សូមមើលផ្នែកខាងលើ |

| | | | |
|---|---|---|---|
| **ការអភិវឌ្ឍជំនាញ** | | | |
| • ឱកាសបណ្តុះបណ្តាល | OTJ មានកម្រិតនៅតាមគ្រឹះស្ថានធំៗ។ ភាគច្រើនបំផុត មានលក្ខណៈក្រៅ ប្រព័ន្ធ។ គ្មានTVET | OTJ មានកម្រិតនៅតាមគ្រឹះស្ថានធំៗ។ ភាគច្រើនបំផុត មានលក្ខណៈក្រៅ ប្រព័ន្ធ។ គ្មានTVET ។ មានការបណ្តុះបណ្តាល RUA ខ្លះៗ។ | OTJ មានកម្រិតនៅតាមគ្រឹះស្ថានធំៗ។ ភាគច្រើនបំផុត មានលក្ខណៈក្រៅ ប្រព័ន្ធ។ គ្មានTVET |
| • ឱកាសការងារ | នៅមានកម្រិតទាប លើកលែងតែនៅតាម គ្រឹះស្ថានធំៗ | នៅមានកម្រិតទាប លើកលែងតែនៅតាម រោងម៉ាស៊ីនកិនស្រូវធំៗ | នៅមានកម្រិតទាប លើកលែងតែនៅតាម គ្រឹះស្ថានធំៗមួយចំនួនតូច |
| **លក្ខខណ្ឌរស់នៅ** | | | |
| • លទ្ធភាពមានទីជម្រក | រស់នៅតាមជនបទ៖ លទ្ធភាពមានទី ជម្រក ល្អ | រោងម៉ាស៊ីនកិនស្រូវ ផ្តល់ទីជម្រក។ គុណភាព មានកម្រិត | រស់នៅតាមជនបទ៖ លទ្ធភាពមាន ទីជម្រកល្អ |
| • អនាម័យបរិស្ថាន (ទឹក/បង្គន់អនាម័យ) | គុណភាពបង្គន់ និងទឹក៖ ប្រែប្រួល ខុសៗគ្នា | គុណភាពបង្គន់ និងទឹក៖ ប្រែប្រួល ខុសៗគ្នា | គុណភាពបង្គន់ និងទឹក៖ ប្រែប្រួលខុសៗ គ្នា |
| **ផលប៉ះពាល់តាមតំបន់** | | | |
| • កម្រិតបឋម | ខេត្តតាមឆ្នេរសមុទ្រ ខេត្តដែលមានផ្លូវទឹក | ព្រៃវែង តាកែវ កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ | បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន កំពង់ចាម |
| • កម្រិតមធ្យម | | ខេត្តភាគច្រើនបំផុត | ខេត្តភាគច្រើនបំផុត |
| **ផលប៉ះពាល់ផ្នែកបរិស្ថាន** | | | |
| • ថាមពល | មានតិចតួច លើកលែងតែក្រុមហ៊ុនធំៗ | ពឹងផ្អែកលើអគ្គិសនី។ អាចប្រើប្រាស់ដំណោះស្រាយថាមពល ប្រកបដោយនិរន្តរភាព។ | ផ្អែកពាក់កណ្តាលកៃច្នៃ ត្រូវការអគ្គិសនី តិចតួច |
| • ទឹក | មានការប្រើប្រាស់ច្រើន។ ការគ្រប់គ្រង សំណល់ទឹកមានកម្រិត | មិនដឹង | មិនដឹង |
| • ដី | សំណល់រឹងអាចមានផលប៉ះពាល់អវិជ្ជមាន ទៅលើដី ប្រសិនមិនបានគ្រប់គ្រងត្រឹមត្រូវ | មិនដឹង | ការដាំដំឡូងមី មានផលប៉ះពាល់អវិជ្ជមាន ទៅលើដី គ្មានការសម្រាលផលប៉ះពាល់ ទេនោះ |
| • សំណល់ | ការគ្រប់គ្រងសំណល់នៅមានកម្រិត | អាចប្រើប្រាស់អង្កាមជាជីវឥន្ទនៈបាន | សំណល់អាចប្រើប្រាស់ជាជីវឥន្ទនៈ ឬជាជីបាន |

| | ជំរកៅស៊ូធម្មជាតិ | ទេសចរណ៍ | សូត្រមានតម្លៃខ្ពស់ |
|---|---|---|---|
| **ការបង្កើតការងារ** | | | |
| • ការងារតាមវិស័យ (2012) | ប្រហែលជា60,000 នៅតាមចម្ការធំៗនិងអ្នកធ្វើចម្ការខ្នាតតូចៗ រាប់ពាន់ការងារនៅក្នុងផ្នែកកែច្នៃ | ប្រមាណជា 620,000 | 20,000+ អ្នកតម្បាញ; អ្នកចិញ្ចឹមដង្កូវនាង1000 នាក់ |
| • កំណើនតាមវិស័យនៅពេលអនាគត | អាចឡើងខ្ពស់។អាចកើនមួយទ្វេជាបីឬជាបីក្នុងរយៈពេល៥ឆ្នាំបន្ទាប់។ | 3% ឬលើសនេះ - ការងារថ្មីចំនួនឬច្រើនលើសនេះជារៀងរាល់ឆ្នាំ | យឺត |
| • ផលប៉ះពាល់ប្រយោលសំខាន់ៗ | ក្រុមគ្រួសាររស់នៅតាមចម្ការធំៗ | ប្រាក់បញ្ញើទៅតាមខេត្ត | រួមចំណែកដល់ "ផ្នែកវប្បធម៌" របស់ប្រទេសកម្ពុជា |
| **សមភាពយេនឌ័រ** | ភាគច្រើនបំផុតជាបុរស | 40% ទៅ 60% ជាស្ត្រី | 90 ទៅ 95% ជាស្ត្រី |
| **ប្រាក់ឈ្នួលនិងម៉ោងធ្វើការ** | ចំណូលជាសាច់ប្រាក់ផ្អែកតាមការប្រមូលផល។ម៉ោងធ្វើការប្រែប្រួលខុសៗគ្នា។ | គ្មានប្រាក់ឈ្នួលអប្បបរមា។ចាប់ផ្តើមដោយប្រាក់ខែពី $45-$60ក្នុង១ខែ។ ការងារច្រើនម៉ោងនៅតាម SME។ ការងារតាមវេនផ្អែកតាមក្នុងរយៈពេល២៤ម៉ោង។ | ច្រើនម៉ោង។ប្រាក់ឈ្នួលលើសផ្អែកកាត់ដេរបន្តិចបន្តួចប៉ុន្តែប្រែប្រួលទៅតាមការបញ្ជាទិញ |
| **លក្ខខណ្ឌការងារ** | | | |
| • តំណាងកម្មករ | គ្មាន | គ្រឹះស្ថានមួយចំនួនត្រូវបានរៀបចំជាសហជីព | គ្មាន |
| • ការត្រួតពិនិត្យតាមវិស័យ | ការត្រួតពិនិត្យគុណភាពអាចក្លាយជាបញ្ហាមួយ | គ្មាន | គ្មាន |
| • អនាម័យនិងសុវត្ថិភាព | ឧបករណ៍កែច្នៃជារឿយៗគ្មានអនាម័យ | ប្រែប្រួលខុសៗគ្នា។ អនាម័យផ្ទាល់ខ្លួននិងអនាម័យបរិស្ថានគឺជាបញ្ហាអភិវឌ្ឍតាមវិស័យជាគន្លឹះ | ជាបរិយាកាសការងារតាមផ្ទះ។ ជាទូទៅមានសុវត្ថិភាព |
| **ការអភិវឌ្ឍជំនាញ** | | | |
| • ឱកាសបណ្តុះបណ្តាល | OJT គ្មានTVET | ភាគច្រើនបំផុតជា OTJ។ ខ្វះខាតTVET | OTJជាប្រពៃណី។ អាចបាត់បង់ជំនាញប្រសិនបើវិស័យនេះថយចុះ។ |
| • ឱកាសការងារ | នៅមានកម្រិតទាបប្រសិនបើការកែច្នៃបែបទំនើបមិនត្រូវបានអភិវឌ្ឍ។ | មានលក្ខណៈជាដុំកំភួន | មានកម្រិតលើកលែងតែជំនាញខ្ពស់ៗ (ជំនាញរចនានិងទីផ្សារ) |

| | | | |
|---|---|---|---|
| **លក្ខខណ្ឌរស់នៅ** | | | |
| • លទ្ធភាពមានទីជម្រក | ក្រុមហ៊ុនកែច្នៃមានផ្តល់ទីជម្រកល្អ | គុណភាពអាចមានលក្ខណៈអន់នៅតាមតំបន់ក្រុង | ការរស់នៅតាមជនបទៈលទ្ធភាពមានទីជម្រកល្អ |
| • អនាម័យបរិស្ថាន (ទឹក/បង្គន់អនាម័យ) | អនាម័យបរិស្ថានល្អតភ្ជាប់នឹងទីលំនៅល្អ | គុណភាពអាចមានលក្ខណៈអន់នៅតាមតំបន់ក្រុង | លទ្ធភាពប្រើប្រាស់បង្គន់អនាម័យល្អ។ទឹកៈ ប្រែប្រួលខុសៗគ្នា |
| **ផលប៉ះពាល់តាមតំបន់** | | | |
| • កម្រិតបឋម | កំពង់ចាមក្រចេះប៉ៃលិនរតនគិរីស្ទឹងត្រែង | សៀមរាបភ្នំពេញក្រុងព្រះសីហនុ | **តម្បាញៈ** សៀមរាបតាកែវព្រៃវែងបន្ទាយមានជ័យកំពង់ចាមកំពង់ធំកណ្តាលភ្នំពេញនិងស្ទឹងត្រែងការ **ចិញ្ចឹមដង្កូវនាងៈ** បន្ទាយមានជ័យ |
| • កម្រិតមធ្យម | មណ្ឌលគីរី | តំបន់ពាយព្យតំបន់ឆ្នេរសមុទ្រខេត្តដែលមានផ្លូវទឹក | គ្មាន |
| **ផលប៉ះពាល់ផ្នែកបរិស្ថាន** | | | |
| • ថាមពល | មានលក្ខណៈប្រពលសម្រាប់ការកែច្នៃ | ការប្រើប្រាស់អគ្គិសនីនិងឥន្ធនៈច្រើនសម្រាប់ដាំទឹក | ការប្រើប្រាស់អគ្គិសនីមានកម្រិតទាប |
| • ទឹក | ត្រូវការទឹកខ្លះៗសម្រាប់ការកែច្នៃ។ មានការប្រើប្រាស់សារធាតុគីមី | ការប្រើប្រាស់ទឹកច្រើនជាពិសេសនៅក្នុងផ្ទះបាយ។ ប្រព្រឹត្តកម្មទឹកនៅមានកម្រិត | មានការប្រាស់ថ្នាំជ្រលក់។លែងប្រើប្រាស់ថ្នាំជ្រលក់ធ្វើដោយខ្លួនឯង |
| • ដី | មានផលប៉ះពាល់អវិជ្ជមានបើគ្មានវិធានការសម្រាល | មិនដឹង។ការធ្វើជីកំប៉ុស្តនៅមានកម្រិត | មិនដឹង |
| • សំណល់ | សំណល់តិចតួច | ការប្រើប្រាស់ឡើងវិញនៅមានកម្រិត។ ជបផ្លាស្ទិច | មិនដឹង |

# ផែនទីបង្ហាញផ្លូវនៃអភិក្រមគ្រប់ដណ្តប់ វិស័យពាណិជ្ជកម្មកម្ពុជាឆ្នាំ២០១៤-២០១៨៖ លទ្ធផលជាយុទ្ធសាស្ត្រទាំង២០

ដើម្បីដោះស្រាយបញ្ហាជាស្នូលនៃភាពប្រកួតប្រជែងវិស័យពាណិជ្ជកម្ម ការបង្កើតការងារនិងប្រាក់ចំណូលព្រមទាំងការអភិវឌ្ឍមនុស្សជាតិប្រកបដោយនិរន្តរភាពនៅក្នុងរយៈពេល៥ឆ្នាំខាងមុខ ផែនទីបង្ហាញផ្លូវនៃអភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade Sector-Wide Approach-Trade SWAp) នៅពេលបន្ទាប់របស់កម្ពុជានឹងផ្តោតលើលទ្ធផលជាយុទ្ធសាស្ត្រចំនួន២០។ លទ្ធផលទាំងនេះដោះស្រាយបញ្ហាប្រឈមជាក់លាក់នៅកម្រិតលទ្ធភាពទីផ្សារនិងបរិយាកាសធុរកិច្ចនៅកម្រិតសង្វាក់តម្លៃនៅកម្រិតទីផ្សារការងារនិងជំនាញ ព្រមទាំងការគ្រប់គ្រងនិងការប្រើប្រាស់ធនធានជំនួយបច្ចេកទេសនិងការផ្តោតទៅលើវិស័យដែលត្រូវការកំណែទម្រង់និងការអភិវឌ្ឍស្ថាប័ន។

វឌ្ឍនភាពធៀបនឹងលទ្ធផលជាយុទ្ធសាស្ត្រទាំង ២០ នេះនឹងត្រូវវាស់វែងមួយផ្នែកដោយផលប៉ះពាល់នៃផលប្រយោជន៍របស់វាក្នុងការជួយដល់កម្ពុជា ដើម្បីសម្រេចគោលដៅអភិវឌ្ឍសេដ្ឋកិច្ចធំៗរបស់ខ្លួនដូចជាគោលដៅពង្រឹងភាពប្រកួតប្រជែងវិស័យពាណិជ្ជកម្មការបង្កើតការងារថ្មីៗនិងកាន់តែល្អប្រសើរការបង្កើនប្រាក់ចំណូលនិងការកាត់បន្ថយភាពក្រីក្រជាដើម។ ផលប៉ះពាល់ទូលំទូលាយទាំងនោះ មានចែងនៅក្រោមគោលដៅអភិវឌ្ឍន៍ចំនួន៥។

គោលដៅអភិវឌ្ឍន៍ទាំង៥នេះមិនខុសប្លែកខ្លាំងពីគោលដៅដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវ Trade SWAp ដំបូងដែលកើតចេញពី CTIS 2007 នោះទេ។ លទ្ធផលទាំង២០នេះរាប់បញ្ចូល "កិច្ចការដែលត្រូវអនុវត្តបន្ត" ពីផែនទីបង្ហាញផ្លូវកន្លងទៅដែលត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីបូកបញ្ចូលវឌ្ឍនភាពដែលសម្រេចបានតាំងពីឆ្នាំ២០០៧ និងដើម្បីដោះស្រាយតម្រូវការជាបន្ថែម។ បញ្ជីនេះក៏រាប់បញ្ចូលផងដែរ នូវលទ្ធផលថ្មីៗមួយចំនួនដែលឆ្លុះបញ្ចាំងអំពីអាទិភាពថ្មីៗដែលទើបតែលេចចេញឡើងនៅក្នុងឆ្នាំថ្មីៗនេះ។ តារាងខាងក្រោមនេះ (តារាងទី២) រៀបរាប់អំពីគោលដៅទាំង៥និងលទ្ធផលទាំង២០ សម្រាប់ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។ វាត្រូវបានរៀបចំឡើងឱ្យស្របនឹងសសរស្តម្ភទាំងបីនៃ Trade SWAp របស់រដ្ឋាភិបាល។

| តារាងទី២៖ផលប៉ះពាល់នៃការអភិវឌ្ឍនិងលទ្ធផលជាយុទ្ធសាស្ត្រនៃTrade SWAp ឆ្នាំ២០១៤-២០១៨ | |
|---|---|
| | |
| **ផលប៉ះពាល់/គោលដៅនៃការអភិវឌ្ឍ** | |
| ផលប៉ះពាល់/គោលដៅទី១ | ភាពប្រកួតប្រជែងត្រូវបានកែលម្អ រួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការងារថ្មីៗនិងកាន់តែល្អប្រសើរ |
| ផលប៉ះពាល់/គោលដៅទី២ | កំណើនជាជុំកំភួនក្នុងការរួមចំណែករបស់វិស័យពាណិជ្ជកម្មដល់ GDP និងបង្កើនភាពចម្រុះនៃមូលដ្ឋាននាំចេញរបស់កម្ពុជា |
| ផលប៉ះពាល់/គោលដៅទី៣ | ពង្រឹងសមត្ថភាព RGC ដើម្បីរៀបចំនិងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាណិជ្ជកម្ម |
| ផលប៉ះពាល់/គោលដៅទី៤ | ភាពឆ្លើយតបរបស់ RGC ចំពោះតម្រូវការរបស់ផ្នែកឯកជនកើនឡើងជាលទ្ធផលនៃកិច្ចសន្ទនាកាន់តែប្រសើរ |
| ផលប៉ះពាល់/គោលដៅទី៥ | បង្កើនសមត្ថភាពរៀបចំផែនការអនុវត្តត្រួតពិនិត្យរបស់ RGC តាមរយៈការអនុវត្តការ Trade SWAp |
| **លទ្ធផលជាយុទ្ធសាស្ត្រ** | |
| *សសរស្តម្ភទី១* | |
| លទ្ធផលទី១ | <u>កំណែទម្រង់គោលនយោបាយពាណិជ្ជកម្មនិងការចរចាពាណិជ្ជកម្ម</u>៖កម្ពុជាបំពេញកាតព្វកិច្ចកំណែទម្រង់ផ្នែកច្បាប់ពាណិជ្ជកម្មរបស់ខ្លួនឱ្យស្របតាម WTO និង ASEAN ពង្រឹងលទ្ធភាពចូលទីផ្សាររបស់ខ្លួនតាមរយៈការចរចាពាណិជ្ជកម្មពង្រឹងតម្លាភាពនៃវិធាននិងច្បាប់ពាណិជ្ជកម្មរបស់ខ្លួន។ |
| លទ្ធផលទី២ | <u>កិច្ចសម្រួលពាណិជ្ជកម្ម</u>៖កម្ពុជាបង្កើនភាពប្រកួតប្រជែងរបស់ខ្លួនតាមរយៈការកាត់បន្ថយចំណាយនាំចេញ/នាំចូល។ |
| លទ្ធផលទី៣ | <u>ការដឹកជញ្ជូនពាណិជ្ជកម្ម</u>៖កម្ពុជាបង្កើនភាពប្រកួតប្រជែងរបស់ខ្លួនតាមរយៈការដឹកជញ្ជូនពាណិជ្ជកម្មដែលប្រសើរឡើង។ |
| លទ្ធផលទី៤ | <u>ស្តង់ដារបច្ចេកទេសនិងលក្ខខណ្ឌSPS</u>៖សមត្ថភាពផ្នែកនាំចេញរបស់កម្ពុជាដើម្បីបំពេញតាមស្តង់ដារបច្ចេកទេសនិងលក្ខខណ្ឌ SPS ដែលបានកំណត់ដោយផ្នែកនាំចូលនិងប្រទេសនាំចូលកើនឡើង។ |
| លទ្ធផលទី៥ | <u>បរិយាកាសវិនិយោគសម្រាប់នាំចេញ</u>៖បរិយាកាសវិនិយោគនៅក្នុង DTIS 2013 ទាំង១០ ផ្តោតលើផ្នែកនាំចេញត្រូវបានពង្រឹង។ |
| លទ្ធផលទី៦ | <u>កម្មសិទ្ធិបញ្ញា</u>៖គោលការណ៍កម្មសិទ្ធិបញ្ញាត្រូវបានបង្កើតអនុវត្តន៍និងពង្រឹង។ |
| *សសរស្តម្ភទី២* | |
| លទ្ធផលទី៧ | <u>ផ្នែកសម្លៀកបំពាក់</u>៖កម្ពុជាបន្តបង្កើននិងធ្វើឱ្យផ្នែកនាំចេញសម្លៀកបំពាក់របស់ខ្លួនមានលក្ខណៈចម្រុះតាមរយៈការស្វែងរកទីផ្សារថ្មីការបង្កើនជាតុចូលក្នុងស្រុកនិងការពង្រីកផលិតផលមានតម្លៃខ្ពស់។ |
| លទ្ធផលទី៨ | <u>ផ្នែកស្បែកជើង</u>៖កម្ពុជាបន្តបង្កើននិងធ្វើឱ្យផ្នែនាំចេញស្បែកជើងរបស់ខ្លួនមានលក្ខណៈចម្រុះតាមរយៈការស្វែងរកទីផ្សារថ្មីនិងការបង្កើតចំណែកទីផ្សារថ្មី។ |

| | |
|---|---|
| លទ្ធផលទី៩ | 9A: SEZ៖SEZកម្ពុជាបង្កើនភាពប្រកួតប្រជែងរបស់ខ្លួននិងទាក់ទាញវិនិយោគផ្នែកផលិតបន្ថែម។ |
| | 9B: រោងចក្រផលិតផុនស្រាល៖កម្ពុជាបន្តលេចមុខជាមជ្ឈមណ្ឌលក្នុងបណ្ដាញផលិតកម្មប្រចាំតំបន់ |
| លទ្ធផលទី១០ | អាហារកែច្នៃ៖កម្ពុជាបន្តបង្កើននិងធ្វើឱ្យផ្នែកការច្នៃអាហាររបស់ខ្លួនមានលក្ខណៈចម្រុះតាមរយៈបណ្ដាញទីផ្សារនាំចេញឆ្ពោះទៅរកផលិតផលមានតម្លៃខ្ពស់និងការពង្រីកជាតុចូលក្នុងស្រុក។ |
| លទ្ធផលទី១១ | ផលិតផលនេសាទ៖វិស័យនេសាទប្រកបដោយនិរន្តរភាពមើលឃើញកំណើននាំចេញរបស់កម្ពុជាជាលទ្ធផលនៃគុណភាពកាន់តែប្រសើរឡើងដោយបង្កើនទំហំផលិតកម្មនិងពង្រឹងលទ្ធភាពទៅកាន់ទីផ្សារ។ |
| លទ្ធផលទី១២ | អង្ករ៖ កម្ពុជាសម្រេចគោលដៅដែលបានកំណត់នៅក្នុងគោលនយោបាយស្រូវអង្កររបស់ RGC ឆ្នាំ២០១០ សម្រាប់នាំចេញអង្ករ។ |
| លទ្ធផលទី១៣ | ដំឡូងមី៖កម្ពុជាពង្រឹងការនាំចេញដំឡូវមីតាមរយៈការនាំចេញដោយផ្ទាល់ទៅកាន់ប្រទេសចិន និងសាធារណរដ្ឋកូរ៉េនិងកាត់បន្ថយការពឹងផ្អែករបស់ខ្លួនលើការនាំចេញមើមដំឡូងមីមិនទាន់កែច្នៃទៅកាន់ប្រទេសថៃនិងវៀតណាម។ |
| លទ្ធផលទី១៤ | កៅស៊ូ៖កម្ពុជាវិវឌ្ឍក្លាយជាប្រទេសផលិតនិងនាំចេញកៅស៊ូដ៏សំខាន់។ |
| លទ្ធផលទី១៥ | ទេសចរណ៍៖កម្ពុជាឆ្ពោះទៅសម្រេចគោលដៅឆ្នាំ២០២០របស់ RGC ដែលបានកំណត់សម្រាប់វិស័យទេសចរណ៍៖ទេសចរបរទេសចំនួន៨ លាននាក់។ |
| លទ្ធផលទី១៦ | ផលិតផលសូត្រមានតម្លៃខ្ពស់៖ផលិតករកម្ពុជាមួយចំនួនតូចប៉ុន្តែកាន់តែកើនច្រើនឡើងមានសមត្ថភាពរចនានិងនាំចេញផលិតផលសូត្រដែលមានតម្លៃខ្ពស់។ |
| *សសរស្តម្ភទី៣* | |
| លទ្ធផលទី១៧ | កង្វះខាតជំនាញសម្រាប់នាំចេញ៖ RGC និងផ្នែកនាំចេញកម្ពុជាលុបបំបាត់កង្វះខាតជំនាញតាមរយៈផ្នែកអប់រំក្នុងប្រព័ន្ធនិងបង្កើនភាពជាដៃគូរវាងផ្នែកសារធារណៈនិងផ្នែកឯកជនដើម្បីអភិវឌ្ឍន៍ការអប់រំវិជ្ជាជីវៈ/បច្ចេកទេស។ |
| លទ្ធផលទី១៨ | ការបញ្ជ្រាបពាណិជ្ជកម្ម៖គោលបំណងអភិវឌ្ឍពាណិជ្ជកម្មត្រូវបានបញ្ជ្រាបយ៉ាងពេញលេញទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងទៅក្នុងយុទ្ធសាស្ត្រផលិតកម្មនិងសេវាកម្ម។ |
| លទ្ធផលទី១៩ | ការត្រួតពិនិត្យនិងការគៀងគរជំនួយសម្រាប់ពាណិជ្ជកម្ម៖សមត្ថភាពរបស់RGCដើម្បីឆ្លើយតបចំពោះលទ្ធផល M&E Trade SWAp ត្រូវបានពង្រឹងនាំឆ្ពោះទៅរកការគៀងគរកាន់តែរឹងមាំនូវAfTនៅក្នុងនិងនៅក្រៅSWAp។ |
| លទ្ធផលទី២០ | ការពង្រឹងការចូលរួមរបស់ផ្នែកឯកជននៅក្នុងជំនួយសម្រាប់ពាណិជ្ជកម្ម៖ កិច្ចសន្ទនាមានរចនាសម្ព័ន្ធកាន់តែប្រសើរឡើងរវាងផ្នែកឯកជននិងរដ្ឋាភិបាលរួមចំណែកដល់ភាពជាដៃគូប្រកបដោយប្រសិទ្ធិផលរវាងផ្នែកសាធារណៈនិងឯកជនសម្រាប់អភិវឌ្ឍន៍ពាណិជ្ជកម្មផ្អែកតាមធនធានជំនួយសម្រាប់ពាណិជ្ជកម្ម។ |

# សសរស្តម្ភទី១

បញ្ហាអន្តរវិស័យចំនួន ៦ ជាស្នូលនៃភាពប្រកួតប្រជែងរបស់ផ្នែកពាណិជ្ជកម្មកម្ពុជាត្រូវបានវិភាគនៅក្រោមសសរស្តម្ភទី១ នៃ *CTIS 2014-2018* ៖

- ការផ្លាស់ប្តូរនិយាមពាណិជ្ជកម្មនិងការស្វែងរកទីផ្សារ
- កិច្ចសម្រួលពាណិជ្ជកម្ម
- ការដឹកជញ្ជូន
- វិធានការអនាម័យនិងភូតគាមអនាម័យនិងស្តង់ដារបច្ចេកទេស
- បរិយាកាសវិនិយោគសម្រាប់នាំចេញ
- កម្មសិទ្ធិបញ្ញា

## លំនាំដែលកំពុងមានការផ្លាស់ប្តូរនៃពាណិជ្ជកម្មនិងការចូលទីផ្សារ

ការនាំចេញរបស់កម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ២០០៧មកនៅពេលដែល *CTIS 2007* ត្រូវបានរៀបចំឡើង។ ការវិភាគអំពីការអភិវឌ្ឍនេះនាំឱ្យមានការសង្កេតឃើញគួរឱ្យចាប់អារម្មណ៍មួយចំនួនអំពីវឌ្ឍនភាពជាដុំកំភួនសម្រេចបានដោយរដ្ឋាភិបាល ក្នុងការបង្កើតបរិយាកាសគាំទ្រសម្រាប់ពាណិជ្ជកម្មនិងដោយផ្នែកឯកជនក្នុងការកសាងសមត្ថភាពផ្គត់ផ្គង់ការនាំចេញ។ ការវិភាគដូចពោលនេះក៏ផ្តល់ជាមេរៀនសំខាន់ៗសម្រាប់អនាគតជាពិសេសទាក់ទងនឹងសារៈសំខាន់នៃការស្វែងរកទីផ្សារមានលក្ខណៈអនុគ្រោះ។

បើក្រឡេកទៅមើលចុងទសវត្សន៍ឆ្នាំ១៩៩០វិញ កម្ពុជាពឹងផ្អែកយ៉ាងខ្លាំងទៅលើការនាំចេញសម្លៀកបំពាក់និងសេវាទេសចរណ៍ជាប្រាក់ចំណូលពីខាងក្រៅ។ រហូតមកដល់ឆ្នាំ២០១១ការនាំចេញសម្លៀកបំពាក់សំខាន់គឺឆ្ពោះទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ ចាប់តាំងពីឆ្នាំ២១២មក E.U. បានក្លាយជាទីផ្សារនាំចេញនាំមុខគេ។ ការធ្វើឱ្យការនាំចេញផលិតផលនិងសេវាឱ្យមានលក្ខណៈចម្រុះនិងការធ្វើឱ្យទីដៅនាំចេញមានលក្ខណៈចម្រុះ បានក្លាយជាគោលដៅគោលនយោបាយមួយអស់រយៈពេលជាច្រើនឆ្នាំមកហើយ ហើយបានក្លាយជាប្រធានបទដ៏សំខាន់មួយដែលត្រូវបានពិនិត្យពិច័យនៅក្នុង *CTIS 2007*។ មានភស្តុតាងបញ្ជាក់យ៉ាងច្បាស់ថា កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល និងផ្នែកឯកជនដើម្បីធ្វើឱ្យមានលក្ខណៈចម្រុះនេះបានចាប់ផ្តើមផ្តល់ផ្លែផ្កាហើយ។

ដូចបង្ហាញនៅក្នុងតារាងទី៣ការនាំចេញទំនិញនិងសេវាដែលបានកត់ត្រាទុកបានកើនឡើង ជាមធ្យមជិត១៣ភាគរយក្នុងមួយឆ្នាំក្នុងចន្លោះឆ្នាំ២០០៧និង២០១១ ពីចំនួន $៤៥០.៩០០កោដិដុល្លា ដល់$៧៣៣.៥០០កោដិដុល្លា។ ចំណែកឯវិស័យសម្លៀកបំពាក់និងទេសចរណ៍វិញនៅតែបន្តកាន់កាប់ចំណែកយ៉ាងធំនៃការនាំចេញដែលបានកត់ត្រាទុកចំណែករួមគ្នានៃវិស័យទាំងពីរនេះបានធ្លាក់ចុះដោយសារចំណែកនាំចេញដែលបានកត់ត្រាទុកផ្សេងៗទៀតបានកើនឡើងពី១០ទៅ២០ភាគរយនៅអំឡុងពេលដដែលនេះ។

| តារាងទី៣៖ សមាសភាគនៃការនាំចេញរបស់កម្ពុជាដែលបានកត់ត្រាទុកឆ្នាំ២០០៧ធៀបនឹងឆ្នាំ២០១១ | | | | |
|---|---|---|---|---|
| | ឆ្នាំ២០០៧ | | ឆ្នាំ២០១១ | |
| | គិតជាលាន $ | ចំណែកជា % | គិតជាលាន$ | ចំណែកជា% |
| ការនាំចេញសរុបដែលបានកត់ត្រាទុក ( ទំនិញ + សេវា ) | 4,509 | 100 | 7,335 | 100 |
| *សមាសភាគនៃការនាំចេញសរុប* | | | | |
| សម្លៀកបំពាក់ | 2,653 | 59 | 3,978 | 54 |
| ទេសចរណ៍ | 1,398 | 31 | 1,907 | 26 |
| ការនាំចេញដែលបានកត់ត្រាទុកដទៃទៀត | 451 | 10 | 1,467 | 20 |
| **ប្រភព៖** GDCE សម្រាប់ទំនិញសមតុល្យនៃការបង់ថ្លៃសេវា MoT សម្រាប់ប៉ាន់ប្រមាណទេសចរណ៍ | | | | |

ប៉ុន្តែការនាំចេញដែលបានកត់ត្រាបង្ហាញតែមួយផ្នែកនៃរូបភាពនៃការផ្លាស់ប្តូរប៉ុណ្ណោះ។ ដូចដែលបានដឹងច្បាស់ហើយថាកម្ពុជាគឺជាប្រភពនៃការនាំចេញក្រៅផ្លូវការដ៏ធំមួយជាពិសេសទំនិញកសិកម្មមួយចំនួន។ ជំពូកទី១នៃ*CTIS 2014-2018* មានវិភាគអំពីការលំបាកមួយចំនួនក្នុងការវាស់វែងការនាំចេញក្រៅផ្លូវការនិងបង្កើតបានជាការប៉ាន់ស្មានតម្លៃបែបសាមញ្ញ។ របកគំហើញមានបង្ហាញនៅក្នុងតារាងទី៤។

| តារាងទី៤៖ សមាសភាពនៃការនាំចេញដែលបានកត់ត្រានិងការនាំចេញក្រៅផ្លូវការដែលបានប៉ាន់ស្មាន ឆ្នាំ២០០៧-២០១១ | | | | |
|---|---|---|---|---|
| | ឆ្នាំ២០០៧ | | ឆ្នាំ២០១១ | |
| | គិតជាលាន $ | ចំណែកជា % | គិតជាលាន $ | ចំណែកជា % |
| ការនាំចេញសរុបដែលបានកត់ត្រាទុក (ទំនិញ + សេវា) | 4,509 | | 7,335 | |
| ការនាំចេញដែលបានកត់ត្រានិងការនាំចេញក្រៅផ្លូវការ (ទំនិញ + សេវា) | 4,945 | 100 | 8,155 | 100 |
| *សមាសភាពនៃការនាំចេញដែលបានកត់ត្រានិងការនាំចេញក្រៅផ្លូវការដែលបានប៉ាន់ស្មានសរុប* | | | | |
| សម្លៀកបំពាក់ | 2,653 | 54 | 3,978 | 48 |
| ទេសចរណ៍/ការធ្វើដំណើរ | 1,398 | 28 | 1,907 | 23 |
| វិស័យផ្សេងទៀត(រួមទាំងការនាំចេញក្រៅផ្លូវការផងដែរ) | 894 | 18 | 2,418 | 29 |
| *សមាសភាពវិស័យដទៃទៀត* | | | | |
| យានជំនិះភាគច្រើនបំផុតជាកង់ (ដែលបានកត់ត្រា) | 49 | 1 | 298 | 4 |
| ស្បែកជើង (ដែលបានកត់ត្រា) | 79 | 2 | 267 | 3 |
| កៅស៊ូ (ដែលបានកត់ត្រា) | 43 | 1 | 192 | 2 |
| អង្ករ (ដែលបានកត់ត្រា) | 2 | * | 106 | 1 |
| ពោត + សណ្តែក (ដែលបានកត់ត្រា) | 6 | * | 4 | * |
| ដំឡូងមី (ដែលបានកត់ត្រា) | * | * | 2 | * |
| ស្រូវ (ក្រៅផ្លូវការ - ប៉ាន់ស្មាន) | 356 | 7 | 581 | 7 |
| ដំឡូងមី (ក្រៅផ្លូវការ - ប៉ាន់ស្មាន) | 37 | 1 | 161 | 2 |
| ពោត + សណ្តែក (ក្រៅផ្លូវការ - ប៉ាន់ស្មាន) | 42 | 1 | 78 | 1 |
| វិស័យផ្សេងទៀតដែលបានកត់ត្រា (ទំនិញ + សេវា) | 280 | 5 | 729 | 9 |

**ប្រភព៖** GDCE សម្រាប់ការនាំចេញទំនិញដែលបានកត់ត្រាសមតុល្យនៃការបង់ថ្លៃ "សេវា" មានបញ្ចូលនៅក្នុង "ការនាំចេញដែលបានកត់ត្រាសរុប" ក្រសួងទេសចរណ៍សម្រាប់ការប៉ាន់ប្រមាណ"ទេសចរណ៍" និងសូមមើល

ជំពូកទី១នៃរបាយការណ៍ទាំងស្រុងសម្រាប់ការប៉ាន់ប្រមាណតម្លៃសន្ទតនៃការដោះដូរទំនិញក្រៅផ្លូវការ

**កំណត់សម្គាល់៖**"យានជំនិះ"រួមមានរថយន្តធុនតូចទោចក្រយានយន្តនិងទោចក្រយាន។ តួលេខនេះរួមបញ្ចូលការនាំចេញយានជំនិះចាស់ (ជជុះ)ផងដែរ។ សញ្ញា( * ) បញ្ជាក់ចំនួនតិចជាង១ភាគរយ។

ដោយដាក់បញ្ចូលចំនួនប៉ាន់ស្មានបែបសាមញ្ញនៃការនាំចេញក្រៅផ្លូវការ តារាងបង្ហាញឱ្យឃើញថា ការប្រមូលផ្តុំលើវិស័យសម្លៀកបំពាក់និងទេសចរណ៍ មានចំនួនតិចជាងអ្វីដែលអាចបង្ហាញដោយការពិនិត្យមើលតែការដោះដូរពាណិជ្ជកម្មតែមួយ ដោយចំណែកនៃការនាំចេញផ្សេងទៀត កើនឡើងពី១៨ ទៅ២៩ភាគរយ នៅអំឡុងឆ្នាំ ២០០៧-២០១១។ ទោចក្រយាន ស្បែកជើង កៅស៊ូនិងអង្ករ កំពុងលេចធ្លោជាទំនិញនាំចេញដែលបានកត់ត្រាកំពុងកើនឡើងយ៉ាងឆាប់រហ័ស ស្រូវ ដំឡូងមី ពោតនិងសណ្តែកសៀងជាទំនិញនាំចេញក្រៅផ្លូវការដែលកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស។

រួមជាមួយនឹងការធ្វើឱ្យមានលក្ខណៈចម្រុះនៃការនាំចេញលាយឡំគ្នាក្នុងចន្លោះឆ្នាំ២០០៧-២០១១ ត្រូវបានកត់សម្គាល់ដោយការផ្លាស់ប្តូរយ៉ាងធំនៃទីដៅនាំចេញ។ តារាងទី៥ ចង្អុលបង្ហាញឱ្យឃើញនូវនិន្នាការធំៗមួយចំនួនកំពុងតែកើតមានឡើងនៅក្នុងឆ្នាំថ្មីៗនេះ ទាក់ទងនឹងការនាំចេញទំនិញ។

**តារាងទី៥៖ ទីដៅនាំចេញទំនិញរបស់កម្ពុជា**

| | 2007 | 2011 |
|---|---|---|
| ការនាំចេញដែលបានកត់ត្រាត( ជាលាន$) | 2,962 | 5,122 |
| គោលដៅនាំចេញ( ចំណែកជា% | | |
| សហរដ្ឋអាមេរិក | 64 | 41 |
| សហភាពអឺរ៉ុប | 23 | 30 |
| អាស៊ាន | 5 | 8 |
| ផ្សេងៗទៀត | 8 | 22 |
| | | |
| ការនាំចេញដែលបានកត់ត្រា និងក្រៅផ្លូវការ ( ជាលាន$) | 3,397 | 5,942 |
| ទីដៅនាំចេញ( ចំណែកជា%) | | |

| | | |
|---|---|---|
| សហរដ្ឋអាមេរិក | 55 | 35 |
| សហភាពអឺរ៉ុប | 20 | 26 |
| អាស៊ាន | 17 | 21 |
| ក្នុងចំណោមនោះមានៈប្រទេសថៃ និងវៀតណាម | (17) | (20) |
| កាណាដា | 4 | 6 |
| ជប៉ុន | 1 | 3 |
| ចិន | * | 3 |
| កូរ៉េខាងត្បូង | * | * |
| កាណាដា | 4 | 6 |
| ផ្សេងៗទៀត | 3 | 6 |

ប្រភពៈ GDCE សម្រាប់ការនាំចេញទំនិញដែលបានកត់ត្រា តម្លៃសន្មតនៃការដោះដូរទំនិញក្រៅផ្លូវការ (សូមមើលជំពូកទី១) សម្រាប់ការនាំចេញទំនិញដែលបានកត់ត្រា (សូមមើលជំពូកទី១)។ សញ្ញា (*) បញ្ជាក់អំពីចំនួនតិចជាង១ភាគរយ។

ការសង្កេតឃើញពីរចំណុច មានលក្ខណៈលេចធ្លោជាងគេ។ ការនាំចេញទៅកាន់សហរដ្ឋអាមេរិក គិតជាចំណែកមួយនៃការនាំចេញសរុបកំពុងតែថយចុះ។ ផ្ទុយទៅវិញ ចំណែកនៃការនាំចេញទៅកាន់សហភាពអឺរ៉ុប កាណាដា ចិន ជប៉ុន ថៃនិងវៀតណាមកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស។ ចំពោះការនាំចេញដែលបានកត់ត្រា តែឯងចំណែកទៅកាន់សហរដ្ឋអាមេរិកថយចុះពី៦៤ភាគរយ មកត្រឹម៤១ភាគរយ ក្នុងចន្លោះឆ្នាំ២០០៧ និង២០១១ សម្រាប់ការនាំចេញដែលបានកត់ត្រានិងក្រៅផ្លូវការ ចំណែកនោះថយចុះពី៥៥ភាគរយមកត្រឹម៣៥ភាគរយ។ ដំណើររឿងសំខាន់ៗនៅពីក្រោយការថយចុះទាំងនេះ គឺការស្ថិតនៅនឹងថ្កល់នៃការនាំចេញសម្លៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិកការកើនឡើងយ៉ាងឆាប់រហ័សនៃការនាំចេញសម្លៀកបំពាក់ទៅកាន់សហភាពអឺរ៉ុប កាណាដា និងទីផ្សារអាស៊ាន និងការកាន់តែមានសារៈសំខាន់នៃពាណិជ្ជកម្មផ្នែកកសិកម្មនៅក្នុង GMS តំបន់អាស៊ានទាំងមូល។

គួរឱ្យចាប់អារម្មណ៍នោះ គឺការផ្លាស់ប្តូរដែលបានកត់សម្គាល់ក្នុងការនាំចេញទំនិញក៏សមស្របនឹងការផ្លាស់ប្តូរក្នុងវិស័យទេសចរណ៍ដែរ។ ដូចមានបង្ហាញនៅក្នុងតារាងទី៦ នៅអំឡុងឆ្នាំ២០០៧-២០១១ ដដែលនោះ ចំណែកនៃការមកដល់នៃចំនួនទេសចរអន្តរជាតិ ពីតំបន់អាស៊ីប៉ាស៊ីហ្វិក បានកើនឡើងពី៦២ភាគរយទៅដល់៧៣ភាគរយ ចំណែកឯចំនួនមកដល់សរុបបានកើនឡើងប្រមាណជា១០ភាគរយក្នុងមួយឆ្នាំជាមធ្យមនៅអំឡុងឆ្នាំដដែលនេះ។

| តារាងទី៦៖ ចំនួននិងប្រភពដើមនៃភ្ញៀវទេសចរអន្តរជាតិដែលមកដល់ | | |
|---|---|---|
| | 2007 | 2011 |
| ចំនួនសរុបនៃទេសចរអន្តរជាតិដែលមកដល់ | 2,015,128 | 2,881,862 |
| *ប្រភពដើម ( ចំណែកជា% )* | | |
| *អាស៊ីប៉ាស៊ីហ្វិក* | 62 | 73 |
| វៀតណាម | 6 | 21 |
| កូរ៉េខាងត្បូង | 16 | 12 |
| ចិន | 6 | 9 |
| ជប៉ុន | 8 | 6 |
| ថៃ | 5 | 4 |
| ឡាវ | 1 | 4 |
| អូស្ត្រាលី | 4 | 4 |
| ម៉ាឡេស៊ី | 4 | 4 |
| *អឺរ៉ុប អាមេរិក អាហ្វ្រិក និងមជ្ឈឹមបូព៌ា* | 38 | 27 |
| សហរដ្ឋអាមេរិក | 7 | 5 |
| បារាំង | 4 | 4 |
| ចក្រភពអង់គ្លេស | 4 | 4 |

ប្រភព៖ ក្រសួងទេសចរណ៍ *ស្ថិតិទេសចរណ៍៖ របាយការណ៍ប្រចាំឆ្នាំ* ២០០៧ និង២០១១

**កំណត់សម្គាល់៖** ប្រទេសទាំងអស់ផ្តល់ទេសចរ១០០.០០០នាក់ ឬច្រើនជាងនេះ នៅឆ្នាំ ២០១១ មានបង្ហាញរៀងៗខ្លួននៅក្នុងតារាងនេះ។

អ្វីខ្លះដែលនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានទាំងនេះ? ជាសង្ខេប មានកត្តាបី៖

- ភាពអនុគ្រោះពាណិជ្ជកម្ម និងវិធានប្រភពដើមទំនិញ
- វិនិយោគដែលកើនឡើងជាលំដាប់ក្នុងសមត្ថភាពផ្គត់ផ្គង់
- បានបន្តកំណែទម្រង់នៅក្នុងបរិយាកាសធ្វើធុរកិច្ច

កម្ពុជាកំពុងតែប្រើប្រាស់យ៉ាងច្រើននូវភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម។ សហរដ្ឋអាមេរិកមិនបានផ្តល់ភាពអនុគ្រោះសម្រាប់វិស័យសម្លៀកបំពាក់ទេ។ EU ផ្តល់ភាពអនុគ្រោះ ស្របតាមកម្មវិធី "អ្វីៗទាំងអស់លើកលែងតែអាវុធ" ("Everything-but-Arms"-EBA)ដូចប្រទេសកាណាដា ចិន កូរ៉េខាងត្បូង ជប៉ុននិងដៃគូពាណិជ្ជកម្មដទៃទៀត ស្របតាមកម្មវិធី GSP និងឥតគិតពន្ធមិនគិតកូតា (DFQF) ឬFTA។ ការផ្លាស់ប្តូរដ៏ធំបំផុត គឺការផ្លាស់ប្តូរក្នុងវិធានប្រភពដើម EBA របស់ EU កាលពីខែមករា ឆ្នាំ២០១១។ ការនាំចេញទៅកាន់ EU មានចំនួនកើនឡើងលើសពីរដងក្នុងចន្លោះឆ្នាំ២០០៧ និង២០១១ ពីចំនួនទឹកប្រាក់ $៦៦៤លានដុល្លា ទៅដល់ $១.៥០៣លានដុល្លា។ ចំណែកនៃការដោះដូរតាមរយៈកម្មវិធី EBA បានកើនឡើងពី៧២ភាគរយ ទៅដល់៩២ភាគរយ។ ដូចគ្នានេះដែរ ចំណែកនៃការនាំចេញដែលបានកត់ត្រាតាមរយៈ AFTA ពីកម្ពុជាទៅថៃនិងវៀតណាម ដែលជាដៃគូពាណិជ្ជកម្មអាស៊ានដ៏ធំជាងគេពីររបស់កម្ពុជាបានកើនឡើងពី១៥ ទៅដល់៤២ភាគរយ។

ការលើកលែងពន្ធដែលកម្ពុជាទទួលបាននៅក្នុងទីផ្សារនាំចេញរបស់ខ្លួនមួយចំនួន តាមរយៈការផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មផ្សេងៗ គឺកត្តាគន្លឹះនាំឱ្យមានកំណើនយ៉ាងឆាប់រហ័សនិងការផ្លាស់ប្តូរទីដៅនៃទំនិញនាំចេញដែលផលិតនៅកម្ពុជា។ ៨០ភាគរយនៃកំណើនក្នុងនាំចេញទំនិញដែលបានកត់ត្រារបស់កម្ពុជា ចាប់តាំងពីឆ្នាំ២០០៧មក បានដៅទៅរកទីផ្សារដែលផ្តល់ភាពអនុគ្រោះ។ ភាពអនុគ្រោះនេះ នឹងក្លាយជាកត្តាកំណត់ដ៏សំខាន់នៃគុណផលនាំចេញនៅក្នុងរយៈពេលខាងមុខ។

លក្ខណៈសំខាន់នៃគម្រោងអនុគ្រោះទាំងអស់នេះ គឺជាវិធាននៃប្រភពដើមទំនិញ ឧទាហរណ៍ដូចជាសំណុំនៃវិធានដែលត្រូវអនុវត្តតាម ដើម្បីកំណត់ថាតើទំនិញដែលផលិតនៅកម្ពុជាអាចទទួលបានភាពអនុគ្រោះទៅកាន់ប្រទេសនាំចូលឬយ៉ាងណា។ ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃការនាំចេញសម្លៀកបំពាក់និងទោចក្រយានពីកម្ពុជាទៅកាន់ EU ត្រូវបានជំរុញមួយផ្នែកធំដោយវិធានប្រភពដើមទំនិញដ៏មានផលប្រយោជន៍នេះ។ ជំពូក១ នៅក្នុង *CTIS 2014-2018* មានវិភាគអំពីរបៀបដែលវិធានប្រភពដើមបានកំណត់ និងអាចកំណត់អំពីផលិតផលនាំចេញនិងទីដៅនាំចេញរបស់កម្ពុជា។ ជំពូកនេះ ក៏មានពិភាក្សាផងដែរអំពីវិធានប្រភពដើមទំនិញដែលកំណត់អំពីរបៀបដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់កម្ពុជាអាចរៀបចំឡើងវិញ ដើម្បីបម្រើផលប្រយោជន៍កម្ពុជាកាន់តែប្រសើរ ដូចជាសារៈសំខាន់នៃការចរចារអំពីវិធានប្រភពដើមទំនិញក្នុងបរិបទភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់ (Regional Comprehensive Economic Partnership-RCEP) ដែលកើតមានឡើងនៅពេលខាងមុខ ដែលនឹងរួមបញ្ចូលសមាជិកអាស៊ាន១៦ និងដៃគូសន្ធនានានានៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មីសេរីមួយ។

កំណើនដ៏ឆាប់រហ័សត្រូវបានគាំទ្រដោយវិនិយោគថ្មីៗដែលកើនឡើងជាលំដាប់ ទាំងវិនិយោគបរទេសទាំងវិនិយោគក្នុងស្រុកនៅក្នុងវិស័យជាច្រើន រួមទាំងវិស័យនាំចេញផងដែរ និយាយដោយឡែក។ ការអភិវឌ្ឍទាំងនេះ ត្រូវបានពិនិត្យមើលលម្អិតជាងនេះ នៅក្នុងជំពូកទាក់ទងនឹងបរិយាកាសវិនិយោគ និងជំពូកទាំង១០ និយាយអំពីវិស័យនាំចេញដែលបានកំណត់នៅក្នុង *CTIS 2014-2018* ។ ទោះជាយ៉ាងណាក៏ដោយច្បាស់ណាស់ថាការកែលម្អនៅក្នុងលទ្ធភាពស្វែងរកទីផ្សារដូចបានពណ៌នាខាងលើ កំពុងជំរុញទៅមុខខណៈពេលដែលវិនិយោគថ្មីៗ នៅតែបន្តមានចំណែកឯការវិនិយោគនេះទៀតសោត កំពុងតែត្រូវបានសម្របសម្រួលដោយការកែកម្អក្នុងបរិយាកាសធុរកិច្ចក្នុងស្រុក។

ក្រោយពីបានចូល WTO កម្ពុជាបានអនុវត្តកម្មវិធីកំណែទម្រង់ដ៏សំខាន់មួយ ដើម្បីផ្សារភ្ជាប់ខ្លួនទៅនឹងកាតព្វកិច្ច WTO របស់ខ្លួននិងដើម្បីបង្កើនភាពទាក់ទាញនៃបរិយាកាសធុរកិច្ចរបស់ខ្លួន។ ការពិនិត្យគោលនយោបាយពាណិជ្ជកម្មធ្វើឡើងនៅក្រុងហ្សឺណែវកាលពីខែវិច្ឆិកា ឆ្នាំ២០១១ បានបង្ហាញឱ្យឃើញថា កំណែទម្រង់ផ្នែកច្បាប់ចាំបាច់មួយភាគធំដែលត្រូវបានកំណត់ភ្លាមៗ ក្រោយពីបានចូល WTO និងបានបង្ហាញយ៉ាងច្បាស់នៅក្នុងកម្មវិធីការងារឆ្នាំ២០០៤ របស់រដ្ឋាភិបាលស្តីពីកាតព្វកិច្ច WTO ( *2004 Work Program on WTO Obligations*)នោះ ត្រូវបានបំពេញចប់សព្វគ្រប់ហើយ។ កំណែទម្រង់ដែលនៅសេសសល់ធំៗ ត្រូវបានបញ្ចូលនៅក្នុងកម្មវិធីការងារឆ្នាំ២០១២ ជាបន្ត ដោយមានគោលដៅបញ្ចប់នៅឆ្នាំ២០១៥។ *កម្មវិធីការងារឆ្នាំ២០១២* មានកំណត់សកម្មភាពចំនួន៨៤។ កម្ពុជាក៏កំពុងតែបំពេញការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសមាគីអាស៊ានដែរ ជាពិសេសទាក់ទងនឹងសហគមន៍សេដ្ឋកិច្ចអាស៊ាន( AEC )ដែលកំពុងតែឈានមកដល់យ៉ាងឆាប់រហ័សនោះ។ ដើម្បីទាញយកប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងទាំងនេះ កម្ពុជាកំពុងតែបោះជំហានទៅមុខ ដើម្បីផ្តល់តម្លាភាពកាន់តែប្រសើរឡើងដោយបង្កើតជាគេហទំព័រដើម្បីផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិផ្សេងៗដែលទាក់ទងនឹងពាណិជ្ជកម្ម។

ចំណុចចុងក្រោយបំផុត និងមានសារៈសំខាន់ដែរនោះ គឺការលេចចេញមុខទំនិញកសិកម្ម ជាប្រភពនាំចេញមានទំហំសមស្របថ្មីដែលកំពុងតែកើនឡើង ទោះបីមិនទាន់កែច្នៃពាក់កណ្តាលកែច្នៃ ឬកែច្នៃហើយនោះ បង្ហាញអំពីសារៈសំខាន់ឱ្យកម្ពុជាបង្កើនល្បឿននៃការបង្កើតស្ថានភាព SPS មួយស្របតាមតាមលក្ខខណ្ឌអន្តរជាតិ។ ចំណុចនេះ មាននិយាយបន្ថែមនៅក្នុងជំពូកស្តីពីវិធានការ SPS និងស្តង់ដារបច្ចេកទេស (SPS Measures and Technical Standards )។

## កិច្ចសម្រួលពាណិជ្ជកម្ម

រាជរដ្ឋាភិបាលកម្ពុជា បានធ្វើឱ្យមានភាពជឿនលឿនជាដុំកំភួនក្នុងការកែលម្អគុណផលនៃកិច្ចសម្រួលពាណិជ្ជកម្មរបស់ខ្លួន ក្នុងឆ្នាំថ្មីៗនេះ។ ក្រោយពីបានអនុវត្ត *ផែនការសកម្មភាពដប់ពីរចំណុច (Twelve-Point Action Plan)* ដែលបានរៀបចំឡើងដោយរដ្ឋាភិបាលកាលពីខែមិថុនា ឆ្នាំ២០០៤ និងដោយមានជាតុចូលផ្នែកជំនួយបច្ចេកទេសជាដុំកំភួនពីសំណាក់សហគមន៍អភិវឌ្ឍន៍ស្ថាប័នគ្រប់គ្រងតាមព្រំដែនសំខាន់ៗ ជាពិសេស*អគ្គនាយកដ្ឋានគយ*

*និងរដ្ឋាករ* (GDCE) បានពង្រឹងសមត្ថភាពស្ថាប័នរបស់ខ្លួននិងបានបោះជំហានទៅមុខក្នុងការអនុវត្តស្តង់ដារអន្តរជាតិនិងរបៀបប្រតិបត្តិល្អមួយចំនួន។ សមិទ្ធិផលសំខាន់ៗ មកដល់ពេលនេះ រួមមាន៖

- ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ (អនុក្រឹត្យលេខ២១និងបទប្បញ្ញត្តិពាក់ព័ន្ធអនុក្រឹត្យលេខ២០៩)
- ការអនុម័តឯកសាររដ្ឋបាលតែមួយ (Single Administrative Document-SAD) ដែលជំនួសឱ្យឯកសារមិនតិចជាង ៤៥ច្បាប់
- ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធស្វ័យប្រវត្តិកម្មគយ (ASYCUDA) នៅច្រកព្រំដែនជាតិទាំងអស់
- ការណែនាំឱ្យប្រើប្រាស់ការត្រួតពិនិត្យពន្ធគយតែមួយកន្លែងនិងការបង្កើតគណៈកម្មការដឹកនាំបញ្ជរតែតែមួយជាតិ(National Single Window Steering Committee) (នៅខែឧសភាឆ្នាំ២០០៨)
- ការអនុវត្តផែនការសកម្មភាពក្របខ័ណ្ឌ WCO SAFE
- ការសម្រួលប្រតិបត្តិការឆ្លងកាត់រួមទាំងតាមរយៈការអនុវត្តកិច្ចព្រមព្រៀងឆ្លងកាត់ GMS និង ASEAN និងកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសជិតខាង ផងដែរ
- ការរៀបចំផែនការសកម្មភាពសម្រាប់ចូលរួមអនុសញ្ញាក្រុងក្យូតូដែលបានកែសម្រួល
- ការត្រៀមលក្ខណៈដើម្បីអនុវត្តកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម WTO នាពេលអនាគត[3]

កំណែទម្រង់ទាំងនេះបាននាំឱ្យមានភាពល្អប្រសើរឡើងនៅក្នុងសូចនាករនៃកិច្ចសម្រួលពាណិជ្ជកម្មសំខាន់ៗដែលត្រូវបានត្រួតពិនិត្យដោយអង្គការអន្តរជាតិនានា ឆ្លុះបញ្ចាំងឱ្យឃើញនូវការពង្រឹងកម្ពុជាឱ្យក្លាយជាគោលដៅវិនិយោគប្រកបដោយភាពទាក់ទាញនិងជាវេទិកាពាណិជ្ជកម្មដ៏ល្អមួយ។

ទោះជាយ៉ាងណាក៏ដោយ ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាឱ្យមានការអនុវត្តយ៉ាងពេញលេញនូវកាតព្វកិច្ចទាំងឡាយកើតចេញពីកម្មវិធីការងារសម្របសម្រួលពាណិជ្ជកម្មអាស៊ាននិងការកែសម្រួលគោលនយោបាយពាណិជ្ជកម្ម WTO និងដើម្បីធ្វើឱ្យកម្ពុជាក្លាយជាទីដៅកាន់តែទាក់ទាញសម្រាប់ការវិនិយោគថ្មីៗ។ បញ្ហាប្រឈមសំខាន់ៗដែលនៅសេសសល់នឹងត្រូវដោះស្រាយរួមមាន៖

1. ពិនិត្យកែសម្រួលដោយប្រុងប្រយ័ត្ននូវកិច្ចព្រមព្រៀង WTO ស្តីពីការសម្របសម្រួលពាណិជ្ជកម្មដែលបានអនុម័តនៅខែធ្នូ ឆ្នាំ២០១៣ ជាផ្នែកមួយនៃ "កញ្ចប់កិច្ចព្រមព្រៀងក្រុងបាលី" និងការអនុវត្តឱ្យបានឆាប់រហ័សតាមការតម្រូវ
2. ការសម្រួលឲ្យសាមញ្ញនូវនីតិវិធីនិងដំណើរការនៃការនាំចេញនាំចូលនិងឆ្លងកាត់ព្រំដែន ដើម្បីបន្ថយចំណាយនិងពេលវេលាជម្រះយកទំនិញ

[3] កិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្ម WTO បានត្រូវអនុម័តដោយសមាជិក WTO ក្នុងអំឡុងពេលសន្និសីទថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងបាលីកាលពី ខែធ្នូឆ្នាំ២០១៣ ដែលជាផ្នែកមួយនៃ "កញ្ចប់កិច្ចព្រមព្រៀងក្រុងបាលី"

3. ស្វ័យប្រវត្តិកម្មទាំងស្រុងនូវនីតិវិធីឆ្លងកាត់ព្រំដែនមានវិសាលភាពគ្របដណ្តប់ទីភ្នាក់ងារគ្រប់គ្រងព្រំដែនទាំងឡាយ (បញ្ជរតែមួយជាតិNational Single Window) រួមមានអាជ្ញាប័ណ្ណវិញ្ញាបនប័ត្រលិខិតអនុញ្ញាតនិងការយល់ព្រមទាក់ទងនឹងការនាំចេញ/នាំចូល។[4]
4. ការកែលម្អនីតិវិធីនិងដំណើរការវាយតម្លៃនិងគ្រប់គ្រងហានិភ័យដោយ GDCE និងទីភ្នាក់ងារពាក់ព័ន្ធដទៃទៀត ដូចជា ការរៀបចំប្រព័ន្ធប្រតិបត្តិករសេដ្ឋកិច្ចដែលមានការអនុញ្ញាតជាដើម
5. ការអនុវត្តថ្លៃសេវាផ្លូវការដែលកំណត់ដោយប្រកាសដែលចេញនៅខែធ្នូឆ្នាំ២០១២និងលុបបំបាត់ការបង់ប្រាក់ក្រៅផ្លូវការ
6. រៀបចំកិច្ចព្រមព្រៀងកម្រិតសេវាដើម្បីកែលម្អភាពទស្សទាយបាននៃរយៈពេលជម្រះយកទំនិញ
7. របៀបប្រមូលពន្ធគយដែលស្របទាំងស្រុងទៅនឹងលក្ខខណ្ឌសុពលកម្មពន្ធគយ WTO
8. បង្កើនតម្លាភាពនៃតារាងពន្ធគយនិងបទប្បញ្ញត្តិពាណិជ្ជកម្មដទៃទៀតដោយមានផ្តល់ជូនតាមអ៊ីនធើណិតនិងដោយឥតគិតថ្លៃ(មជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មជាតិ - National Trade Repository)
9. ការរៀបចំជាបន្ថែមនិងការអនុវត្តនីតិវិធីសម្រេចជាមុន (Advance Ruling procedures)ដែលណែនាំឱ្យប្រើដោយ GDCE ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងពន្ធគយរវាង GDCE និងផ្នែកឯកជន
10. ការកែលម្អនីតិវិធីនិងដំណើរការឆ្លងកាត់ព្រំដែន ដើម្បីគាំទ្រសមាហរណកម្មពេញលេញនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននិងដើម្បីទទួលផលប្រយោជន៍ពីការផ្សារភ្ជាប់ជាមួយបណ្តាញផលិតកម្មនិងសង្វាក់ផ្គត់ផ្គង់តំបន់
11. លុបបំបាត់ចំណុចត្រួតពិនិត្យ (និងការបង់ប្រាក់ក្រៅផ្លូវការ) តាមច្រករបៀងសេដ្ឋកិច្ចសំខាន់ៗ។ កម្ពុជាគួរផ្តោតលើការបង្កើនភាពប្រកួតប្រជែងរបស់ខ្លួនដោយកាត់បន្ថយពេលវេលា/ចំណាយសម្រាប់ការនាំចេញ/នាំចូល។ នៅត្រឹមឆ្នាំ២០០៨កម្ពុជាអាចកាត់បន្ថយចំណាយមកត្រឹម១២០ភាគរយនៃចំណាយមធ្យមភាគអាស៊ាន ៦ (បច្ចុប្បន្ន១៣៦ភាគរយ) ហើយអាចកាត់បន្ថយរយៈពេលមធ្យមអាស៊ាន (១៦ថ្ងៃ) សម្រាប់បញ្ចេញការដឹកជញ្ជូនទំនិញ(បច្ចុប្បន្ន២៤ថ្ងៃ)។ កិច្ចការនេះអាចសម្រេចបានដោយការសម្រួលឲ្យសាមញ្ញនិងស្វ័យប្រវត្តិកម្មនីតិវិធីឆ្លងកាត់ព្រំដែននឹងបន្តកែលម្អរបៀបគ្រប់គ្រងហានិភ័យរបស់ខ្លួន។ តម្រូវការទាំងនេះនឹងត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពតាមដានបន្តដល់ផែនការសកម្មភាព១២ចំណុចឆ្នាំ២០០៤។

---

[4]ជាផ្នែកមួយនៃដំណើរការនេះ ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានប្រកាសនៅចុងខែវិច្ឆិកា ឆ្នាំ២០១៣ថាក្រសួងកំពុងចាត់វិធានការដើម្បីសម្រេចបានស្វ័យប្រវត្តិកម្មដំណើរការនៃការចេញវិញ្ញាបនបត្រប្រភពដើមទំនិញត្រឹមចុងឆ្នាំ២០១៤។

## ការដឹកជញ្ជូនពាណិជ្ជកម្ម

ការខ្វះខាតពេលវេលាក្នុងផ្នែកភស្តុភារពាណិជ្ជកម្មនឹងរារាំងសក្តានុពលនាំចេញរបស់កម្ពុជា ប្រសិនបើមិនត្រូវបានដោះស្រាយទេនោះ។ ការនាំចេញសម្លៀកបំពាក់គឺជាផ្នែកមួយនៃសង្វាក់ផ្គត់ផ្គង់ដែលទាមទារឱ្យមានល្បឿនឆាប់រហ័សនិងភាពអាចទុកចិត្តក្នុងការដឹកជញ្ជូន។ អង្ករជំឡូងមីកៅស៊ូនិងទំនិញកសិកម្មដទៃទៀតត្រូវការបណ្តាញដឹកជញ្ជូនផ្ទៃក្នុងល្អប្រសើរពីមូលដ្ឋានផលិតទៅកាន់ព្រំដែននិងមធ្យោបាយទុកដាក់សមស្រប។គុណផលនៃសង្វាក់ផ្គត់ផ្គង់របស់កម្ពុជាក៏ប្រឈមមុខនឹងទំហំតូចមានកម្រិតមិនគ្រប់គ្រាន់ដើម្បីទទួលវិនិយោគធំៗឬកែលម្អប្រសិទ្ធភាពឡើយចំណែកឯគូប្រកួតប្រជែងធំៗរបស់ខ្លួនឧទាហរណ៍នៅក្នុងវិស័យសម្លៀកបំពាក់ (វៀតណាម ចិននិងបង់ក្លាដែសជាដើម) សុទ្ធតែមានប្រៀបផ្នែកសេដ្ឋកិច្ចមាត្រដ្ឋានគុណផលការដឹកជញ្ជូនរបស់កម្ពុជាទោះបីជាមានលក្ខណៈសមស្របជាមួយប្រទេសជាច្រើនដូចជា ឡាវក៏ដោយក៏ស្ថិតនៅទាបជាគូប្រកួតប្រជែងធំៗដូចជាវៀតណាមដែរ។ ជាងនេះទៅទៀតសង្វាក់ផ្គត់ផ្គង់មួយចំនួនរបស់ប្រទេសត្រូវគ្រប់គ្រងដោយក្រុមហ៊ុនបញ្ជាទិញខាងក្រៅជាជាងក្រុមហ៊ុនផលិតក្នុងស្រុក។ជាការសំខាន់មិនត្រូវកែលម្អតែការដឹកជញ្ជូនពាណិជ្ជកម្មនៅថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ចាំបាច់ត្រូវដោះស្រាយលក្ខខណ្ឌតម្រូវមួយចំនួនរបស់ផ្នែកនាំចេញសំខាន់ៗរបស់ខ្លួនដែរ។

ការកែលម្អថ្មីៗនេះ ក្នុងច្រករបៀងការដឹកជញ្ជូនសំខាន់ៗរបស់កម្ពុជាបានផ្តល់លទ្ធផលល្អជាដុំកំភួនដល់ការធ្វើពាណិជ្ជកម្ម។ លទ្ធភាពចេញចូលកំពង់ផែក្រុងព្រះសីហនុត្រូវបានកែលម្អចំណែកលទ្ធភាពចេញចូលដែលត្រូវបានពង្រីកទៅកាន់កំពង់ផែប្រកបដោយប្រសិទ្ធភាព នៅវៀតណាមបានកាត់បន្ថយពេលវេលានិងចំណាយសម្រាប់ការដឹកជញ្ជូនអន្តរជាតិមួយចំនួន។ ការកែលម្អទាំងនេះបានអនុញ្ញាតឱ្យមានការធ្វើពាណិជ្ជកម្មកាន់តែច្រើនឡើងដោយការពន្លឿនពាណិជ្ជកម្មផ្លូវការនិងក្រៅផ្លូវជាមួយវៀតណាមនិងថៃ។

ច្រករបៀងពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជារួមមាន៖

*១. ភូមិភាគបស្ចឹមនៃកម្ពុជា - ប៉ោយប៉ែត - បាងកក*
*២. ភូមិភាគកណ្តាលឬបូព៌ានៃកម្ពុជា - បាវិត - ហូជីមិញ*
*៣. ភ្នំពេញ - ក្រុងព្រះសីហនុ*
*៤. ភូមិភាគកណ្តាលនៃកម្ពុជា - ទន្លេមេគង្គ - កំពង់ផែព្រៃនគរទៅកាន់ CaiMep*

ផ្លូវដឹកជញ្ជូនភ្នំពេញ - ក្រុងព្រះសីហនុរួមមានការផ្ទេរពីផ្លូវថ្នល់ទៅកាន់នាវានិងពីផ្លូវដែកទៅកាន់នាវាចាប់តាំងពីការបើកផ្លូវដែកឡើងវិញក្រោយពីការស្តារបណ្តាញផ្លូវដែក។ សម្រាប់ផ្លូវដឹកជញ្ជូនភ្នំពេញ-ក្រុងព្រះសីហនុរយៈពេលឆ្លងកាត់គឺ២ទៅ៣ថ្ងៃរួមបញ្ចូលទាំងពេលវេលាសម្រាប់ផ្ទុកទំនិញនិងដាក់ទំនិញសម្រាប់ផ្លូវដឹកជញ្ជូនកម្ពុជា-មេគង្គ-ព្រៃនគរទៅកាន់ CaiMep មានរយៈពេល៤ទៅ៥ថ្ងៃ។

ច្រករបៀងដ៏សំខាន់បំផុតគឺច្រករបៀងដែលផ្តល់បណ្តាញតភ្ជាប់ទៅកាន់កំពង់ផែទឹកជ្រៅរបស់វៀតណាម(ភូមិភាគកណ្តាល/បូព៌ានៃកម្ពុជា - *បាវិត* - *ហូជីមិញនិងភូមិភាគកណ្តាលនៃកម្ពុជា* - *មេគង្គ* - *កំពង់ផែព្រែនគរទៅកាន់ CaiMep*)។ ចំពោះទំនិញកសិកម្មច្រកទាំងនេះផ្តល់លទ្ធភាពឱ្យនាវាដឹកទំនិញទូទៅធំៗចេញចូលបាន។ សម្រាប់កុងតឺន័រវាផ្តល់លទ្ធភាពចេញចូលផ្ទាល់ដោយនាវា ដែលធ្វើប្រតិបត្តិការតាមចក្ររបៀងអន្តរជាតិទៅកាន់សហរដ្ឋអាមេរិកនិងអឺរ៉ុប។ លទ្ធភាពទាំងពីរនេះផ្តល់ការសន្សំសំចៃក្នុងថ្លៃដឹកជញ្ជូនដោយសារទំហំចរាចរណ៍ធំៗនៅតាមកំពង់ផែវៀតណាម។ បញ្ហារាំងតែមួយគត់គឺនីតិវិធីសម្រាប់ឆ្លងកាត់ព្រំដែន និងការចល័តទំនិញនៅចំណុចឆ្លងកាត់។ គុណផលនៃច្រករបៀងទាំងនេះ កំពុងតែកែលម្អខណៈពេលដែលបណ្តាញដឹកជញ្ជូនទាំងនេះចូលរួមក្នុងការផ្តល់សេវាដើមដំបូងឆ្ពោះទៅកាន់កំពង់ផែ។ ការកែលម្អគុណផលបន្ថែមគួរចាត់ទុកជាអាទិភាពផ្អែកតាមផលប៉ះពាល់លើការចំណាយនិងពេលវេលាសម្រាប់ចល័តទំនិញនៅតាមច្រករបៀងទាំងមូល។

ការវាយតម្លៃការដឹកជញ្ជូននិងកិច្ចសម្រួលពាណិជ្ជកម្ម (Recent *Transport and Trade Facilitation Assessment* -TTFA) និងការវាយតម្លៃច្រករបៀងដឹកជញ្ជូន (*Transport Corridor Assessment*-TCA) នាពេលថ្មីៗនេះបានកំណត់ឃើញបញ្ហាសំខាន់ៗដែលត្រូវដោះស្រាយ ដើម្បីកែលម្អស្ថានភាពការដឹកជញ្ជូនពាណិជ្ជកម្មនៅកម្ពុជា។ បញ្ហាទាំងនោះមានពិភាក្សាលម្អិតជាងនេះនៅក្នុងរបាយការណ៍ពេញលេញ*CTIS 2014-2018* ។ បញ្ហាទាំងនោះរួមមាន៖

1. ខ្វះខាតឬអនុវត្តមិនបានល្អនូវកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងព្រំដែនបង្កឱ្យមានអប្រសិទ្ធភាពនិងបន្ថយភាពប្រកួតប្រជែងផលិតផលរបស់កម្ពុជា។
2. ខ្វះខាតការធានារ៉ាប់រងដោយភាគីទីបីលើការដឹកជញ្ជូនឆ្លងព្រំដែន។
3. ភាពខុសគ្នារវាងកម្រិតបន្ទុករវាងកម្ពុជានិងប្រទេសជិតខាងរបស់ខ្លួន។
4. ខ្វះ "លទ្ធភាពដោះដូរ" នៃទីផ្សារកុងតឺណឺដោយសារអតុល្យភាពពាណិជ្ជកម្ម។
5. ទោះបីមានការលម្អក៏ដោយក៏ផ្លូវថ្នល់ត្រូវអ្នកបើកបររថយន្តដឹកជញ្ជូនចាត់ទុកថាគ្មានសុវត្ថិភាពគ្រប់គ្រាន់។
6. គ្រប់ដណ្តប់ដោយក្រុមហ៊ុនដឹកជញ្ជូនធំៗមួយចំនួនតូចនៅក្នុងផ្នែកដឹកជញ្ជូនផ្លូវគោកដែលមានរថយន្តដឹកជញ្ជូនចាស់ៗបណ្តាលមកពីពុំសូវមានការប្រកួតប្រជែង។
7. ចំណាយលើប្រេងឥន្ធនៈខ្ពស់ចាត់ទុកជាឧបសគ្គរាំងដ៏ធំបំផុតចំពោះប្រតិបត្តិការធុរកិច្ចដោយស្រូបយកចំណាយសរុបជាច្រើន។
8. ខ្វះការប្រកួតប្រជែងដោយក្រុមហ៊ុនបរទេសលើផ្លូវគោកកម្ពុជាភាគច្រើនបំផុតនាំឱ្យតម្លៃនៅតែខ្ពស់សម្រាប់ការដឹកជញ្ជូនដោយរថយន្ត។
9. បណ្តាញផ្លូវដែកកម្ពុជាមិនទាន់តភ្ជាប់ជាមួយថៃនិងវៀតណាមនៅឡើយ។
10. ហេដ្ឋារចនាសម្ព័ន្ធកំពង់ផែមានលក្ខណៈគ្រប់គ្រាន់សម្រាប់ទំហំពាណិជ្ជកម្មបច្ចុប្បន្ននេះប៉ុន្តែត្រូវការពង្រីកដើម្បីធានាឱ្យមានសមត្ថភាពគ្រប់គ្រាន់គាំទ្រដល់កំណើនពាណិជ្ជកម្ម។

11. ត្រូវជំរុញការប្រើប្រាស់ផ្លូវទឹកជំនួសជាពិសេសតាមបណ្តោយទន្លេមេគង្គដើម្បីបង្កើនការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធកំពង់វៀតណាមកាន់តែទូលំទូលាយ។
12. ភាពមិនច្បាស់លាស់នៃចំណាយនៅក្នុងថ្លៃដឹកជញ្ជូនចុងក្រោយនិងបណ្តាញឈ្នួញកណ្តាលមានលក្ខណៈស្មុគស្មាញ។
13. ការបង់ថ្លៃក្រៅផ្លូវការមានកម្រិតខ្ពស់ដើម្បីជម្រះបញ្ជីដឹកជញ្ជូនទំនិញដែលមួយផ្នែកធំហាក់ដូចជាចាប់យកដោយក្រុមហ៊ុនដឹកជញ្ជូនធំៗ។
14. ការដឹកជញ្ជូនមិនគ្រប់គ្រាន់ដើម្បីគាំទ្រការនាំចេញអង្ករនិងទំនិញកសិកម្មដទៃទៀត។

ការដោះស្រាយបញ្ហាទាំងនេះ ពិតជាមានសារៈសំខាន់ណាស់ចំពោះការពង្រីកពាណិជ្ជកម្មកម្ពុជាប្រកបដោយនិរន្តរភាព។ កម្រិតនៃបញ្ហានេះត្រូវដោះស្រាយដោយការយកចិត្តទុកដាក់ចំពោះការតាក់តែងគោនយោបាយប្រកបដោយភាពរឹងមាំយូរអង្វែងពីថ្នាក់កំពូលនៃរដ្ឋាភិបាល ដើម្បីត្រួសត្រាយផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការអន្តរក្រសួងប្រកបដោយផ្លែផ្កាដើម្បីរៀបចំនិងអនុវត្តកំណែទម្រង់។ ដូច្នេះក្រុមការងារថ្នាក់ជាតិមួយដែលមានអាណត្តិរៀបចំផែនការលម្អិតអំពីការដឹកជញ្ជូនថ្នាក់ជាតិ (National Logistics Blueprint-NLB) អាចនឹងត្រូវបានបង្កើតឡើងដោយរាជក្រឹត្យកំណត់អំពីគោលបំណងភារកិច្ចនិងពេលវេលាច្បាស់លាស់។ NLB អាចត្រូវរៀបចំឡើងនិងអនុវត្តរួមជាមួយគំនិតផ្តួចផ្តើមនានា គាំទ្រដល់សង្វាក់ផ្គត់ផ្គង់មួយចំនួននិងសំដៅកែលម្អការកិច្ចសម្រួលពាណិជ្ជកម្ម។ ហេតុដូច្នេះ NLB អាចត្រូវរៀបចំឡើងយ៉ាងល្អបំផុតដោយសហការយ៉ាងជិតស្និទ្ធជាមួយ Trade SWAp – ពោលគឺរួមជាមួយផែនទីបង្ហាញផ្លូវសសរស្តម្ភ - ដើម្បីជានាឱ្យមានប្រសិទ្ធិផលជាអតិបរមាក្នុងកិច្ចសហការក្នុងចំណោមក្រសួងនិងទីភ្នាក់ងារនានានិងរវាង RGC និងអង្គភាពឯកជន។

អន្តរាគមន៍ដែលត្រូវបញ្ចូលទៅក្នុង NLB ជាប្រយោជន៍ដល់ភាពប្រកួតប្រជែងពាណិជ្ជកម្មទូទៅរបស់កម្ពុជាគួរមានចំណុចដូចតទៅនេះ៖

1. ចរចាឱ្យមានកិច្ចព្រមព្រៀងកាន់តែល្អប្រសើរសម្រាប់ទីផ្សារដឹកជញ្ជូនផ្លូវគោកមានលក្ខណៈសមាហរណកម្មជាមួយថៃនិងវៀតណាម។ កិច្ចព្រមព្រៀងនេះគួរបញ្ចូលការបន្តការអនុញ្ញាតមួយចំនួនដែលបានផ្តល់ជូនក្រុមហ៊ុនធំៗដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស និងជានាឱ្យមានការគាំទ្រជាទៀងទាត់ដល់ការដឹកជញ្ជូនតាមទន្លេមេគង្គ។
2. រៀបចំនិងអនុវត្តផែនការការដឹកជញ្ជូនជាតិនិងធ្វើសមាហរណកម្មផែនការទាំងនោះជាមួយអាស៊ានផ្សារភ្ជាប់គោលការណ៍ដែលមានស្រាប់ដូចជា "ផែនទីបង្ហាញផ្លូវសម្រាប់សមាហរណកម្មសេវាការដឹកជញ្ជូន" ជាដើម។ ទាក់ទាញចំណាប់អារម្មណ៍របស់រដ្ឋសមាជិកអាស៊ានដទៃទៀតឱ្យយកចិត្តទុកដាក់ចំពោះភាពចាំបាច់ដែលត្រូវផ្តល់សច្ចាប័ននិងអនុវត្តកិច្ចព្រមព្រៀងដែលមានស្រាប់។
3. កែលម្អបទប្បញ្ញត្តិដឹកជញ្ជូន (ការទទួលខុសត្រូវកម្រិតបន្ទុកគុណវុឌ្ឍន៍របស់អ្នកបើកបរព្រមទាំងស្ថានភាពស្តង់ដារសុវត្ថិភាពកិច្ចសន្យា។ល។) ដូចជាអនុម័តយកស្តង់ដារអន្តរជាតិជាដើមដើម្បីទាក់ទាញវិនិយោគ។

4. បង្កើតគម្រោងជានារ៉ាប់រងបំណុលដោយភាគីទីបីនិងធ្វើសុខដុមកម្មកម្រិតបន្ទុកដឹកជញ្ជូននៅតាមចក្ររបៀងសំខាន់ៗ។
5. ណែនាំឱ្យប្រើប្រាស់គម្រោងទំនើបកម្មមធ្យោបាយដឹកជញ្ជូនដោយមានយន្តការហិរញ្ញប្បទាននិងពង្រឹងគុណភាពសមស្រប។
6. លុបបំបាត់ឧបសគ្គរាំងដល់ FDI ក្នុងការដឹកជញ្ជូនដើម្បីបង្កើនភាពប្រកួតប្រជែងវិស័យនេះនិងកាត់បន្ថយការចំណាយលើសេវារបស់ពាណិជ្ជករ។
7. អភិវឌ្ឍសមត្ថភាពក្នុងចំណោមៈ (ក) ទីភ្នាក់ងារជម្រះទំនិញនិងដឹកជញ្ជូនបន្តផ្អែកតាមលំនាំ FIATA (ខ) ប្រតិបត្តិករនៅក្នុងឧស្សាហកម្មដឹងកជញ្ជូន ទាក់ទងនឹងការគ្រប់គ្រងនិងទំនើបកម្មមធ្យោបាយដឹកជញ្ជូននិងអាជ្ញាធរនិយ័តកម្មការដឹកជញ្ជូនដែលទទួលខុសត្រូវចំពោះការធ្វើនិយ័តកម្មកំពង់ផែផ្លូវគោកនិងផ្លូវដែកនិងការកំណត់អត្រាថ្លៃសេវា។
8. ភ្ជាប់បណ្តាញផ្លូវដែករវាងថៃនិងកម្ពុជាឡើងវិញផ្តល់អាទិភាពសម្រាប់ប្រតិបត្តិការដឹកជញ្ជូន។
9. ស្វែងរកលទ្ធភាពតភ្ជាប់បណ្តាញផ្លូវដែកពីកម្ពុជាទៅវៀតណាម។
10. ជំរុការប្រកួតប្រជែងក្នុងចំណោមកំពង់ផែនានាដោយធ្វើសេរីភាវូបនីយកម្មថ្លៃសេវាដើម្បីជំរុញការប្រកួតប្រជែងតម្លៃសេវា។
11. ស្វែងរកជម្រើសសម្រាប់បង្កើនការប្រើប្រាស់កុងតឺន័រចាកចេញទទេរ ដើម្បីធ្វើឱ្យការនាំចេញផលិតកសិកម្មមានលក្ខណៈផ្លូវការ (ដូចជាអង្ករជំឡូងមីកៅស៊ូពោត។ល។)។

## វិធានការអនាម័យ និងភូតគាមអនាម័យ – ស្តង់ដារបច្ចេកទេសនានា

ចាប់តាំងពីចុងទស្សវត្សន៍ឆ្នាំ២០០០មក កម្ពុជាទទួលបានការលូតលាស់ផ្នែកផលិតនិងនាំចេញ អង្ករ ដំឡូងមី កៅស៊ូធម្មជាតិនិងផលិតផលកសិកម្មមួយចំនួនទៀត ដូចជាពោតជាដើម។ ការលូតលាស់នេះ ត្រូវបានសម្រប សម្រួលដោយទំនាក់ទំនងកាន់តែប្រសើរនៅក្នុងតំបន់ GMS តម្លៃខ្ពស់ និងការមានដីមិនប្រើប្រាស់មិនអស់លទ្ធភាពនិងពលកម្ម។ កំណើនជាបន្តទៀត ច្បាស់ជាអាចនឹងកើតមានបាន។

ទោះជាយ៉ាងណាក៏ដោយ ការលូតលាស់នេះក៏បានបង្ហាញឱ្យឃើញនូវចំណុចខ្សោយនិងហានិភ័យជាច្រើនដែលត្រូវយកចិត្តទុកដាក់ ដើម្បីទទួលបានផលប្រយោជន៍ពេញលេញពីការលូតលាស់នេះ។ បច្ចុប្បន្ននេះ កម្ពុជាប្រឈមុខនឹងឧបសគ្គផ្នែកធំៗមួយចំនួនក្នុងការបំពេញតាមស្តង់ដារគុណភាពនិងសុវត្ថិភាព ដែលទាមទារដោយទីផ្សារបរទេសក្នុងការបន្ថែមតម្លៃទៅលើវត្ថុធាតុដើម។ ជាលទ្ធផលផលិតផលមួយភាគធំត្រូវបានដោះដូរដោយមិនបានកែច្នៃដោយតម្លៃទាបជាមួយទីផ្សារក្រៅប្រព័ន្ធនៅក្នុងប្រទេសជិតខាង។ កម្ពុជា មិនមែនត្រឹមតែបាត់បង់ឱកាសសម្រាប់តម្លៃបន្ថែមនិងទទួលបានតម្លៃប្រសើរជាងនេះប៉ុណ្ណោះទេ ប៉ុន្តែការនាំចេញបច្ចុប្បន្ននេះអាស្រ័យលើការអនុគ្រោះលក្ខខណ្ឌ SPS របស់ប្រទេសជិតខាងផងដែរ មានន័យថា ការនាំចេញទាំងនេះ អាចមានគ្រោះ

ថ្នាក់ ប្រសិនបើគេអនុវត្តលក្ខខណ្ឌទាំងនោះ។ ដូច្នេះហើយ ការកែលម្អសមត្ថភាពផ្នែកសាធារណៈនិងផ្នែកឯកជនដ៏ទន់ខ្សោយនេះ ដើម្បីជានាឱ្យមានស្តង់ដារគុណភាពនិងសុវត្ថិភាពកាន់តែខ្ពស់ គឺជាកិច្ចការដ៏ធំមួយសម្រាប់រក្សាលទ្ធភាពចូលទីផ្សារសម្រាប់ជំរុញភាពចម្រុះ នៃទីផ្សារនិងសម្រាប់ពង្រឹងលទ្ធភាពចូលចំណែកទីផ្សារដែលមានលក្ខណៈតឹងតែង និងបានតម្លៃខ្ពស់ជាងមុន។

ការជំរុញការកែលម្អគុណភាពផលិតផលនិងការធ្វើឱ្យទីផ្សារមានលក្ខណៈចម្រុះក៏ត្រូវអនុវត្តចំពោះផលិតផលសូត្រ ជលផលនិងអាហារកែច្នៃឬវិស័យទេសចរណ៍ផងដែរ។ វិស័យទេសចរណ៍ កំពុងតែរីកចម្រើនយ៉ាងឆាប់រហ័ស ប៉ុន្តែស្ថានភាពរបស់វិស័យនេះងាយនឹងរងគ្រោះដោយសារមុខសញ្ញាគ្រោះថ្នាក់នៃសុវត្ថិភាពអាហារ។ វិស័យជលផលអាចសម្រេចផលបានល្អប្រសើរជាងនេះ ប្រសិនគេអាចគ្រប់គ្រង់សុវត្ថិភាពនិងគុណភាពបាន។

ស្របពេលជាមួយនឹងពាណិជ្ជកម្មកើនឡើង ហានិភ័យនៃការចម្លងសត្វចង្រៃនិងជំងឺផ្សេងៗ ដោយប្រទេសដែលនាំចូលពីកម្ពុជាក៏កើនឡើងដែរ។ ហានិភ័យនេះ ត្រូវការយកចិត្តទុកដាក់ដោយសារវាអាចនាំឱ្យបាត់បង់ផលិតកម្មនិងការហាមឃាត់ការនាំចេញរបស់កម្ពុជា។ ដូចគ្នានេះដែរ កម្ពុជាត្រូវបញ្ចៀសហានិភ័យពាក់ព័ន្ធនឹងការនាំចូលអាហារធុនអន់និងគ្មានសុវត្ថិភាព ថ្នាំសម្លាប់សត្វចង្រៃនិងថ្នាំព្យាបាលជំងឺសត្វផ្សេងៗទៀត។

ក្រុមហ៊ុនឯកជន ស្ថិតនៅក្នុងសមរភូមិការពារជួរមុខ ក្នុងការបំពេញតាមលក្ខខណ្ឌគុណភាពនិងសុវត្ថិភាពចំណីអាហាររបស់ក្រុមហ៊ុនបញ្ជាទិញនិងប្រទេសនាំចូល។ ពួកគេត្រូវកសាងសមត្ថភាពសម្រាប់គ្រប់គ្រងគុណភាពនិងសុវត្ថិភាពនៅតាមរោងចក្រ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេក៏ត្រូវការបរិយាកាសអនុគ្រោះនិងការគាំទ្រពីផ្នែកសាធារណៈផងដែរ ជាពិសេស ទាក់ទងនឹងស្តង់ដារបច្ចេកទេសនិងវិធានការអនាម័យនិងអនាម័យភូតគាម។

GMP និង HACCP គឺជាឧបករណ៍ដ៏សំខាន់សម្រាប់សហគ្រាសកែលម្អការគ្រប់គ្រងគុណភាពនិងសុវត្ថិភាពរបស់ខ្លួន ហើយអតិថិជនបានទាមទារឱ្យប្រើប្រាស់ឧបករណ៍ទាំងនេះកាន់តែច្រើនឡើងៗ។ ការទាមទារនេះ ធ្វើឡើងចំពោះរោងម៉ាស៊ីនកិនស្រូវ ក្រុមហ៊ុនកែច្នៃដំឡូងមីស្ងួត ក្រុមហ៊ុនកែច្នៃពោត អាហារកែច្នៃនិងក្រុមហ៊ុនកែច្នៃផលិតផលត្រី។ ចំពោះការគ្រប់គ្រងគុណភាពនិងសុវត្ថិភាពនៅតាមសណ្ឋាគារនិងភោជនីយដ្ឋាន ប្រព័ន្ធដែលផ្អែកតាម GHP/GMP អាចមានប្រសិទ្ធភាពគ្រាន់បើ។ រដ្ឋាភិបាលអាចគាំទ្រការអនុវត្តប្រព័ន្ធវិញ្ញាបនកម្មសម្រាប់វិស័យនីមួយៗនេះ។

ក្រុមហ៊ុនក៏ប្រឈមមុខនឹងបញ្ហាលំបាកក្នុងការស្វែងរកវត្ថុធាតុដើម ដែលមានគុណភាពនិងសុវត្ថិភាពខ្ជាប់ខ្ជួនឱ្យបានគ្រប់គ្រាន់ផងដែរ។ ទោះបីបញ្ហានេះ គឺជាទំនួលខុសត្រូវជាមូលដ្ឋានរបស់ក្រុមហ៊ុនឯកជនក៏ដោយក៏រដ្ឋាភិបាលអាចផ្តល់ការគាំទ្រក្នុងការដោះស្រាយឧបសគ្គរាំង ដូចជាការត្រួតពិនិត្យការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃលើដំណាំនិងថ្នាំអង់ទីប៊ីយ៉ូទិកក្នុងវារីវប្បកម្មជាដើម។ គោលនយោបាយល្អសម្រាប់គ្រប់គ្រងគ្រាប់ពូជដំណាំ និងសម្ភារៈបណ្តុះគ្រាប់ពូជកៅស៊ូ មានសារៈសំខាន់ណាស់សម្រាប់គុណភាពផលិតផលកសិដ្ឋាន។ ក្នុងករណីមួយ

ចំនួន រដ្ឋាភិបាលអាចគាំទ្រការប្រើប្រាស់ GAP (GAP-good agriculture practice and good aquaculture practice- របៀបធ្វើកសិកម្មល្អនិងរបៀបធ្វើវារីវប្បកម្មល្អ)។

នៅប្រទេសជាច្រើន លទ្ធភាពចូលទីផ្សារសម្រាប់ផលិតផលរុក្ខជាតិ ដូចជា អង្ករ ដំឡូងមីស្ងួតនិងពោត ជាដើម អាចផ្តល់ជូនបានល្អិកណា កម្ពុជាអាចផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីស្ថានភាពសត្វចង្រៃនិងជំងឺតាមរយៈការអង្កេត និងការធានាថា វិធានការបញ្ចៀសហានិភ័យពិសេសត្រូវបានធ្វើឡើង ដូចជាការសម្លាប់មេរោគនិងសម្ងួត ជាដើម។ ប្រទេសចិន តម្រូវឱ្យមានការចុះបញ្ជីតំបន់ផលិតកម្មការតាមដានមើលថ្នាំគីមីកសិកម្មដែលបានប្រើប្រាស់ការចុះបញ្ជីក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងសង្វាក់នាំចេញក្រោយពេលប្រមូលផលនិងការប្រើប្រាស់ស្តង់ដារ GMP ក្នុងរោងចក្រកែច្នៃ។ ប្រទេសជាច្រើន តម្រូវឱ្យមានការធ្វើវិញ្ញាបនកម្មផ្អែកតាម HACCP សម្រាប់ក្រុមហ៊ុននាំចេញផលនេសាទ។ ការនាំចេញផលិតផលនេសាទទៅកាន់ EU ទាមទារឱ្យមានការអនុញ្ញាតជាមុនពីរោងចក្រកែច្នៃដែលជាលក្ខខណ្ឌបន្ថែម ចំពោះសមត្ថភាពរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីត្រួតពិនិត្យសុវត្ថិភាពផលិតផលចាប់តាំងពីពេលនេសាទរហូតដល់ពេលនាំចេញ។ ហើយសម្រាប់ការដឹកជញ្ជូនផលិតផលរុក្ខជាតិ ផលិតផលសត្វឬផលិតផលនេសាទ ប្រទេសនាំចូល អាចទាមទារឱ្យមានវិញ្ញាបនប័ត្របញ្ជាក់អនាម័យនិងភូតគាមអនាម័យ ដើម្បីធានាថា ផលិតផលទាំងនេះ បំពេញតាមស្តង់ដារសុវត្ថិភាពដែលបានកំណត់។ វិធីសាស្ត្រនិងពិធីសាសម្រាប់អង្កេតផ្តល់ព័ត៌មានបញ្ចៀសហានិភ័យរោគវិនិច្ឆ័យ ការវាយតម្លៃអនុលោមភាពនិងវិញ្ញាបនកម្ម មានកំណត់ភាគច្រើនបំផុតនៅក្នុងស្តង់ដារអន្តរជាតិ។

ដើម្បីចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិឱ្យបានជោគជ័យដែលទាមទារចាំបាច់នូវ SPS និងស្តង់ដារបច្ចេកទេស ប្រទេសនានាត្រូវកសាងសមត្ថភាពទាក់ទងនឹងផ្នែកនាំចូល ដើម្បីការពារដំណាំសត្វនិងអតិថិជនទល់នឹងហានិភ័យនៃសត្វចង្រៃជំងឺនិងអាហារគ្មានសុវត្ថិភាពនិងសមត្ថភាពទាក់ទងនឹងការនាំចេញ ដើម្បីសម្រួលពាណិជ្ជកម្មដែលប្រឈមមុខនឹងលក្ខខណ្ឌសុវត្ថិភាពនិងគុណភាពពីប្រទេសនាំចូល។ តាមលក្ខខណ្ឌរដ្ឋជាសមាជិកត្រូវអនុវត្តតាមគោលការណ៍ SPS និង TBT របស់ WTO។ អនុសាសន៍ជាចម្បងរបស់ WTO គឺឱ្យប្រទេសនានាធ្វើសុខដុមកម្មស្តង់ដារអន្តរជាតិ។ ASEAN ប្រើប្រាស់គោលការណ៍និងអនុសាសន៍របស់ WTO ទាំងនេះជាមូលដ្ឋានសម្រាប់សមាហរណកម្មសេដ្ឋកិច្ច។

ចាប់តាំងពីមាន CTIS 2007 មកកម្ពុជាបានធ្វើឱ្យមានការរីកចម្រើនជាច្រើន ដើម្បីកែលម្អអនុលោមភាពតាមគោលការណ៍ SPS និង TBT និងអនុសាសន៍របស់WTOនិងដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួនសម្រាប់ពង្រឹងយុទ្ធសាស្ត្រនាំចេញរបស់ខ្លួននិងត្រួតពិនិត្យសុវត្ថិភាពផលិតផលនាំចេញរបស់ខ្លួន។ ប៉ុន្តែនៅមានឧបសគ្គរាំងនិងចំណុចខ្សោយជាច្រើនដែលត្រូវដោះស្រាយ។ អនុសាសន៍ទាំងនោះរួមមាន៖

## ពង្រឹងសមត្ថភាពផ្នែកឯកជន៖

ជំរុញវិញ្ញាបនកម្មផ្នែកតាមស្តង់ដារនិងប្រព័ន្ធអន្តរជាតិ (HACCP, GMP, GAP, GHP, Codex, OIE) ដែលមានលក្ខណៈសមស្របសម្រាប់ធានាសុវត្ថិភាពនិងគុណភាពក្នុងចំណោមសក្រុមហ៊ុន (សម្រាប់អង្ករ ដំឡូងមីស្ងួត ពោត ផលិតផលត្រីនិងអាហារកែច្នៃ) និងតាមសណ្ឋាគារនិងភោជនីយដ្ឋាន។

1. ជំរុញគុណភាពសូត្រកៅស៊ូធម្មជាតិសម្លៀកបំពាក់ស្បែកជើងនិងរោងចក្រកម្មន្តសាល។
2. ជំរុញគុណភាពនិងសុវត្ថិភាពវត្ថុធាតុដើមឱ្យបានខ្ជាប់ខ្ជួនតាមរយៈការលុបបំបាត់ចំណុចខ្សោយនៅក្នុងសង្វាក់ផ្គត់ផ្គង់។

## ពង្រឹងសមត្ថភាពផ្នែកសាធារណៈ៖

1. ដោះស្រាយបញ្ហាអនុវត្តច្បាប់របស់WTOក្នុងការកំណត់ស្តង់ដារការផ្តល់ការទទួលស្គាល់និងការវាយតម្លៃអនុលោមភាព។
2. កែលម្អគុណភាពអត្ថបទច្បាប់និងអនុម័តច្បាប់ឬអត្ថបទច្បាប់បន្ថែមដើម្បីដោះស្រាយភាពខ្វះចន្លោះដែលនៅសេសសល់ធានាឱ្យច្បាប់និងអត្ថបទច្បាប់ទាំងនេះស្របតាមនិយាមការ SPS និង TBT។ គាំទ្រការ-អនុវត្តច្បាប់សំខាន់ៗប្រកបដោយប្រសិទ្ធភាព។
3. កំណត់ប្រព័ន្ធអង្កេតប្រកបដោយប្រសិទ្ធភាពនិងធ្វើការអង្កេតជាទៀងទាត់អំពីសត្វចង្រៃជំងឺនិងថ្នាំគីមីកសិកម្មដែលបានប្រើប្រាស់ក្នុងតំបន់ផលិតកម្មដំណាំនាំចេញតាមការស្នើសុំរបស់ប្រទេសនាំចូល។
4. បង្កើតប្រព័ន្ធត្រួតពិនិត្យផ្អែកតាមហានិភ័យនិងធានាឱ្យមានការត្រួតពិនិត្យផ្អែកតាមហានិភ័យឱ្យបានត្រឹមត្រូវនូវទីផ្សារនាំចូលនិងទីផ្សារក្នុងស្រុក ដើម្បីលើកកម្ពស់សុវត្ថិភាពអាហារថ្នាំសម្លាប់សត្វចង្រៃនិងថ្នាំព្យា-បាលសត្វ។
5. កែសម្រួលនីតិវិធីសម្រាប់កំណត់និងអនុម័តស្តង់ដារ ដើម្បីដោះស្រាយបញ្ហារាំងស្ទះក្នុងអនុវត្តស្តង់ដារអន្តរជាតិ
6. ពង្រឹងវិធីសាស្ត្រគ្រប់គ្រងរដ្ឋបាលផ្គត់ផ្គង់មូលនិធិនានា ដល់មន្ទីរពិសោធន៍ស្របច្បាប់សម្រាប់ SPS ជាប្បញ្ញត្តិ។
7. ពង្រឹងការអភិវឌ្ឍបុគ្គលិកបច្ចេកទេសSPSដែលបានទទួលការបណ្តុះបណ្តាលនិងមានបទពិសោធន៍។

## បរិយាកាសវិនិយោគសម្រាប់ការអភិវឌ្ឍពាណិជ្ជកម្ម

ការអភិវឌ្ឍផ្នែកឯកជនបានក្លាយជាអាទិភាពដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ដើម្បីជំរុញកំណើននាំមុខដោយការនាំចេញគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈការធ្វើពាណិជ្ជ-កម្មពិពិធកម្ម RGC បានប្តេជ្ញាចិត្តជំរុញការវិនិយោគរបស់ផ្នែកឯកជនតាមវិស័យ (ជាអាទិភាព) ដូចជាវិស័យកសិកម្មឧស្សាហកម្មនិងសេវាកម្មជាដើម។

ឆ្នាំ២០១២គឺជារបត់ផ្លូវមួយក្នុងការអភិវឌ្ឍផ្នែកឯកជនរបស់កម្ពុជានាំមុខដោយលំហូរចូល FDI ចំនួន $១,៥ លានដុល្លារកើនឡើងរហូតដល់ $៩០០ លានដុល្លារនៅ ឆ្នាំ២០១១។ ទោះជាយ៉ាងណាក៏ដោយផ្នែកឯកជនរបស់កម្ពុជានៅមានស្ថានភាពជា SME តូចនិងក្រៅប្រព័ន្ធជាច្រើននិងមានសហគ្រាសធំៗមួយចំនួនតូច។

តារាងទី៧៖ផ្តល់ទិន្នន័យលម្អិតអំពីលំហូរចូល FDI

| តារាងទី៧៖លំហូរចូល FDI សុទ្ធគិតតាមវិស័យឆ្នាំ២០០០-២០១២ | | | | | |
|---|---|---|---|---|---|
| | គិតជាលាន$ | | | | អត្រាផ្លាស់ប្តូរប្រចាំឆ្នាំ |
| | 2000 | 2007 | 2011 | 2012 | 2007-2012 |
| កសិកម្ម | 5.8 | 118.0 | 188.1 | 295.5 | 20% |
| កម្មន្តសាល/ផលិតកម្ម | 132.3 | 231.1 | 262.0 | 557.6 | 19% |
| សេវាកម្ម | -48.2 | 273.2 | 53.6 | 67.9 | 4% |
| ធនាគារពាណិជ្ជកម្ម | 3.7 | 167.3 | 216.5 | 424.8 | 20% |
| ផ្សេងៗ | 54.8 | 77.6 | 181.4 | 211.3 | 22% |
| សរុប | 148.5 | 867.3 | 901.7 | 1,557.1 | 14% |
| ប្រភព៖ធនាគារជាតិកម្ពុជា | | | | | |

អត្រាពង្រីកទាបនៅអំឡុងឆ្នាំ២០០៧-២០១២ធៀបនឹងឆ្នាំ២០០០-២០០៧ឆ្លុះបញ្ចាំងឱ្យឃើញនូវឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុ។ ចំណុចទាបនៃ FDI គឺនៅឆ្នាំ២០០៩នៅពេលលំហូរចូលសុទ្ធបានធ្លាក់ចុះមកត្រឹម$៥៣៩លានដុល្លារ។ ទោះជាយ៉ាងណាក៏ដោយ FDI បានកើនឡើងយ៉ាងស្វាហាប់នៅអំឡុងឆ្នាំ២០០៧-២០១២នៅគ្រប់វិស័យទាំងអស់លើកលែងតែវិស័យសេវាកម្ម។

ដើម្បីជំរុញវិនិយោគផ្នែកឯកជនមានកំណែទម្រង់ផ្នែកច្បាប់និងបទប្បញ្ញត្តិនិងវិធានការសំខាន់ៗ ជាច្រើនត្រូវបានអនុវត្តនៅថ្នាក់ជាតិនិងកំពុងដំណើរនៅថ្នាក់ផ្សេងទៀត។ កំណែទម្រង់មួយចំនួនធំត្រូវបានធ្វើឡើងក្រោមវិសាលភាពនៃការបំពេញកាព្វកិច្ចរបស់កម្ពុជាស្របតាមលក្ខខណ្ឌចូលរួម WTO របស់កម្ពុជា (សូមមើលជំពូកទី១នៃរបាយការណ៍ទាំងស្រុង)។

ប៉ុន្តែ នៅមានឧបសគ្គជាច្រើនចំពោះការអភិវឌ្ឍផ្នែកឯកជននៅកម្ពុជាទាំងនៅថ្នាក់ជាតិនិងថ្នាក់ខេត្ត។ បញ្ហាប្រឈមយូរយារមកហើយរួមមានៈ ភាពទន់ខ្សោយផ្នែកហេដ្ឋារចនាសម្ព័ន្ធ (តម្លៃអគ្គិសនីថ្លៃដឹកជញ្ជូន) អភិបាលកិច្ចទន់ខ្សោយសមត្ថភាពមានកម្រិតរបស់ទីភ្នាក់ងាររដ្ឋាភិបាលលទ្ធភាពទទួលបាននិងចំណាយហិរញ្ញប្បទាន(ដូចបានកំណត់នៅក្នុង*ការវាយតម្លៃបរិយាកាសវិនិយោគ* ឆ្នាំ២០០៩និង២០១១)។ បញ្ហាប្រឈមដែលលេចធ្លោ រួមមានៈកង្វះខាតជំនាញនិងជំនាញមិនសមស្របការដឹកជញ្ជូននិងកិច្ចសម្រួលពាណិជ្ជកម្ម ការកែលម្អនិងច្នៃប្រឌិតបច្ចេកវិទ្យាតម្រូវការបង្កើត "ឱកាសសារពើព័ន្ធ" (ដូចបានកំណត់នៅក្នុង*ការវាយតម្លៃបរិយាកាសវិនិយោគឆ្នាំ២០១២*)។ បញ្ហាប្រឈមជាយូរយានិងលេចធ្លោទាំងនោះ ភាគច្រើនបំផុតមាននិយាយនៅក្នុងជំពូកផ្សេងៗនៃ*CTIS 2014-2018*។

ជំពូកនិយាយអំពីមន្ត្រីវិនិយោគនិងការវិភាគនិន្នាការវិនិយោគនាពេលបច្ចុប្បន្ននិងបរិយាកាសវិនិយោគនិងពិចារណាអំពីរបៀបដែលវិនិយោគបរទេសអាចត្រូវជំរុញ ដើម្បីដោះស្រាយចំណុចខ្សោយក្នុងរចនាសម្ព័ន្ធផ្នែកឯកជន (ទាំងនៅតំបន់ជនបទនិងតំបន់ក្រុង) និងគាំទ្រការធ្វើឱ្យសេដ្ឋកិច្ចមានលក្ខណៈចម្រុះ។

ដើម្បីគាំទ្រដល់ការវិនិយោគផ្នែកឯកជនឱ្យមាននិរន្តរភាពទាមទារឱ្យមានការរៀបចំនិងការអនុវត្តឱ្យបានឆាប់នូវយុទ្ធសាស្ត្រជំរុញវិនិយោគប្រកបដោយភាពច្នៃប្រឌិតផ្តោតលើៈ

(ក) ភាពចាំបាច់ដែលត្រូវធានាឱ្យវិនិយោគិនយល់ដឹងកាន់តែច្បាស់អំពីឱកាសវិនិយោគដែលកម្ពុជាផ្តល់ឱ្យជាពិសេសទាក់ទងនឹងការវិវឌ្ឍថ្មីៗនៃលក្ខខណ្ឌវិនិយោគក្នុងសេដ្ឋកិច្ចអាស៊ាននិងការអភិវឌ្ឍនៅក្នុងសង្វាក់គុណតម្លៃក្នុងតំបន់និងពិភពលោក

(ខ) មធ្យោបាយមានលក្ខណៈច្នៃប្រឌិត ដើម្បីបង្ហាញថាកម្ពុជាជាទីតាំងវិនិយោគប្រកបដោយភាពទាក់ទាញសម្រាប់វិនិយោគិនបរទេសពីប្រទេសជិតខាងនិងប្រទេសនៅឆ្ងាយដូចជារបៀបឆ្លៀតឱកាសទាញយកផល

ប្រយោជន៍អំពីការបែងចែកពលកម្មអន្តរជាតិផ្អែកតាមមូលដ្ឋាននៃសង្វាក់គុណតម្លៃពិភពលោកនិងធនធានដែលអាចរកបាននៅកម្ពុជា

(គ) ពង្រឹងសមត្ថភាពដើម្បីឱ្យកម្ពុជាក្លាយជាមជ្ឈមណ្ឌលកំណើននៃច្រករបៀងសេដ្ឋកិច្ចភូមិភាគខាងត្បូងរបស់ GMS និងក្នុងន័យទូលាយសម្រាប់មហាអនុតំបន់មេគង្គទាំងមូល។ មធ្យោបាយដែលកម្ពុជាអាចលើកកម្ពស់តួនាទីរបស់ខ្លួននៅក្នុងច្រករបៀបសេដ្ឋកិច្ចភូមិភាគខាងត្បូងរបស់ GMS នេះ គឺត្រូវពិនិត្យពិច័យដោយប្រុងប្រយ័ត្ននិងត្រូវបញ្ចូលទៅក្នុងយុទ្ធសាស្ត្រជាពិសេសសង្កត់ធ្ងន់ពីតួនាទីរបស់ក្រុងព្រះសីហនុជាក្បាលម៉ាស៊ីនជំរុញច្រករបៀងសេដ្ឋកិច្ចនេះ

(ឃ) ការពិនិត្យដោយយកចិត្តទុកដាក់អំពីរបៀបដែលត្រូវទាក់ទាញក្រុមហ៊ុនអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយសក្តានុពល ដើម្បីជាប្រយោជន៍ដល់ការវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេសនេះនិយាយដោយឡែកនៅតំបន់ក្រុងព្រះសីហនុ។ យុទ្ធសាស្ត្រជំរុញវិនិយោគទូលំទូលាយនេះអាចជាផ្នែកដ៏សំខាន់មួយនៃការកសាងទំនុកចិត្តនេះអមដោយកំណែទម្រង់ក្នុងក្របខណ្ឌភាពជាដៃគូរវាងផ្នែកសាធារណៈនិងផ្នែកឯកជននិង

(ង) ភាពចាំបាច់ដែលកម្ពុជាត្រូវកំណត់ស្ថានភាពខ្លួនឯងទប់ទល់នឹងគូប្រកួតប្រជែងនៅក្នុងនិងនៅក្រៅមហាអនុតំបន់ទន្លេមេគង្គ។

ដើម្បីដោះស្រាយតម្រូវការកែលម្អដ៏សំខាន់នៃបរិយាកាសវិនិយោគនេះគេត្រូវចាត់វិធានការ ដូចតទៅនេះ៖

## ១. រៀបចំយុទ្ធសាស្ត្រជាតិជំរុញវិនិយោគ

ជំហានដ៏ធំដំបូងផុតគឺត្រូវរៀបចំយុទ្ធសាស្ត្រជាតិជំរុញវិនិយោគទុកជាផ្នែកដ៏សំខាន់មួយនៃគោលនយោបាយរួមដើម្បីអភិវឌ្ឍសក្តានុពលវិនិយោគរបស់ប្រទេសនិងដើម្បីដោះស្រាយភាពក្រីក្រនិងសុខមាលភាព។ គោលនយោ-បាយដូចពោលនេះគួររួមមានអង្គជាតុផ្សេងៗ ដូចខាងក្រោមនេះ៖

(ក) យល់ឱ្យច្បាស់អំពីស្ថានភាពកម្ពុជានិងទិសដៅដែលប្រទេសនេះសំដៅទីរកក្នុងន័យធុរកិច្ច។ គួរពិចារណាឱ្យបានល្អិតល្អន់អំពីមេរៀនទទួលបានពីបទពិសោធន៍ថ្មីៗនេះទាក់ទងនឹងវិនិយោគបរទេសនៅកម្ពុជានិងមហាអនុតំបន់ទន្លេមេគង្គពីព្រោះវាអាចផ្តល់ជាការយល់ដឹងដ៏មានតម្លៃមិនអាចកាត់ថ្លៃបានអំពីបញ្ហា ដែលត្រូវជួបប្រទះនៅពេលអនាគតទាំងក្នុងន័យវិជ្ជមាននិងអវិជ្ជមាន។

(ខ) យុទ្ធសាស្ត្រដែលមានលក្ខណៈជាក់ស្តែងមួយដើម្បីជំរុញការអភិវឌ្ឍធុរកិច្ចឱ្យត្រូវទិសដៅគួបផ្សំនឹងវិធានការនានាដើម្បីដោះស្រាយឧបសគ្គនៃការអភិវឌ្ឍ។

(គ) តម្រង់ទិសនិងជំរុញ FDI ជាលក្ខណៈយុទ្ធសាស្ត្រ។ ខណៈពេលដែលការប្រកួតប្រជែងចេះតែកើនឡើងចំណែកឯសង្វាក់គុណតម្លៃពិភពលោកកាន់តែមានលក្ខណៈបែកខ្ញែកនោះវាកាន់តែមានសារៈសំខាន់ ដែលត្រូវរៀបចំអភិក្រមកាន់តែមានគោលដៅច្បាស់លាស់និងមានលក្ខណៈជាយុទ្ធសាស្ត្រចំពោះ FDI។ អភិក្រមជាយុទ្ធសាស្ត្រនេះត្រូវបញ្ចូលទៅក្នុងរបៀបដែលភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម ដូចជាវិធានប្រភពដើម

ទំនិញជាដើមកំពុងតែផ្តល់ផលប្រយោជន៍ដល់កម្ពុជា ក្នុងនាមជាទីតាំងវិនិយោគមួយ។ មកដល់ពេលនេះ កម្ពុជាមានកម្មវិធីជាយុទ្ធសាស្ត្រតិចតួចណាស់ដើម្បីស្វែងរកនិងទាក់ទាញ FDI ទៅក្នុងឧស្សាហកម្មជាអាទិភាព។ កម្ពុជាត្រូវរៀនសូត្រពីគូប្រកួតប្រជែងនៅក្នុង តំបន់ចាប់ពីសឹង្ហបុរីម៉ាឡេស៊ីរហូតដល់ថៃឡង់ដ៏។ រដ្ឋាភិបាលត្រូវបំពេញតួនាទីកាន់តែប្រតិសកម្មថែមទៀត ក្នុងការសម្របសម្រួលសកម្មភាពរួមជាមួយវិនិយោគិនបរទេសដើម្បីជំរុញកំណើនរបស់បណ្តាញនិងសេវាពង្រឹងភាពប្រកួតប្រជែង។

(ឃ) វិធានការ/សកម្មភាពជាក់ស្តែងដើម្បីពង្រឹងវិស័យជាគោលដៅសំខាន់ៗ (សូមមើលជំពូកនីមួយៗផ្តោតទៅលើវិស័យទាំង១០) ឬដើម្បីរក្សាវិនិយោគមានស្រាប់ដែលងាយនឹងផ្លាស់ប្តូរទីតាំង (ដូចជាវិនិយោគដែលត្រូវការចំណាយពលកម្មទាប ជាដើម)

(ង) វិធានការមានលក្ខណៈអនុវត្តជាក់ស្តែង ដែលបញ្ចូលកិច្ចសហប្រតិបត្តិការនិងសមាហរណកម្មតំបន់ដើម្បីបង្ហាញថាកម្ពុជាជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយសម្រាប់ប្រទេសជិតខាងនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។

(ច) យុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សតាមតម្រូវការ ដើម្បីកសាងជំនាញដែលចាំបាច់ដោយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធរវាងវិស័យឧស្សាហកម្មនិងវិស័យអប់រំទុកជាផ្នែកជាគន្លឹះនៃយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្ស។ យុទ្ធសាស្ត្រនេះត្រូវការតួអង្គសំខាន់ៗចូលរួមដូចជាក្រុមហ៊ុនទីភ្នាក់ងាររដ្ឋាភិបាលនិងស្ថាប័នអប់រំជាដើម (សូមមើលកង្វះខាតជំនាញនៅក្នុងជំពូកទី១៧នៃរបាយការណ៍ទាំងស្រុង)។ធាតុដ៏សំខាន់មួយនៃយុទ្ធ-សាស្ត្ររួមនេះត្រូវធានាថាធនធានមនុស្សនៅក្នុងក្រុមប្រឹក្សាវិនិយោគកម្ពុជានិងស្ថាប័នពាក់ព័ន្ធដទៃទៀតត្រូវបានរៀបចំឡើងយ៉ាងល្អនិងមានធនធានគ្រប់គ្រាន់។

(ឆ) ស្វែងយល់ដោយប្រុងប្រយ័ត្នអំពីជំហានផ្សេងៗនៃ "វដ្តជំរុញវិនិយោគ" ចាប់តាំងពីដំណាក់កាលស្រាវជ្រាវដំបូងរហូតដល់ពេលធ្វើប្រតិបត្តិជាប្រចាំ ពិសេសធានាឱ្យមានការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់ចំពោះវិនិយោគិនក្រោយពេលចាប់ផ្តើមគម្រោងរហូតដល់បំពេញមុខងារ "ក្រោយពេលថែទាំ(វិនិយោគ)"។ ការងារដ៏សំខាន់មួយគឺត្រូវមានប្រព័ន្ធតាមដានក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាពមួយ។




## ២. ពង្រឹងសមត្ថភាពជំរុញនិងការសម្របសម្រួលវិនិយោគរបស់រដ្ឋាភិបាលថ្នាក់ខេត្ត

បច្ចុប្បន្ននេះវិនិយោគភាគច្រើនបំផុតនៅកម្ពុជា គឺសំដៅទៅរកតំបន់ក្រុងនៅមជ្ឈមណ្ឌលសេដ្ឋកិច្ចសំខាន់ៗ (ភ្នំពេញ សៀមរាបនិងក្រុងព្រះសីហនុ) ខណៈពេលដែលសក្តានុពលវិនិយោគនៅតំបន់ជនបទនិងខេត្តផ្សេងទៀតនៅមានជាដុំកំភួនប៉ុន្តែមិនទាន់បានទាញយកប្រយោជន៍នៅឡើយ។ នេះមួយផ្នែកដោយសារសមត្ថភាពជំរុញនិងសម្របសម្រួលវិនិយោគនៅទន់ខ្សោយឬមិនទាន់មាននៅឡើយនៅតាមខេត្តនិងតំបន់ជនបទ។ ការបង្កើនការយល់ដឹងឱ្យកាន់តែប្រសើរឡើងអំពីធុរកិច្ចឯកជននិងសមត្ថភាពស្វែងរកនិងផ្តល់សេវាដល់វិនិយោគិនខាងក្រៅនៅក្នុងខេត្តនឹងរួមចំណែកកែលម្អបរិយាកាសធុរកិច្ចនិងជំរុញវិនិយោគដែលគាំទ្រដល់ជនក្រីក្រ។

នៅតំបន់ជំរុញវិនិយោគស្របតាមកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់រដ្ឋាភិបាល (D&D) និងដើម្បីជំរុញសេវាប្រកបដោយប្រសិទ្ធិផលដល់វិនិយោគផ្នែកឯកជន រដ្ឋាភិបាលបានចេញអនុក្រឹត្យកាលពីខែកុម្ភៈ ឆ្នាំ២០០៥ ស្របនឹងច្បាប់វិនិយោគកម្ពុជា ដោយបានបង្កើតអនុគណៈកម្មការវិនិយោគខេត្ត (PISC) ក្នុងគោលបំណងជាចម្បង ដើម្បីចុះបញ្ជីសំណើវិនិយោគនិងផ្តល់ការលើកទឹកចិត្តសម្រាប់វិនិយោគដែលមានទុនតិចជាង$២លានដុល្លារ។ ទោះជាយ៉ាងណាក៏ដោយគេបានមើលឃើញថាសកម្មភាពជំរុញនិងសម្របសម្រួលវិនិយោគទាំងអស់នៅតែផ្តុំនៅថ្នាក់ជាតិក្នុងគណៈកម្មាធិការវិនិយោគកម្ពុជា (CIB)។ PISC ត្រូវការគោលការណ៍ណែនាំកាន់តែរឹងមាំនិង

ច្បាស់លាស់ជាងមុនព្រមទាំងការគាំទ្រពី CIB និងត្រូវការកសាងសមត្ថភាពរបស់ខ្លួនដើម្បីផ្តល់សេវាដល់វិនិយោគិនឯកជននិងថ្នាក់ខេត្ត។

ការកសាងសមត្ថភាពរបស់ CIB ដើម្បីគាំទ្រដល់ PISC និងការផ្តល់លទ្ធភាព PISC ឱ្យបំពេញមុខងារជាទីភ្នាក់ងារជំរុញការវិនិយោគ (IPA) នៅថ្នាក់ខេត្តកាន់តែមានប្រសិទ្ធភាពនឹងផ្តល់លទ្ធភាពឱ្យអាជ្ញាធរខេត្តផ្តល់សេវាកាន់តែប្រសើរឡើងដល់វិនិយោគិនឯកជន។ កិច្ចខិតខំប្រឹងប្រែងដំបូងៗគួរផ្តោតលើវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ធ្វើដូច្នេះនឹងទាក់ទាញវិនិយោគកាន់តែច្រើននិងបង្កើនវត្តមានរបស់វិនិយោគដែលមានស្រាប់នៅក្នុងខេត្ត។ ក្នុងរយៈពេលយូរអង្វែគួរផ្តោតលើការពង្រឹងបរិយាកាសធុរកិច្ចនៅតាមខេត្តនិងទាក់ទាញវិនិយោគដែលបង្កើតការងារដែលជំរុញទំនាក់ទំនងត្រឡប់ទៅរកវិស័យ MSME និងដែលរួមចំណែកដល់ការកំណត់គោលដៅការអភិវឌ្ឍរបស់ខេត្ត។

## ៣. ជំរុញទំនាក់ទំនង FDI និងការសាយភាពៈកម្មវិធីជាតិអភិវឌ្ឍក្រុមហ៊ុនផ្គត់ផ្គង់

កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនផលប្រយោជន៍សាយភាពពី FDI គួរជាផ្នែកដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលដើម្បីបង្កើនភាពប្រកួតប្រជែងនិងកែសម្រួលរចនាសម្ព័ន្ធឧស្សាហកម្ម។ ការធ្វើឱ្យឧស្សាហកម្មមានលក្ខណៈស៊ីជម្រៅដោយបង្កើនកម្រិតតម្លៃបន្ថែមក្នុងការផលិតទំនិញនិងសេវាកម្ម គឺជាគន្លឹះធ្វើឱ្យកម្ពុជាមានភាពប្រកួតប្រជែងនិងភាពស្វាហាប់ផ្នែកសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ មានករណីដ៏រឹងមាំ ដើម្បីឱ្យរដ្ឋាភិបាលធ្វើអន្តរគមន៍ដោយសារតែមានលក្ខណៈខាងក្រៅ និងបញ្ហាព័ត៌មានយ៉ាងទូលំទូលាយ ពាក់ព័ន្ធនឹងការកសាងទំនាក់ទំនងមូលដ្ឋាន។ កម្មវិធីដូចពោលមកនេះ ពុំទាន់មាននៅឡើយទេនៅកម្ពុជាហើយកំពុងតែក្លាយជាការងារបន្ទាន់ដែលត្រូវធ្វើដោយសារមានលំហូរចូលនៃវិនិយោគបរទេសនិងការប្រកួតប្រជែងកាន់តែច្រើនឡើងនៅក្នុងទីផ្សារពិភពលោក។

ជាការសំខាន់កម្ពុជាត្រូវដកយកបទពិសោធន៍ពីប្រទេសផ្សេងនៅក្នុងតំបន់នេះ កែសម្រួលឱ្យត្រូវនឹងតម្រូវការមូលដ្ឋាននិងបង្កើតកម្មវិធីអភិវឌ្ឍក្រុមហ៊ុនផ្គត់ផ្គង់ ដោយមានការប្តេជ្ញាចិត្តគាំទ្រពីរដ្ឋាភិបាលនិងការបែងចែកធនធានឱ្យបានគ្រប់គ្រាន់។ ដើម្បីទទួលបានជោគជ័យ កម្មវិធីនេះត្រូវប្រមែប្រមូលទីភ្នាក់ងារនិងតួអង្គទាំងអស់ដែលធ្វើការទាក់ទងនឹងការអភិវឌ្ឍ SME និងវិស័យដែលពាក់ព័ន្ធឱ្យធ្វើការរួមគ្នា។ ត្រូវប្រើប្រាស់ធនធានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាពនិងត្រូវបែងចែកធនធានបន្ថែមជាលក្ខណៈខ្ជាប់ខ្ជួន ដើម្បីជៀសវាងការធ្វើប្រើប្រាស់ធនធានជាន់គ្នានិងខ្ជះខ្ជាយឥតប្រយោជន៍។ ការចូលរួមរបស់ផ្នែកឯកជន គឺជាផ្នែកដ៏សំខាន់របស់កម្មវិធីទាំងមូល។ ស្ថាប័ន និងអង្គការ/សមាគមន៍ផ្នែកឯកជន ត្រូវតែបញ្ចូលទៅក្នុងគ្រប់ផ្នែកទាំងអស់នៃកម្មវិធីនេះចាប់តាំងពីពេលកំណត់គោលដៅនិងមុខសញ្ញារហូតដល់ពេលអនុវត្តនិងត្រួតពិនិត្យសកម្មភាពជាក់លាក់។

ឧស្សាហកម្មនាំចេញដែលមានស្រាប់ហើយ គឺជាចំណុចចាប់ផ្តើមជាធម្មតាសម្រាប់ការធ្វើឱ្យឧស្សាហកម្មមានលក្ខណៈស៊ីជម្រៅ។ ឧស្សាហកម្មសម្លៀកបំពាក់ ទោចក្រយាននិងស្បែកជើងរបស់កម្ពុជា សុទ្ធតែឈានដល់កម្រិតផលិតកម្មដែលបង្កើតបានជាទីផ្សារគួរឱ្យទាក់ទាញចំពោះធុរកិច្ច ដោយមានលទ្ធភាពអាចផ្គត់ផ្គង់ជាតុចូលដល់ឧស្សាហកម្មទាំងនេះបាន។ ក្រៅពីការពង្រឹងសមត្ថភាព SME របស់កម្ពុជា ឱ្យបំពេញតួនាទីឱ្យកាន់ច្រើន

ថែមទៀត គេត្រូវខិតខំប្រឹងប្រែងជំរុញ FDI នៅក្នុងផ្នែកផលិតសរសៃសូត្រនិងក្រណាត់ផ្នែកផលិតគ្រឿងបន្លាស់ ទោចក្រយាននិងជាតុចូលសម្រាប់ផលិតស្បែកជើង។ FDI ក្នុងផ្នែកទាំងនេះ ជារឿយៗ គឺសម្រាប់នាំចេញនិង សម្រាប់ផ្គត់ផ្គង់ក្រុមហ៊ុនផលិតសម្លៀកបំពាក់ ទោចក្រយាននិងស្បែកជើងក្នុងស្រុក។ ប៉ុន្តែ វត្តមាននៃផ្នែកទាំងនេះ នឹងបង្កើតបានជាវិស័យនាំចេញកាន់តែមានលក្ខណៈសមាហរណកម្មយ៉ាងរឹងមាំ បង្កើនសមត្ថភាពក្រុមហ៊ុនផលិត សម្លៀកបំពាក់ ទោចក្រយាន និងគ្រឿងបំពាក់ជើងឱ្យអនុវត្តតាមវិធានប្រភពដើមនិងរួមចំណែកដល់ការបង្កើតការ ងារថ្មីៗ។ បញ្ហានេះ មានពិភាក្សាថែមទៀតនៅក្នុងផ្នែកផលិតផលនីមួយៗខាងក្រោម។

### ៤. ការផ្តល់ការគាំទ្រផ្នែកហរិញ្ញវត្ថុ ដល់ការវិនិយោគសម្រាប់នាំចេញ

នៅក្នុងវិស័យមួយចំនួន ការវិនិយោគសម្រាប់នាំចេញត្រូវការគាំទ្រពីស្ថាប័នហិរញ្ញវត្ថុប្រកបដោយការលះបង់ដែល គាំទ្រដល់ប្រតិបត្តិការរបស់វិនិយោគិន។ ឧទាហរណ៍ ក្នុងករណីម៉ាស៊ីនកិនស្រូវគេអាចមើលឃើញយ៉ាងច្បាស់ថា វិនិយោគិនត្រូវការការគាំទ្រតាមរយៈការផ្តល់ទុនប្រតិបត្តិការឱ្យបានគ្រប់គ្រាន់។ ជាលទ្ធផល រាជរដ្ឋាភិបាលបាន ផ្លាស់ប្តូរមូលធនធនាគារអភិវឌ្ឍន៍ជនបទបន្ថែមទុនមួយទ្វេជាពីររបស់ធនាគារកសិកម្មនិងមូលនិធិគាំទ្រនិងរៀបចំ ឱ្យមានគម្រោងធានារ៉ាប់រងឥណទាន។ ការគាំទ្រដោយការលះបង់ដូចពោលមកនេះ ត្រូវធ្វើការកែលម្អនិងជាត្រូវការ ចាំបាច់សម្រាប់វិស័យដទៃទៀតដែរ។ ឧទាហរណ៍ ការពង្រឹងខ្សែរយៈផ្គត់ផ្គង់របស់ SME ទៅកាន់ឧស្សាហកម្មនាំ ចេញ ដែលបានពិភាក្សាខាងលើទាមទារឱ្យមានការបោះជំហានទៅមុខទាក់ទងនឹងលទ្ធភាពស្វែងរកទុនពីធនាគារ របស់ SME។ គេត្រូវស្វែងយល់ថែមទៀតអំពីការបង្កើតធនាគារអាហារណ៍-នីហរណ៍របស់កម្ពុជា។

# កម្មសិទ្ធិបញ្ញា

ចាប់តាំងពាក់កណ្ដាលទសវត្សន៍២០០០ មក កម្ពុជាបានបោះជំហានយ៉ាងធំក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធកម្មសិទ្ធិបញ្ញា (Intellectual Property Rights-IPRs) ទំនើបមួយដោយផ្ដោតលើការអនុម័តគោលការណ៍ច្បាប់សម្របតាម WTO មួយ ការអនុវត្តនិងការជំរុញគោលការណ៍ច្បាប់នេះ។

ទំនួលខុសត្រូវចំពោះកិច្ចការពារកម្មសិទ្ធិបញ្ញានៅកម្ពុជា ត្រូវបានបែងចែកទៅតាមក្រសួងជាច្រើន។ ក្រសួងពាណិជ្ជកម្មទទួលខុសត្រូវចំពោះពាណិជ្ជសញ្ញា ម៉ាកសម្គាល់ភូមិសាស្ត្រ និងអាថ៌កំបាំងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើមឡើយជាក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលទទួលខុសត្រូវចំពោះប្រកាសនីយប័ត្រតក្កកម្ម គំនូសឧស្សាហកម្ម គំរូដែលមានអត្ថប្រយោជន៍ (Utility Models) សៀគ្វីចម្រុះ (Integrated Circuits) ព្រមទាំងការគ្រប់គ្រងគ្រាប់ពូជនិងសិទ្ធិបង្កាត់ពូជរុក្ខជាតិ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈទទួលខុសត្រូវចំពោះសិទ្ធិចម្លងនិងសិទ្ធិពាក់ព័ន្ធព្រមទាំងចំណេះដឹងបុរាណធនធានសេនេទិចនិងការសម្ដែងវប្បធម៌ប្រពៃណី ក្រសួងសុខាភិបាលទទួលខុសត្រូវចំពោះការផ្ដល់អាជ្ញាប័ណ្ណបញ្ជាសម្រាប់សេវាសុខភាពសាធារណៈ ក្រសួងព័ត៌មានទទួលខុសត្រូវចំពោះការផ្សព្វផ្សាយ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទទួលខុសត្រូវចំពោះឈ្មោះអ៊ីនធើណិតដូមែន (internet domain names)។

ក្រសួងនីមួយៗបាន និងកំពុងតែផ្ដោតលើការអភិវឌ្ឍសមត្ថភាពនិងការអនុវត្តនៅក្នុងដែនទទួលខុសត្រូវរបស់ខ្លួន។ ការចុះបញ្ជីពាណិជ្ជសញ្ញាដោយក្រសួងពាណិជ្ជកម្ម បានកើនឡើងយ៉ាងឆាប់រហ័សនៅឆ្នាំថ្មីៗនេះ (សរុបបង្គមានចំនួន ៤៣.២៤០ ពាណិជ្ជសញ្ញានៅដំណាច់ឆ្នាំ២០១២)។ នៅឆ្នាំ២០១២ មានការស្នើសុំចុះបញ្ជីពាណិជ្ជសញ្ញាថ្មី ចំនួន៥.១៤០ ហើយពាណិជ្ជសញ្ញាចំនួន ៣.៤៩០ ត្រូវបានចុះបញ្ជី។ ការចុះបញ្ជីតាមឆន្ទានុសិទ្ធិនូវសិទ្ធិចម្លងក៏បានកើនឡើងដែរ (ប្រហែលជា៥០ នៅឆ្នាំ២០១០)។ ទោះបីកម្ពុជា មិនទាន់ជាសមាជិកនៃអនុសញ្ញាក្រុងប៊ីនក៏ដោយ ក៏សិទ្ធិចម្លងដែលចេញនៅក្នុងប្រទេសជាសមាជិក WTO ត្រូវបានការពារនៅកម្ពុជារហូតដល់ទៅរយៈពេល៥០តាមការកំណត់របស់ប្រទេស។ កិច្ចការពារនេះ ស្ថិតក្រោមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង TRIPS ដែលកម្ពុជាជាហត្ថលេខីមួយដែរ។ គិតមកដល់ឆ្នាំ២០១២ MIME បានទទួលពាក្យស្នើសុំចុះបញ្ជីគំរូឧស្សាហកម្មចំនួន ២៣២ ពីក្រុមហ៊ុនក្នុងស្រុក។ ក្នុងចំណោមពាក្យស្នើសុំទាំង២៣២ នោះបានទទួលការចុះបញ្ជីចំនួន១៩២ ក្នុងនោះចំនួន២៥ សម្រាប់ក្រុមហ៊ុនក្នុងស្រុក។ ការស្នើសុំចុះបញ្ជីប្រកាសនីយប័ត្រតក្កកម្មបានកើនឡើងដល់ទី១៩៦ នៅដំណាច់ឆ្នាំ២០១២។ មកដល់ពេលនេះ ប្រកាសនីយប័ត្រតក្កកម្មមិនទាន់បានប្រគល់ឱ្យឡើយ។ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម កំពុងតែធ្វើការរៀបចំដំណើរការចុះបញ្ជីផ្លូវការដោយមានជំនួយខ្លះៗពី WIPO។

យន្តការដោះស្រាយវិវាទប្រែប្រួលទៅតាមលក្ខណៈនៃសិទ្ធិ ប៉ុន្តែមានជាស្រេចហើយឬកំពុងតែរៀបចំឱ្យមាននៅតាមផ្នែកនៃ IP សំខាន់ៗភាគច្រើនបំផុត។ ជាតួយ៉ាង ម្ចាស់កម្មសិទ្ធិអាចប្រើប្រាស់មធ្យោបាយមួយចំនួន ដើម្បីការពារសិទ្ធិរបស់ខ្លួន ដូចជាលិខិត "បញ្ឈប់ឬលែងបន្ត" ឬការសម្រុះសម្រួលតាមរយៈក្រសួងពាក់ព័ន្ធ

(ឧទាហរណ៍៖ ក្រសួងពាណិជ្ជកម្មបានសមសម្រួលនិងដោះស្រាយវិវាទពាណិជ្ជសញ្ញាចំនួន ៣២ ក្នុងចំណោម ៣៥ នៅឆ្នាំ២០១០) ដោយស្នើសុំជំនួយពីនគរបាលសេដ្ឋកិច្ច (នគរបាលសេដ្ឋកិច្ចមានសមត្ថកិច្ចបញ្ឈប់ការក្លែងបន្លំដាក់ស្តែង CD/DVD ចំនួន ២៥០.០០០បន្ទះ ត្រូវបានរឹបអូសនៅឆ្នាំ ២០១០ កើនឡើងពីចំនួន ២៧.០០០ បន្ទះនៅឆ្នាំ២០០៩) ឬឡើងទៅតុលាការដើម្បីស្វែងរកអធិបញ្ញា។

ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍កន្លមកទាក់ទងនឹងការដោះស្រាយវិវាទ ក៏បង្ហាញឱ្យឃើញនូវភាពចាំបាច់ដើម្បីបង្កើនកិច្ចសម្របសម្រួលក្នុងចំណោមតួអង្គជាច្រើន ដែលទទួលខុសត្រូវចំពោះការអនុវត្តនិងលើកកម្ពស់កម្មសិទ្ធិបញ្ញា មែនមានត្រឹមតែក្រសួងដែលបានពោលខាងដើមនេះទេ ប៉ុន្តែនគរបាលសេដ្ឋកិច្ចនៃក្រសួងមហាផ្ទៃ អគ្គនាយដ្ឋានគយនិងរដ្ឋាករ (GDCE,) អគ្គនាយកដ្ឋានអធិការកិច្ចនីហារណ៍-អាហារណ៍និងអគ្គនាយកដ្ឋានបង្ក្រាបអំពើក្លែងបន្លំ (Fraud Repression Directorate General-Camcontrol) នៃក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌និងក្រសួងដទៃទៀត ក៏ត្រូវចូលរួមដែរ។

នៅឆ្នាំ២០០៨ រដ្ឋាភិបាលបានអនុម័តអនុក្រឹត្យមួយ បង្កើតគណៈកម្មជាតិកម្មសិទ្ធិបញ្ញា (NCIPR) ដើម្បីសម្របសម្រួលទីភ្នាក់ងារទាំងអស់ ដែលពាក់ព័ន្ធនឹងការការពារកកម្មសិទ្ធិបញ្ញា។ NCIPR ថ្មីនេះ ជំនួសឱ្យគណៈកម្មការកន្លងទៅ (គណៈកម្មការ អន្តរក្រសួងគ្រប់គ្រងកម្មសិទ្ធិបញ្ញាបីវិស័យ)។ ក្រៅពីផ្តោតលើតម្រូវការជំនួយបច្ចេកទេសនិងការសម្របសម្រួលការស្វែងរកជំនួយ AfT គណៈកម្មការនេះកំពុងតែបង្កើតអនុគណៈកម្មការចំនួនពីរ៖ មួយផ្តោតលើការអនុវត្តកម្មសិទ្ធិបញ្ញានិងមួយទៀតផ្តោតលើការអប់រំ (សេចក្តីណែនាំអំពីការបង្កើតអនុគណៈកម្មការទាំងពីរនេះ មិនចេញនៅឡើយទេ)។ អនុគណៈកម្មការជំរុញច្បាប់ការពារកម្មសិទ្ធិបញ្ញា មានគោលបំណងពង្រឹងកិច្ចសម្របសម្រួលក្នុងចំណោមស្ថាប័នអនុម័តច្បាប់ បញ្ជាក់ពីទំនួលខុសត្រូវឱ្យបានច្បាស់លាស់ រៀបចំគោល-ការណ៍ណែនាំមានលក្ខណៈស៊ីសង្វាក់និងរៀបចំមូលដ្ឋានទិន្នន័យអនុវត្តច្បាប់។ អនុគណៈកម្មការអប់រំមានគោលបំណងរៀបចំកម្មវិធីសិក្សា ដើម្បីបណ្តុះបណ្តាលអ្នកមានវិជ្ជាជីវៈផ្នែកច្បាប់ នៅតាមសាកលវិទ្យាល័យនិងអ្នកមានវិជ្ជាជីវៈសកម្មនិងការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន។

ក្នុងដំណើរឆ្ពោះទៅមុខ NCIPR បានរៀបចំផែនការសកម្មភាពលម្អិត ផ្តោតលើបីចំណុចសំខាន់ៗ ដែលការកសាងសមត្ថភាពនិងកំណែទម្រង់ជាបន្ថែម គឺជាការចាំបាច់៖

1. កំណែទម្រង់ច្បាប់ រួមទាំងអត្ថបទច្បាប់សំខាន់ៗ ដែលគ្របដណ្តប់គោលការណ៍ច្បាប់ក្នុងស្រុក ព្រមទាំងសមាជិកភាពមួយចំនួនធ្វើឡើង ដើម្បីចូលរួមកាតិកាសញ្ញានិងអនុសញ្ញាអន្តរជាតិនានា។ កម្ពុជា ជាសមាជិក WIPO, WTO (រួមជាមួយនឹងកិច្ចព្រមព្រៀងTRIPS របស់ខ្លួនផងដែរ) និងអនុសញ្ញាក្រុងប៉ារីសស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម។ កម្ពុជា ចូលរួមក្នុងក្របខ័ណ្ឌអាស៊ានស្តីពីកិច្ចសហប្រតិបត្តិការការពារកម្មសិទ្ធិបញ្ញា។ កម្ពុជា មិនទាន់បានចូលរួមការៀបចំជាអន្តរជាតិ អនុសញ្ញានិងកិច្ចព្រមព្រៀងមួយចំនួន ដូចជាសន្ធិសញ្ញាសហប្រតិបត្តិការការពារប្រកាសនីយប័ត្រតក្កកម្ម (Patent Cooperation Treaty-

PCT) អនុសញ្ញាក្រុងប៊ែនទាក់ទងនឹងសិទ្ធិថតចម្លងនិងសិទ្ធិប្រហាក់ប្រហែល (Berne Convention relating to Copyrights & Related Rights) អនុសញ្ញាក្រុងហ្សឺណែវស្តីពីការការពារផលិតករមូលសទ្ទលេខទល់នឹងការថតចម្លងមូលសទ្ទលេខដោយគ្មានការអនុញ្ញាត (the Geneva Convention for the Protection of Producers of Phonograms Against Unauthorized Duplications of their Phonograms) សហភាពអន្តរជាតិដើម្បីការពារពូជរុក្ខជាតិថ្មី (UPOV Convention)និងពិធីសាក្រុងម៉ាឌ្រីដស្តីពីសន្ធិសញ្ញាដែលបានអនុវត្តន៍ (Madrid Protocol on Administered Treaties) នៅឡើយទេ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារការចូលជាសមាជិកនៃច្បាប់ទាំងនេះ មិនមែនជាកាតព្វកិច្ចក្នុង WTO កម្ពុជា ជាបឋម ត្រូវវាយតម្លៃដោយប្រុងប្រយ័ត្នអំពីអត្ថប្រយោជន៍និងការចំណាយសម្រាប់ការចូលរួម សន្ធិសញ្ញានិងអនុសញ្ញាទាំងនេះ ស្របតាមទស្សនៈរបស់សាធារណជនកម្ពុជាឬផ្នែកឯកជន។

2. ការគាំទ្រផ្នែកស្ថាប័នដើម្បីអនុវត្តនិងជំរុញច្បាប់និងបទបញ្ញត្តិទាក់ទងនឹង IPRs ព្រមទាំងកិច្ចសម្របសម្រួលយ៉ាងរឹងមាំក្នុងចំណោមទីភ្នាក់ងារទទួលខុសត្រូវចំពោះ IPRs ការបញ្ជាក់អំពីអាណត្តិឱ្យបានច្បាស់លាស់និងការបណ្តុះបណ្តាលអ្នកអនុវត្តច្បាប់ ដូចជាចៅក្រមនិងមេធាវីបំពេញការងារជាដើម។
3. ការលើកកម្ពស់ការយល់ដឹងអំពី IPRs ក្នុងសហគមន៍ធុរកិច្ចនិងសាធារណជនកម្ពុជាទូទៅ។ ការយល់ដឹងអំពី IPRs នៅទន់ខ្សោយនៅឡើយ ក្នុងចំណោមអតិថិជនកម្ពុជា។ ផលិតករកម្ពុជា ត្រូវការរៀនសូត្រអំពីរបៀបប្រើប្រាស់កិច្ចការពារ IPRs ជាប្រយោជន៍របស់ខ្លួន ដើម្បីប្រកួតប្រជែងឱ្យកាន់តែប្រសើរឡើង នៅក្នុងសេដ្ឋកិច្ចពិភពលោក។

# សសរស្តម្ភទី២

បញ្ហាប្រឈមនិងឱកាសផ្នែកប្រកួតប្រជែង មានវិភាគនៅក្នុងខ្សែសង្វាក់តម្លៃនាំចេញជាគន្លឹះទាំង១០ ក្រោមសសរស្តម្ភទីពីរនៃ *CTIS 2014-2018* :

- សម្លៀកបំពាក់
- ស្បែកជើង
- វិស័យកម្មន្តសាលដំឡើងធុនស្រាលនៅតាមតំបន់សេដ្ឋកិច្ចពិសេស
- អាហារកែច្នៃ
- ផលិតផលនេសាទ
- អង្ករ
- ដំឡូងមី
- កៅស៊ូ
- ទេសចរណ៍
- ផលិតផលសូត្រ

រកគំហើញសំខាន់ៗសម្រាប់វិស័យទាំង១០ ដែលបានសិក្សានេះ ត្រូវបានបូកសរុបជាទម្រង់តារាង SWOT (Strengths/ចំណុចខ្លាំង Weaknesses/ចំណុចខ្សោយ Opportunities/ ឱកាសនិង Threats/ គំរាមកំហែង) ១១ចំណុច។ មានតារាងពីរ សម្រាប់វិស័យផលិតនៅតាមតំបន់សេដ្ឋកិច្ចពិសេស។ តារាងមួយផ្តោតលើវិស័យកម្មន្តសាល កើតមានឡើងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ តារាងមួយទៀត ផ្តោតលើបញ្ហាពាក់ព័ន្ធនឹងភាពប្រកួតប្រជែងរបស់តំបន់សេដ្ឋកិច្ចពិសេស ដែលជាបរិយាកាសសម្រាប់ធុរកិច្ចនិងការវិនិយោគផ្តោតលើការនាំចេញផ្ទាល់តែម្តង។

## វិស័យសំលៀកបំពាក់

### ព័ត៌មានមូលដ្ឋាន

- ការនាំចូលសម្លៀកបំពាក់ទូទាំងពិភពលោក មានចំនួនទឹកប្រាក់ $៤១២ពាន់លានដុល្លារអាមេរិកដោយ EU និង US មានចំនួនពីរភាគបីនៃការនាំចូលសរុប។
- ការនាំចេញសម្លៀកបំពាក់កម្ពុជា មានចំនួន $៤,៤ ពាន់លានដុល្លារអាមេរិក ប្រមាណជា៤៥ភាគរយ ត្រូវបម្រុងទុកសម្រាប់ US។
- EU ចិន កូរ៉េខាងត្បូងនិងជប៉ុន គឺជាទីផ្សារថ្មីកំពុងធំឡើងយ៉ាងឆាប់រហ័សសម្រាប់ការនាំចេញសម្លៀកបំពាក់របស់កម្ពុជា។ ការនាំចេញទៅកាន់សហរដ្ឋអាមេរិកនៅនឹងមួយកន្លែង ចំណែកឯទឹកប្រាក់សរុបនៃការនាំចេញទៅកាន់សហរដ្ឋអាមេរិកកំពុងថយចុះ។
- ការប្រកួតប្រជែងក្នុងពិភពលោកសម្រាប់ពាណិជ្ជកម្មសម្លៀកបំពាក់កំពុងតែកើនឡើងយ៉ាងខ្លាំង ដោយផ្នែកផលិត ទទួលបានប្រាក់ចំណូលកាន់តែតិចធៀបនឹងស្ថានភាពចំណាប់អារម្មណ៍កាន់តែកើនឡើងរបស់អតិថិជនចំពោះក្រមសីលធម៌ឧស្សាហកម្ម។
- វិស័យសម្លៀកបំពាក់កម្ពុជា កត់សម្គាល់ដោយផលិតភាពកម្មករទាបធៀបនឹងប្រទេសប្រកួតប្រជែង។
- ការប្រើប្រាស់កម្មករនៅតាមរោងចក្រនាំចេញទាំងអស់ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ BFC ធៀបនឹងស្តង់ដារអន្តរជាតិ។

### ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • កំណើនក្នុងវិស័យសម្លៀកបំពាក់ គឺជាដំណើររឿងជោគជ័យដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងកិច្ចខិតខំប្រឹងប្រែងធ្វើសមាហរណកម្មពាណិជ្ជកម្មនាពេលថ្មីៗនេះ របស់កម្ពុជា។<br>• កម្លាំងពលកម្មភាគច្រើនបំផុតជាស្ត្រី ដែលមួយផ្នែកធំនៃប្រាក់ឈ្នួល បានផ្ញើទៅចិញ្ចឹមគ្រួសារនៅតាមជនបទ។<br>• តាមរយៈបទពិសោធន៍ជាង២០ឆ្នាំ វិស័យផលិតសម្លៀកបំពាក់កម្ពុជា បានកសាងកេរ្តិ៍ឈ្មោះ ថាមានក្រមសីលធម៌ជាលទ្ធផលនៃ *កម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា*<br>• កំណើនក្នុងផ្នែកនាំចេញសម្លៀកបំពាក់ ត្រូវជំរុញដោយកំណើនដ៏រឹងមាំក្នុងទំហំផលិតសម្លៀកបំពាក់ជាមូលដ្ឋាន<br>• ការផ្តោតលើផលិតកម្មសម្លៀកបំពាក់ជាមូលដ្ឋាន | • កម្ពុជាបំរើទីផ្សារមួយចំនួនតូច (ភាគច្រើននៅ US និង EU) ជាមួយនឹងសម្លៀកបំពាក់មានតម្លៃទាបជាមូលដ្ឋាន<br>• វិស័យសម្លៀកបំពាក់ នៅផ្តោតលើផលិតកម្ម "កាត់-ដេរតម្រឹម" មានតម្លៃទាបធម្មតា ដោយទទួលបានប្រាក់ចំណូលតិចតួច។<br>• រោងចក្រសម្លៀកបំពាក់ភាគច្រើនបំផុត (៩៤%) ជារបស់បរទេស ដោយគ្មានវិនិយោគិននាំមុខជាជនជាតិកម្ពុជា នៅក្នុងវិស័យនេះ។<br>• រោងចក្រសម្លៀកបំពាក់ភាគច្រើនបំផុត មានសមត្ថភាពតិចតួច ដើម្បីទាក់ទាញការបញ្ជាទិញដោយឯករាជ្យ ឬដើម្បីធ្វើឱ្យមានលក្ខណៈចម្រុះ។<br>• ការពឹងផ្អែកលើពលកម្មបរទេស សម្រាប់មុខតំណែង |

| | |
|---|---|
| *មួយភាគ* ការពារវិស័យសម្លៀកបំពាក់កម្ពុជា ពីការរួញថយនៃសេដ្ឋកិច្ចពិភពលោក បើធៀបនឹងពាណិជ្ជកម្មសម្លៀកបំពាក់ដែលជិតចប់។<br>• រយៈពេលសម្រាប់ផលិតកម្មសម្លៀកបំពាក់ មានលក្ខណៈប្រហាក់ប្រហែលនឹងប្រទេសប្រកួតប្រជែងនៅក្នុងតំបន់។<br>• បរិយាកាស FDI មានលក្ខណៈទាក់ទងនៅកម្ពុជា<br>• ទីដៅនាំចេញសំខាន់ៗ គឺជាទីផ្សារដែលផ្តល់ចំណូលខ្ពស់នៅអាមេរិកខាងជើងនិង EU។<br>• ពន្ធនាំចេញនាំចូលទាប ឬមានការអនុគ្រោះពន្ធនាំចេញនាំចូល លើមុខទំនិញមួយចំនួន ជំរុញការនាំចេញសម្លៀកបំពាក់កម្ពុជា ទៅកានទីផ្សារ US និង EU<br>• វិនិយោគិនបរទេស ផ្តល់ចំណេះធ្វើនិងឯកទេស ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ។<br>• ការគាំទ្រយូរអង្វែងរបស់ឧស្សាហកម្ម និងរដ្ឋាភិបាលចំពោះ *គម្រោងរោងចក្រកាន់តែប្រសើរ នៅកម្ពុជា* ផ្តល់ទំនុកចិត្តផ្នែកធុរកិច្ច ដល់វិនិយោគិននិងក្រុមហ៊ុនបញ្ញាទិញអន្តរជាតិ។ | បច្ចេកទេស និងគ្រប់គ្រងសំខាន់ៗ ធ្វើអនាគតឧស្សាហ-កម្មក្នុងស្រុកចុះខ្សោយ (មិនស្ថិតក្នុងកណ្តាប់អ្នកក្នុងស្រុក)។<br>• មានភស្តុតាងតិចតួចបញ្ជាក់អំពីការធ្វើឱ្យផលិតផលមានលក្ខណៈចម្រុះ-សម្លៀកបំពាក់ដែលនាំចេញសព្វថ្ងៃដូចគ្នានឹងសម្លៀកបំពាក់ដែលនាំចេញកាលពីពាក់កណ្តាលទសវត្សរ៍ ១៩៩០។<br>• ក្រណាត់ សរសៃអំបោះ គ្រឿងផ្សំ និងការកាត់តម្រឹមដែលប្រើនៅក្នុងការផលិតសម្លៀកបំពាក់ ត្រូវនាំចូលពីភាគច្រើនបំផុត នាំឱ្យមានការបាត់បង់តម្លៃ។<br>• ផលិតភាពរបស់កម្មករកាត់ដេរកម្ពុជា នៅក្រោយប្រទេសប្រកួតប្រជែង នៅក្នុងតំបន់។<br>• កម្លាំងពលកម្មមានផ្លាស់ប្តូរកន្លែងធ្វើការខ្ពស់ កាត់បន្ថយទឹកចិត្តក្រុមហ៊ុនក្នុងការនិវិយោគលើកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>• តម្លៃអគ្គិសនីខ្ពស់ ប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញផលិតកម្មសម្លៀកបំពាក់ឱ្យកាន់តែខ្ពស់ឡើង(តម្លៃបន្ថែម)។<br>• រោងចក្រភាគច្រើនបំផុតមានការវិនិយោគតិចតួចបំផុតលើអចលនទ្រព្យ និងអាចផ្លាស់ប្តូរទីតាំង ប្រសិនបើចំណាយប្រតិបត្តិការលែងមានលក្ខណៈប្រកួតប្រជែង។ |

| ឱកាស | ការគំរាមកំហែង |
|---|---|
| • អត្ថប្រយោជន៍ផ្នែកសុខមាលភាពជាដុំកំភួនបានមកពីប្រាក់ឈ្នួលតាមវិស័យនិងកំណើនការងារ ជួយសម្រេចគោលដៅកាត់បន្ថយភាពក្រីក្រ។<br>• វិសាលភាពបង្កើនចំណូលនិងប្រាក់ឈ្នួលតាមរយៈការផលិតសម្លៀកបំពាក់មានតម្លៃខ្ពស់ជាងមុន។<br>• សក្តានុពលផ្សារភ្ជាប់យីហោ "ផលិតនៅកម្ពុជា" ជាមួយច្បាប់ការងារនិងរបៀបគ្រប់គ្រងពលកម្ម ដ៏ល្អ។<br>• ភាពល្អប្រសើរតាមច្រករបៀបឆ្លងកាត់ តភ្ជាប់កំពង់ផែភ្នំពេញនិងវៀតណាម នឹងកាត់បន្ថយពេលវេលានាំចូលក្រណាត់និងនាំ ចេញសម្លៀកបំពាក់អាចទាក់ទាញការបញ្ជាទិញសម្លៀកបំពាក់មានតម្លៃ ខ្ពស់ដែលជំរុញពេលវេលាវិលត្រឡប់កាន់តែឆាប់ជាងមុន។<br>• ការសន្សំសំចៃពេលវេលាឆ្លងកាត់បន្ថែមអាចធ្វើឡើងតាមរយៈកាត់បន្ថយពេលវេលាទូទាត់ ក្រណាត់នាំចូលនិងសម្លៀកបំពាក់នាំចេញ។<br>• មជ្ឈមណ្ឌលបណ្តុះបណ្តាលនាំមុខដោយឧស្សាហកម្ម នឹងដោះស្រាយកង្វះខាតជំនាញដ៏ធ្ងន់ធ្ងរក្នុងសង្វាក់ផ្គត់ផ្គង់។<br>• វិសាលភាពបញ្ចូលផលិតកម្មសម្លៀកបំពាក់កម្ពុជា ទៅក្នុងសង្វាក់ផ្គត់ផ្គង់តំបន់សម្រាប់ផលិតផលមានតម្លៃខ្ពស់។ | • ប្រទេសមីយ៉ាន់ម៉ាអាចងើបមុខជាមជ្ឈមណ្ឌលផលិតសម្លៀកបំពាក់ ដែលចំណាយទាប នៅក្នុងរយៈពេល៥ឆ្នាំខាងមុខ។<br>• កំណើនចំណាយផលិត (ប្រាក់ឈ្នួលនិងថាមពល)។<br>• ការដកខ្លួនរបស់វិនិយោគធំៗ អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ មិនល្អលើចំណូលជាតិ និងជីវភាពជនបទ។<br>• ល្បឿនៃកំណើនវិស័យសម្លៀកបំពាក់របស់កម្ពុជា ដូចនឹងល្បឿនដែលវិស័យនេះចុះថយ ដូចដែលធ្លាប់កើតមាននៅឆ្នាំ ២០០៨ - ២០០៩។<br>• ចំណាយខ្ពស់ និងវិបត្តិហិរញ្ញវត្ថុ ទម្លាក់ទឹកចិត្តរោងចក្រជាកម្មសិទ្ធិរបស់វិនិយោគិនក្នុងស្រុកមិនឱ្យពង្រីកផលិតកម្ម ឬបង្កើនសកម្មភាពរបស់ខ្លួន។<br>• ការប្រកួតប្រជែងដ៏ខ្លាំងពីក្រុមហ៊ុននាំចេញសម្លៀកបំពាក់ជាមូលដ្ឋានធំៗ ដូចជាវៀតណាម បង់ក្លាដេស ចិន និងឥណ្ឌា ជាដើម ដែលផ្តល់សេដ្ឋកិច្ចមាត្រដ្ឋាន។<br>• ការថយចុះនៃភាពអនុគ្រោះនៅក្នុងទីផ្សារនាំចេញសំខាន់ៗ<br>• អសមត្ថភាពធ្វើឱ្យផលិតផល ឬទីផ្សារនាំចេញមានលក្ខណៈចម្រុះ។<br>• ភាពស្ទាក់ស្ទើររបស់វិនិយោគិនក្នុងស្រុក ការហក់ចូលក្នុងវិស័យនេះ។<br>• អស្ថិរភាពបណ្តាលមកពីវិវាទការងារ។ |

## វិស័យស្បែកជើង

### ព័ត៌មានមូលដ្ឋាន

- ពាណិជ្ជកម្មស្បែកជើងក្នុងពិភពលោកឈានដល់$១១៦ ពាន់លានដុល្លារ នៅឆ្នាំ២០១១ មានកំណើន៣៦ ភាគរយ ចាប់តាំងពីឆ្នាំ២០០៧ មក។
- បរិមាណនាំចេញស្បែកជើងពីកម្ពុជា មានចំនួន $៣១១លានដុល្លារ នៅឆ្នាំ២០១២ ចំណែកឯកកម្ពុជា នាំចូលគ្រឿងផ្សំនៃស្បែកជើងចំនួន$១៤០លានដុល្លារ។ រហូតមកដល់ពេលថ្មីៗនេះ ឧស្សាហកម្មស្បែកជើងនៅកម្ពុជា ជាចម្បងផ្តោតលើការផលិតស្បែកជើងធ្វើពីស្បែក។ ទោះជាយ៉ាងណាក៏ដោយវិស័យនេះកំពុងតែធ្វើឱ្យមានលក្ខណៈចម្រុះយ៉ាងឆាប់រហ័សទៅក្នុងផ្នែកវាយនភ័ណ្ឌនិងការផលិតស្បែកជើងធ្វើពីកៅស៊ូ។ កម្ពុជានាំចូលភាគច្រើនបំផុតនៃជាតុចូលរបស់ខ្លួន។
- ទីផ្សារស្បែកជើងសម្រាប់កម្ពុជានៅឆ្នាំ២០១១ (គ្មានទិន្នន័យសម្រាប់ឆ្នាំ២០១២) រួមមានចក្រភពអង់គ្លេស $៤៨ លានដុល្លារអាល្លឺម៉ង់ $៣៨ លានដុល្លារ ជប៉ុន $២៨ លានដុល្លារសហរដ្ឋអាមេរិក$២៦លានដុល្លារ។ ការនាំចេញស្បែកជើងកម្ពុជាទៅកាន់ទីផ្សារទាំងនេះ បានកើនឡើង១៨៩ភាគរយ ៦៥ភាគរយ ២៥ភាគរយ និង ៣៤០៦ភាគរយ ជាបន្តបន្ទាប់ នៅចន្លោះឆ្នាំ២០០៧ និង២០១១។
- វិស័យស្បែកជើង ត្រូវប៉ាន់ស្មានថា ផ្តល់ការងារផ្ទាល់ ចំនួន៦៩.១៨៤ ការងារ នៅឆ្នាំ២០១២ ដោយ មានប្រាក់ឈ្នួលប្រហាក់ប្រហែលនឹងវិស័យសម្លៀកបំពាក់ដែរ។
- ផលប៉ះពាល់ផ្នែកបរិស្ថាននៃសកម្មភាពមួយចំនួនទាក់ទងនឹងវិស័យនេះ (ដូចជា ការបណ្តុះបណ្តាលជាដើម) បង្កជាបញ្ហាប្រឈមផ្នែកបរិស្ថានជាដុំកំភួននិងមិនទាន់បានគ្រប់គ្រងឱ្យបានត្រឹមត្រូវនៅឡើយទេ។

### ការវិភាគចំណុចខ្លាំង ចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • កម្លាំងពលកម្មមានជំនាញទាប ចំណាយទាបរបស់កម្ពុជាមានលក្ខណៈទាក់ទាញជាខ្លាំងសម្រាប់ ផលិតកម្មគ្រឿងបំពាក់ជើង ដែលត្រូវការពលកម្មច្រើននិងមិនស្មុគ្រស្មាញ។<br>• ទីតាំងភូមិសាស្ត្រនៅជិតសង្វាក់ផលិតកម្មស្បែកជើងផ្សេងទៀត នៅថៃ និងវៀតណាម ជួយសម្រួលដល់សមាហរណកម្មឧស្សាហកម្មស្បែកជើងកម្ពុជា ជាមួយបណ្តាញផលិតកម្មនៅក្នុងតំបន់។<br>• កម្ពុជាមានរោងចក្រលក់មួយចំនួនតូច ដែលមានបរិក្ខារទំនើប ផលិតភាពខ្ពស់។<br>• បរិយាកាសវិនិយោគមានលក្ខណៈអនុគ្រោះសម្រាប់ក្រុ | • កម្លាំងពលកម្មមានជំនាញទាប និងផលិតភាពទាប កំពុងតែកម្រិតការផ្លាស់ប្តូរទីតាំងរបស់រោងចក្រផលិតស្បែកជើងស្មុគ្រស្មាញមកកម្ពុជា។<br>• ឧស្សាហកម្មស្បែកជើងកម្ពុជា ផ្តោតលើ ការផលិតស្បែកជើងធ្វើពីស្បែក។<br>• ឧស្សាហកម្មស្បែកជើងកម្ពុជា ពឹងផ្អែកលើសម្ភារៈនាំចូលស្ទើរតែទាំងស្រុងសម្រាប់ផលិតកម្មរបស់ខ្លួន។<br>• តម្លៃខ្ពស់ និងភាពមិនអាចទុកចិត្តនៃអគ្គិសនី រំខានដល់រោងចក្រផលិតស្បែកជើង។<br>• កម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធខ្សោយ បើធៀបនឹងប្រទេសជិតខាង (ថៃ វៀតណាម ចិន) រារាំងដល់ភាព |

| | |
|---|---|
| មហ៊ុន ស្បែកជើង ដែលទទួលផលប្រយោជន៍ពីគម្រោងវិនិយោគ មានគុណវុឌ្ឍស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។<br>• កម្ពុជាមានការលើកលែងពន្ធចូលទីផ្សារ E.U និងទីផ្សារមួយចំនួនទៀត ដោយមានវិធានប្រភពដើមទំនិញជាលក្ខណៈអនុគ្រោះ។ | ប្រកួតប្រជែងរបស់ខ្លួន។<br>• មានរោងចក្រធំៗតែមួយចំនួនតូច និងមានលទ្ធភាពមានកម្រិតក្នុងការទាញយកធនធានពីក្នុងស្រុករារាំងដល់ការអភិវឌ្ឍឧស្សាហកម្មស្បែកជើងនៅកម្ពុជា។<br>• រោងចក្រនៅកម្ពុជា ការត្រួតពិនិត្យសង្វាក់ផ្គត់ផ្គង់ចូល និងចេញមានកម្រិត គ្មានការត្រួតពិនិត្យរចនាបថ នាំឱ្យមានឱកាសតិចតួចដើម្បីបង្កើនផលិតផលសម្រេចដែលមានតម្លៃខ្ពស់។<br>• ឧស្សាហកម្មស្បែកជើងនៅកម្ពុជា គ្មានស្ថាប័នតំណាងរបស់ខ្លួនផ្ទាល់។ បច្ចុប្បន្ន តំណាងផ្នែកឯកជនរបស់ឧស្សាហកម្មនេះ ត្រូវ បញ្ចូលជាមួយវិស័យសម្លៀកបំពាក់នៅក្នុងGMAC |

| ឱកាស | ការគំរាមកំហែង |
|---|---|
| • ថ្លៃពលកម្មកាន់តែកើននៅប្រទេសចិន ថៃនិងវៀតណាមអនុគ្រោះដល់ការផ្លាស់ប្តូរទីតាំងផលិតកម្មមកកម្ពុជា។<br>• ផលិតកម្មស្បែកជើង មានផ្នែក និងដំណើរការ ជាច្រើន នាំឱ្យមានការបែងចែកពលកម្មនៅទូទាំងប្រទេសអាស៊ានទាំងឡាយ។ កម្ពុជាអាចចាប់យកដំណើរការណាដែលប្រើពលកម្មច្រើន បច្ចេកវិទ្យាទាប។<br>• កម្ពុជាមានសមត្ថភាពអភិវឌ្ឍផ្នែក និងសម្ភារៈនៃស្បែកជើង (ឧទាហរណ៍ ឱ្យពណ៌ជាដើម) នៅក្នុងបរិវេណរោងចក្រកែច្នៃ នាំទៅរកការបង្កើតជាកម្រងផលិតកម្ម ជាពិសេសក្នុងចំណោមក្រុមហ៊ុនម៉ៅការផលិត។<br>• គេអាចរកកៅស៊ូនៅក្នុងស្រុបាន ដើម្បីបំពេញដំណើរការផលិតស្បែកជើង។<br>• ការវិនិយោគមានលក្ខណៈរឹងមាំជាបន្តបន្ទាប់ដោយក្រុមហ៊ុនផលិតស្បែកជើង ជំរុញការផ្ទេរបច្ចេក វិទ្យាដែលអាចគាំទ្រដល់ការធ្វើឱ្យមានលក្ខណៈចម្រុះនៃការនាំចេញស្បែកជើងរបស់កម្ពុជា ឧទាហរណ៍ ដូចជាការបង្កើនការផលិតស្បែកជើងជាមួយផ្នែកខាងលើនៃវាយភ័ណ្ឌ ដែលអាចនាំឱ្យមានតម្លៃ FOB ៥០ ភាគ ខ្ពស់ជាងមុន។ | • ការបន្ធូរបន្ថយរូបមន្តវិធានប្រភពដើមអន្តរជាតិ អាចកាត់បន្ថយចំណែកនៃដំណើរការផលិតកម្មស្បែកជើងដែលជាក់ស្តែងកំពុងតែកើតមាននៅកម្ពុជា។<br>• ការបញ្ចប់វិធានការប្រឆាំងនឹងលក់បង្ខូចថ្លៃអឺរ៉ុបទល់នឹងក្រុមហ៊ុននាំចេញស្បែកជើងរបស់ចិន និងវៀតណាម អាចនាំឱ្យវិនិយោគិនវិលត្រឡប់ទៅកាន់ទីតាំងទាំងនោះវិញ ដែលនោះទីនោះ ពួកគេអាចទទួលផលប្រយោជន៍ពី ផលិតភាពប្រសើរជាង ហេដ្ឋារចនាសម្ព័ន្ធប្រសើរជាង មានការផ្គត់ផ្គង់ធាតុចូលក្នុងស្រុក និងសេដ្ឋកិច្ចមាត្រដ្ឋានធំជាង។<br>• ការថយចុះនៃលទ្ធភាពទទួលបានការអនុគ្រោះពន្ធរបស់កម្ពុជា ដោយសារការកាត់បន្ថយជាទូទៅនៃពន្ធលើស្បែកជើង អាចកាត់បន្ថយភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងតំបន់។<br>• ការនាំចេញផលិតផលស្បែកជើងចុងក្រោយ ពឹងផ្អែកលើទីផ្សារមួយចំនួនតូច (ជិត៦០ភាគរយ នាំចេញទៅកាន់ទីផ្សារធំៗបួនរបស់ខ្លួន)។<br>• កម្រិតចំណូលទាបនិងកាន់តែថយចុះទៀតសម្រាប់ផលិតកម្មស្បែកជើង រារាំងសមត្ថភាពរបស់ វិនិយោគិនក្នុងការផ្តល់កម្មវិធីបណ្តុះបណ្តាលសម្រាប់ កម្មករ។<br>• ហានិភ័យផ្នែកសង្គម និងបរិស្ថាន ទាក់ទងនឹងផ្នែកខ្លះនៃដំណើរការផលិតកម្មស្បែកជើង (ការឱ្យពណ៌) ត្រូវត្រួត |

| | |
|---|---|
| • កម្រិតប្រាក់ចំណូលទាប និងចេះតែថយចុះសម្រាប់ផលិតកម្មស្បែកជើងគុណភាពទាប និងមធ្យម ជំរុញឱ្យវិនិយោគិនអន្តរជាតិស្វែងរកការសន្សំសំចៃចំណាយ ជាពិសេសតាមរយៈការកាត់បន្ថយចំណាយពលកម្ម។ | ពិនិត្យមិនបានជិតដល់នៅកម្ពុជា នាពេលបច្ចុប្បន្ននេះ។<br>• កំណើនប្រាក់ឈ្នួលនៅកម្ពុជា សម្រាប់កម្មករជំនាញ គឺជាការចាំបាច់ ដើម្បីធ្វើឱ្យមានលក្ខណៈចម្រុះ និងបង្កើនជំនាញផលិតកម្ម ដែលកាត់បន្ថយភាពប្រកួតប្រជែងជាចម្បងរបស់កម្ពុជា ជាលទ្ធផលត្រឡប់មកវិញ<br>• ភាពរំជើបរំជួលរបស់កម្មករនៅតាមរោងចក្រផលិតស្បែកជើងធំៗ រំខានដល់ដំណើរការផលិតកម្ម។ |

# ប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេស

## ព័ត៌មានមូលដ្ឋាន

- នៅឆ្នាំ២០១៣ កម្ពុជា មានតំបន់សេដ្ឋកិច្ចពិសេសចំនួន៨ ដែលមានដំណើរការ រួមមាន តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុទី២ តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ តំបន់សេដ្ឋកិច្ចពិសេសម៉ានហាតាន់តំបន់សេដ្ឋកិច្ចពិសេស តាយសេង បាវិត តំបន់សេដ្ឋកិច្ចពិសេសនាងកោះកោះកុងតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែតអូរនាង និង តំបន់សេដ្ឋកិច្ចពិសេស Goldfame Pak Shun – ដោយមានប្រតិបត្តិករមកពីកម្ពុជា ជប៉ុន ចិន ថៃ និងតៃវ៉ាន់។ តំបន់សេដ្ឋកិច្ចពិសេសចំនួន១៤ ថែមទៀតត្រូវបានបង្កើតឡើង ប៉ុន្តែពុំទាន់មានវិនិយោគិននៅតាមតំបន់ទាំងនេះ នៅឡើយទេ។
- តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ គឺជាតំបន់សេដ្ឋកិច្ចពិសេសតែមួយគត់ ដែលគ្រប់គ្រងដោយរដ្ឋាភិបាលកម្ពុជា។ តំបន់សេដ្ឋកិច្ចពិសេសនេះ ទទួលមូលនិធិជាកម្ចីមកពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។
- នៅឆ្នាំ២០១៣ មានក្រុមហ៊ុនចំនួន៩៤ ធ្វើប្រតិបត្តិការនៅតាមតំបន់សេដ្ឋកិច្ចពិសេស រួមមានចំនួន៣៧នៅភ្នំពេញ ១៨ នៅតំបន់សេដ្ឋកិច្ចពិសេស Manhattan (ដែលតំបន់សេដ្ឋកិច្ចពិសេសដំបូង ដែលបានបង្កើតឡើងនៅកម្ពុជា) និង១៨នៅ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុទី២។ វាជាតំបន់សេដ្ឋកិច្ចដ៏ធំជាងគេបំផុតទាំងបី។
- ក្នុងមកដល់ឆ្នាំ២០១៣ តំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជា រួមមាន ៦៩ក្រុមហ៊ុនកម្មន្តសាលផុនស្រាល ១៧ក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ និង៦ ក្រុមហ៊ុនផលិតស្បែកជើង។

## ការវិភាគចំណុចខ្លាំង ចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • តំបន់សេដ្ឋកិច្ចពិសេស ផ្តល់ហេដ្ឋាសម្ព័ន្ធប្រសើរជាងទីកន្លែងផ្សេងទៀតនៅកម្ពុជា (ជាពិសេស ទឹក ប្រព្រឹត្តិកម្មសំណល់ទឹកការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍)។<br>• ក្រុមហ៊ុនមានទីតាំងនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស ទទួលបានផលប្រយោជន៍ពីឋានៈគម្រោងវិនិយោគមានគុណវុឌ្ឍ។ QIP ផ្តល់ជូន វិនិយោគិនថ្មី (នៅក្នុងនិងក្រៅ SEZ) នូវការលើកទឹកចិត្តវិនិយោគនិងការអនុគ្រោះពន្ធមួយចំនួន<br>• មន្ត្រីរដ្ឋាភិបាលនៅតាមតំបន់សេដ្ឋកិច្ចពិសេសនូវសេវាតែមួយកន្លែង ដើម្បីគ្រប់គ្រងការស្នើសុំធ្វើវិនិយោគ | • ក្រុមហ៊ុនមានទីតាំងនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស អាចទទួលភាពអនុគ្រោះផ្នែកវិនិយោគនិងពន្ធស្រដៀងនឹងក្រុមហ៊ុនមានទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលស្ថិតនៅក្រោមឋានៈគម្រោងវិនិយោគមានគុណវុឌ្ឍដែលកាត់បន្ថយភាពទាក់ទាញរបស់តំបន់សេដ្ឋកិច្ចពិសេស។<br>• ភាពអនុគ្រោះដល់វិនិយោគដែលរួចពន្ធមិនលើកទឹកចិត្តដល់ការពង្រីកវិនិយោគទេ ដោយសារភាពនុគ្រោះនេះអនុវត្តន៍ចំពោះ តែការវិនិយោគដំបូងៗ ប៉ុណ្ណោះ។<br>• វិធានរបស់តំបន់សេដ្ឋកិច្ចពិសេសគ្មានលក្ខណៈច្បាស់លាស់ថាតើនីតិវិធីណាខ្លះ ដែលត្រូវអនុវត្តាម ដើម្បីធ្វើ |

| | |
|---|---|
| បរទេសសំណើនិងបណ្តឹងផ្សេងៗ។<br>• តំបន់សេដ្ឋកិច្ចពិសេសផ្តល់ជូននីតិវិធីពាណិជ្ជកម្ម និងរដ្ឋបាលមានលក្ខណៈស៊ីសង្វាក់។<br>• ថ្លៃសេវាផ្លូវការដែលត្រូវបានបោះពុម្ពផ្សាយ ផ្តល់តម្លាភាព និងភាពប្រាកដប្រជាដល់វិនិយោគិន។<br>• ប្រតិបត្តិករ តំបន់សេដ្ឋកិច្ចពិសេសផ្តល់ជំនួយដល់វិនិយោគិនទាក់ទងនឹងការងាររដ្ឋបាល។<br>• ការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសជាលក្ខណៈឯកជន ផ្តល់សេវាមានប្រសិទ្ធិផលនិងប្រសើរជាងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។<br>• តំបន់សេដ្ឋកិច្ចពិសេសនៅជិតព្រំដែន ឬហេដ្ឋារចនាសម្ព័ន្ធនាំចេញសម្រួលដល់សមាហរណកម្មធ្យោបាយផលិតជាមួយសង្វាក់ ផលិត កម្មតំបន់ ជាពិសេសជាមួយប្រទេសជិតខាង ដែលជាប្រទេសផ្គត់ផ្គង់ ឬអតិថិជន (ពិសេស ថៃនិងវៀតណាម)។<br>• ការនៅជិតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនអន្តរជាតិកាត់បន្ថយរយៈពេលនាំចេញនិងការចំណាយ (កំពង់ផែ ឬអាកាសយានដ្ឋាននៅភ្នំពេញក្រុងព្រះសីហនុ)។<br>• តំបន់សេដ្ឋកិច្ចពិសេសទាក់ទាញកម្មករផ្តល់ជាបណ្តុំកម្មករសម្រាប់ឱ្យក្រុមហ៊ុនជ្រើសរើស។<br>• តំបន់សេដ្ឋកិច្ចពិសេសផ្តល់បរិយាកាសងាយស្រួល និងគាំទ្រសម្រាប់ក្រុមហ៊ុនដែលមានសញ្ជាតិដូចគ្នាធ្វើជាប្រតិបត្តិការ (ឧទាហរណ៍៖ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញសម្រាប់ជប៉ុន ឬតំបន់សេដ្ឋកិច្ចពិសេស II ក្រុងព្រះសីហនុសម្រាប់ចិន)។<br>• ជាសមាគមន៍ នៃតំបន់សេដ្ឋកិច្ចពិសេសធំៗ អនុញ្ញាតឱ្យមានការពិភាក្សាអំពីបញ្ហារួមនិងបញ្ចុះបញ្ចូលរដ្ឋាភិបាល។ | ពាណិជ្ជកម្មជាមួយក្រុមហ៊ុននៅក្រៅតំបន់សេដ្ឋកិច្ចពិសេស ធ្វើឱ្យទំនាក់ទំនងម៉ៅការបន្តជាមួយក្រុមហ៊ុននៅក្រៅ zone គ្មានលក្ខណៈប្រាកដប្រជានិងស៊ីពេលច្រើន។<br>• តំបន់សេដ្ឋកិច្ចពិសេសដូចនៅប្រទេសដទៃទៀតដែររងគ្រោះដោយសារការផ្គត់ផ្គង់អគ្គិសនីថ្លៃនិងមិនអាចទុកចិត្តបាន។ តម្លៃអគ្គិសនីនៅកម្ពុជាគឺប្រមាណជា $0.23 ក្នុង១KWH ចេញពី EDC និងប្រមាណជា $0.40 ក្នុង១KWH ឬកាន់តែថ្លៃជាងនេះ ទៅទៀតប្រសិនបើម៉ាស៊ីនភ្លើងខ្លួនឯង។ តម្លៃអគ្គិសនីនៅវៀតណាម មានចន្លោះពី $0.05 ទៅ $0.09 ក្នុង១KWH និងនៅថៃចន្លោះពី $0.04 ទៅ $0.09 ក្នុង១ KWH។<br>• កង្វះជំនាញភាសាដើម្បីទំនាក់ទំនងជាមួយវិនិយោគិនតំបន់សេដ្ឋកិច្ចពិសេសនិងជំនាញគ្រប់គ្រងទាបរារាំងដល់ការតម្លើងឋានៈកម្មករកម្ពុជាទៅកាន់តំណាងគ្រប់គ្រង និងពាក់កណ្តាលគ្រប់គ្រង។<br>• កម្លាំងពលកម្មកម្ពុជាខ្វះខាតជំនាញបច្ចេកទេសវិស្វកម្ម និងធុរកិច្ច ដែលចាំបាច់សម្រាប់អភិវឌ្ឍស្វ័យប្រវត្តិកម្មប្រតិបត្តិការ ក្រុមហ៊ុននៅតាមតំបន់សេដ្ឋកិច្ចពិសេស។<br>• រដ្ឋាភិបាលកម្ពុជាជាពិសេសនោះ CDC មិនបានសម្របសម្រួលជាមួយប្រតិបត្តិករតំបន់សេដ្ឋកិច្ចពិសេសដើម្បីឱ្យមានគំនិតផ្តួចផ្តើមនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសទេ។<br>• ហេដ្ឋារចនាសម្ព័ន្ធនាំចេញនិងដឹកជញ្ជូនផ្សារភ្ជាប់តំបន់សេដ្ឋកិច្ចពិសេសទៅកាន់ទីផ្សាររបស់ខ្លួនមានលក្ខណៈអន់ថយបើធៀបនឹងស្តង់ដារអន្តរជាតិនិងគូប្រកួតប្រជែង។<br>• ថ្លៃសេវាផ្លូវការដែលបោះពុម្ពផ្សាយមិនត្រូវបានអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួនដោយមន្ត្រីរដ្ឋាភិបាលដោយថ្លៃសេវាក្រៅផ្លូវការនៅតែត្រូវទាមទារជាប្រព័ន្ធ។<br>• មន្ត្រីរដ្ឋាភិបាលនៅតាមទីតាំងតំបន់សេដ្ឋកិច្ចពិសេស មិនបានទទួលព័ត៌មានជានិច្ចកាលអំពីនីតិវិធីរដ្ឋបាលដែលក្រុមហ៊ុន ធ្វើប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសត្រូវអនុវត្តន៍តាមឡើយ។<br>• មិនមែនមន្ត្រីតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ផ្តល់សេវារដ្ឋាភិបាលក្នុងកម្រិតនិងគុណភាពដូចគ្នាទេ។<br>• ការចល័តនិងការបែងចែកកម្លាំងពលកម្មមិនសូវល្អ |

| | |
|---|---|
| | នៅថ្នាក់ជាតិនាំឱ្យតំបន់សេដ្ឋកិច្ចពិសេសមួយចំនួនជួបការលំបាកក្នុងការស្វែងរកកម្លាំងពលកម្មដែលខ្លួនត្រូវការ។ |
| **ឱកាស** | **ការគំរាមកំហែង** |
| • វិនិយោគិនបរទេសសម្តែងចំណាប់ចំណូលចិត្តចង់បានតំបន់សេដ្ឋកិច្ចពិសេសដែលអភិវឌ្ឍន៍និងគ្រប់គ្រងដោយឯកជនដូចក្នុងករណីកម្ពុជា។<br>• វិនិយោគិនបរទេសសម្តែងចំណាប់ចំណូលចិត្តចង់វិនិយោគនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសដែលគ្រប់គ្រងដោយក្រុមហ៊ុនមកពីប្រទេសដើមរបស់ខ្លួន។<br>• កិច្ចសហការរបស់តំបន់សេដ្ឋកិច្ចពិសេសរបស់ធំៗតាមរយៈសមាគមតំណាងតែមួយអាចសម្របសម្រួលការដោះស្រាយបញ្ហាផ្សេងៗ ជាមួយរដ្ឋាភិបាល។<br>• និរន្តរភាពនៃការបន្តគ្រប់គ្រងប្រតិបត្តិការតំបន់សេដ្ឋកិច្ចពិសេសផ្តល់ទំនុកចិត្ត និងភាពជឿជាក់ចំពោះវិនិយោគិន។<br>• គម្រោងមហាអនុតំបន់ទន្លេមេគង្គដែលផ្តោតលើច្រករបៀងសេដ្ឋកិច្ចរវាងភូមិសបូព៌ាបច្ចិម (ពីវៀតណាម ទៅថៃ ឆ្លងកាត់កម្ពុជាបន្តផ្តល់មូលនិធិដល់ការលម្អបណ្តាញផ្លូវគោកនាំឱ្យកាត់បន្ថយពេលវេលាដឹកជញ្ជូនរវាងតំបន់សេដ្ឋកិច្ចពិសេស នៅភ្នំពេញនិងបាវិតនិងការផ្គត់ផ្គង់/ទីផ្សាររបស់ខ្លួន។<br>• ការរៀបចំវេនធ្វើការនៅពេលយប់នៅតាមរោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេសជួយផ្លាស់ប្តូរតម្រូវការអគ្គិសនីដល់ពេលធ្វើការតិច | • កង្វះខាតផ្សេងៗនៅក្នុង តំបន់សេដ្ឋកិច្ចពិសេស (ហេដ្ឋារចនាសម្ព័ន្ធសេវារដ្ឋាភិបាល) បង្កឱ្យមានទស្សនៈអវិជ្ជមានយូរអង្វែងចំពោះប្រព័ន្ធតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាក្នុងចំណោមវិនិយោគិនបរទេស។<br>• តម្រូវការជីវភាពរស់នៅរបស់កម្មករបរទេសមិនអាចបំពេញបានដោយងាយស្រួលចំពោះតំបន់សេដ្ឋកិច្ចពិសេសនៅតាមខេត្ត។<br>• ប្រទេសជិតខាងផ្តល់តំបន់សេដ្ឋកិច្ចពិសេសដែលមានហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងនិងចំណាយវិនិយោទាបជាង (នៅថៃ វៀតណាម ឡាវ) ឬមានសក្តានុពលលូតលាស់ប្រសើរជាង (ប្រទេសមីយ៉ានម៉ា)។ |

## វិស័យដំឡើងកម្មន្តសាលធុនស្រាល

### ព័ត៌មានជាមូលដ្ឋាន

- សម្រាប់គោលបំណងរបស់ *CTIS 2014-2018* វិស័យដំឡើងកម្មន្តសាលធុនស្រាលរបស់កម្ពុជាដែលមានទីតាំងជាចម្បងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ប៉ុន្តែមិនសុទ្ធតែនៅក្នុងតំបន់នេះផ្តាច់មុខនោះទេគឺគ្របដណ្តប់លើប្រតិបត្តិការដែលត្រូវការកម្លាំងពលកម្មច្រើននៅក្នុងការផលិតកម្មកង់ ការផលិតនិងដំឡើងគ្រឿងអគ្គិសនីនិងអេឡិចត្រូនិក ព្រមទាំងផលិតផលធុនស្រាលដទៃទៀតផងដែរ។ (វិស័យស្បែកជើង និងសំលៀកបំពាក់មានជំពូកដាច់ដោយឡែកមួយនៅក្នុង *CTIS 2014-2018* នេះ)។ វិស័យនេះរួមបញ្ចូលប្រព័ន្ធ HS (ប្រព័ន្ធដាក់លេខកូដនិងបរិយាយផលិតផលសុខដុមនីយកម្ម Harmonized Commodity Description and Coding System) ប្រភេទក្រុមលេខ ៨៧, ៨៤និង៨៥។
- ពាណិជ្ជកម្មកម្មន្តសាលធុនស្រាលសកលក្នុងផ្នែកឧបករណ៍អគ្គិសនីនិងអេឡិចត្រូនិកមានតម្លៃប្រមាណ$២.៣ ពាន់លានដុល្លារក្នុងឆ្នាំ 2012 ហើយចំពោះទំនិញកង់ គឺមានតម្លៃ $៨.១ ពាន់លានដុល្លារ។
- ផលិតផលនាំចេញកម្មន្តសាលធុនស្រាលសរុបនៅកម្ពុជាគឺមានតម្លៃ $៣៧២លានដុល្លារក្នុងឆ្នាំ2012 ដែលក្នុងនោះ $២៩១លានដុល្លារគឺជាផលិតផលកង់ដែលដំឡើងនៅក្នុងស្រុក, $៦២លានដុល្លារជាឧបករណ៍អគ្គិសនីនិងអេឡិចត្រូនិកនិង $២០លានដុល្លារជាផលិតផលផ្សេងៗទៀត។
- វិស័យកម្មន្តសាលធុនស្រាលប្រើកម្មករប្រមាណ ៦.០០០ នាក់ក្នុងឆ្នាំ 2011 ប៉ុន្តែការងារនៅក្នុងវិស័យនេះកំពុងតែកើនឡើងយ៉ាងឆាប់រហ័ស។ កម្មករនៅក្នុងឧស្សាហកម្មកម្មន្តសាលក្រៅពីសំលៀកបំពាក់ទទួលបានប្រាក់ឈ្នួលខ្ពស់ជាងវិស័យកាត់ដេរបន្តិច។

### ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • តម្លៃពលកម្មទាបធ្វើឲ្យកម្ពុជាមានការទាក់ទាញវិស័យផលិតកម្មនិងកម្មន្តសាលដែលប្រើកម្លាំងពលកម្មច្រើននៅតំបន់អាស៊ានជាពិសេសកិច្ចការដែលប្រើបច្ចេកវិទ្យាទាបដូចជារមួលខ្សែកាបការដំឡើងគ្រោងសម្រាប់ឧបករណ៍ព័ត៌មានឌីជីថលតូចឬគ្រោងម៉ាស៊ីននានា។<br>• មានបណ្តុំក្រុមហ៊ុនជាច្រើនក្នុងអនុវិស័យនេះ (ដូចជា៖ ទោចក្រយាននិងរុំខ្សែកាបជាដើម) ដែលបង្កឲ្យមាន | • កម្រិតផលិតភាពនិងជំនាញនៅទាបធ្វើឲ្យមានតម្លៃពលកម្មទាបនិងធ្វើឲ្យកម្ពុជាមានការទាក់ទាញតិចតួចលើវិស័យដែលប្រើមូលធនច្រើននៅក្នុងសង្វាក់ផលិតកម្មរបស់អាស៊ានដូចជាដំណើរការរមួលមេកានិកក្នុងការបង្កើតជាខ្សែកាបបន្ទះលោហៈឧបករណ៍ទប់ និងបំលែងអគ្គិសនីនិងម៉ូទ័ររំញ័រ។<br>• តម្លៃអគ្គិសនីខ្ពស់និងការផ្គត់ផ្គង់អគ្គិសនីមិនជាប់លាប់គឺ |

| | |
|---|---|
| ផលិតភាពខ្ពស់និងកំណើនសេដ្ឋកិច្ច។<br>• តម្រូវការទោចក្រយាននិងទោចក្រយានយន្តក្នុងស្រុក និងក្នុងតំបន់មានការកើនឡើងយ៉ាងឆាប់រហ័សជាពិសេសនេះ ដោយសារតែចំនួនប្រជាជនវ័យក្មេងក្នុងតំបន់បានផ្តល់នូវឱកាសអភិវឌ្ឍន៍និងកំណើនសេដ្ឋកិច្ចខ្លាំង។<br>• កម្ពុជាមានឋានៈជាប្រទេសនាំចេញទៅកាន់សហគមន៍អឺរ៉ុបដោយមិនបង់ពន្ធចំពោះទំនិញមួយចំនួន (ដូចជាទោចក្រយាន) ចំណុចនេះបានទាក់ទាញវិនិយោគិនជាច្រើនបានរើផលិតកម្មខ្លួនពីប្រទេសជិតខាងមកកម្ពុជា។<br>• ធាតុផ្សំ គ្រឿងបន្លាស់និងវត្ថុធាតុដើមភាគច្រើនដែលចាំបាច់ក្នុងការផលិត និងដំឡើងអាចនាំចូលពីប្រទេសជិតខាង (ដូចជាថៃ វៀតណាម ចិននិងម៉ាឡេស៊ី)។<br>• ភាពនៅជិតបំផុតនៃទីផ្សារអាស៊ាននាំឲ្យពេលវេលានៃសង្វាក់ផ្គត់ផ្គង់ផលិតកម្មរហ័សជាពិសេសដោយប្រទេសថៃនិងម៉ាឡេស៊ីបានអភិវឌ្ឍន៍ឧស្សាហកម្មអគ្គិសនី និងអេឡិចត្រូនិកបានយ៉ាងល្អហើយ។<br>• កំណើនយ៉ាងឆាប់រហ័សនៃវិស័យកសិកម្ម (ដូចជាស្រូវដំឡូងមីនិងពោតជាដើម) ក៏ដូចជាតម្រូវការក្នុងស្រុក និងក្នុងតំបន់នូវគ្រឿងយន្តបរិក្ខារនិងឧបករណ៍ កសិកម្មនានាដូចជាត្រាក់ទ័រ ម៉ាស៊ីនធ្វើថ្នាលនិងម៉ាស៊ីនច្រូត។<br>• ស្ថិរភាពនយោបាយបានធ្វើឲ្យការរាំងស្ទះលំហូរផ្គត់ផ្គង់បរិក្ខារមានកម្រិតទាប។<br>• និយោជិតជាជនជាតិបរទេសអាចទទួលបានបរិយាកាសស្នាក់នៅប្រកបដោយ សុវត្ថិភាព។ | ជាឧបសគ្គនៃកាអភិវឌ្ឍវិស័យកម្មន្តសាលធុនស្រាលពីព្រោះយើងត្រូវការអគ្គិសនី ដើម្បីដំណើរការម៉ាស៊ីន។ សូមបន្តអានក្នុងការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែងរបស់ប្រតិបត្តិករក្នុងតំបន់សេដ្ឋកិច្ចពិសេស។<br>• វិស័យគមនាគមន៍និងដឹកជញ្ជូននៅមានកម្រិតធ្វើឲ្យភាពមានប្រៀបផ្នែកកម្លាំងពលកម្មធ្លាក់ចុះនិងបានកាត់បន្ថយតម្លៃនិងពេលវាលាក្នុងការប្រកួតប្រជែងក្នុងទីផ្សារ។<br>• ការបញ្ចេញទំនិញនិងនិតិវិធីរដ្ឋបាលមិនចាំបាច់និងមិនមានសង្គតិភាពបានធ្វើឲ្យយឺតយ៉ាវក្នុងការនាំចេញនិងនាំចូលទាំងពាណិជ្ជកម្មក្នុងស្រុកនិងជាផ្នែកមួយនៃបញ្ញត្តិការងារអាស៊ាន។ ប្រការនេះជាការរារាំងដល់ដំណើរការធ្វើសមាហរណកម្មរបស់កម្ពុជាចូលក្នុងសង្វាក់ផលិតកម្មតំបន់។<br>• លើកលែងតែទោចក្រយានចេញកម្ពុជានៅមិនទាន់មានផលិតកម្មជាច្រើនផ្សេងទៀតនៃឧស្សាហកម្មកម្មន្តសាលធុនស្រាលនៅឡើយដោយសារក្រុមហ៊ុននៅកម្ពុជានៅខ្វះសមត្ថភាពផ្គត់ផ្គង់សម្ភារៈវត្ថុធាតុដើម្បីផលិត ប្រការនេះជាឧបសគ្គសម្រាប់ការវិនិយោគ/អភិវឌ្ឍន៍បន្ថែមទៀត (ជាស្ថានភាពអាក្រក់)។<br>• កម្មករកម្ពុជានៅខ្វះសមត្ថភាពផ្នែកភាសាចាំបាច់ដើម្បីឡើងទៅជាថ្នាក់គ្រប់គ្រង ឬតួនាទីគ្រប់គ្រងថ្នាក់កណ្តាលក្នុងក្រុមហ៊ុនបរទេស។<br>• កង្វះខាតបុគ្គលិកបច្ចេកទេសនិងវិស្វកម្មធ្វើឲ្យមានការពឹងអាស្រ័យខ្ពស់លើបុគ្គលិកបរទេសដែលមានតម្លៃថ្លៃ។<br>• ចលាចលក្នុងវិស័យការងារនិងកូដកម្មបង្កឲ្យមានការរំខានដល់ដំណើរការផលិតនិងធ្វើឲ្យការផ្គត់ផ្គង់ទំនិញចូលទៅក្នុងសង្វាក់ផលិតកម្មតំបន់យឺតយ៉ាវ។<br>• ទីផ្សារក្នុងស្រុករបស់កម្ពុជាមានវិសាលភាពតូចក៏ជាកត្តារាំងស្ទះដល់ការអភិវឌ្ឍឧស្សាហកម្មកម្មន្តសាលធុនស្រាលនិងសេដ្ឋកិច្ចផងដែរ។<br>• កង្វះមូលធននិងបច្ចេកវិទ្យាក្នុងស្រុកគឺជាឧបសគ្គដល់ការផ្ទេរបច្ចេកវិទ្យាចូលមកកម្ពុជា។ |

| ឱកាស | ការគំរាមកំហែង |
|---|---|
| • មានបណ្តុំនៃការវិនិយោគពីបរទេសខ្ពស់ពីប្រទេសនានានៅក្នុងតំបន់សេដ្ឋកិច្ចពិសេស (ដូចជា ជប៉ុនក្នុង PPSEZ ចិន/តៃវ៉ាន់នៅបាវិត ចិន នៅក្រុងព្រះសីហនុជាដើម) ប្រការនេះអាចទាក់ទាញអ្នកវិនិយោគពីប្រទេសដូចគ្នានោះថែមទៀត។<br>• កម្ពុជាមានកៅស៊ូដែលអាចជាវត្ថុធាតុដើមដ៏សំខាន់ក្នុងស្រុកក្នុងដំណើរការផលិតកម្មកម្មន្តសាលធុនស្រាល។<br>• បណ្តុំផលិតកម្មយានយន្តអាស៊ាននៅថៃ វៀតណាម និងម៉ាឡេស៊ីបានផ្តល់នូវឱកាសដល់កម្ពុជាដែលជាប្រទេសជិត ខាងអាចចូលរួម ចំណែកក្នុងការដំឡើងនិងផ្គត់ផ្គង់គ្រឿងបន្លាស់ផ្សេងៗបាន។<br>• ការនៅជិតបណ្តាប្រទេសដែលមានវិស័យកម្មន្តសាលធុនស្រាលខ្លាំងនិងការបណ្តាក់ទុនពីសំណាក់ក្រុមហ៊ុននានាដែលមានវត្តមានក្នុងប្រទេសទាំងនោះ ផ្តល់ឱកាសបណ្តុះបណ្តាលដល់ពលករកម្ពុជានិងការផ្ទេរបច្ចេកវិទ្យា។<br>• ការកាត់បន្ថយពន្ធស្ថិតក្រោមគម្រោង AFTA ទំនងជាអាចបង្កើនពាណិជ្ជកម្មនិងចលនាការងារក្នុងតំបន់អាស៊ានដែលធ្វើឲ្យកម្ពុជាចូលទៅកាន់ទីផ្សារអាស៊ានកាន់តែងាយដែលប្រការនេះអាចបង្កើតជាឱកាសសម្រាប់កំណើតសេដ្ឋកិច្ច។<br>• វិនិយោគិនបរទេសកំពុងមានប្រតិបត្តិការក្នុងតំបន់និងបណ្តាញផលិតកម្មអន្តរជាតិនានាកំពុងតែស្វែងរកការកាត់បន្ថយ ភាពអាស្រ័យពឹងពាក់ខ្លាំងលើប្រទេសមួយចំនួនក្នុងតំបន់ (ដូចជា ចិន ថៃ វៀតណាម ឥណ្ឌូនេស៊ីឬម៉ាឡេស៊ីជា ដើម)និងស្វែងរកការបន្ធូរបន្ថយបញ្ហានៃការកើនឡើងនៃថ្លៃពលកម្ម (នៅចិននិងវៀតណាម) និងបញ្ហាគ្រោះធម្មជាតិនៅប្រទេសថៃនិងជប៉ុននិងបញ្ហាដទៃទៀត។<br>• ការកើនឡើងនៃកម្រិតប្រាក់ឈ្នួលនៅប្រទេសចិនដែលកំពុងតែខិតឡើងទៅលើនៃសង្វាក់ផលិតកម្មនៃគ្រឿងអេឡិចត្រូនិកនិងនៅថៃដែលបានក្លាយខ្លួនទៅជាមជ្ឈមណ្ឌលដ៏សំខាន់ក្នុងផលិតកម្មយានយន្តនិង | • ដោយសារការធ្វើលទ្ធកម្មគ្រឿងបន្លាស់និងវត្ថុធាតុដើមផ្សេងៗ ប្រកបដោយប្រសិទ្ធភាពពីប្រទេសដទៃគឺមានសារសំខាន់យ៉ាងខ្លាំងក្នុងដំណើរការផលិតកម្មបញ្ហាដឹកជញ្ជូនក្លាយជាកត្តាដ៏សំខាន់ក្នុងការសម្រេចចិត្ត ធ្វើការវិនិយោគជាងតម្លៃពលកម្ម។ ចំណុចនេះ អាចជាចំណុចអវិជ្ជមានរបស់កម្ពុជាដោយសារតែកម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនទាំងទន់ទាំងរឹងនៅខ្សោយនៅឡើយ។<br>• និន្នាការឆ្ពោះទៅកាន់ផលិតកម្មមានមូលធននិងយន្តកម្មខ្ពស់ កំពុងកាត់បន្ថយភាពមានប្រៀបខាងប្រកួតប្រជែងរបស់កម្ពុជា ថាមានតម្លៃពលកម្មទាប ហើយបញ្ហាអគ្គិសនីក៏រឹតតែធ្វើឲ្យការទាក់ទាញការវិនិយោគលើវិស័យកម្មន្តសាលនេះធ្លាក់ចុះ។<br>• ការផ្លាស់ប្តូរនៃវិធានប្រភពដើមទំនិញជាអវិជ្ជមានរបស់កម្មវិធី EBA សហគមន៍អឺរ៉ុបបានគំរាមកំហែងការទទួលបានទីផ្សារទោចក្រយានកម្ពុជា។<br>• បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលហើយកម្មករកម្ពុជាអាចទទួលបានការងារក្នុងរោងចក្រថៃនិងវៀតណាមដែលមានប្រាក់ឈ្នួលខ្ពស់ជាងរោងចក្រនានាក្នុងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា ដែលនៅជិតព្រំដែន។<br>• ផលិតកម្ម និងទីផ្សារប្រទេសចិនមានទំហំធ្វើឲ្យថ្លៃដើមឧស្សាហកម្មចិននៅតែមានភាពប្រកួតប្រជែងទោះវាមានថេរវេលយូរនិងការឡើងប្រាក់ឈ្នួលយ៉ាងណាក៏ដោយនេះក៏ដោយសារកំណើនសេដ្ឋកិច្ចចិន។<br>• ការបញ្ចុះតម្លៃអគ្គិសនីនៅប្រទេសឡាវបានមកពីគម្រោងវារី អគ្គិសនីធំៗ របស់ខ្លួនក៏អាចជាការទាក់ទាញការវិនិ-យោគវិស័យកម្មន្តសាលធុនស្រាលឲ្យចូលទៅក្នុងប្រទេសនេះផងដែរ។<br>• ដំណើរការធ្វើប្រជាធិបតេយ្យភាវូបនីយកម្មនៅប្រទេសមីយ៉ាន់ម៉ានិងការបើកទ្វារឡើងវិញរបស់ខ្លួនទទួលយកការវិនិយោគពីបរទេសកំពុងតែទាញការចាប់អារម្មណ៍វិនិយោគិនក្នុងតំបន់ដោយសារប្រទេសនេះមានតម្លៃប្រាក់ឈ្នួលទាបនិងទីផ្សារក្នុងស្រុកដ៏ធំ (ទោះជាបញ្ហាខ្លាំង |

| | |
|---|---|
| វៀតណាម ដែលបានក្លាយជាអ្នកផ្គត់ផ្គង់គ្រឿងបន្លាស់និងបរិក្ខារដ៏សំខាន់ក៏ដូចជាសឹង្ហបុរី និងម៉ាឡេស៊ីដែលជាប្រទេសនាំមុខក្នុងការរើទីតាំងផលិតកម្មសំខាន់ទៅប្រទេសផ្សេងទៀតក្នុងតំបន់នោះវាគឺជាឱកាសសម្រាប់កម្ពុជាក្នុងការចាប់យកនូវកិច្ចការងារប្រើកម្លាំងពលកម្មច្រើនមួយចំនួន។<br>• មានការកើនឡើងនូវយុទ្ធសាស្ត្របែងចែកការងារតាមខ្សែទទឹងរបស់ក្រុមហ៊ុនជប៉ុន កូរ៉េ និងតៃវ៉ាន់។<br>• តម្រូវការក្នុងស្រុកនឹងកើនឡើងតាមកំណើនសេដ្ឋកិច្ច។<br>• ក្រុមហ៊ុនកម្មន្តសាលធំៗ ជាពិសេសក្រុមហ៊ុនអេឡិចត្រូនិកមកពីជប៉ុនកំពុងស្វែងរកការធ្វើពិពិធកម្មការផ្គត់ផ្គង់ក្រៅពីក្រុមហ៊ុនចិន (និងចេញពីទីតាំងដទៃទៀតដែលមានហានិភ័យនយោបាយ) នេះគឺជាផ្នែកមួយនៃយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនទាំងនោះ។<br>• ការកើនឡើងនៃការផ្សព្វផ្សាយបច្ចេកវិទ្យារវាងឧស្សាហកម្មនានានៅកម្ពុជាធ្វើឲ្យកម្ពុជាធ្វើសមាហរណកម្មចូលក្នុងផលិត កម្មកម្មន្តសាលធុនស្រាលក្នុងតំបន់ អាស៊ានបានល្អជាងមុនជាពិសេសសម្រាប់ដំណើរការដំឡើងគ្រឿងអេឡិចត្រូនិក។<br>• ក្រុមហ៊ុនទោចក្រយានដែលមានទីផ្សារនៅបស្ចឹមប្រទេសនឹងរើផលិតកម្មខ្លួនមកអាស៊ីដើម្បីកាត់បន្ថយថ្លៃដើមឆ្លើយតបទៅនឹងការធ្លាក់ចុះនៃតម្រូវការទីផ្សារនៅសហរដ្ឋអាមេរិកនិងអឺរ៉ុប ហើយកម្ពុជាកំពុងតែចាប់យកឱកាសវិនិយោគនេះ។ | លើហេដ្ឋារចនាសម្ព័ន្ធបញ្ជាក់ថាមីយ៉ាន់ម៉ានឹងត្រូវការរវាង 4 ឬ 5 ឆ្នាំទៀតដើម្បីធ្វើឲ្យខ្លួនក្លាយជាជំរើសដ៏សំខាន់មួយ)។<br>• មានការបង្កើនវដ្តនៃការរៀបចំនិងផលិតកម្មគ្រឿងអេឡិចត្រូនិកដែលធ្វើឲ្យចំណាយពេលតិចក្នុងការផលិតហើយនេះជាចំណុចខ្សោយមួយរបស់កម្ពុជា។<br>• បរិយាកាសសេដ្ឋកិច្ចអាប់អួរនៅបន្តនៅបស្ចឹមប្រទេសជាពិសេសនៅអឺរ៉ុបធ្វើឲ្យតម្រូវការទីផ្សារទោចក្រយាននិងគ្រឿងបរិក្ខារអេឡិចត្រូនិកដទៃទៀតធ្លាក់ទាប។ |

# វិស័យចំណីអាហារកែច្នៃ

## ព័ត៌មានមូលដ្ឋាន

- ការនាំចេញពិភពលោករបស់ចំណីអាហារកែច្នៃភេសជ្ជៈនិងថ្នាំជក់មានតម្លៃ $៧៩១ ពាន់លានដុល្លារក្នុងឆ្នាំ ២០១១។
- កម្ពុជាគឺជាប្រទេសនាំចូលសុទ្ធនៃទំនិញជាចំណីអាហារកែច្នៃភេសជ្ជៈនិងថ្នាំជក់ ដែលក្នុងនោះឧស្សាហកម្មក្នុងស្រុកផ្តោតអារម្មណ៍សំខាន់តែទៅលើការបំពេញតម្រូវការក្នុងស្រុកនិងផលិតកម្មនានាជំនួសឲ្យការនាំចូលមួយចំនួន។ ការប៉ាន់ប្រមាណការនាំចេញចំណីអាហារកែច្នៃ ភេសជ្ជៈនិងថ្នាំជក់របស់កម្ពុជាក្នុងឆ្នាំ ២០១១ មានតម្លៃស្មើនឹង $៥៩,៦លានដុល្លារ ចំណែកការនាំចូលវិញមានតម្លៃ $២៥១,៨លានដុល្លារ។
- នៅតែមាននិន្នាការសកលលោកយ៉ាងច្បាស់ឆ្ពោះទៅរកការទទួលទានចំណីអាហារមួយចំនួនដោយប្រុងប្រយ័ត្នក្នុងនោះរួមមានផលិតផលសត្វដូចជាត្រី សាច់និងផលិតផលទឹកដោះគោ ហើយផ្ទុយទៅវិញមានការកើនឡើងនូវតម្រូវការចំណីសត្វនិងគ្រាប់ធុញ្ញជាតិផ្សេងៗ។
- នៅក្នុងឆ្នាំ ២០១០មានសហគ្រាសធុនតូចនិងមធ្យម (SME) ចំនួនជាង៣១.៤០០សហគ្រាសបានចុះបញ្ជី (ទុនតិចជាង $៣.០០០ដុល្លារ ហើយភាគច្រើនជាប្រតិបត្តិការតាមគ្រួសារ) នៅក្នុងវិស័យចំណីអាហារកែច្នៃភេសជ្ជៈ និងថ្នាំជក់កម្ពុជា ដែលបានប្រើកម្លាំងពលកម្ម ៩៣.៧០០នាក់។ ផ្ទុយទៅវិញ មានការវិនិយោគធំៗត្រឹមតែ៥៦ ប៉ុណ្ណោះដែលបានចុះបញ្ជីជាមួយក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល (រោងចក្រកែច្នៃចំណីអាហារ ៣០ រោងចក្រភេសជ្ជៈ ១៥ និងរោងចក្រថ្នាំជក់ ១១)។
- វិស័យកែច្នៃផលិតផលកសិកម្មក្នុងស្រុកភាគច្រើនផ្តោតលើម៉ាស៊ីនកិនស្រូវ ផលិតកម្មស្រាបៀរ ស្រា ស្ករស និងថ្នាំជក់ដែលយើងឃើញថាមានអាជីវកម្មជាច្រើនប្រកបរបរខាងលើ។

## ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • ការអភិវឌ្ឍវិស័យចំណីអាហារកែច្នៃក្នុងស្រុកគឺជាការបំពេញបន្ថែមលើសេចក្តីពិពណ៌នារបស់សេដ្ឋកិច្ចកម្ពុជាថាជាអ្នកផលិតកសិផលដែលកាន់តែធំឡើងៗ។<br>• វិស័យចំណីអាហារកែច្នៃភាគច្រើនជាសហគ្រាសធុនតូចនិងមធ្យមនៅតាមផ្ទះនិងតាមភូមិដែលផ្តល់ផលប្រយោជន៍ដោយផ្ទាល់ទៅដល់កម្រិតជីវភាព។<br>• ឧស្សាហកម្មកែច្នៃចំណីអាហារនេះមានសារសំខាន់ចំពោះទាំងការអភិវឌ្ឍទីផ្សារនាំចេញនិងទាំងការជំនួសផលិតផលនាំចូលមួយចំនួនដែលទាញយកប្រាក់ចំណូលពីការតម្លៃបន្ថែមក៏ដូចជាបង្វែរទិសនៃលំហូរសាច់ប្រាក់នៃសេដ្ឋ | • ឧបសគ្គមួយសំខាន់ចំពោះការអភិវឌ្ឍវិស័យចំណីអាហារកែច្នៃសម្រាប់នាំចេញនៅកម្ពុជាគឺកង្វះការប្រតិបត្តិតាមស្តង់ដារអនាម័យនិងភូតគាមអនាម័យ (SPS) អន្តរជាតិ។<br>• ជាទូទៅការមានគុណភាពទាបនិងមិនមានលក្ខណៈសុគតភាពនៃផលិតផលកសិកម្មឆៅ/មិនទាន់កែច្នៃជាការរាំងដល់កិច្ចខិតខំប្រឹងប្រែងមូលដ្ឋានកែច្នៃចំណីអាហារក្នុងស្រុក។<br>• ការនាំចេញមិនផ្លូវការនៃកសិផលមិនទាន់កែច្នៃជាច្រើនបានកាត់បន្ថយបរិមាណធាតុចូលចាំបាច់សម្រាប់ផលិត |

| | |
|---|---|
| កិច្ចជាតិកុំហូរចេញទៅក្រៅប្រទេសទាំងស្រុង។<br>• ការកើនឡើងនៃការនាំចេញកសិផលនឹងបង្កើតឲ្យមានតម្រូវការកសិធុរកិច្ចក្រោយរដូវប្រមូលផលដូចជាការបែងចែកតាមចំណាត់ថ្នាក់ការទុកដាក់និងការដឹកជញ្ជូន ហើយវាគាំទ្រដល់ការអភិវឌ្ឍកាន់តែធំនៃដំណើរការកែច្នៃកសិផលក្នុងស្រុក។<br>• ភាពសំបូរបែបតាមរដូវកាលចំពោះកសិផលដែលងាយនឹងខូចខាត (ដូចជាផ្លែឈើ និងបន្លែ) គឺសុទ្ធតែត្រូវការកែច្នៃបន្ថែម។<br>• កសិផលណាដែលមានគុណភាពទាបមិនស័ក្តិសមក្នុងការកែច្នៃអាចយកទៅធ្វើជាចំណីសត្វនិងគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្មចិញ្ចឹមសត្វក្នុងស្រុក។<br>• ធនធានត្រីដ៏ច្រើនរបស់កម្ពុជាគាំទ្រឧស្សាហកម្មកែច្នៃត្រីដែលផ្តោតលើការបំពេញសេចក្តីត្រូវការចំណង់ចំណូលចិត្តរបស់អតិថិជនក្នុងស្រុក (ដោយមានការនាំចេញតិចតួចទៅតំបន់អាស៊ាន)។<br>• ការក្លាយខ្លួនរបស់កម្ពុជាជាប្រទេសផលិតដំឡូងមីមួយដ៏សំខាន់បានបង្កើតជាឱកាសសម្រាប់បង្កើនផលិតកម្មដំឡូងមីកែច្នៃរួច និងពាក់កណ្តាលកែច្នៃក្នុងនោះរួមមានកាកសំណល់សម្រាប់ផលិតជាចំណីសត្វនិងម្សៅមីសម្រាប់ឧស្សាហកម្មកែច្នៃចំណីអាហារសកលលោក។ | ករកែច្នៃចំណីអាហារ។<br>• ជារឿយៗ យើងឃើញថាមានការនាំចេញកសិផលមិនទាន់កែច្នៃទៅថៃ ឬវៀតណាមដើម្បីកែច្នៃ ហើយនាំចូលត្រលប់មកវិញនូវផលិផលសម្រេចចូលក្នុងទីផ្សារក្នុងស្រុក។<br>• ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍និងរក្សាទុកដាក់នៅខ្សោយនិងតម្លៃថាមពលនៅកម្ពុជាថ្លៃជាហេតុធ្វើឲ្យការវិនិយោគពីវិស័យឯកជនលើមូលដ្ឋានកែច្នៃចំណីអាហារនៅមានកម្រិតនៅឡើយ។<br>• ការទទួលបានហិរញ្ញវត្ថុមានកម្រិតរារាំងដល់ការពង្រីករបស់ឧស្សាហកម្មចំណីអាហារកែច្នៃ។<br>• វិស័យកសិកម្មកម្ពុជាភាគច្រើនជាចម្ការ ស្រែខ្នាតតូចដោយមានកិច្ចសន្យាធ្វើកសិកម្មមានកម្រិតជាមួយអ្នកផលិតចំណីអាហារកែច្នៃនិងកេសជ្ជៈដើម្បីធានាពីការផ្គត់ផ្គង់វត្ថុធាតុដើមប្រកបដោយទំនុកចិត្ត។<br>• ទោះជាកម្ពុជាមានវិស័យបសុសត្វធំយ៉ាងណាក៏ដោយ ក៏កសិដ្ឋានតូចៗទាំងនោះមិនត្រូវការសេវាកម្មគាំទ្របន្ថែមទៀតដូចជាសុខភាពសត្វ ប្រឹក្សាយោបល់ និងបច្ចេកទេសនានាទៀតឡើយ។<br>• ទោះកម្ពុជាមានរបបទាក់ទាញការវិនិយោគដោយផ្ទាល់ពីបរទេស (FDI) យ៉ាងណាក៏ដោយ ក៏ការវិនិយោគពីបរទេសលើវិស័យកែច្នៃចំណីអាហារនៅកម្ពុជាមានទំហំតិចតួចនៅឡើយ បើយើងប្រៀបធៀបទៅនឹងវិស័យដទៃទៀតដូចជាវិស័យកាត់ដេរនិងវិស័យទេសចរណ៍។<br>• វត្តមានតិចតួចនៃពលកម្មមានជំនាញក៏ជាកត្តាមិនទាក់ទាញការវិនិយោគផងដែរ។<br>• កង្វះព័ត៌មានស្តីពីពាណិជ្ជកម្មចំណីអាហារកែច្នៃនៅតំបន់អាស៊ីអគ្នេយ៍ក៏ជាការរារាំងដល់ការវិនិយោគជាយុទ្ធសាស្ត្រនិងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រីកការនាំចេញចំណីអាហារកែច្នៃនេះ (ជាពិសេសសម្រាប់ SMEតាមគ្រួសារនិងតាមភូមិ)។<br>• ភាពអនុគ្រោះពន្ធជាទូទៅមិនមានភាពអំណោយផលសម្រាប់កសិផលកែច្នៃឡើយ។ |

| ឱកាស | ការគំរាមកំហែង |
| --- | --- |
| • ក្នុងពេលកម្ពុជាមានកំណើនសេដ្ឋកិច្ចនិងការប្រើប្រាស់តាមគ្រួសារកើនឡើងឧស្សាហកម្មកែច្នៃចំណីអាហារអាចរំពឹងថាមានការរីកចម្រើនក្នុងល្បឿនយ៉ាងលឿន។<br>• ដោយការកែច្នៃចំណីអាហារភាគច្រើនធ្វើនៅតាមផ្ទះនិងតាមគ្រួសារអនាគតនៃកំណើនក្នុងវិស័យនេះនឹងទាមទារឲ្យមានចំណីអាហារមានតម្លៃបន្ថែមដែលផ្តល់នូវសេន្តិសុខស្បៀងនិងការកាត់បន្ថយភាពក្រីក្រដ៏សំខាន់សម្រាប់កម្ពុជា។<br>• ដោយមានទំនាក់ទំនងសង្វាក់ផ្គត់ផ្គង់ទៅវិញទៅមកវិស័យចំណីអាហារកែច្នៃផ្តល់នូវការបង្កើតការងារ និងការបន្ថែមតម្លៃខ្ពស់។<br>• ការអនុវត្តវិធីប្រមូលផលទំនើបនិងសង្វាក់ផ្គត់ផ្គង់កសិ-ឧស្សាហកម្មនៅកំពុងអភិវឌ្ឍនៅកម្ពុជាចំណុចអាចផ្តល់វិសាលភាពសម្រាប់អភិវឌ្ឍឧស្សាហកម្មចំណីអាហារសរីរាង្គសម្រាប់នាំចេញបានជាពិសេសអនុវិស័យដូចជាអង្ករ សណ្តែកសៀង ស្វាយចន្ទី ផ្លែឈើ គ្រឿងទេសនិងស្ករត្នោត។ បើមានការលើកទឹកចិត្តឲ្យប្រើប្រាស់កសិផលក្នុងស្រុកនៅក្នុងវិស័យកែច្នៃចំណីអាហារនោះវាពិតជាអាចពន្លឿនការអភិវឌ្ឍឧស្សាហកម្មនេះនៅកម្ពុជាបានយ៉ាងឆាប់រហ័ស។<br>• ការពង្រឹងការគ្រប់គ្រងជំងឺនិងការជានាតំបន់មិនមានជំងឺអុតក្តាម (FMD) អាចធ្វើឲ្យកម្ពុជាអភិវឌ្ឍទីផ្សារនាំចេញសាច់ទៅអន្តរជាតិបាន។<br>• ដោយមានការតាក់តែងគោលនយោបាយនិងយុទ្ធសាស្ត្រវិនិយោគសមរម្យ កម្ពុជាអាចក្លាយជាទីតាំងមួយដ៏ល្អសម្រាប់បំពេញសេចក្តីត្រូវការចំណីអាហារដែលចេះតែកើនឡើងនិងបំពេញចំណង់ចំណូលចិត្តរបស់អតិថិជនក្នុងតំបន់អាស៊ីអគ្នេយ៍ក្បែរខ្លួននេះបាន ហើយអាចជួយបំពេញសេចក្តីត្រូវការចំណីអាហារសម្រាប់ឥស្លាមសាស-និកផងដែរ។ | • វិស័យចំណីអាហារកែច្នៃពង្រីកដោយពឹងលើកសិផលនាំចូលនឹងធ្វើឲ្យកសិករក្នុងស្រុកបាត់បង់ឱកាសបង្កើនប្រាក់ចំណូល និងធ្វើពិពិធកម្មសង្វាក់ផ្គត់ផ្គង់។<br>• មូលដ្ឋានកែច្នៃចំណីអាហារធំៗនឹងមិនអាស្រ័យលើកសិករខ្នាតតូច និងមិនមានបច្ចេកទេសដើម្បីផ្គត់ផ្គង់វត្ថុធាតុដើមឡើយ។ ដូច្នេះកសិករប្រភេទនេះនឹងត្រូវបានគេទុកឲ្យនៅក្រៅសង្វាក់ផ្គត់ផ្គង់និងអត្ថប្រយោជន៍សេដ្ឋកិច្ចសង្គមនានាដែលបានមកពីឧស្សាហកម្មកែច្នៃចំណីអាហារ។<br>• ការដែលផលិតករចំណីអាហារកែច្នៃក្នុងស្រុកបរាជ័យក្នុងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយក្រុមពហុជាតិធំៗដទៃទៀត នឹងអាចជាឧបសគ្គក្នុងការយល់ដឹងឲ្យច្បាស់អំពីទីផ្សារអន្តរជាតិ ហើយចំណុចនេះអាចធ្វើឲ្យការស្វែងរកប្រាក់ចំណូលពីការនាំចេញថយចុះ។<br>• ចំណង់ចំណូលចិត្តអតិថិជនក្នុងស្រុកអាចប្តូរទៅចូលចិត្តផលិតផលចំណីអាហារ និងភេសជ្ជៈអន្តរជាតិមានម៉ាកល្បីៗដែលនាំចូល។<br>• បរាជ័យក្នុងការទាក់ទាញបរិមាណសមល្មមនៃការវិនិយោគដោយផ្ទាល់ពីបរទេសក្នុងវិស័យចំណីអាហារកែច្នៃធ្វើឲ្យវិស័យក្នុងស្រុកមិនអាចទទួលបានសង្វាក់តម្លៃបច្ចេកវិទ្យា និងហិរញ្ញវត្ថុសកលលោកបានឡើយ។ |

## វិស័យជលផល

### ព័ត៌មានមូលដ្ឋាន

- ពាណិជ្ជកម្មសកលលោកក្នុងវិស័យជលផលមានតម្លៃប្រមាណជាង $១០០ ពាន់លានដុល្លារក្នុងមួយឆ្នាំ ហើយជប៉ុនគឺប្រទេសនាំចូលដ៏ធំជាងគេបំផុត។
- ក្នុងឆ្នាំ២០១២ កម្ពុជាផលិតត្រីបានប្រមាណ ៦៨២.០០០ តោនហើយ ៥០៩.០០០ តោនបានពីការនេសាទត្រីទឹកសាបនិង ៩៩.០០០ បានពីទឹកប្រៃ ហើយ ៧៤.០០០ តោនបានពីការធ្វើវារីវប្បកម្ម (ផលិតផល ស្ទើងតែទាំងអស់បានពីការនេសាទត្រីទឹកសាប)។
- ការនាំចេញផលិតផលនេសាទរបស់កម្ពុជាដែលបានកត់ត្រាក្នុងឆ្នាំ២០១២ គឺ ២១.០០០ តោន ធ្លាក់ចុះពី ៣៥.០០០ តោនក្នុងឆ្នាំ២០១០។ ទោះបីជាយ៉ាងណាក្តី ការនាំចេញភាគច្រើនគឺក្រៅផ្លូវការនិងគ្មានកំណត់ត្រា។
- វិស័យនេះមានកម្លាំងពលកម្មដោយផ្ទាល់ប្រមាណ៤២០.០០០ នាក់។ គេប៉ាន់ស្មានថា ប្រជាពលរដ្ឋរហូតដល់ ៦ លាននាក់ទទួលអត្ថប្រយោជន៍ពីការងារឬការចូលរួមដោយប្រយោលនៅក្នុងវិស័យជលផលរបស់កម្ពុជា។

### ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • ធនធានទឹកដ៏ធំរបស់កម្ពុជាផ្តល់នូវឱកាសសេដ្ឋកិច្ចយ៉ាងសំខាន់សម្រាប់បង្កើនជីវភាពតាមជនបទក្នុងនោះវាលទំនាបលិចទឹក ទន្លេនិងបឹងផ្តល់នូវការនេសាទតាមបឹងនិងទន្លេ ការនេសាទតាមវាលស្រែនិងវារីវប្បកម្ម។<br>• ការនេសាទទឹកសាបរបស់កម្ពុជាទទួលបានបរិមាណច្រើនឈរជាប្រទេសមានផលនេសាទច្រើនក្នុងសកល-លោក នេះដោយសារមានទំនាបលិចទឹកធំល្វឹងល្វើយនិងបឹងទន្លេសាបជាមួយនឹងទន្លេសាប និងទន្លេមេគង្គ។<br>• ជាវិស័យដ៏យូរលង់មកហើយនៅកម្ពុជានិងមានចំណេះដឹងច្រើននៃប្រភេទនិងទីលំនៅរបស់ជលផល។<br>• ត្រីទឹកសាបគឺជាប្រភពដ៏សំខាន់នៃប្រូតេអ៊ីននៅកម្ពុជាហើយក៏ផ្តល់នូវអាហារូបត្ថម្ភជាច្រើនទៀត។<br>• កាតបង្កើតជាសមាគមន៍ផលិតករតូចៗនៅតាមបណ្តាខេត្តជាប់មាត់សមុទ្រគឺជាជំហានដំបូងដ៏សំខាន់ក្នុងការបង្កើតវិស័យជលផលទឹកប្រៃដែលមានរចនាសម្ព័ន្ធល្អ។ | • ខ្វះចំណេះដឹង និង/ឬការប្រតិបត្តិតាមតម្រូវការ SPS ក្នុងទីផ្សារអន្តរជាតិដែលមានតម្លៃខ្ពស់រួមទាំងទីផ្សារនៅអឺរ៉ុប ប្រការនេះជាការរាំងស្ទះដល់ការប្រមូលប្រាក់ចំណូលពីការនាំចេញ។<br>• ខ្វះការផ្គត់ផ្គង់ប្រកបដោយសុគតភាពដែលជាឧបសគ្គដល់អ្នកកែច្នៃចំណីអាហារលើផ្ទៃសមុទ្រ (រួមទាំងការក្លាសេ) និងការពង្រីកផលិតកម្ម ក៏ដូចជាការស្វែងរកទីផ្សារ។<br>• អ្នកផ្តល់អាជ្ញាប័ណ្ណមានសិទ្ធិទារកំរៃស្មើនឹង 4 ភាគរយនៃតម្លៃនាំចេញត្រី ដែលនេះជាការលើកទឹកចិត្តឲ្យអ្នកនាំចេញនិងពាណិជ្ជករស្វែងរកចន្លោះពាណិជ្ជកម្មមិនផ្លូវការទៅវិញ។<br>• ការដាក់សម្ពាធលើការនេសាទទឹកសាបនិងទឹកប្រៃធ្វើឲ្យការចាប់ត្រីមានតម្លៃសេដ្ឋកិច្ចតិចជាងមុន។<br>• ពូជត្រីធំៗ និងត្រីមានតម្លៃមានបរិមាណថយចុះយ៉ាងឆាប់រហ័សទាំងចំនួននិងទំហំ ហើយបច្ចុប្បន្នប្រភេទ |

| | |
|---|---|
| • ការអនុវត្តការគ្រប់គ្រងរួមគ្នានៃធនធានទឹកសាបតាមរយៈអង្គការសហគមន៍ជលផល (CF) បានធ្វើឲ្យសម្លេងនៃប្រជានេសាទតូចៗខ្លាំងជាងមុននិងលើកកម្ពស់ការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានទឹកសាប។<br>• ចាប់តាំងពីឆ្នាំ ២០១០មកមានការកើនឡើងយ៉ាងឆាប់រហ័សក្នុងទំហំនាំចេញ (សំខាន់គឺបង្គារក្លាសេ) ទៅកាន់ទីផ្សារដ៏ធំ និងមានតម្លៃបំផុត នោះគឺជប៉ុន។<br>• ខណៈដែលការនាំចេញត្រីភាគច្រើនមិនបានកត់ត្រាត្រឹមត្រូវ វាទំនងដែលថាការនាំចេញត្រីទឹកសាបមានទំហំជាងការនាំចេញត្រីទឹកប្រៃគួរឲ្យកត់សម្គាល់។<br>• ជាទូទៅពាណិជ្ជកម្មត្រីសកលលោកប្រឈមនឹងការយកពន្ធទាប (ឬគ្មានពន្ធតែម្តង)។ | ត្រីខាងលើកំពុងតែខ្វះខាតក្នុងទីផ្សារក្នុងស្រុក។<br>• បរិមាណគួរឲ្យកត់សម្គាល់នៃការនេសាទត្រីទឹកជ្រៅដោយប្រជានេសាទកម្ពុជាត្រូវបានលក់ទៅឲ្យនាវានេសាទ ថៃ វៀតណាមនិងហុងកុងដោយមិនបានឆ្លងកាត់ទីផ្សារ និងមូលដ្ឋានកែច្នៃចំណីអាហារកម្ពុជា។<br>• ផ្លូវថ្នល់មិនល្អនិងកង្វះអគ្គិសនីធ្វើឲ្យការទុកដាក់ និងដឹកជញ្ជូនផលត្រីពិបាក។<br>• ការមានទិន្នន័យពាណិជ្ជកម្មមិនអាចទុកចិត្តបាន (ជាពិសេសជលផលទឹកប្រៃ) ជាឧបសគ្គក្នុងការតាក់តែងគោលនយោបាយនិងយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍទីផ្សារនាំចេញ។<br>• មានចំណេះតិចតួចលើទីផ្សារត្រីការអនុវត្តការនាំចេញនិងការធ្វើទីផ្សារជាអន្តរជាតិ។ |
| **ឱកាស** | **ការគំរាមកំហែង** |
| • ការចូលទៅទីផ្សារអន្តរជាតិកាន់តែច្រើននឹងធ្វើឲ្យយើងទទួលបានអត្ថប្រយោជន៍សុខុមាលភាពកាន់តែច្រើន។ វិស័យនេះត្រូវការកម្លាំងពលកម្មដោយផ្ទាល់ចំនួន ៤២០.០០០នាក់ខណៈមនុស្សប្រាំមួយលាននាក់ទទួលបានទម្រង់ណាមួយនៃអត្ថប្រយោជន៍ជីវភាពពីសកម្មភាពនេសាទនៅកម្ពុជា។<br>• *ក្រមខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលៈ ឆ្នាំ ២០១០-២០១៩* និងកំណែទម្រង់ដែលកំពុងអនុវត្តន៍លើការគ្រប់គ្រងនៃជលផលកម្ពុជាផ្តល់ជាវេទិកាបច្ចុប្បន្នដើម្បីទាក់ទាញការវិនិយោគវិស័យឯកជនទៅក្នុងវិស័យជលផលនិងការនាំចេញ។<br>• បរិមាណដ៏ច្រើននៃការនេសាទត្រីទឹកជ្រៅអាចកែច្នៃនៅលើផ្ទៃសមុទ្រតែម្តងនៅកម្ពុជា។<br>• ធនធាន និងសមត្ថភាពកើនឡើងសម្រាប់កម្ពុជាដើម្បីល្បាត និងត្រួតពិនិត្យធនធានជលផលក្នុងសមុទ្រអាចកាត់បន្ថយបរិមាណត្រីដែលទូកនេសាទបរទេសមកចាប់បច្ចុប្បន្នក្នុងដែនទឹករបស់កម្ពុជា។<br>• ការបើកមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍវារីវប្បកម្មធនធានសមុទ្រ (MARDeC) ក្នុងឆ្នាំ ២០១២ អាចជួយឲ្យវិស័យវារីវប្បកម្មធនធានក្នុងសមុទ្ររីកចំរើនបានយ៉ាងឆាប់រហ័ស។ | • ការធ្លាក់ចុះនៃបរិស្ថាននិងការបំផ្លិចបំផ្លាញជម្រកពីការសាងសង់ទំនប់ធំៗ ការកាប់ព្រៃឈើនិងការបំលែងដីទៅប្រើប្រាស់ក្នុងវិស័យកសិកម្មសុទ្ធសឹងជាចំណុចអវិជ្ជមាន។<br>• ការនេសាទហួសហេតុច្រើនករណីទាំងទឹកសាបនិងទឹកប្រៃដោយសារតែការកើនឡើងនៃតម្រូវការមិនមានការកំណត់បរិមាណនៃការចាប់ត្រីក្នុងបទបញ្ញត្តិនិងការអនុវត្តការនេសាទមិនមានប្រសិទ្ធភាព។<br>• ប្រទេសនាំចូលសំខាន់ៗបានអនុម័តការរឹតបន្តឹង SPS និង TBT ថ្មីៗនិងតឹ្បតតៀ្បតជាងមុនលើការនាំចេញត្រីរបស់កម្ពុជា។<br>• មិនមានការបង្កើនសមត្ថភាពស្ថាប័នក្នុងការត្រួតពិនិត្យត្រីនិងមិនមានការអនុវត្តស្តង់ដារគុណភាពនិងសុវត្ថិភាពចំណីអាហារដែលធ្វើឲ្យវិស័យនេះបាត់បង់ឱកាសរក្សាកំណើនថេរពីចំណូលពីការនាំចេញ។<br>• ការផ្ទុះឡើងនៃជំងឺជាពិសេសក្នុងវារីវប្បកម្ម។<br>• ភាពស្ទាក់ស្ទើររបស់រដ្ឋាភិបាល ឬឧស្សាហកម្មក្នុងការវិនិយោគលើការស្រាវជ្រាវវិស័យនេះអាចធ្វើឲ្យកិច្ចខិតខំប្រឹងប្រែងនានាចុះខ្សោយមិនអាចលើកកម្ពស់បច្ចេកវិទ្យាកែច្នៃត្រីនិងកាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល។ |

| | |
|---|---|
| • ការពង្រីកវិស័យវារីវប្បកម្មផ្តល់ឱកាសក្នុងការកាត់បន្ថយសម្ពាធនៃសាទត្រីធម្មជាតិ ហើយវាក៏អាចជួយសមត្ថភានាំចេញនាពេលអនាគតបាន។<br>• ការវិនិយោគលើបច្ចេកវិទ្យាប្រមូលផលនិងក្រោយពេលប្រមូលផលដើម្បីបំពេញស្តង់ដារទីផ្សារសកលលោកនឹងផ្តល់កាតាលីករជួយធ្វើឲ្យទីផ្សារនាំចេញកាន់តែប្រសើរឡើង។<br>• កិច្ចខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្នដើម្បីធ្វើឲ្យរដ្ឋបាលជលផលក្លាយទៅជា "អាជ្ញាធរមានសមត្ថកិច្ច" មួយដែលបំពេញតាមតម្រូវការស្តង់ដារ EU ក៏ដូចជាការអនុវត្តសកម្មភាពឲ្យស៊ីគ្នានឹងជួយលើកកម្ពស់សមត្ថភាព SPS ក្នុងវិស័យនេះ។ | |

# វិស័យអង្ករ

## ព័ត៌មានមូលដ្ឋាន

- ពាណិជ្ជកម្មអង្ករសកលលោកមានចំនួន ៣០ លានតោន ក្នុងមួយឆ្នាំប៉ុន្តែទិន្នន័យនេះមានការប្រែប្រួលខ្លាំង ហើយជារឿយៗមានអន្តរាគមន៍ពីរដ្ឋាភិបាល។
- ការនាំចេញអង្ករជាផ្លូវការរបស់កម្ពុជាបានកើនពី ១៦.០០០ តោនក្នុងឆ្នាំ២០០៩ ទៅ ១៩៥.០០០ តោន ក្នុងឆ្នាំ ២០១១ ហើយប្រមាណជា ៣៥០.០០០តោន ក្នុងឆ្នាំ ២០១៣។ សហគមន៍អឺរ៉ុប រុស្ស៊ី និងម៉ាឡេស៊ី គឺជាទីផ្សារដ៏ធំបំផុតរបស់កម្ពុជា ប៉ុន្តែមានសេចក្តីត្រូវការនិងនិន្នាការថ្មីក្នុងការធ្វើពិពិធកម្មទីផ្សារនាំចេញដោយ រួមទាំងទីផ្សារក្នុងតំបន់ផងដែរ។
- រាជរដ្ឋាភិបាលបានកំណត់ថានឹងនាំចេញឲ្យបាន១ លានតោនត្រឹមឆ្នាំ ២០១៥។
- តម្លៃនៃផលិតកម្មស្រូវនៅកម្ពុជាគឺមានតម្លៃទាបក្នុងចំណោមតម្លៃទាបជាងគេបំផុតលើសកលលោក។
- ផលិតកម្មស្រូវសរុបប្រចាំឆ្នាំបានកើនឡើងជាមធ្យមស្មើនឹងអត្រា ៤,៩ ភាគរយរៀងរាល់ឆ្នាំ។
- ផលិតកម្មលើសលុប (ផលិតលើសសេចក្តីត្រូវការក្នុងស្រុក) នៃស្រូវក្នុងឆ្នាំ ២០១២ គឺប្រមាណ ៤លានតោន នេះបញ្ជាក់ថាកម្ពុជានៅសល់ស្រូវយ៉ាងច្រើនសម្រាប់កិនជាអង្ករនិងនាំចេញ។
- ទិន្នផលស្រូវកំពុងតែកើនឡើងនិងឈានដល់ ៣,២ តោនក្នុងមួយហិកតាក្នុងឆ្នាំ ២០១២។

## ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • ការដាក់ឲ្យប្រើប្រាស់ *ឯកសារគោលនយោបាយស្តីពីការលើកកម្ពស់ផលិតកម្មស្រូវនិងការនាំចេញអង្ករ* ក្នុងឆ្នាំ ២០១០ បានលើកទឹកចិត្តវិនិយោគិនជាច្រើនចូលមកជួយលើកសមត្ថភាពនៃការកិចស្រូវរបស់កម្ពុជា។<br>• ដំណាំស្រូវគឺជាដំណាំតាមប្រពៃណីយវប្បធម៌និងជាប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា ហើយផលិតកម្មស្រូវនៅកម្ពុជាមានទំហំធំ និងពាសពេញផ្ទៃប្រទេស។<br>• តម្លៃស្រូវនៅទាបផ្តល់អត្ថប្រយោជន៍ឲ្យរោងម៉ាស៊ីនកិនស្រូវមានប្រៀបជាងក្នុងការប្រកួតប្រជែងជាអន្តរជាតិ។<br>• ការបង្កបង្កើនផលស្រូវមានការកើនឡើងយ៉ាងខ្លាំង និងទិន្នផលខ្ពស់បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនបរិមាណអង្ករសម្រាប់នាំចេញ។ ទិន្នផលស្រូវនៅកម្ពុជាគឺ ៣,២ តោនក្នុងមួយហិកតាក្នុងឆ្នាំ ២០១២ (៥,៦ តោន/ហិកតា នៅវៀតណាម និង ២,៨ | • គុណភាពស្រូវទាប និងមិនមានសុគតភាពរួមទាំងបច្ចេកទេសនៃការចាត់ចែងក្រោយពេលប្រមូលផលនៅមានកម្រិតធ្វើឲ្យតម្លៃអង្ករកិនរួចមានតម្លៃទាប។<br>• និតិវិធីនាំចេញអង្កររបស់កម្ពុជានៅមានភាពសាំញ៉ាំ និងថ្លៃខ្ពស់៖ $១១ ដុល្លារ/តោន បើប្រៀបធៀបនឹងថៃត្រឹម $០,១០ដុល្លារ/តោន និង $០,០៥ ដុល្លារ/តោននៅវៀតណាម។ ចំនួនស្ថាប័នរដ្ឋច្រើនធ្វើឲ្យភារកិច្ចខ្វះជាន់គ្នានាំឲ្យតម្លៃធ្វើអាជីវកម្ម និងការនាំចេញអង្ករខ្ពស់។<br>• មានចំនួនសហគតិចតួចដើម្បីជួយចងក្រងកសិករ (ម្ចាស់កម្មសិទ្ធិដីតូចៗ) ធ្វើការទទួលបានសេវាកម្មពង្រីកនានា ព័ត៌មានទីផ្សារ និងហិរញ្ញវត្ថុមានកម្រិត និងកាត់បន្ថយអំណាចនៃការចរចារ។<br>• កិច្ចគាំទ្រកសាងសមត្ថភាពមិនទាន់គ្រប់គ្រាន់។<br>• ការផ្គត់ផ្គង់មិនទាន់សមស្រប និងទុនការងារបានកាត់ |

| | |
|---|---|
| តោន/ហិកតា នៅថៃ)។<br>• ភាពអនុគ្រោះពន្ធដែលកម្ពុជាទទួលបានពីអឺរ៉ុបនិងរុស្ស៊ីគឺជាចលករដ៏សំខាន់នៃកំណើនការនាំចេញយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ ២០០៩ មក។<br>• ឱកាសក្នុងចាប់យកភាគហ៊ុននៃទីផ្សារពីគូប្រកួតប្រជែងដទៃនៅពេលពាណិជ្ជកម្មសកលកំពុងរង្គោះរង្គើដោយសារគោលនយោបាយអង្កររបស់រដ្ឋាភិបាលប្រទេសមួយចំនួន (ដូចជាថៃនិងឥណ្ឌា)។ | បន្ថយប្រសិទ្ធភាពនិងការចំណេញពីប្រតិបត្តិការកិចស្រូវ។<br>• ការទទួលបានហិរញ្ញវត្ថុមិនគ្រប់គ្រាន់បង្ខំឲ្យម៉ាស៊ីនកិនស្រូវក្នុងស្រុកដណ្ដើមទិញស្រូវជាមួយឈ្មួញថៃ/វៀតណាម។<br>• កម្ពុជាមានសមត្ថភាពកិនស្រូវតាមវិធីសាស្ត្រទំនើបនៅមានកម្រិតដែលជាហេតុការធ្វើឲ្យការនាំចេញនៅមានទំហំតូចជាងអ្វីដែលអាចធ្វើបាន។<br>• ខ្វះជង្រុក និងមូលដ្ឋានស្តុកទំនើបសម្រាប់ម៉ាស៊ីនកិនស្រូវធំៗដើម្បីប្រមូលទិញស្រូវបន្តិចម្តងៗ។<br>• អាជីវករកិនស្រូវនៅកម្ពុជាត្រូវចំណាយថវិកាជាច្រើនលើការដឹកជញ្ជូន អគ្គិសនីប្រេងនិងកំពុងផែច្រើនជាងគូប្រជែងរបស់ខ្លួនក្នុងប្រទេសថៃនិងវៀតណាម។<br>• ពិបាកបំពេញតាមស្តង់ដារអន្តរជាតិរួមទាំងលក្ខខ័ណ្ឌនៃអង្ករនិង SPS។<br>• ខ្វះពលកម្មជំនាញដើម្បីបំរើការងារនិងគ្រប់គ្រងប្រតិបត្តិការកិននិងការសម្រិតអង្ករ។<br>• ការអនុវត្តលាយពូជស្រូវផ្សេងៗចូលគ្នារបស់កម្ពុជាក៏ជាការរារាំងអ្នកនាំចេញមិនអាចទទួលបានគុណភាពល្អដែរ។ |

| **ឱកាស** | **ការគំរាមកំហែង** |
|---|---|
| • ការចូលទៅក្នុងទីផ្សារសកលលោកកាន់តែខ្លាំងនឹងធ្វើឲ្យចំណូលបានពីឧស្សាហកម្មកាន់តែប្រសើរ និងផ្តល់សក្តានុពលចំណូលខ្ពស់សម្រាប់ ២.៩លានស្រែ។<br>• បទប្បញ្ញត្តិនានាអាចពង្រីកសេវាកម្មធ្វើឲ្យការដាំដុះស្រូវទទួលបានទិន្នផលប្រសើរជាងមុននឹងបង្កើនផលិតកម្ម និងការស្តុកស្រូវមានគុណភាពល្អជាងមុនសម្រាប់កិនជាអង្ករ។<br>• ពាណិជ្ជកម្មអង្ករសកលលោករំពឹងថានឹងរក្សាទំហំធំរបស់ខ្លួនថេរក្នុងរយៈពេលមធ្យម (គឺក្នុងបរិមាណជាង ៣០លានតោនក្នុងមួយឆ្នាំ)។<br>• មានទីផ្សារនាំចូលអង្ករធំជាមួយទិដ្ឋភាពកំណើនខ្លាំងនៅក្បែរកម្ពុជា-រួមមាន ឥណ្ឌូនេស៊ី ហ្វីលីពីន និងចិន។<br>• បន្តការពង្រីកនិងធ្វើទំនើបកម្មវិស័យកិនស្រូវនៅកម្ពុជានឹងបង្កើនការនាំចេញក្នុងតម្លៃទាបជាងគេ។ | • មីយ៉ាន់ម៉ាអាចនឹងក្លាយជាប្រទេសនាំចេញអង្ករមានតម្លៃទាបក្នុងរយៈប្រាំឆ្នាំទៀត ហើយនឹងអាចទទួលបានអត្ថប្រយោជន៍ពីភាពអនុគ្រោះពន្ធដូចកម្ពុជាដែរ។<br>• អត្រាឡើងថ្លៃក្នុងផលិតកម្មស្រូវដែលពីមុនមិនធ្លាប់មានអាចធ្វើឲ្យពិបាកទប់ទល់ជាខ្លាំង។<br>• ប្រទេសថៃជាគូប្រជែងដ៏សំខាន់ក្នុងការនាំចេញអង្ករក្រអូបខណៈវៀតណាមជាគូប្រជែងនាំចេញអង្ករមិនក្រអូប។<br>• ការត្រលប់មកវិញនៃឥណ្ឌា និងថៃជាប្រទេសនាំមុខគេក្នុងការនាំចេញអង្ករទំនងជាធ្វើឲ្យតម្លៃអង្ករសកលធ្លាក់ចុះ។<br>• ការលក់ទៅទីផ្សារអឺរ៉ុបអាចឈានដល់ចំណុចខ្ពស់បំផុតរួចហើយ។<br>• ទីផ្សារអង្ករសកលលោកមិនអាចព្យាករទុកមុនបានឡើយហើយជារឿយមានការអន្តរាគមពីរដ្ឋាភិបាលនានា។<br>• ភាពប្រែប្រួលនៃតម្លៃនិងលក្ខខ័ណ្ឌធម្មជាតិមិនពិតប្រាកដធ្វើឲ្យមានហានិភ័យខ្ពស់និងការបន្ថយប្រាក់ចំណូលពីការ |

| | |
|---|---|
| • មានក្ដីសង្ឃឹមខ្ពស់សម្រាប់ការនាំចេញអង្ករក្រអូបទៅកាន់ប្រទេសចិន។<br>• ការបំបែកការចរចាតម្លៃអង្កររួមក្នុងបណ្ដាប្រទេសតាមដងទន្លេមេគង្គនឹងអាចធ្វើឲ្យការប្រកួតប្រជែងនាំចេញអង្កររបស់កម្ពុជាប្រសើរឡើង។<br>• កម្ពុជាមានឱកាសជាច្រើនក្នុងការដោះស្រាយបញ្ហាតម្លៃអគ្គិសនីខ្ពស់តាមរយៈការប្រើប្រាស់ប្រភពថាមពលនិងបច្ចេកវិទ្យាដែលមានតម្លៃទាបជាងមុនផ្សេងៗទៀត (ដូចជាការប្រើអង្កាមជាប្រេងជីវម៉ាស់ជាដើម)។ | វិនិយោគលើវិស័យនេះ។<br>• ការពឹងផ្អែកតែទៅលើការលើកដាក់ក្នុងកុងតឺនីដើម្បីនាំចេញអង្ករនៅពេលនេះកំពុងហួសសម័យហើយ ដោយការអនុវត្តល្អបច្ចុប្បន្នគឺគេដឹកជញ្ជូនដោយមិនដាក់កុងតឺនី (break bulk rice)។<br>• បើកម្ពុជាមិនមានលទ្ធភាពផលិតអង្ករដែលសុទ្ធល្អក្នុងបរិមាណច្រើននិងគួរឲ្យទុកចិត្តទេ នឹងមានការដាក់កំហិតនៅពេលយើងចូលទៅក្នុងទីផ្សារអន្តរជាតិ។<br>• ការដំឡើងថ្លៃអគ្គិសនីអាចឲ្យម្ចាស់ម៉ាស៊ីនកិនស្រូវមានសម្ពាធខាងតម្លៃកាន់តែខ្លាំង។<br>• ការនាំចេញអង្ករក្រអូបនិងអង្ករធម្មតានឹងបន្តកើនឡើងដរាបណាមានការបន្តបង្កើនសមត្ថភាពនិងវិធីសាស្ត្រកិនស្រូវទំនើបៗនិងស្វែងរកទីផ្សារថ្មីៗថែមទៀតសម្រាប់ក្រុមហ៊ុននាំចេញថែមពីលើទីផ្សារបច្ចុប្បន្ន (អឺរ៉ុប និង រុស្ស៊ី)។<br>• មានការគំរាមកំហែងពីសត្វល្អិតនិងជំងឺថ្មីៗ។<br>• កង្វះប្រព័ន្ធឃ្លាំមើលសត្វល្អិតនិងជំងឺអាចនាំឲ្យមានការហាមឃាត់ដោយប្រទេសនាំចូលក្នុងពេលមានករណីអាក្រក់មួយកើតឡើង។ |

# ទិសដៅជំឡូងមី

## ព័ត៌មានមូលដ្ឋាន

- ផលិតកម្មដំឡូងមីសកលលោក (ដំឡូងស្រស់) គឺជាង ២៨២ លានតោនក្នុងឆ្នាំ ២០១២ គឺ ១២ ភាគរយ តិចជាងផលិតកម្មសរុបបានធ្វើពាណិជ្ជកម្មក្នុងទីផ្សារសកលលោកឆ្នាំ ២០១១។
- ផលិតកម្មដំឡូងមីកម្ពុជាបានកើនឡើងពី ១៥០,០០០ តោនក្នុងឆ្នាំ ២០០០ ដល់ ៨លានតោនក្នុងឆ្នាំ ២០១១។ ការនាំចេញដំឡូងមីកម្ពុជាជាផ្លូវការកើនបានពី $0.4 លានដុល្លារក្នុងឆ្នាំ ២០១០ ដល់ $២,៣លានដុល្លារក្នុងឆ្នាំ ២០១១។ ទោះយ៉ាងណា ផលិតកម្មដំឡូងមីកម្ពុជាភាគច្រើនបាននាំចេញជាមើមដំឡូងស្រស់ ឬចំណិតស្ងួត ហើយការនាំចេញភាគច្រើនមិនផ្លូវការនិងមិនមានការកត់ត្រាច្បាស់លាស់ទៅកាន់ប្រទេសថៃ និងវៀតណាម។
- ផ្ទៃដីដាំដុះថ្មីអាចផ្តល់ទិន្នផលលើសពី ៤០តោន ក្នុងមួយហិកតា។
- ការអនុវត្តការដាំដុះមានភាពទន់ខ្សោយធ្វើឲ្យកសិករប្រថុយប្រថាននិងការធ្វើឲ្យដីខូច រិចរិល និងទិន្នផលធ្លាក់ចុះ។ ពូជភាគច្រើននាំចូលមិនផ្លូវការនិងមិនមានការត្រួតពិនិត្យពីវៀតណាមនិងថៃនិងមានជំងឺ។ កម្ពុជាចាំបាច់អភិវឌ្ឍន៍ពូជដើមដែលស៊ាំនឹងជំងឺនិងសមស្របតាមប្រភេទដីនៅកម្ពុជា។

## ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • ដំឡូងមីជារុក្ខជាតិអាចសម្របខ្លួនតាមបរិយាកាសនិងប្រភេទដីផ្សេងៗ ដែលអាចផ្តល់ជាប្រភពចំណូលដល់កសិករដែលមានដីមិនល្អ។<br>• ជាប្រភពកាបូអ៊ីដ្រាតដែលមានតម្លៃថោក ហើយអាចបរិភោគជំនួសបាយក្នុងពេលខ្វះខាតនិងផ្តល់នូវសន្តិសុខស្បៀងយ៉ាងសំខាន់ចំពោះតំបន់ជនបទក្រីក្រនៅអាស៊ី។<br>• ការដាំដំឡូងមីនៅកម្ពុជាទទួលបានទិន្នផលខ្ពស់ក្នុងចំណោមទិន្នផលផ្តល់បំផុតលើសកលលោកគឺជាមធ្យម ២០តោន/ហិកតា។<br>• ដំឡូងមីអាចដាំជាដំណាំទោល ឬដាំជាមួយដំណាំដទៃទៀតបាន ផ្តល់ជាប្រភពចំណូលបន្ថែម។<br>• តម្លៃដែលកំពុងថ្លៃបានលើកទឹកចិត្តឲ្យមានការដាំកាន់តែច្រើន និងបង្កើនប្រាក់ចំណូលសម្រាប់កសិករ។<br>• ដំឡូងមីផ្តល់ដល់កសិករនូវពេលវេលាប្រមូលផលអាចបត់បែនតាមលក្ខខណ្ឌទីផ្សារសមរម្យ។ | • មើមដំឡូងមីឆៅងាយនឹងខូចហើយចាំបាច់មានការកែច្នៃឲ្យបានរហ័ស (កាត់ជាចំនិតរួចហាល)។<br>• ការវិនិយោគក្នុង R&D នៅខ្សោយនិងមិនមានសេវាកម្មពង្រីកគ្រប់គ្រាន់ដើម្បីគាំទ្រឲ្យប្រើពូជដែលមានទិន្នផលខ្ពស់ជាងនេះ ឬធ្វើឲ្យការអនុវត្តគ្រប់គ្រងដំណាំប្រសើរឡើយ។<br>• ការនាំចេញភាគច្រើនជាមើមដំឡូងមីស្រស់និងចំនិតស្ងួតជាលក្ខណៈមិនផ្លូវការតាមព្រំដែនថៃនិងវៀតណាម ហើយត្រូវបង់ប្រាក់ឆ្លងកាត់ព្រំដែនក្នុងតម្លៃខ្ពស់។<br>• ពូជដំឡូងមីថ្មីមានជំងឺពូជគុណភាពអន់និងការចាត់ចែងក្រោយពេលប្រមូលផលមិនបានល្អធ្វើឲ្យពិបាកក្នុងការរក្សាទិន្នផលខ្ពស់ ឬបំពេញតាមលក្ខខណ្ឌនាំចេញទៅទីផ្សារដែលមានតម្លៃខ្ពស់។<br>• មិនអាចផ្គត់ផ្គង់ឲ្យបានថេរក្នុងបរិមាណច្រើន។<br>• ការរៀបចំសម្ងួតនិងទុកដាក់មិនបានល្អធ្វើឲ្យគុណភាព |

| | |
|---|---|
| • កម្លាំងពលកម្មទាបធ្វើឲ្យការដាំដុះនិងការប្រមូលផលដំឡូងមីអាចគ្រប់គ្រងបានយ៉ាងប្រសើរ។<br>• ដំឡូងមីអាចប្រើប្រាស់បានច្រើនយ៉ាងនៅលើសកលលោកអាចជាចំណីអាហារជាចំណីសត្វជាប្រេងជីវសាស្ត្រនិងអាចប្រើក្នុងវិស័យពាក់កណ្តាលឧស្សាហកម្មទៀតផង។<br>• ការយកដំឡូងមីជំនួសពោតក្នុងឧស្សាហកម្មប្រេងជីវម៉ាស់របស់ចិនបានបើកទិផ្សារថ្មីមួយទៀតដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់ដំឡូងមីស្ងួត។<br>• ការទាក់ទាញការវិនិយោគដោយផ្ទាល់ពីបរទេសពីប្រទេសកូរ៉េខាងត្បូងនិងចិនដើម្បីបង្កើតជាចម្ការពាណិជ្ជកម្មនិងមូលដ្ឋានកែច្នៃធំៗ (សម្រាប់ប្រេងជីវម៉ាស់)។<br>• ការនាំចេញដំឡូងមីរបស់កម្ពុជាទទួលបានភាពអនុគ្រោះពន្ធពីអាស៊ាន EU និងចិន។ | ដំឡូងមីធ្លាក់ចុះនិងថ្លៃ។<br>• ឥណទានមានតម្លៃខ្ពស់ជាការរារាំងដល់កិច្ចខិតខំប្រឹងប្រែងធ្វើឲ្យការចាត់ចែងក្រោមពេលប្រមូលផលប្រសើរឡើងនិងប៉ះពាល់ចំណូលរបស់ចម្ការ។<br>• មានការវិនិយោគលើមូលដ្ឋានកែច្នៃទាបទោះជាវិស័យនេះមានការរីកចម្រើននិងឱកាសនាំចេញថ្មីៗក៏ដោយ។<br>• ការប្រកួតប្រជែងជាមួយពាណិជ្ជករថៃនិងវៀតណាមសម្រាប់ដំឡូងមីផៅធ្វើឲ្យការស្តុកសម្រាប់ការកែច្នៃក្នុងស្រុកជួបបញ្ហា ហើយធ្វើឲ្យធ្លាក់ចុះប្រាក់ចំណេញនិងកំណើនក្នុងវិស័យនេះទៀត។<br>• ខ្វះពលកម្មមានជំនាញដើម្បីប្រតិបត្តិការនិងគ្រប់គ្រងមូលដ្ឋានកែច្នៃ។<br>• មានបទពិសោធន៍មានកម្រិតក្នុងការគ្រប់គ្រងទីផ្សារសង្វាក់ផ្គត់ផ្គង់និងការនាំចេញ។<br>• ពិបាកក្នុងការបំពេញតាមស្តង់ដារ SPS សម្រាប់ទីផ្សារសំខាន់ដូចជាចិន។ |

| ឱកាស | ការគំរាមកំហែង |
|---|---|
| • គ្រួសារក្រីក្របំផុតតាមជនបទដាំដំឡូងមីនិងជាឱកាសស្វែងរកចំណូលខ្ពស់ជាងមុនធ្វើឲ្យមានការលើកកម្ពស់អត្ថប្រយោជន៍និងសុខុមាលភាព។<br>• ការធ្វើយន្តកម្មក្នុងការកាត់ដំឡូងមីនៅឯចម្ការអាចកាត់បន្ថយតម្លៃពលកម្មតាមរដូវកាលកាត់បន្ថយការខ្ជះខ្ជាយពីស្តុកដែលខូចនិងបង្កើនប្រាក់ចំណូលកសិករ។<br>• ការអភិវឌ្ឍសមត្ថភាពកែច្នៃក្នុងស្រុកនៅក្បែរតំបន់ផលិតសំខាន់នឹងបង្កើនការប្រកួតប្រជែងសម្រាប់ដំណាំដំឡូងមីក៏ដូចជាតម្លៃដំឡូងមីនៅឯចម្ការ។<br>• ការកើនឡើងនៃសមត្ថភាពកែច្នៃក្នុងស្រុកនឹងជួយដល់អនាគតទូទៅរបស់វិស័យនេះយ៉ាងខ្លាំងហើយនឹងជួយគាំទ្រដល់វិស័យកែច្នៃកសិផលផ្សេងទៀត។<br>• មានវិសាលភាពក្នុងការធ្វើពិពិធកម្មនៃការនាំចេញទៅកាន់ទីផ្សារដទៃទៀតនៅអាស៊ីពិសេសចិន កូរ៉េ ឥណ្ឌូនេស៊ីនិងម៉ាឡេស៊ី។<br>• អនុស្សារណៈនៃការយោគយល់គ្នាកម្ពុជានិងចិន ផ្តល់នូវវេទិកាដ៏សំខាន់ក្នុងការសម្របសម្រួលផ្លាស់ប្តូរបច្ចេក-ទេសនិងនាំចេញដំឡូងស្ងួតរហូតដល់ ១លានតោនក្នុងមួយឆ្នាំ។ | • បង្កើនការដាំដុះដំឡូងមី ធ្វើឲ្យកាប់ព្រៃឈើច្រើន។<br>• តម្លៃនៃធាតុចូលកសិកម្មកើនឡើងនិងកង្វះពលកម្មក្នុងពេលដាំដុះនិងប្រមូលផល។<br>• ការរក្សាការអនុវត្តដាំដុះដំឡូងមីដែលមិនល្អសមរម្យអាចនាំទៅរកការបំផ្លាញគុណភាពដី ដីរិចរិលទិន្នផលធ្លាក់ចុះនិងប្រាក់ចំណេញទាប។<br>• ការបិទព្រំដែនដែលមិនអាចស្មានទុកមុន (ដូចជាមួយថៃ)និងការទទួលបានឥណទានហិរញ្ញវត្ថុដើម្បីពង្រីកផលិតកម្មនៅមានកម្រិត។<br>• ភាពមានប្រៀបពីសំណាក់ពាណិជ្ជករថៃនិងវៀតណាមរារាំងដល់កិច្ចខិតខំប្រឹងប្រែងក្នុងការផ្លាស់ប្តូរផលិតកម្មពីក្រៅស្រុកមកក្នុងស្រុកដើម្បីបូកតម្លៃបន្ថែម និងបង្កើតប្រាក់ចំណូលខ្ពស់ដល់សហគមន៍ជនបទ។<br>• ព័ត៌មានទីផ្សារមានកម្រិតធ្វើឲ្យកសិករនៅតែលក់កសិផលនៅនឹងចម្ការក្នុងតម្លៃទាប ដោយមិនបានដឹងថាតម្លៃដំឡូងមីក្នុងតំបន់និងអន្តរជាតិខ្ពស់។<br>• ប៉ះពាល់ពីការផ្លាស់ប្តូរគោលនយោបាយប្រេងជីវម៉ាស់និងការនាំចូលរបស់ប្រទេសចិន។<br>• ជាទូទៅ រដ្ឋាភិបាលនិងវិស័យឯកជនមានការស្ទាក់ស្ទើរក្នុងការវិនិយោគឲ្យបានច្រើនលើឧស្សាហកម្មដំឡូងមី។ |

## កៅស៊ូធម្មជាតិ

### ព័ត៌មានមូលដ្ឋាន

- ការផលិតកៅស៊ូធម្មជាតិជាប្រចាំឆ្នាំនៅទូទាំងពិភពលោកមានចំនួនលើសពី ១០ លានតោន (៥០ ពាន់លានដុល្លារ) ដោយជោគវាសនានិងសង្វាក់ផ្គត់ផ្គង់នៃឧស្សាហកម្មនេះផ្តោតយ៉ាងខ្លាំងលើឧស្សាហកម្មយានយន្តរបស់ពិភពលោក។
- កម្ពុជាបាននាំចេញកៅស៊ូធម្មជាតិជិត ៥៥.០០០ តោនក្នុងឆ្នាំ ២០១២។
- នាពេលបច្ចុប្បន្ន កម្ពុជាមានចម្ការកូនដំណាំកៅស៊ូទំហំ ២២៥.០០០ ហិកតា ដែលនឹងផលិតកៅស៊ូក្នុងរយៈពេលពីរបីឆ្នាំទៀត ដែលនឹងនាំឲ្យមានកំណើនយ៉ាងខ្លាំងនៃការផលិតកៅស៊ូធម្មជាតិ។
- រដ្ឋាភិបាលបានកំណត់គោលដៅជាតិផលិតកៅស៊ូស្ងួត ២៩០.០០០ តោន នៅត្រឹមឆ្នាំ ២០២០ ជាមួយនឹងផ្ទៃដីដាំដុះសរុបកើនឡើងដល់ ៤០០.០០០ ហិកតា (បានជាជ័រកៅស៊ូលើផ្ទៃដីទំហំ ៣០០.០០០ ហិកតា)។

### ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • វិស័យនេះមានការគាំទ្រខ្លាំងពីរដ្ឋាភិបាលព្រមជាមួយនឹងកត្តាអាកាសធាតុដី សត្វល្អិត និងជំងឺមានលក្ខខណ្ឌអំណោយផលល្អសម្រាប់ចម្ការកៅស៊ូ។<br>• ផ្តល់ការងារដល់ប្រជាជន ៤០.០០០ នាក់ ភាគច្រើននៅតាមសហគមន៍ជនបទ ក្នុងឆ្នាំ ២០០៧ (ដែលអាចមានចំនួនកើនឡើងទ្វេដងនៅត្រឹមឆ្នាំ ២០១២)។<br>• ប្រជាជនប្រហែល ២១.០០០ គ្រួសារដែលដាំកៅស៊ូលក្ខណៈគ្រួសារជាមូលដ្ឋានគ្រឹះនៃវិស័យកៅស៊ូកម្ពុជា។<br>• ដើមកៅស៊ូពេញវ័យជាធម្មតាបន្តផ្តល់ទិន្នផលគួរឲ្យទុកចិត្តសម្រាប់រយៈពេល ២៥-៣០ ឆ្នាំ ផ្អែកលើការដាំដុះ ការគ្រប់គ្រង និងការទប់ស្កាត់ជំងឺបានត្រឹមត្រូវ។<br>• ជម្រើសដាំដំណាំចន្លោះដើមកៅស៊ូ ដែលទើបដាំថ្មីគឺជាប្រភពប្រាក់ចំណូលបន្ថែមនិងជួយបង់ថ្លៃចំណាយចាប់ផ្តើមដែលមានចំនួនច្រើន។<br>• ក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួចរបស់កម្ពុជាផ្តល់លទ្ធភាពរួចពន្ធចំពោះការនាំចេញកៅស៊ូធម្មជាតិចូលទៅកាន់សហគមន៍អឺរ៉ុប សហរដ្ឋអាមេរិក ជប៉ុន កូរ៉េ ដែលសុទ្ធតែជាប្រទេសនាំចូលសំខាន់ៗ។<br>• ខណៈដែលចម្ការកៅស៊ូទើបតែដាំដុះនាពេលថ្មីៗនេះធំ | • ឧបសគ្គខ្លាំងចំពោះការចូលមកក្នុងឧស្សាហកម្មនេះដោយគិតអំពីចំណាយហិរញ្ញវត្ថុជាច្រើនសម្រាប់រយៈពេលជាច្រើនឆ្នាំពី ៥ ទៅ ៧ឆ្នាំ មុនពេលដើមកៅស៊ូធំពេញវ័យនិងអាចចាប់ផ្តើមផ្តល់ជ័រ។<br>• ចំណេះដឹងមានកម្រិតអំពីបច្ចេកទេសដាំដុះទំនើបការគ្រប់គ្រងសត្វល្អិតនិងការចាត់ចែងក្រោយពេលប្រមូលផល នាំឲ្យមានទិន្នផលនិងគុណភាពទាប។<br>• ចម្ការកៅស៊ូលក្ខណៈគ្រួសារភាគច្រើនពឹងផ្អែកលើដំណាំកៅស៊ូអាយុលើស ២៥ ឆ្នាំ ដែលផ្តល់ទិន្នផលមិនល្អ។<br>• ការស្រាវជ្រាវ និងអភិវឌ្ឍមានលក្ខណៈទន់ខ្សោយ អវត្តមាននៃសេវាផ្សព្វផ្សាយ និងលទ្ធភាពទទួលព័ត៌មានទីផ្សារមិនល្អប៉ះពាល់ដល់សមត្ថភាពរបស់កសិករក្នុងការធ្វើសេចក្តីសម្រេចមួយដែលមានព័ត៌មានគ្រប់គ្រាន់ក្នុងអាជីវកម្មដែលមានលក្ខណៈប្រថុយប្រថាននេះ។<br>• ជាញឹកញាប់ការពឹងផ្អែកលើធាតុចូលសម្រាប់ផលិតកម្មដែលនាំចូលពីបរទេសបណ្តាលឲ្យជួបប្រទះនឹងការខ្វះខាតជីនិងថ្នាំសម្លាប់សត្វល្អិត។<br>• ខ្វះខាតអ្នកជៀជំរជំនាញខណៈដែលការប្រើប្រាស់កម្លាំងពលកម្មគ្មានជំនាញធ្វើឲ្យខូចខាតដល់ដើមកៅស៊ូ។ |

| | |
|---|---|
| ពេញវ័យ ហើយអាចផលិតជ័រកៅស៊ូ នោះទិន្នផលនិងសមត្ថភាពនាំចេញនឹងកើនឡើងយ៉ាងខ្លាំង។<br>• បរិស្ថានដ៏ទាក់ទាញសម្រាប់ការវិនិយោគផ្ទាល់បរទេស ព្រមជាមួយនឹងថ្លៃដីកាន់តែទាប ( និងមានច្រើនជាង ) ប្រទេសដែលនាំចេញកៅស៊ូជាលក្ខណៈប្រពៃណី ដូចជាប្រទេសម៉ាឡេស៊ី។<br>• ថ្លៃពលកម្មទាបជាអត្ថប្រយោជន៍នៃការប្រកួតប្រជែង។ | • ងាយរងគ្រោះចំពោះបម្រែបម្រួលតម្លៃនិងលទ្ធភាពទទួលបានឥណទានដើម្បីវិនិយោគឡើងវិញក្នុងវិស័យនេះនៅមានកម្រិត។<br>• ឧស្សាហកម្មកែច្នៃកៅស៊ូផ្តោតជ្រុលហួសហេតុលើផលិតផលជ័រកៅស៊ូ - ដែលជាផលិតផលប្រកួតប្រជែងបំផុត ប៉ុន្តែជាចំណែកដ៏តូចនៃពាណិជ្ជកម្មកៅស៊ូទូទាំងពិភពលោក។<br>• ស្តង់ដារកៅស៊ូកម្ពុជាពុំទទួលបានការជឿទុកចិត្តពីសំណាក់អ្នកទិញអន្តរជាតិ ដែលជាញឹកញាប់តម្រូវឲ្យទំនិញនាំចេញត្រូវធ្វើឆ្លងកាត់ការពិសោធន៍ឯករាជ្យដោយមន្ទីរពិសោធន៍ប្រទេសសឹង្ហបូរី។ |
| **ឱកាស** | **ការគំរាមកំហែង** |
| • នេះជាវិស័យដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ដែលនាំឲ្យមានការបង្កើតការងារច្រើន។ កំណើននៃការនាំចេញកៅស៊ូធម្មជាតិនឹងធ្វើឲ្យវិស័យនេះចូលរួមចំណែកកាន់តែសំខាន់ថែមទៀតក្នុងការកាត់បន្ថយភាពក្រីក្រនៅតាមសហគមន៍ជនបទ។<br>• ចក្ខុវិស័យរឹងមាំចំពោះពាណិជ្ជកម្មកៅស៊ូធម្មជាតិនៅលើពិភពលោកដែលផ្អែកលើតម្រូវការកាន់តែកើនឡើងនិងជឿទុកចិត្តបានពីសំណាក់អ្នកផលិតយានយន្តនៅលើពិភពលោក។<br>• មានទីតាំងជិតប្រទេសចិន ដែលជាប្រទេសនាំចូលកៅស៊ូធម្មជាតិធំជាងគេនៅលើពិភពលោក។<br>• ការបង្កើនគុណភាពនៃកៅស៊ូកែច្នៃនឹងបង្កើនលទ្ធភាពរកប្រាក់ចំណេញនិងតម្លៃលក់ចេញពីកសិដ្ឋានបានច្រើន។<br>• ការលើកទឹកចិត្តអ្នកកែច្នៃ ដើម្បីធ្វើពិពិធកម្មពីជ័រកៅស៊ូទៅរកផលិតផលកៅស៊ូធម្មជាតិក្នុងទម្រង់ដទៃទៀត អាចបង្កើតឱកាសទីផ្សារថ្មី។<br>• ការផ្តល់ការទទួលស្គាល់នាពេលថ្មីៗនេះចំពោះមន្ទីរពិសោធន៍កៅស៊ូកម្ពុជាគួរអនុញ្ញាតឲ្យមានលទ្ធភាពទីផ្សារកាន់តែធំទូលាយ និងការចេញលិខិតបញ្ជាក់ក្នុងស្រុកចំពោះការនាំចេញ ធៀបនឹងស្តង់ដារអន្តរជាតិ។ | • អាចប្រឈមនឹងបញ្ហាបរិស្ថានធ្ងន់ធ្ងររយៈពេលវែង ប្រសិនបើការពង្រីកឧស្សាហកម្មនេះពឹងផ្អែកលើការកាប់បំផ្លាញព្រៃឈើ។<br>• តម្លៃជ័រកៅស៊ូធម្មជាតិដែលប្រែប្រួលនៅលើពិភពលោកបានធ្វើឲ្យសេចក្តីសម្រេចវិនិយោគជាសេចក្តីសម្រេចដ៏ពិបាកនិងប្រថុយប្រថាន។<br>• កង្វះនៃអ្នកជៀជ័រដែលមានជំនាញក្នុងអំឡុងរយៈពេលដែលដើមកៅស៊ូពេញវ័យកំពុងតែមានចំនួនកើនឡើងយ៉ាងឆាប់រហ័ស បណ្តាលឲ្យមានការខាតបង់ច្រើនពីចម្ការដែលមិនបានជៀជ័រ។<br>• ថ្លៃដីកើនឡើង - ជាពិសេសដីដែលនៅជាប់នឹងផ្លូវជាសរសៃឈាមសំខាន់ៗ។<br>• ឧស្សាហកម្មកម្ពុជាស្ថិតក្រោមគូប្រកួតប្រជែងថ្នាក់តំបន់ដែលគ្រប់គ្រងលើផលិតកម្មនិងពាណិជ្ជកម្មកៅស៊ូធម្មជាតិនៅលើពិភពលោក គឺប្រទេសថៃ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ចិននិងឥណ្ឌា។<br>• បទពិសោធន៍ផ្សព្វផ្សាយទីផ្សារនិងនាំចេញនៅមានកម្រិត។<br>• បរាជ័យក្នុងការបង្កើនទិន្នផល បើទោះបីជាផ្ទៃដីទើបតែដាំដុះបានឈានដល់អាយុពេញវ័យក៏ដោយ។<br>• ការបន្តយល់ឃើញថាកម្ពុជាជាប្រទេសផ្គត់ផ្គង់កៅស៊ូធម្មជាតិដែលមានកម្រិតទាបនិងគុណភាពមិនល្អ។ |

## វិស័យទេសចរណ៍

### ព័ត៌មានមូលដ្ឋាន

- ការមកដល់នៃភ្ញៀវទេសចរណ៍អន្តរជាតិបានកើនឡើងរហូតដល់ចំនួនខ្ពស់បំផុតគឺ ១ ពាន់លាននាក់ នៅទូទាំងពិភពលោក ជាលើកទី ១ ក្នុងឆ្នាំ ២០១២។
- ចំនួនភ្ញៀវទេសចរណ៍មកដល់កម្ពុជា បានកើនឡើងពី ២៩០.០០០ នាក់ ក្នុងឆ្នាំ ១៩៩៨ រហូតដល់ជិត ៣,៦ លាននាក់ក្នុងឆ្នាំ២០១២ ដែលបានផ្តល់ប្រាក់ចំណូលលើការនាំចេញប្រមាណ $២,២ ពាន់លានដុល្លារអាមេរិក។
- រដ្ឋាភិបាលបានកំណត់គោលដៅភ្ញៀវទេសចរណ៍អន្តរជាតិឲ្យបានចំនួន ៨ លាននាក់ នៅត្រឹមឆ្នាំ ២០២០។
- វិស័យទេសចរណ៍ត្រូវបានប៉ាន់ប្រមាណថាបានផ្តល់ការងារដោយផ្ទាល់ដល់មនុស្សប្រហែល ៦២០.០០០ នាក់ (ប្រហែល ៨,១ ភាគរយនៃកម្លាំងពលកម្មសរុប) ហើយចូលរួមចំណែកប្រហែល ៩,៦ ភាគរយនៃផលទុនជាតិក្នុងស្រុកសរុប នៅក្នុងឆ្នាំ ២០១២។
- កន្លែងផ្តល់សេវាបដិសណ្ឋារកិច្ចនៅកម្ពុជាប្រមូលផ្តុំច្រើននៅខេត្តសៀមរាប រាជធានីភ្នំពេញនិងក្រុងព្រះសីហនុ។ ចាំបាច់ត្រូវធ្វើពិពិធកម្មលើគោលដៅទេសចរណ៍និងផលិតផល។ លទ្ធភាពប្រើពលកម្មជំនាញមានការកំហិតខ្លាំង។

### ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • វិស័យទេសចរណ៍ជាប្រភពនាំមុខនៃកំណើនសេដ្ឋកិច្ច និងការងារនៅកម្ពុជា។<br>• អង្គរវត្តជាបេតិកភណ្ឌពិភពលោកអង្គការយូណេស្កូ លេចធ្លោ និងល្បីឈ្មោះលើឆាកអន្តរជាតិនិងជាទិសដៅទាក់ទាញភ្ញៀវទេសចរណ៍ជាពិសេសសម្រាប់កម្ពុជា។<br>• ប្រាក់ចំណូលទទួលបានពីទេសចរណ៍បានជំរុញដល់ការអភិរក្សទ្រព្យសម្បត្តិដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ វប្បធម៌និងបរិស្ថាន។<br>• ជោគជ័យនៃយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ *"កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ"* បានចូលរួមចំណែកធ្វើឲ្យមានកំណើនខ្លាំងនៃការមកដល់របស់ភ្ញៀវទេសចរណ៍។<br>• អាស៊ីអាគ្នេយ៍នៅតែជាទីផ្សារភ្ញៀវទេសចរណ៍ដែលរីកលូតលាស់យ៉ាងឆាប់រហ័សលើពិភពលោក ដោយកម្ពុជាក៏ទទួលបានអត្ថប្រយោជន៍ផងដែរពី"ដំណើរកំសាន្តរបស់ភ្ញៀវទេសចរណ៍" មកពីប្រទេសថៃនិងវៀត-ណាម។ | • ការស្នាក់នៅជាមធ្យមមានរយៈពេលខ្លីជាងប្រទេសថៃនិងវៀតណាម។<br>• កម្ពុជាត្រូវបានគេយល់ឃើញថាជាទិសដៅទេសចរណ៍ដែល "ចំណាយតិច" ជាហេតុបង្កការលំបាកកាន់តែខ្លាំងឡើងក្នុងការជម្រុញកំណើនក្នុងសេវាកម្មទេសចរណ៍សំខាន់ៗ។ ចំណាយជាប្រចាំថ្ងៃជាមធ្យមចំពោះភ្ញៀវទេសចរណ៍ម្នាក់គឺ $១០៧ ដុល្លារអាមេរិក/ក្នុងមួយថ្ងៃ នៅឆ្នាំ ២០០៧ និង $៩៨ ដុល្លារអាមេរិក/ក្នុងមួយថ្ងៃ នៅឆ្នាំ ២០១២។<br>• ការប្រមូលផ្តុំខ្លាំងនៃសកម្មភាពទេសចរណ៍នៅតំបន់មួយចំនួនតូច (ជាពិសេស ខេត្តសៀមរាប) បណ្តាលឲ្យកើតបញ្ហាកកស្ទះនិងការលំបាក។<br>• អាជីវកម្មដែលចំណាយកាន់តែច្រើនមានតែ ៥% នៃការមកដល់របស់ភ្ញៀវទេសចរណ៍សរុបក្នុងឆ្នាំ ២០១២ ប៉ុណ្ណោះ។<br>• ចំនួនភ្ញៀវទេសចរណ៍មានតិចដែលស្នាក់នៅសណ្ឋាគារ |

| | |
|---|---|
| • កំណើនរឹងមាំនៃភ្ញៀវទេសចរណ៍ថ្នាក់តំបន់ពីអាស៊ីក៏បានជួយទប់ទុលកំណើនយឺតយ៉ាវនៃភ្ញៀវទេសចរណ៍ពីទីផ្សារលក្ខណៈប្រពៃណី (ជាពិសេស សហគមន៍អឺរ៉ុបនិងអាមេរិកខាងជើង)។<br>• កំណើននៃក្រុមហ៊ុនអាកាសចរថ្នាក់តំបន់តម្លៃទាប ដែលហោះហើរមកកាន់អាកាសយានដ្ឋានកម្ពុជា និងបែបបទសុំទិដ្ឋការងាយស្រួលបានលើកទឹកចិត្តដល់ការមកដល់របស់ភ្ញៀវទេសចរណ៍។<br>• ការធ្វើទំនើបកម្មអាកាសយានដ្ឋានសំខាន់ៗបានលើកកម្ពស់បទពិសោធន៍នៃការមកដល់/ចាកចេញពីកម្ពុជា។ | ផ្កាយប្រាំ ធ្វើឲ្យប៉ះពាល់ទឹកចិត្តក្នុងការវិនិយោគបន្ថែមទៀតលើកន្លែងស្នាក់ទំនើបនិងអគារសន្និសីទ។<br>• ច្បាប់ការពារអ្នកប្រើប្រាស់មិនរឹងមាំនិងការគ្មានការត្រួតពិនិត្យដើម្បីបង្ការការផ្សព្វផ្សាយមិនពិតអំពីសណ្ឋាគារជាពិសេសទាក់ទងនឹងការលក់តាមអ៊ិនធឺណេត។<br>• អនាម័យម្ហូបអាហារមិនល្អ។<br>• បើទោះបីជាមានកំណើននៃការប្រកួតប្រជែងក៏ដោយ ក៏ប៉ុន្តែថ្លៃសំបុត្រយន្តហោះមកកាន់/ពីកម្ពុជានៅតែមានតម្លៃថ្លៃជាងទិសដៅទេសចរណ៍ដទៃទៀតក្នុងតំបន់។<br>• ការខ្វះខាតធ្ងន់ធ្ងរនៃពលកម្មជំនាញក្នុងវិស័យបដិសណ្ឋារកិច្ច រាប់ទាំងក្នុងការគ្រប់គ្រងសណ្ឋាគារនិងម្ហូបអាហារ។<br>• ហេដ្ឋារចនាសម្ព័ន្ធនៅមានកម្រិតនិងការតភ្ជាប់ផ្លូវអាកាសក្នុងស្រុកនៅមានកម្រិតខ្លាំង ជម្រុញបន្ថែមឲ្យភ្ញៀវទេសចរណ៍ប្រមូលផ្តុំគ្នាតាមតំបន់តូចៗ។ |
| **ឱកាស** | **ការគំរាមកំហែង** |
| • យុទ្ធនាការទីផ្សារនិងផ្សព្វផ្សាយជាយុទ្ធសាស្ត្រដើម្បីតម្រង់គោលដៅលើអនុវិស័យជាក់លាក់នៃភ្ញៀវទេសចរណ៍អន្តរជាតិដែលមកកាន់កម្ពុជា។<br>• យុទ្ធសាស្ត្រជំរុញទីផ្សារថ្នាក់ជាតិ ដើម្បីទាក់ទាញពាណិជ្ជកម្មលើអនុវិស័យសម្រាប់ការរៀបចំកិច្ចប្រជុំ កម្មវិធីលើកទឹកចិត្តបុគ្គលិក សន្និសីទនិងពិព័ណ ដែលមិនទាន់មានការរីកចម្រើនខ្លាំង។<br>• ចំណាប់អារម្មណ៍ពីក្រុមហ៊ុនអាកាសចរ Gulf ក្នុងការហោះហើរមកអាកាសយានដ្ឋានភ្នំពេញនឹងជួយទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិពីមជ្ឈឹមបូព៌ា និងអឺរ៉ុប។<br>• សំណើគម្រោងទិដ្ឋការរួមសម្រាប់អាស៊ាននឹងសម្រួលដល់កំណើននៃការមកដល់របស់ភ្ញៀវទេសចរណ៍អន្តរជាតិ។ សំណើចាប់ផ្តើមបើកក្រុមហ៊ុនអាកាសចរជាតិទី ២ នឹងបង្កើនការប្រកួតប្រជែងទាំងផ្លូវក្នុងស្រុក និងទាំងផ្លូវថ្នាក់តំបន់  ហើយទាក់ទាញការមកដល់ទាំងពាណិជ្ជករផង និងទាំងភ្ញៀវទេសចរណ៍ផង។<br>• កំណើននៃកម្លាំងពលកម្មជំនាញក្នុងឧស្សាហកម្មបដិសណ្ឋារកិច្ចនិងភោជនីយដ្ឋាននឹងជួយដោះស្រាយឧបសគ្គបច្ចុប្បន្ន។ | • ការព្យាករណ៍អំពីកំណើនភ្ញៀវទេសចរណ៍អន្តរជាតិនឹងបង្កើនតម្រូវការចំពោះកម្លាំងពលកម្មជំនាញថែមទៀតក្នុងឧស្សាហកម្មបដិសណ្ឋារកិច្ច។<br>• វិស័យទេសចរណ៍ទទួលរងការធ្លាក់ចុះដោយសារវិបត្តិនយោបាយនិងសេដ្ឋកិច្ចថ្នាក់តំបន់/សកលលោក គ្រោះធម្មជាតិនិងការកើតមានជំងឺរាតត្បាត។<br>• ការសង្កត់ធ្ងន់ហួសហេតុលើការទាក់ទាញចំនួនភ្ញៀវទេសចរណ៍ឲ្យបានច្រើន ជាជាងលើការផ្តោតលើភ្ញៀវទេសចរណ៍ដែលអាចចំណាយកាន់តែច្រើន និងស្នាក់នៅរយៈពេលកាន់តែយូរ។<br>• បរាជ័យក្នុងការទាក់ទាញការរៀបចំព្រឹត្តការណ៍ពាណិជ្ជកម្មខ្នាតមធ្យមនិងធំដែលមានតម្លៃខ្ពស់ លើអនុវិស័យសម្រាប់ការរៀបចំកិច្ចប្រជុំ កម្មវិធីលើកទឹកចិត្តបុគ្គលិក សន្និសីទនិងពិព័រណ៌ដែលកត្តាចំណាយនិងថ្លៃសំបុត្រយន្តហោះគឺជាកត្តាកំណត់សំខាន់មួយក្នុងការជ្រើសរើសទីក្រុងធ្វើជាម្ចាស់ផ្ទះ។<br>• អត្ថប្រយោជន៍បង្កើតប្រាក់ចំណូលពីសកម្មភាពទេសចរណ៍ពុំត្រូវបានបែងចែកស្មើគ្នានៅទូទាំងប្រទេសកម្ពុជា។ |

| | |
|---|---|
| • ការអភិវឌ្ឍទិសដៅទេសចរណ៍ថ្មីក្នុងប្រទេស ដែលកំណត់ក្នុង*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា ២០១២* ក៏ដូចជាការពង្រឹងការផ្តល់សេវាកម្មនឹងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា និងលើកទឹកចិត្តចំពោះការស្នាក់នៅរយៈពេលកាន់តែវែង។<br>• ការធ្វើពិពិធកម្មផលិតផល និងទិសដៅទេសចរណ៍មិនត្រឹមតែបង្កើតវិស័យឲ្យកាន់តែរឹងមាំប៉ុណ្ណោះទេ ហើយថែមទាំងផ្តល់នូវអត្ថប្រយោជន៍ចំពោះការកាត់បន្ថយភាពក្រីក្រកាន់តែទូលំទូលាយថែមទៀត។ | • លំហូរសេវាកម្ម និងកម្លាំងពលកម្មជំនាញដោយសេរីនៅក្រោមសហគមន៍សេដ្ឋកិច្ចអាស៊ាន អាចធ្វើឲ្យប៉ះពាល់ដល់កម្លាំងពលកម្មជំនាញនៅកម្ពុជា បើគិតអំពីប្រាក់ឈ្នួលដែលកាន់តែខ្ពស់នៅកន្លែងផ្សេងទៀតនៅក្នុងតំបន់។ |

# វិស័យសូត្រ

## ព័ត៌មានមូលដ្ឋាន

- ការផលិតវត្ថុធាតុដើមសូត្រនៅលើពិភពលោកមានចំនួនជាមធ្យម ៨០.០០០ តោនក្នុងមួយឆ្នាំ ដោយចំនួនប្រហែល ៧០% ត្រូវបានផលិតនៅក្នុងប្រទេសចិន។
- ពាណិជ្ជកម្មក្រណាត់សូត្រនៅលើពិភពលោកត្រូវបានប៉ាន់ប្រមាណថាមានតម្លៃប្រហែល $២,៥ ពាន់លានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០១១។
- ក្នុងឆ្នាំ ២០១២ កម្ពុជាបាននាំចេញផលិតផលសូត្រតម្លៃ $៧ លានដុល្លារអាមេរិក តាមរយៈពាណិជ្ជកម្មឆ្លងកាត់ព្រំដែន និងការលក់ឲ្យភ្ញៀវទេសចរណ៍បរទេស។ ផលិតផលសូត្រប្រហែល ៩៨ ភាគរយ ត្រូវបានផលិតពីសរសៃសូត្រព៌ណសដែលបាននាំចូល គឺប្រហែល ៤០០ តោនក្នុងមួយឆ្នាំ។
- កោសេយ្យវប្បកម្មជាឧស្សាហកម្មខ្នាតតូចបំផុតនៅកម្ពុជា ដែលផលិតសរសៃសូត្របានតែ ១ តោនប៉ុណ្ណោះក្នុងឆ្នាំ ២០១២។
- មានអ្នកត្បាញជាង ២០.០០០ នាក់ នៅកម្ពុជា ដែលផ្តល់ការងារច្រើននៅតាមជនបទ។

## ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • ការផលិតសរសៃសូត្រនិងការត្បាញជាសកម្មភាពសំខាន់តាមភូមិដែលផ្តល់ការងារច្រើននៅតាមជនបទ ជាពិសេសសម្រាប់ស្ត្រីនិងជនពិការ។<br>• ក្នុងគ្រួសារមួយចំនួន ការត្បាញគឺជាប្រភពចំណូលតែមួយគត់សម្រាប់គ្រួសារជាច្រើននៅតាមជនបទ។<br>• ប្រើប្រាស់បច្ចេកទេសត្បាញដោយដៃលក្ខណៈប្រពៃណី និងបន្តអនុវត្តទម្លាប់ដែលមានតម្លៃផ្នែកប្រវត្តិសាស្ត្រ និងវប្បធម៌ចំពោះកម្ពុជា។<br>• ការអភិរក្សបច្ចេកទេសប្រពៃណីពីជំនាន់មួយទៅជំនាន់មួយ។<br>• ផលិតសូត្រដែលត្បាញដោយដៃតាមភូមិ គឺជាការបំពេញបន្ថែមលក្ខណៈធម្មជាតិចំពោះវិស័យទេសចរណ៍ដែលកំពុងរីកចម្រើន។<br>• លក្ខណៈពិសេសនៃសរសៃសូត្រព៌ណមាសពីធម្មជាតិគឺស័ក្តិសមក្នុងការបែងចែកផលិតផលសម្រេចពីការប្រកួតប្រជែង។<br>• ចំណូលចិត្តខ្លាំងពីសំណាក់អ្នកប្រើប្រាស់ក្នុងទីផ្សារក្នុងស្រុកចំពោះសូត្រត្បាញក្នុងស្រុក។ | • ការផលិតសរសៃសូត្រខ្នាតតូចនិងការខ្វះខាតនៃការទទួលស្គាល់កម្ពុជាជាប្រទេសផ្គត់ផ្គង់សរសៃសូត្រមានគុណភាពនៅលើទីផ្សារអន្តរជាតិ។<br>• ផលបានពីការចិញ្ចឹមដង្កូវនាង *ត្រូវបានយល់* ថាមានចំនួនទាបពេកដោយកសិករកម្ពុជា មិនអាចលើកទឹកចិត្តឲ្យបង្កើនការផលិតសរសៃសូត្រឡើយ។<br>• ផលិតសូត្រ ដែលផលិតក្នុងស្រុកមួយចំណែកតូចត្រូវបាននាំចេញ។<br>• ភ្ញៀវទេសចរណ៍មិនអាចទទួលបានព័ត៌មានស្តីពីវិស័យសូត្រក្នុងស្រុកយ៉ាងងាយស្រួលទេ ឬអង្កេតការប្រើប្រាស់ឧបករណ៍និងការត្បាញឡើយ។<br>• អ្នកផលិតសូត្រខ្នាតតូចៗជួបឧបសគ្គខាងការចំណាយ និងឧបសគ្គខ្វះសរសៃសូត្រគុណភាពខ្ពស់។<br>• ខ្វះការចាប់អារម្មណ៍ពីសំណាក់អ្នកវិនិយោគកំហិតការរីកលូតលាស់នៃការចិញ្ចឹមដង្កូវនាង។<br>• ខ្វះបទពិសោធន៍ទីផ្សារនាំចេញ។ |

| | |
|---|---|
| • ការចិញ្ចឹមដង្កូវនាងអាចផ្តល់ប្រាក់ចំណូលក្នុងមួយហិកតាដល់កសិករខ្ពស់ជាងការធ្វើស្រែ ឬដាំដំឡូងមី។ | |
| **ឱកាស** | **ការគំរាមកំហែង** |
| • ការបង្កើនបរិមាណសរសៃសូត្រនិងការត្បាញនៅតាមភូមិអាចលើកកម្ពស់សុខមាលភាព។<br>• វិសាលភាពក្នុងការបង្កើតផលិតផលក្នុងស្រុកដែលមានតម្លៃខ្ពស់ដោយប្រើសរសៃសូត្រព៌ណមាស។<br>• ការបង្កើនលើគុណភាព និងចំនួនផលិតផលសូត្រសម្រេចនឹងបើកចំហទីផ្សារ។<br>• តារាងពន្ធគយ ឬការរឹតត្បិតការនាំចូលដទៃទៀតមានចំនួនតិចតួចចំពោះពាណិជ្ជកម្មសូត្រពិភពលោក។<br>• ឧបករណ៍ត្បាញ  និងការត្បាញដោយដៃតាមភូមិ អាចផ្សព្វផ្សាយដល់ភ្ញៀវទេសចរណ៍ឲ្យមកទស្សនា។<br>• កំណើននៃការផលិតក្រណាត់សូត្រដោយប្រើប្រាស់សរសៃសូត្រដែលនាំចូល។<br>• កំណើននៃការផលិតក្រណាត់គុណភាពខ្ពស់ដោយប្រើប្រាស់ "សូត្រមាសខ្មែរ" ដែលតម្រង់គោលដៅលើអ្នកប្រើប្រាស់តម្លៃខ្ពស់ ( ទាំងភ្ញៀវទេសចរណ៍ និងសម្រាប់នាំចេញ )។<br>• ការបង្កើតក្រុមប្រឹក្សាសូត្រជាតិអាចលើកកម្ពស់សមត្ថភាពវិស័យនេះ ដើម្បីសម្របសម្រួលសង្វាក់ផលិតកម្មនិងរៀបចំរចនាសម្ព័ន្ធផ្គត់ផ្គង់រួមមួយ។ | • កំណើននៃតម្លៃធាតុចូលក្នុងផលិតកម្មដែលនាំចូល ដូចជាសរសៃសូត្រ ថ្នាំជ្រលក់ព៌ណ និងវត្ថុធាតុកែច្នៃ។<br>• អ្នកផ្គត់ផ្គង់សំខាន់ៗនៃសរសៃសូត្រដែលនាំចូល ដូចជាវៀតណាម បានកាត់បន្ថយផលិតកម្ម ធ្វើឲ្យវិស័យត្បាញកម្ពុជាជួបប្រទះការខ្វះខាតសរសៃសូត្រ។<br>• តម្រូវការក្នុងស្រុកចំពោះក្រណាត់សូត្រអាចនៅនឹងដោយសារតែការផ្លាស់ប្តូរនៃចំណូលចិត្តរបស់អ្នកប្រើ-ប្រាស់និងចំនួនផលិតផលជំនួស។<br>• ការចិញ្ចឹមដង្កូវនាងលើពិភពលោកមានការធ្លាក់ចុះជាទូទៅ។<br>• ការប្រកួតប្រជែងសំខាន់នៅលើទីផ្សារអន្តរជាតិពីប្រទេសថៃចំពោះផលិតផលសូត្រត្បាញដោយដៃជាលក្ខណៈប្រពៃណី។<br>• កម្ពុជាទទួលបរាជ័យក្នុងការលើកកម្ពស់គុណភាព និងចំនួនផលិតផលសូត្រសម្រេច។<br>• កម្ពុជាបរាជ័យក្នុងការថែរក្សាការផលិតសរសៃសូត្រព៌ណមាសក្នុងស្រុក (ចំនួនតែ ១ តោនប៉ុណ្ណោះបានផលិតក្នុងឆ្នាំ ២០១២)។<br>• សមត្ថភាពផ្សព្វផ្សាយទីផ្សារសម្រាប់ទំនិញសូត្រនាំចេញរបស់កម្ពុជាអាចអន់ជាងអ្នកផ្គត់ផ្គង់សូត្រធំៗនៅក្នុងតំបន់។<br>• ការស្ទាក់ស្ទើរជាទូទៅនិងការខ្វះការចាប់អារម្មណ៍ក្នុងការទ្រទ្រង់ ឬគាំទ្រវិស័យកោសេយ្យវប្បកម្មក្នុងស្រុក។ |

# សសរស្តម្ភទី ៣

ក្រោមសសរស្តម្ភទី ៣ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (CITS) ២០១៤-២០១៨ ផ្តោតលើចំណុចសំខាន់ចំនួន ៤៖

- ការលុបបំបាត់គម្លាតនៃជំនាញក្នុងវិស័យនាំចេញ
- ការបញ្ច្រាបពាណិជ្ជកម្ម
- ការពិនិត្យតាមដាន និងកៀងគរជំនួយសម្រាប់វិស័យពាណិជ្ជកម្ម
- ការពង្រឹងការចូលរួមពីវិស័យឯកជនក្នុងកម្មវិធីជំនួយសម្រាប់ពាណិជ្ជកម្ម

## ការកាត់បន្ថយគម្លាតនៃជំនាញក្នុងវិស័យនាំចេញ

### ទីផ្សារការងារ

- កម្ពុជាមានប្រជាពលរដ្ឋវ័យក្មេងច្រើន។ ប្រជាពលរដ្ឋចំនួនជិត ៦០ ភាគរយ មានអាយុ ២៥ ឆ្នាំ ឬតិចជាងនេះ។
- អ្នកស្វែងរកការងារថ្មីប្រហែល ៣០០.០០០ - ៤០០.០០០ នាក់ បានចូលមកក្នុងទីផ្សារការងារកម្ពុជាជារៀងរាល់ឆ្នាំ។
- ទិន្នន័យអត់ការងារធ្វើ និងខ្វះការងារធ្វើពិបាកក្នុងការគ្រប់គ្រង។ ភាពអត់ការងារធ្វើមានកម្រិតខ្ពស់ខ្លាំងតាមទីប្រជុំជនជាងតាមជនបទ។ អត្រាអត់ការងារធ្វើរបស់យុវជន (អាយុ ១៥ ដល់ ២៤ ឆ្នាំ) គឺខ្ពស់ជាអត្រាអត់ការងារធ្វើសរុប។ ការខ្វះការងារធ្វើអាចមានចំនួនច្រើន។
- ឧស្សាហកម្ម (ភាគច្រើនគឺ វិស័យរោងចក្រនិងសំណង់) បានចូលរួមចំណែក ២៤ ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ ២០១១ ហើយផ្តល់ការងារដល់ស្ត្រីចំនួន ១៨ ភាគរយនៃកម្លាំងពលកម្មស្រីសរុប និងបុរសចំនួន ១៦ ភាគរយនៃកម្លាំងពលកម្មបុរសសរុបនៅក្នុងឆ្នាំ ២០១១។ វិស័យរោងចក្រផ្តល់ការងារភាគច្រើនដល់ស្ត្រីជនបទដែលមានជំនាញនិងគ្មានជំនាញ ចំណែកឯវិស័យសំណង់ផ្តល់ការងារភាគច្រើនដល់បុរសជនបទ ដែលចូលធ្វើការក្នុងវិស័យសំណង់ ជាពិសេស នៅពេលរដូវដាំដុះមិនសូវជាប់រវល់។ វិស័យទាំងនេះគ្មានការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬខ្វះគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេក-ទេសវិជ្ជាជីវៈ (TVET) ដែលបំពេញសេចក្តីត្រូវការរបស់ឧស្សាហកម្មទេ។
- កសិកម្មបានចូលរួមចំណែក ៣៧ ភាគរយនៃផលិតផលក្នុងស្រុកសរុប ហើយបានផ្តល់ការងារ ៥៦ ភាគរយនៃការងារសរុបនៅក្នុងឆ្នាំ ២០១១ (ក្នុងនោះស្ត្រីមានចំនួន ៥៧ ភាគរយនិងបុរស ៥៥ ភាគរយ នៅក្នុងឆ្នាំ ២០១១)។ ចំពោះវិស័យកសិកម្ម មានសាកលវិទ្យាល័យមួយនិងកម្មវិធីបណ្តុះបណ្តាលរយៈពេល

ខ្លីជាច្រើនរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលប្រតិបត្តិការពេលចាប់ផ្តើមគម្រោង។ មិនបានផ្តល់កម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET) ឬ ការទទួលស្គាល់គុណភាពនៅក្នុងវិស័យនេះទេ។

- សេវាកម្ម (លក់រាយ និងលក់ដុំ សណ្ឋាគារ និងភោជនីយដ្ឋាន ដឹកនាំជញ្ជូន និងគមនាគមន៍ អចលនវត្ថុ ធនាគារ។ល។) បានចូលរួមចំណែក ៤០ ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅក្នុងឆ្នាំ ២០១១ ហើយបានផ្តល់ការងារដល់ស្ត្រីចំនួន ២៦ ភាគរយនៃកម្លាំងពលកម្មស្ត្រីសរុបនិងដល់បុរសចំនួន ២៩ ភាគរយនៃកម្លាំងពលកម្មបុរសសរុបនៅក្នុងឆ្នាំ ២០១១។ សិស្សបញ្ចប់សាកលវិទ្យាល័យជាច្រើននាក់កំពុងធ្វើការនៅក្នុងវិស័យនេះ ហើយជាពិសេស នៅសណ្ឋាគារនិងភោជនីយដ្ឋាន។ បច្ចុប្បន្ន កម្មវិធីអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ(TVET) ក្នុងវិស័យបដិសណ្ឋារកិច្ចកំពុងផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាលដែលបម្រើប្រជាជនក្រីក្រ។

## ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

- ករណីខុសជំនាញ គម្លាតនៃជំនាញនិងកង្វះជំនាញ មានសារៈសំខាន់ក្នុងវិស័យនាំចេញអាទិភាពទាំងអស់។
- វិស័យសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជាខ្វះការបណ្តុះបណ្តាលជាលក្ខណៈប្រព័ន្ធ ឬកម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET) ដើម្បីបណ្តុះបណ្តាលអ្នកជំនាញសម្រាប់ឧស្សាហកម្ម។ ឧទាហរណ៍ គ្មានសាលា ឬកម្មវិធីសិក្សាតម្រង់ទិសវិស័យកាត់ដេរទេ។[5] ជំនាញភាគច្រើនទទួលបាន តាមរយៈការបណ្តុះបណ្តាលក្នុងពេលបំពេញការងារ ដែលផ្តល់ជូនដោយនិយោជកផ្ទាល់។
- កម្ពុជាមានសាលាសរុប ១១.០៤៦ ក្នុងនោះមានសាលាមតេយ្យ សាលាបឋមសិក្សានិងសាលាមធ្យមសិក្សាគិតមកដល់ឆ្នាំ ២០១២។ ប្រព័ន្ធសាលារដ្ឋមិនដាក់បញ្ចូលជំនាញភាសាក្នុងកម្មវិធីសិក្សាទេ (ពោលគឺភាសាអង់គ្លេសនិងចិន) ប៉ុន្តែ កម្មវិធីសិក្សានេះត្រូវមាននៅសាលាឯកជនជាច្រើន។
- ក្នុងឆ្នាំ ២០១២ មានកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ TVET ចំនួន ៣៨ ដែលភាគច្រើនដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តោតលើប្រជាជនក្រីក្របំផុត។
- ក្នុងឆ្នាំ ២០១២ មានគ្រឹះស្ថានឧត្តមសិក្សា (HEI) សរុប ១០១។ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា (HEI) ចំនួន ១០១ មានគ្រឹះស្ថានឧត្តមសិក្សា(HEI) របស់រដ្ឋចំនួន ៣៩ និងរបស់ឯកជនចំនួន ៦២។ គ្រឹះស្ថានឧត្តមសិក្សា(HEI) មានទីតាំងនៅភ្នំពេញនិងខេត្តចំនួន ១៨។ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា (HEI) សរុបចំនួន ៦១ (៩ របស់រដ្ឋ និង ៥២ របស់ឯកជន) ស្ថិតក្រោមក្រសួងអប់រំ យុវជននិងកីឡា ហើយមានគ្រឹះស្ថានឧត្តមសិក្សា(HEI) ចំនួន ៤០ ផ្សេងទៀត ស្ថិតនៅក្រោមក្រសួងដទៃទៀតចំនួន ១៨ ក្រសួង។

[5] សមាគមរោងចក្រកាត់ដេរនៅកម្ពុជាគឺកំពុងរៀបចំបង្កើតឡើងនូវមជ្ឈមណ្ឌល TVET មួយសម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់ និងកាត់ដេរស្បែកជើង

- មាននិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យចំនួន ៣៤.៩៧៨ នាក់ ក្នុងឆ្នាំ ២០១២ ក្នុងនោះនិស្សិតស្ត្រីមានចំនួន ១៤.៤៣២ នាក់។ ចំនួននិស្សិតបញ្ចប់ការសិក្សាពីសកលវិទ្យាល័យកំពុងតែកើនឡើងរៀងរាល់ឆ្នាំ។
- ការអប់រំនិងឧស្សាហកម្មមានការតភ្ជាប់តិចបំផុត ហើយប្រព័ន្ធអប់រំនៅថ្នាក់មធ្យមសិក្សាសម្រាប់អប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET) ឬថ្នាក់សាកលវិទ្យាល័យមិនកំពុងផលិតនិស្សិតដែលបំពេញតម្រូវការរបស់ឧស្សាហកម្ម ទាក់ទងនឹងជំនាញបច្ចេកទេសនិងមូលដ្ឋានគ្រឹះ/ជំនាញផ្នែកទន់។ មានភាពចាំបាច់សំខាន់ណាស់ក្នុងការលុបបំបាត់គម្លាតរវាងអ្វី ដែលប្រព័ន្ធអប់រំផលិតបាននិងតម្រូវការរបស់ទីផ្សារការងារ។
- គំរូផ្សេងៗនៃភាពជាដៃគូរវិស័យសាធារណៈ - ឯកជន (PPP) នឹងត្រូវការដើម្បីលុបបំបាត់គម្លាតនេះ។
- មូលដ្ឋានគ្រឹះជំនាញផ្នែកទន់ខ្សោយ (ពោលគឺ ការអាននិងការគណនា ការប្រាស្រ័យទាក់ទង ការងារជាក្រុម ការដោះស្រាយបញ្ហាភាសា ។ល។) ជាបញ្ហាចម្បងមួយ ព្រោះវាជាមូលដ្ឋាននៃការបន្តសិក្សារៀនសូត្រអស់មួយជីវិត និងសមត្ថភាពរបស់និយោជកក្នុងការបណ្តុះបណ្តាលនិងបណ្តុះបណ្តាលកម្លាំងពលកម្មដែលមានស្រាប់ឡើងវិញ។

## ការវិភាគចំណុចខ្លាំងចំណុចខ្សោយឱកាសនិងការគំរាមកំហែង

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| • មានកម្លាំងពលកម្មវ័យក្មេង និងក្លៀវក្លា ចង់រៀនសូត្រ និងសម្របខ្លួនសិក្សារៀនសូត្រ។<br>• ចំនួនប្រជាជនដល់វ័យធ្វើការកើនឡើងយ៉ាងឆាប់រហ័ស និងកម្លាំងពលកម្មលើសតម្រូវការ។<br>• សេដ្ឋកិច្ចបើកចំហមានន័យថា អ្នកវិនិយោគអាចទប់ទល់នឹងកង្វះកម្លាំងពលកម្មជំនាញក្នុងស្រុក ដោយជ្រើសរើសកម្មករ ឬអ្នកវិជ្ជាជីវៈបរទេសដែលមានជំនាញ។<br>• សេដ្ឋកិច្ចរីកចម្រើនឆាប់រហ័ស ដែលមានសក្តានុពលរឹងមាំសម្រាប់កំណើនបន្ថែមទៀតនិងការបង្កើតការងារក្នុងសកម្មភាពដែលផ្តល់តម្លៃបន្ថែមកាន់តែខ្ពស់និងដែលមានឱកាសរកប្រាក់ចំណូលសម្រាប់យុវជននិងអ្នកស្វែងរកការងារធ្វើ។<br>• រដ្ឋាភិបាលបានកំណត់គម្លាតនៃជំនាញនិងការអភិវឌ្ឍជំនាញជាអាទិភាពចម្បង។ | • ការខ្វះការងារគឺជាបញ្ហាប្រឈមចំពោះកម្ពុជា ជាពិសេសចំពោះយុវជនក្នុងតំបន់ប្រជុំជន។<br>• មានការខ្វះខាតជំនាញធ្ងន់ធ្ងរទាំងជំនាញបច្ចេកទេស/ការងារ និងជំនាញមូលដ្ឋានគ្រឹះ/ផ្នែកទន់នៅក្នុងវិស័យភាគច្រើន។<br>• ផលិតភាព ជាពិសេស ក្នុងវិស័យឧស្សាហកម្មនិងសេវាកម្មជាច្រើន នៅមានកម្រិតទាប ដោយសារតែកម្លាំងពលកម្មមានកម្រិតជំនាញទាប។<br>• មានការខ្វះខាតវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកជន និងរដ្ឋ។<br>• កម្មវិធីបណ្តុះបណ្តាលក្រៅប្រព័ន្ធនិងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ(TVET)ជាច្រើនពុំមានមូលនិធិគ្រប់គ្រាន់និងមានគុណភាពមិនស្មើគ្នា ហើយមិនឆ្លើយតបនឹងតម្រូវការរបស់ទីផ្សារ។<br>• មានកម្មវិធីអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជា<br>• ជីវៈ (TVET)ល្អៗតិចតួចផ្តោតលើប្រជាជនក្រីក្រ ហើយពុំមានសម្រាប់យុវជនជាទូទៅទេ។ |

| | |
|---|---|
| | • មាននិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យជាច្រើនមានជំនាញតិចតួចនៅកន្លែងធ្វើការ។<br>• ការកំណត់តួនាទីរៀងៗខ្លួនរបស់វិស័យសាធារណៈ និងឯកជន ក្នុងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅតែជាបញ្ហាប្រឈម។<br>• មានបញ្ហាប្រឈមក្នុងការធ្វើសមាហរណកម្មសហគមន៍អ្នកផ្តល់ការអប់រំនិងបណ្តុះបណ្តាលជុំវិញយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងសេចក្តីត្រូវការរបស់វិស័យការងារ។<br>• ទីផ្សារការងារគ្មានតម្លាភាព។ មានការខ្វះខាតព័ត៌មាន និងការសម្របសម្រួលដើម្បីបំពេញការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម។<br>• ដោយសារតែកង្វះនៃព័ត៌មាន ការរំពឹងទុករបស់យុវជនដែលចូលទៅក្នុងទីផ្សារការងារជាញឹកញាប់ផ្ទុយពីការពិតជាក់ស្តែង។<br>• លទ្ធភាពទទួលបាននូវព័ត៌មាននៅតែជាបញ្ហាប្រឈមសម្រាប់យុវជនជាច្រើននាក់ ជាពិសេស យុវជនដែលមិនអាចប្រើប្រាស់ព័ត៌មានតាមទំព័រអ៊ិនធឺណេត។<br>• យុវជនយល់ថា ការអប់រំនៅសាកលវិទ្យាល័យជាគន្លឹះសំខាន់ក្នុងការផ្តល់លទ្ធភាពរបស់ពួកគេទទួលបានការងារល្អប្រសើរ និងចាត់ទុកការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET)ជាការអប់រំសម្រាប់ "កម្មករ"។<br>• ផលប៉ះពាល់ជាសក្តានុពលនៃការធ្វើសមាហរណកម្មអាស៊ានមកលើកម្ពុជា និងការធ្វើចំណាកស្រុកពុំត្រូវបានស្រាវជ្រាវ និងយល់ដឹងឡើយ។ |
| **ឱកាស** | **ការគំរាមកំហែង** |
| • ពង្រឹងការគាំទ្រស្ថាប័ន និងការសម្របសម្រួល ដើម្បីបំពេញការផ្គត់ផ្គង់ទៅនឹងតម្រូវការចំពោះកម្លាំងពលកម្ម ហើយលើកកម្ពស់លទ្ធភាពទទួលបាន និងការចែករំលែកព័ត៌មាន។<br>• លើកកម្ពស់ការអប់រំជាវិស័យមួយ ដែលតម្រូវឲ្យមានការវិនិយោគសាធារណៈ និងឯកជន ក្នុងនោះ រួមមានការប្រើគំរូភាពជាដៃគូរវាងវិស័យសាធារណៈ-ឯកជន (PPP)។ | • សមាហរណកម្មអាស៊ានអាចធ្វើឲ្យកម្លាំងពលកម្មជំនាញកម្ពុជាហូរចេញទៅប្រទេសដទៃទៀត ដែលមានប្រាក់ឈ្នួលខ្ពស់ជាងកម្ពុជា។<br>• ការតម្លើងប្រាក់ឈ្នួលក្នុងស្រុកចាំបាច់ត្រូវសមាមាត្រនឹងអត្ថប្រយោជន៍សរុបនៃកត្តាផលិតភាព។<br>• បរិយាកាសនៃទំនាក់ទំនងវិជ្ជាជីវៈមានលក្ខណៈមិនរឹងបឹង និងបង្កើតជាបញ្ហាប្រឈមចំពោះទស្សនៈទូទៅរបស់អ្នកវិនិយោគស្តីពីស្ថិរភាព និងភាពសុខដុមរមនា |

| | |
|---|---|
| • ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមសហជីព និយោជក រដ្ឋាភិបាលនិងអ្នកផ្តល់ការអប់រំ (ដូចជា ក្រុមប្រឹក្សាជំនាញនៃឧស្សាហកម្ម) តាមរយៈការរៀបចំស្ថាប័ន ដែលផ្តោតលើការពង្រឹងយុទ្ធសាស្ត្រនិងវិធីសាស្ត្រឆ្ពោះទៅមុខ ចំពោះការអភិវឌ្ឍជំនាញនិងការផ្តល់ជំនាញជាថ្មីដល់កម្លាំងពលកម្ម។<br>• លើកទឹកចិត្តការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈដោយមានការចូលរួមពីវិស័យឯកជននិងរដ្ឋ (PPP TVET)ដើម្បីផ្គត់ផ្គង់កម្លាំងពលកម្មដែលមានជំនាញដល់អ្នកវិនិយោគ។<br>• លើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ TVET ជាជម្រើសអប់រំដែលអាចទទួលបានជោគជ័យ។<br>• គិតគូរឡើងវិញនូវក្របខ័ណ្ឌច្បាប់នៃឧត្តមសិក្សា ដើម្បីបង្កើតឱកាសអប់រំផ្សេងសម្រាប់យុវជនដែលរួមមានការបង្កើតសកលវិទ្យាល័យថ្នាក់ទី ២ (វិទ្យាស្ថានពហុបច្ចេកវិទ្យា) ដែលមានឯកទេសផ្តល់កម្មវិធីសិក្សារយៈពេលខ្លី (ដូចជា រយៈពេល ២ ឆ្នាំ) ដែលផ្តោតខ្លាំងលើជំនាញដែលពាក់ព័ន្ធនឹងវិស័យជាក់លាក់។<br>• ពង្រឹងការអប់រំថ្នាក់បឋមនិងមធ្យមសិក្សា ជាពិសេសលើជំនាញភាសា។<br>• ពង្រឹងកិច្ចព្រមព្រៀងទ្វេភាគី (អនុស្សារណៈនៃការយោគយល់គ្នា) ជាមួយនឹងប្រទេសនានា ដើម្បីបណ្តុះបណ្តាលកម្មករកម្ពុជាក្នុងវិស័យជាក់លាក់។ | ក្នុងឧស្សាហកម្ម។<br>• ចាំបាច់ត្រូវបន្តរក្សាភាពបត់បែននៃការងារសម្រាប់អ្នកវិនិយោគ ដើម្បីធ្វើការច្នៃប្រឌិតថ្មីនិងពង្រីកកម្លាំងពលកម្ម តាមតម្រូវការ។<br>• ថ្ងៃឈប់សម្រាកសាធារណៈមានចំនួនច្រើនដែលប៉ះពាល់ចំពោះផលិតភាពនិងម៉ោងការងារ ជាពិសេសក្នុងរោងចក្រនិងឧស្សាហកម្មដែលប្រើកម្លាំងកម្មករច្រើន។<br>• ការងារថែមម៉ោងច្រើនហួសហេតុអាចក្លាយជាបន្ទុកលើភាពប្រកួតប្រជែងខាងតម្លៃពលកម្ម។<br>• សុខភាព អាហារូបត្ថម្ភនិងហេដ្ឋារចនាសម្ព័ន្ធគាំពារ (លំនៅដ្ឋាន អនាម័យការបណ្តុះបណ្តាល។ល។) ពុំគ្រប់គ្រាន់ ដើម្បីធានានូវតុល្យភាពរវាងការងារ និងជីវិតឡើយដែលបណ្តាលឲ្យមានផលអវិជ្ជមានលើផលិតភាពការងារ។<br>• កម្មករជំនាញធ្វើចំណាកស្រុកទៅប្រទេសជិតខាងដែលមានប្រាក់ឈ្នួលខ្ពស់។<br>• កង្វះនៃព័ត៌មានទីផ្សារការងារក្នុងតំបន់ ដើម្បីពង្រឹងសមត្ថភាពកម្ពុជាក្នុងការបណ្តុះបណ្តាលកម្លាំងពលកម្មរបស់ខ្លួនសម្រាប់កង្វះកម្លាំងពលកម្មនៅបណ្តាប្រទេសក្នុងតំបន់។ |

## ការបញ្ជ្រាបពាណិជ្ជកម្ម ការកៀរគរជំនួយសម្រាប់ពាណិជ្ជកម្ម ការចូលរួមរបស់វិស័យឯកជន

បើទោះបីជាកម្ពុជាមានកំណើន GDP ល្អរឹងមាំ លទ្ធផលនៃការនាំចេញល្អ និងកំណត់ត្រានៃការកាត់បន្ថយភាពក្រីក្រល្អ ដែលឆ្លុះបញ្ចាំងតាមរយៈវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សន៍ក៏ដោយ ក៏ប៉ុន្តែការចូលរួមចំណែកនៃពាណិជ្ជកម្មពុំត្រូវបានបញ្ជ្រាបពេញលេញក្នុងផែនការនិងយុទ្ធសាស្ត្រអភិវឌ្ឍជាតិពីមុនៗឡើយ ដូចជា*កម្មវិធីយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៨-២០១៣* (NSDP) និង *យុទ្ធសាស្ត្រចតុកោណ ២០០៨-២០១៣* (RS.) របស់រាជរដ្ឋាភិបាល។ កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ពាណិជ្ជកម្មបច្ចុប្បន្ន ដែលដឹកនាំដោយក្រសួងពាណិជ្ជកម្ម ដើម្បីគាំទ្រការរៀបចំកម្មវិធីយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងយុទ្ធសាស្ត្រជាតិ (NS) ថ្មីបង្ហាញឲ្យឃើញថា ចាំបាច់ត្រូវដោះស្រាយបញ្ហាសំខាន់ៗ ដើម្បីជៀសវាងឧបសគ្គចំពោះការបញ្ជ្រាប។ ការ

បង្កើនការពឹងផ្អែកលើទិន្នន័យត្រឹមត្រូវ ដែលទាន់ពេលវេលានិងងាយស្រួល ការពង្រឹងការចូលរួមពីសំណាក់វិស័យឯកជនក្នុងការរៀបចំគោលនយោបាយតាមវិស័យនិងការរៀបចំគម្រោងសម្រាប់ឆ្លើយតបនិងទំនាក់ទំនងកាន់តែរឹងមាំថែមទៀត រវាងការអភិវឌ្ឍពាណិជ្ជកម្មនិងការកាត់បន្ថយភាពក្រីក្រ គឺជាចំណុចមួយចំនួនតូចដែលត្រូវការការយកចិត្តទុកដាក់បន្ថែមទៀត។

ការបញ្ចូលពាណិជ្ជកម្មទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍជាតិមិនបានគ្រប់គ្រាន់ អាចបណ្តាលឲ្យមានការវិនិយោគមិនគ្រប់គ្រាន់ពីសំណាក់រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងផ្នែកចាំបាច់នានា ដូចជាហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពផលិត ការពង្រឹងភាពអង់អាចដល់ស្ត្រីនិងបាត់បង់អានុភាព ដែលពាណិជ្ជកម្មអាចមានក្នុងការបង្កើនការងារបង្កើនប្រាក់ចំណូលនិងកាត់បន្ថយភាពក្រីក្រ។ វាក៏អាចធ្វើឲ្យប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់កម្ពុជាផងដែរ ជាពិសេសនៅពេលប្រៀបធៀបជាមួយនឹងប្រទេសជិតខាងដែលសុទ្ធតែមានជំហរទទួលបាននូវផលប្រយោជន៍ពេញលេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA)។

ការបញ្ជ្រាបពាណិជ្ជកម្ម គឺជាដំណើរការធ្វើសមាហរណកម្មពាណិជ្ជកម្ម ទៅក្នុងការរៀបចំផែនការអភិវឌ្ឍតាមវិស័យ ការបង្កើតគោលនយោបាយ ការអនុវត្ត និងការត្រួតពិនិត្យ ដែលមានលក្ខណៈស៊ីសង្វាក់គ្នានិងជាយុទ្ធសាស្ត្រ។ វាមានន័យថា គឺជាការពិចារណាបញ្ហាទាក់ទងពាណិជ្ជកម្ម នៅពេលរៀបចំផែនការនិងអនុវត្តគោលបំណងអភិវឌ្ឍកាន់តែទូលំទូលាយ។ ម្យ៉ាងទៀត វាពាក់ព័ន្ធនឹងការប្រើប្រាស់ពាណិជកម្មយ៉ាងសកម្មជាមុន ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ ដែលរាប់បញ្ចូលការកាត់បន្ថយភាពក្រីក្រ។ ការបញ្ជ្រាបពាណិជ្ជកម្មធ្វើឡើងនៅ ៤ កម្រិតថ្នាក់៖ (១) ការបញ្ជ្រាបការអភិវឌ្ឍពាណិជ្ជកម្មក្នុងគោលនយោបាយជាតិនិងតាមវិស័យ (២) ការពង្រឹងស្ថាប័នដែលទទួលខុសត្រូវអនុវត្តគោលនយោបាយទាំងនោះ (៣) ការពង្រឹងកិច្ចពិភាក្សានិងភាពជាដៃគូរវាងរដ្ឋាភិបាលនិងវិស័យឯកជននិង (៤) ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងដៃគូអភិវឌ្ឍដើម្បីពង្រឹងប្រសិទ្ធភាពនៃកម្មវិធីជំនួយសម្រាប់ពាណិជ្ជកម្ម។ ខណៈកម្ពុជាគឺជាគំរូមួយសម្រាប់បណ្តាប្រទេសមានការអភិវឌ្ឍតិចតួច (LDCs) ដទៃទៀតស្តីពីតួនាទីនៃការបញ្ជ្រាបពាណិជ្ជកម្មក្នុងសេដ្ឋកិច្ចដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័សនេះ ប្រទេសកម្ពុជាចាំបាច់ត្រូវផ្តោតលើយុទ្ធសាស្ត្រអភិវឌ្ឍពាណិជ្ជកម្មជំនាន់ក្រោយ ហើយត្រៀមរៀបចំឧបករណ៍សមស្របដើម្បីអនុវត្ត។

ការឆ្លើយតបដំបូងរបស់ដៃគូអភិវឌ្ឍន៍ចំពោះវឌ្ឍនភាពសមាហរណកម្មពាណិជ្ជកម្មកម្ពុជានៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ២០០០ បានធ្វើឲ្យគេជឿជាក់ថា ការសន្យាផ្តល់ជំនួយសម្រាប់ពាណិជ្ជកម្ម ដើម្បីគាំទ្រដល់របៀបវារៈអភិវឌ្ឍពាណិជ្ជកម្មនៅកម្ពុជានៅតែជារឹងមាំ។ យន្តការស្ថាប័នរឹងមាំត្រូវបានបង្កើតឡើង តាមរយៈអភិក្រមផ្តោតលើកម្មវិធីដែលមានមហិច្ឆតាមួយ ហៅថា អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) បន្ទាប់ពីបានអនុម័តយកការវិភាគយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (DTIS) កំណែថ្មីឆ្នាំ ២០០៧។ អភិបាលកិច្ច ការតាមដានការរៀបចំផែនការយុទ្ធសាស្ត្រនិងការរៀបចំស្ថាប័នក្រោមក្របខ័ណ្ឌនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) កម្ពុជា ចំពោះអភិក្រមទូទាំងវិស័យ (SWAp)រួមមាន អនុគណៈកម្មាធិការការអភិវឌ្ឍពាណិជ្ជកម្មនិងការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម គណៈកម្មាធិការអនុវត្តអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម SWAp

(IC) ក្រុមការងារសេសរស្តម្ភទាំងបីរបស់អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (SWAp) លេខាធិការដ្ឋានអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ-DICO) មន្ត្រីបង្គោលនៃកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្ម (EIF) និងមន្ត្រីសម្របសម្រួលម្ចាស់ជំនួយ។ ការងាររបស់ពួកគេគឺធានាថា ធនធាននៃជំនួយសម្រាប់ពាណិជ្ជកម្មដែលត្រូវការខ្លាំងនោះ ត្រូវបានយកមកប្រើដោយត្រឹមត្រូវសម្រាប់គោលបំណងត្រឹមត្រូវនិងក្នុងស្មារតីនៃភាពជាម្ចាស់។ ជាលទ្ធផល បរិមាណនិងគុណភាពនៃធនធានជំនួយសម្រាប់ពាណិជ្ជកម្មដែលបានបែងចែកនៅកម្ពុជាបានកើនឡើង។

តាមរយៈការយកមកប្រើនូវការរកឃើញនិងបទពិសោធន៍ពីការត្រួតពិនិត្យឯករាជ្យលើ Trade SWAp បេសកកម្មត្រួតពិនិត្យជាប្រចាំលើកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) *របៀបវារៈបញ្ជ្រាបពាណិជ្ជកម្មជាតិ* ដែលបានរៀបចំដោយកម្មវិធីអភិវឌ្ឍនៃអង្គការសហប្រជាជាតិ-ទីក្រុងហ្សឺណែវ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត គេអាចកំណត់ឃើញនូវជំហានបន្ទាប់ ដើម្បីបញ្ជ្រាបពាណិជ្ជកម្មឲ្យកាន់តែល្អប្រសើរ ដែលមានការចូលរួមច្រើនថែមទៀតនិងកាត់បន្ថយភាពក្រីក្រ។

ទោះបីជាមានការបង្កើតគោលនយោបាយកាន់តែល្អប្រសើរ ការពង្រឹងក្របខណ្ឌស្ថាប័នសម្រាប់ការពិគ្រោះយោបល់ ការអនុវត្តនិងការត្រួតពិនិត្យតាមដាន ព្រមទាំងការពិភាក្សាជាមួយនឹងដៃគូអភិវឌ្ឍយ៉ាងណាក៏ដោយ ក៏ប៉ុន្តែធនធានសម្រាប់កំណើនត្រូវបានមើលរំលង ដូចជាការពង្រឹងលទ្ធភាពទទួលបានធនធានពីម្ចាស់ជំនួយថ្មី ការតម្រង់យុទ្ធសាស្ត្រជំនួយសម្រាប់ពាណិជ្ជកម្មឲ្យស្របនឹងនិន្នាការគោលនយោបាយពាណិជ្ជកម្មនិងសំខាន់បំផុតនោះ គឺការស្វែងការភាពជាដៃគូជាមួយនឹងវិស័យឯកជនឲ្យកាន់តែរឹងមាំនិងល្អប្រសើរក្នុងការបង្កើតគោលនយោបាយពាណិជ្ជកម្មការរៀបចំគម្រោងនិងការអនុវត្តគម្រោង។

បើទោះបីកម្មវិធីយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិទីបី (NSDP III)(២០០៩-២០១៣) លើកឡើងថា ការអភិវឌ្ឍពាណិជ្ជកម្មអាចជាប្រភពនៃការកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏ប៉ុន្តែការតភ្ជាប់នៅតែមិនរឹងមាំនៅឡើយទេ ហើយមានតែវិស័យសង្គមប៉ុណ្ណោះត្រូវបានគេមើលឃើញថា បានចូលរួមចំណែកដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ។ នៅថ្ងៃអនាគត ការវិនិយោគនិងវិធានការគាំទ្រប្រជាជនក្រីក្រគួរត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) និងយុទ្ធសាស្ត្រចតុកោណ (RS)របស់កម្ពុជា ដើម្បីឲ្យគោលនយោបាយអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិស័យឯកជនឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការកាត់បន្ថយភាពក្រីក្រ។ ផ្ទុយទៅវិញ ករណីនេះអាចធ្វើទៅបានតែតាមរយៈការប្រមូល ការចងក្រងនិងផ្សព្វផ្សាយទិន្នន័យកាន់តែល្អប្រសើរឡើង។ គំនិតផ្តួចផ្តើមស្របគ្នាត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងក្រសួងពាណិជ្ជកម្ម (ផែនការមេ ICT ការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញដោយម៉ាស៊ីនស្វ័យប្រវត្តិ ការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីកម្មសិទ្ធិបញ្ញា) នៅក្នុងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ (ការដាក់ប្រព័ន្ធស្វ័យប្រវត្តិកម្មគយច្រកចេញចូលតែមួយ) និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ប្រព័ន្ធព័ត៌មានពាណិជ្ជកម្ម ទិន្នន័យអាស៊ាន)។ គេគួរខិតខំប្រឹងប្រែង ដើម្បីធ្វើឲ្យទិន្នន័យមានលក្ខណៈស៊ីសង្វាក់គ្នា ហើយងាយស្រួលប្រើប្រាស់ដោយអ្នកបង្កើតគោលនយោបាយ។

គោលនយោបាយតាមវិស័យទើបតែបានចាប់ផ្តើមដាក់បញ្ចូលពាណិជ្ជកម្មជាអាទិភាពមួយក្នុងចំណោមអាទិភាពផ្សេងៗ។ ឧទាហរណ៍វិជ្ជមានច្បាស់មួយគឺ *ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ* ដែលគាំទ្រដោយរដ្ឋាភិបាលក្នុងខែកក្កដា ឆ្នាំ២០១០។ គេគួរខិតខំប្រឹងប្រែងថែមទៀត ដើម្បីយកតម្រាប់តាមកិច្ចខិតខំប្រឹងប្រែងជោគជ័យនេះ ក្នុងវិស័យនាំចេញដទៃទៀត ដូចជា ជំឡុងមី កៅស៊ូ ហើយអាចក្នុងឧស្សាហកម្មធន់ស្រាល ដែលបានលើកឡើងក្នុងជំពូកពាក់ព័ន្ធក្នុងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (CTIS) ២០១៤-២០១៨។ ប៉ុន្តែការបង្កើតនយោបាយបានល្អប្រសើរក៏ត្រូវឲ្យមានការចូលរួមកាន់តែល្អប្រសើរនិងស៊ីជម្រៅពីវិស័យឯកជនក្នុងដំណើរការបង្កើតគោលនយោបាយ។ ចំណុចនេះមានន័យថា វិស័យឯកជនគួររៀបចំខ្លួនឲ្យបានល្អប្រសើរ ជាពិសេសនៅថ្នាក់សមាគមន៍ ដើម្បីចូលរួមក្នុងកិច្ចពិភាក្សាដ៏មានន័យជាមួយនឹងរដ្ឋាភិបាល សិក្សាអំពីគុណវិបត្តិនៃ G-PSF ប៉ុន្មានឆ្នាំថ្មីៗនេះ ឬចូលរួមក្នុងភាពជាដៃគូរវាងវិស័យសាធារណៈ-ឯកជន (PPP)។

ជាការរំពឹងទុក អាចមានវឌ្ឍនភាពបន្ថែមទៀត ដើម្បីប្រែក្លាយយន្តការនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ឲ្យទៅជាឧបករណ៍មានអំណាចថែមទៀតដែលអាចផ្តល់ព័ត៌មានជាយុទ្ធសាស្ត្រកាន់តែរឹងមាំដល់រដ្ឋាភិបាលកម្ពុជា ដើម្បីដឹកនាំការអភិវឌ្ឍពាណិជ្ជកម្មនិងការកាត់បន្ថយភាពក្រីក្រទាំងមូល ដើម្បីពង្រឹងការគ្រប់គ្រងនិងការសម្របសម្រួលជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) ជាច្រើនឬដើម្បីដាក់បញ្ចូលវិស័យឯកជនដោយផ្ទាល់ក្នុងការគាំទ្រការអនុវត្តនូវអាទិភាពជាយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា រាប់បញ្ចូលទាំងក្នុងវិស័យពាណិជ្ជកម្ម។

ដើម្បីសម្រេចគោលដៅនេះ គេត្រូវការការអភិវឌ្ឍស្ថាប័ននិងការកសាងសមត្ថភាពបន្ថែមទៀត ដើម្បីគាំទ្ររដ្ឋាភិបាលទទួលយកការដឹកនាំទាំងស្រុងលើការសម្របសម្រួលនិងការគ្រប់គ្រងជំនួយសម្រាប់ពាណិជ្ជកម្ម (AfT)ព្រមទាំងការបញ្ជ្រាបពាណិជ្ជកម្ម។ ការរៀបចំថ្នាក់ជាតិនាពេលបច្ចុប្បន្ន សម្រាប់ការអនុវត្តអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ចាំបាច់ត្រូវលើកកម្ពស់និងធ្វើឲ្យមានលក្ខណៈងាយស្រួល ដែលក្រសួងពាណិជ្ជកម្មបានចាប់ផ្តើមអនុវត្តរួច ហើយក្នុងគោលបំណងបង្កើនការចូលរួមនិងគុណភាពនៃកិច្ចពិភាក្សាព្រមទាំងត្រៀមសម្រាប់ថ្ងៃអនាគតពេលមានជំនួយផ្សេងទៀតពីម្ចាស់ជំនួយប្រសិនបើមិនតិចជាងមុនទេ។ ការផ្តោតនៃផែនការលំអិតនៃសសរទ្រូងនីមួយៗរបស់អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) គួរកែប្រែ ដើម្បីឲ្យផែនការលំអិតនេះ មិនមែនជាឧបករណ៍សម្រាប់ការដឹកនាំនិងតាមដានការអនុវត្តគម្រោងម្ចាស់ជំនួយនីមួយៗ (ដែលផ្តោតលើសកម្មភាព និងធាតុចេញ) តែជាឧបករណ៍សម្រាប់ជួយរចនាសម្ព័ន្ធអភិបាលកិច្ចរបស់ Trade SWAp ដើម្បីតាមដានវឌ្ឍនភាពក្នុងការអនុវត្តការអភិវឌ្ឍពាណិជ្ជកម្ម និងកម្មវិធីជំនួយសម្រាប់ពាណិជ្ជកម្ម (AfT)ទាំងមូល (ដែលសង្កត់ធ្ងន់លើប្រសិទ្ធភាព និងលទ្ធផល)។ ការផ្លាស់ប្តូរពីការអនុវត្តផ្តោតលើគម្រោងនីមួយៗទៅជាផ្តោតលើកម្មវិធីវិញ នឹងជួយកម្ពុជាតម្រង់ខ្លួនឲ្យស្របនឹងសេចក្តីប្រកាសទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពជំនួយឆ្នាំ២០០៥ ដែលចែងថា៖ "ជំនួយសម្រាប់ពាណិជ្ជកម្មមានប្រសិទ្ធភាព ពេលស្ថិតក្រោមការគ្រប់គ្រងរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលដឹកនាំគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន ត្រូវបានតម្រង់ឲ្យស្របនឹងយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់ប្រទេសកំពុងអភិវឌ្ឍន៍ឲ្យមានការឯកភាពក្នុងចំណោមម្ចាស់ជំនួយ ដើម្បីជៀសវាងកុំឲ្យជាន់គ្នា តែគឺផ្តោតលើលទ្ធផល ហើយត្រូវមានការទទួលខុសត្រូវទៅវិញទៅមក"។

គេគួរចងចាំអំពីលំនាំនៃការផ្លាស់ប្តូររបៀបរបបនៅថ្នាក់តំបន់និងលើពិភពលោក នៅពេលធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រជំនួយសម្រាប់ពាណិជ្ជកម្មនៅពាក់កណ្តាលអាណត្តិរបស់ប្រទេស មួយស្របនឹងសេចក្តីប្រកាសទីក្រុង Busan។ ខណៈដែលលំនាំនៃពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាផ្លាស់ប្តូរ ដូច្នេះកិច្ចពិភាក្សាជាមួយនឹងដៃគូអភិវឌ្ឍន៍ក៏គួរផ្លាស់ប្តូរផងដែរ។ ខណៈដែលពាណិជ្ជកម្មជាមួយនឹងសហរដ្ឋអាមេរិកនិងសហគមន៍អឺរ៉ុបបានកើនឡើងយ៉ាងខ្លាំង ដោយសារតែគ្មានពន្ធនាំចូលគ្មានកូតា (DFQF) ឬគម្រោងអនុគ្រោះដទៃទៀត នៅថ្ងៃអនាគតអាចនឹងមានការរីកចម្រើនខ្លាំងនៃពាណិជ្ជកម្មជាមួយនឹងអាស៊ាន ចិននិងអាស៊ីជាទូទៅ។ ដូច្នេះ វាសំខាន់ត្រូវធ្វើទំនាក់ទំនងជាមួយនឹងម្ចាស់ជំនួយថ្មីពីតំបន់។

ជាមួយគ្នានេះដែរ នៅថ្ងៃអនាគតជំនួយសម្រាប់ពាណិជ្ជកម្មក៏អាចប្រែក្លាយទៅជាការវិនិយោគសម្រាប់ពាណិជ្ជកម្មផងដែរ គឺកិច្ចពិភាក្សាដ៏រឹងមាំរវាងវិស័យសាធារណៈនិងឯកជន មានសារៈសំខាន់ដើម្បីយល់ដឹងថាតើ មានឧបសគ្គចំពោះការវិនិយោគ និងសកម្មភាពនៃវិស័យឯកជនឬអត់និងថាតើ រដ្ឋាភិបាលអាចបែងចែកជំនួយសម្រាប់ពាណិជ្ជ-កម្មកាន់តែមានប្រសិទ្ធភាពដោយរបៀបណា។ វិស័យឯកជនគួរចូលរួមក្នុងគោលនយោបាយអភិវឌ្ឍពាណិជ្ជកម្មរបស់កម្ពុជានៅកម្រិតថ្នាក់ផ្សេងៗ។ វិស័យឯកជនគួរអាចចូលរួមចំណែកខាងហិរញ្ញវត្ថុ ផ្អែកលើការចូលរួមស៊ីជម្រៅក្នុងការរចនាប្លង់ ការបង្កើត និងការអនុវត្តគម្រោងជំនួយសម្រាប់ពាណិជ្ជកម្ម។ ក្រុមការងារវេទិការាជរដ្ឋាភិបាល-វិស័យឯកជន (G-PSF) និងក្រុមការងារការអភិវឌ្ឍវិស័យឯកជន (PSD) គួរដាក់ឲ្យប្រតិបត្តិការពេញលេញឡើងវិញ ដើម្បីការអភិវឌ្ឍភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជនកាន់តែល្អប្រសើរថែមទៀត ដើម្បីជានាការអភិវឌ្ឍវិស័យពាណិជ្ជកម្មកាន់តែមានសុខដុម ហើយការអភិវឌ្ឍសេដ្ឋកិច្ចកាន់តែរឹងមាំថែមទៀត នៅទីបំផុត។

# ផែនទីបង្ហាញផ្លូវអភិក្រមគ្របដណ្ដប់លើ
# វិស័យពាណិជ្ជកម្ម ២០១៤-២០១៨

## ផលប៉ះពាល់នៃការអភិវឌ្ឍ លទ្ធផលជាយុទ្ធសាស្ត្រ
## និងសូចនាករវាស់វែងសកម្មភាព
## សម្រាប់រយៈពេលខ្លីនិងមធ្យម

### ជាមួយសូចនាករសំខាន់ៗ

ភ្នំពេញ, មករា ឆ្នាំ២០១៤

## ពាក្យបំព្រួញ

| | | |
|---|---|---|
| AfT | Aid for Trade | ជំនួយសម្រាប់ពាណិជ្ជកម្ម |
| AFSIS | ASEAN Food Security Information System | ប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ាន |
| AFTEX | ASEAN Federation of Textile Industries | សហព័ន្ធឧស្សាហកម្មវាយនភណ្ឌអាស៊ាន |
| AIDSP | Agro-Industry Development Strategic Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិឧស្សាហកម្ម |
| ARASFF | ASEAN Rapid Alert System for Food and Feed | ប្រព័ន្ធស្បៀងនិងចំណីសត្វសម្រាប់ប្រកាសអាសន្នរហ័សសម្រាប់អាស៊ាន |
| ASEAN | Association of South East Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| ATIGA | ASEAN Trade in Goods Agreement | កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន |
| BFC | Better Factories Cambodia | ឧស្សាហកម្មប្រសើរជាងមុននៅកម្ពុជា |
| CAMFEBA | Cambodian Federation of Employers and Business Associations | សហព័ន្ធនិយោជកនិងសមាគមធុរកិច្ចកម្ពុជា |
| CARDI | Cambodia Agriculture Research & Development Institute | វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CBA | Collective Bargaining Agreement | កិច្ចព្រមព្រៀងចរចាថ្លៃរួមគ្នា |
| CCIC | China Certificate and Inspection Group, Cambodia | វិញ្ញាបនបត្រចិននិងក្រុមអធិការកិច្ចនៅកម្ពុជា |
| CDC | Council for the Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CEDEP | Cambodia Export Development and Expansion Program | កម្មវិធីអភិវឌ្ឍន៍និងពង្រីកការនាំចេញរបស់កម្ពុជា |
| CIS | Confederation of Independent States | សហព័ន្ធរដ្ឋឯករាជ្យ |
| CLV | Cambodia Laos Vietnam | កម្ពុជាឡាវវៀតណាម |
| CO | Certificate of Origin | វិញ្ញាបនបត្រប្រភពដើមទំនិញ |
| CoM | Council of Ministers | គណៈរដ្ឋមន្ត្រី |
| CSF | Classical swine fever | គ្រុនជ្រូកធម្មតា |
| CTIS | Cambodia Trade Integration Strategy | យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា |
| DAC | Development Assistance Committee | គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ |
| DAHP | Department of  Animal Health and Production | នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |

| | | |
|---|---|---|
| DFQF | Duty-Free Quota-Free | ឥតគិតពន្ធមិនគិតកូតា |
| DICO | Department of International Cooperation | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| DP | Development Partner | ដៃគូអភិវឌ្ឍន៍ |
| DTIS | Diagnostic Trade Integration Study | ការសិក្សាវិភាគសមាហរណកម្មពាណិជ្ជកម្ម |
| EBA | Everything-but-Arms | អ្វីៗទាំងអស់លើកលែងតែអាវុធ |
| EDC | Electricité du Cambodge | អគ្គិសនីកម្ពុជា |
| FDI | Foreign Direct Investment | ការវិនិយោគដោយផ្ទាល់ពីបរទេស |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| FMD | Foot and mouth disease | ជម្ងឺអុតក្តាម |
| FOCC | Footwear & Garment Order Center of Cambodia | មជ្ឈមណ្ឌលកម្ពុជាទទួលការបញ្ជាទិញស្បែកជើងនិងសម្លៀកបំពាក់ |
| FSCC | Food Safety System Certification | វិញ្ញាបនកម្មប្រព័ន្ធសុវត្ថិភាពអាហារ |
| GCC | Gulf Countries Council | ក្រុមប្រឹក្សានៃប្រទេសក្នុងឈូងសមុទ្រ |
| GDA | General Directorate of Agriculture | អគ្គនាយកដ្ឋានកសិកម្ម |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយនិងរដ្ឋាករ |
| GDP | Gross Domestic Product | ផលទុនក្នុងស្រុកសរុប |
| GHP | Good Health Practice | ទម្លាប់សុខភាពល្អ |
| GMAC | Garment Manufacturers Association of Cambodia | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| GMP | Good Manufacturing Practice | ទម្លាប់ល្អក្នុងសហគ្រាសផលិតកម្ម |
| G-PSF | Government-Private Sector Forum | វេទិការដ្ឋាភិបាលនិងវិស័យឯកជន |
| GSP | General System of Preference | ប្រព័ន្ធអនុគ្រោះទូទៅ |
| INFOSAN | International Food Safety Authorities Network | បណ្តាញអាជ្ញាធរសុវត្ថិភាពចំណីអាហារអន្តរជាតិ |
| HACCP | Hazard Analysis and Critical Control Points | ការវិភាគគ្រោះថ្នាក់និងចំណុចត្រួតពិនិត្យសំខាន់ៗ |
| IP | Intellectual Property | កម្មសិទ្ធិបញ្ញា |
| IPPC | International Plant Protection Convention | អនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ |

| | | |
|---|---|---|
| IPM | Integrated Pest Management | វិធានការចម្រុះការពារដំណាំ |
| IPR | Intellectual Property Right | សិទ្ធិលើកម្មសិទ្ធិបញ្ញា |
| ISC | Institute of Standards Cambodia | វិទ្យាស្ថានស្តង់ដារកម្ពុជា |
| ISO | International Standards Organization | អង្គការស្តង់ដារអន្តរជាតិ |
| LDC | Least Developed Country | ប្រទេសអភិវឌ្ឍន៍តិចតួច |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MICE | Meetings, Incentives, Conventions & Exhibitions | ការប្រជុំលើកទឹកចិត្តការសន្និបាតនិងពិពណ៌ |
| MoC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MoCFA | Ministry of Culture & Fine Arts | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| MoEYS | Ministry of Education, Youth and Sports | ក្រសួងអប់រំយុវជននិងកីឡា |
| MoFA | Ministry of Foreign Affairs | ក្រសួងការបរទេស |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoI | Ministry of the Interior | ក្រសួងមហាផ្ទៃ |
| MoIH | Ministry of Industry and Handicrafts | ក្រសួងឧស្សាហកម្មនិងសិប្បកម្ម |
| MoPWT | Ministry of Public Works and Transport | ក្រសួងសាធារណៈការនិងដឹកជញ្ជូន |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| MoU | Memorandum of Understanding | អនុស្សរណៈនៃការយោគយល់ |
| MoWA | Ministry of Women Affairs | ក្រសួងកិច្ចការនារី |
| NCIPR | National Committee on Intellectual Property Rights | គណៈកម្មាធិការជាតិកម្មសិទ្ធិបញ្ញា |
| NEA | National Employment Agency | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |

| | | |
|---|---|---|
| NSW | National Single Window | ប្រព័ន្ធជាតិច្រកចេញចូលតែមួយ |
| NTM | Non-Tariff Measure | វិធានការមិនមែនតារាងពន្ធ |
| OECD | Organization for Economic Cooperation and Development | អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| OIE | Office International de l'Epizootie | ការិយាល័យអន្តរជាតិជម្ងឺសត្វ |
| PPP | Public-Private Partnership | ភាពជាដៃគូសាធារណៈ-ឯកជន |
| PRC | People's Republic of China | សធារណរដ្ឋប្រជាមានិតចិន |
| PRRS | Porcine reproductive and respiratory syndrome | ប្រជុំរោគសញ្ញាលើប្រដាប់បន្តពូជនិងប្រដាប់ដង្ហើមជ្រូក |
| PSD | Private Sector Development | ការអភិវឌ្ឍវិស័យឯកជន |
| RACA | Royal Academy of Culinary Arts | រាជបណ្ឌិតសភាសិល្បៈម្ហូបអាហារ |
| RCEP | Regional Comprehensive Economic Partnership | ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់ |
| RDB | Rural Development Bank | ធនាគារអភិវឌ្ឍន៍ជនបទ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RO | Rules of Origin | វិធានប្រភពដើមទំនិញ |
| RoI | Return on Investment | ចំណូលលើការវិនិយោគ |
| RSA | Royal School of Administration | សាលាភូមិន្ទរដ្ឋបាល |
| RRIC | Rubber Research Institute of Cambodia | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា |
| RUA | Royal University of Agriculture | សកលវិទ្យាល័យភូមិន្ទកសិកម្ម |
| SEZ | Special Economic Zone | តំបន់សេដ្ឋកិច្ចពិសេស |
| SNEC | Supreme National Economic Council | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SPS | Sanitary and Phytosanitary | អនាម័យនិងភូតគាមអនាម័យ |
| S-SC | Sub-Steering Committee | អនុគណៈកម្មាធិការ |
| TA | Technical Assistance | ជំនួយបច្ចេកទេស |
| TBT | Technical Barrier to Trade | របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម |
| Trade SWAp | Trade Sector-Wide Approach | អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម |

| | | |
|---|---|---|
| TEU | Twenty-Foot Equivalent Unit | ឯកត្តាសមមូលម្ភៃហ្វូត |
| TRTA | Trade Related Technical Assistance | ជំនួយបច្ចេកទេសដែលទាក់ទងនឹងពាណិជ្ជកម្ម |
| TTRI | Trade Training and Research Institute | វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវពាណិជ្ជកម្ម |
| TVET | Technical Vocational Education and Training | ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ |
| TWG | Technical Working Group | ក្រុមការងារបច្ចេកទេស |
| VAT | Value Added Tax | ពន្ធលើតម្លៃបន្ថែម |
| WG | Working Group | ក្រុមការងារ |
| WTO | World Trade Organization | អង្គការពាណិជ្ជកម្មពិភពលោក |

| ផលប៉ះពាល់នានានៃការអភិវឌ្ឍ/គោលដៅលទ្ធផលសូចនាករវាស់វែងសកម្មភាព | សូចនាករសំខាន់ៗ | | ភាគីទទួលខុសត្រូវ |
|---|---|---|---|
| | ព័ត៌មានគ្រឹះ | ចំណុចដៅឆ្នាំ២០១៦ឬ២០១៨ | |
| **ផលប៉ះពាល់នានានៃការអភិវឌ្ឍ/គោលដៅនានានៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម** | | | |
| *គោលដៅ១នៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម៖*<br>កំណើនភាពប្រកួតប្រជែងបានរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការងារថ្មីៗ និងល្អជាងមុន | នៅអំឡុងឆ្នាំ២០០៥-២០១៣កម្ពុជាបានបំពេញគម្លាតរបស់ខ្លួនពីស្ថានភាពជាប្រទេសដែលអនុវត្តបានល្អលើគ្រប់សូចនាកររួមគ្នាក្នុងការអនុវត្តធុរកិច្ចបាន ១១,១%។ កម្ពុជានៅឆ្នាំ២០១៣គឺបានស្ថិតនៅលេខរៀងទី១៣៣ ក្នុងចំណោម១៨៥ប្រទេស។ | កម្ពុជាបានបំពេញគម្លាតរបស់ខ្លួនពីស្ថានភាពជាប្រទេសដែលអនុវត្តបានល្អលើគ្រប់សូចនាកររួមគ្នាចំនួន១០% បន្ថែមហូតដល់ឆ្នាំ២០១៨ | n.a. |
| *គោលដៅ២ នៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម៖*<br>កំណើនយ៉ាងច្រើននៃវិភាគទានពីវិស័យពាណិជ្ជកម្មទៅក្នុងផលទុនក្នុងស្រុកសរុបនិងពង្រីកពិពិធកម្មលើមូលដ្ឋាននៃការនាំចេញរបស់កម្ពុជា | កំណើនការនាំចេញទំនិញនិងសេវាជាមធ្យម ១៣%ក្នុងមួយឆ្នាំនៅក្នុងអំឡុងឆ្នាំ២០០៧-១១ | កំណើនការនាំចេញទំនិញនិងសេវាជាមធ្យម ១១%ក្នុងមួយឆ្នាំនៅក្នុងអំឡុងឆ្នាំ២០១៤-២០១៨ | n.a. |
| | វិស័យកាត់ដេរនិងទេសចរណ៍តំណាងឲ្យ ៨០% នៃទំនិញនិងសេវានាំចេញសរុបដែលបានកត់ត្រាក្នុងឆ្នាំ២០១១ | វិស័យកាត់ដេរនិងទេសចរណ៍តំណាងឲ្យ៦០% នៃទំនិញនិងសេវានាំចេញសរុបដែលបានកត់ត្រាក្នុងឆ្នាំ២០១៨ | n.a. |
| *គោលដៅ៣ នៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម៖*<br>បានពង្រឹងសមត្ថភាព RGC លើការកសាងនិងអនុវត្តគោលនយោបាយនិងយុទ្ធសាស្រ្តពាណិជ្ជកម្ម | គោលនយោបាយតាមវិស័យចំនួន១ដែលផ្តោតលើការនាំចេញ(អង្ករ) នៅឆ្នាំ២០១៣ | គោលនយោបាយតាមវិស័យបន្ថែមចំនួន៤ហូតដល់ឆ្នាំ២០១៨ដែលផ្តោតលើការនាំចេញ | n.a. |
| *គោលដៅ៤ នៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម៖* | CDC បានអនុម័តគម្រោងវិនិយោគដែលមានតម្លៃ៣៥,៥៣ពាន់លានដុល្លាអាមេរិកនៅ | គម្រោងវិនិយោគដែល CDC បានអនុម័តកើនតម្លៃទ្វេដងដល់៧០ពាន់លានដុល្លា(ឬច្រើនជាងនេះ)នៅរវាងឆ្នាំ២០១៤-២០១៨ | n.a. |

| | | | |
|---|---|---|---|
| ការឆ្លើយតបរបស់ RGC ទៅនឹងតម្រូវការរបស់វិស័យឯកជនបានកើនឡើងដោយសារការសន្ទនាប្រសើរជាងមុន | រវាងឆ្នាំ ២០០៧-២០១១ | | |
| *គោលដៅ ៥ នៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម៖*<br>បានកែលម្អសមត្ថភាពកសាងអនុវត្តនិងពិនិត្យតាមដានផែនការរបស់ RGC តាមរយៈការអនុវត្តអភិក្រមគ្របដណ្តប់លើ វិស័យពាណិជ្ជកម្ម | លទ្ធផល១៤ក្នុងចំណោម២០ក្នុងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មឆ្នាំ២០១៤-២០១៨ទទួលការគាំទ្រជំនួយបច្ចេកទេស (TA) គិតមកទល់ឆ្នាំ២០១៣។ក្នុងចំណោមលទ្ធផលចំនួន១៤ ជាមួយ TA មានតែ ១០ ដែលមាន TA ១ឬច្រើនដែលត្រួតពិនិត្យតាមដានតាមរយៈអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មក្នុងនោះ៣មាន TA ២ ឬច្រើនសម្រាប់ការ ត្រួតពិនិត្យតាមដាន (ម៉ាទ្រិក TRTA) | យ៉ាងហោចណាស់លទ្ធផលចំនួន១៦ ក្នុងចំណោមលទ្ធផលចំនួន២០ ទទួលការគាំទ្រ TA និងយ៉ាងហោចណាស់មាន TA ១ដែលតាមដានតាមរយៈអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម។ ក្នុងចំណោមលទ្ធផលចំនួន១៦យ៉ាងហោចណាស់១០មាន TA ២ ឬ ច្រើនជាងនេះដែលតាមដានតាមរយៈអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម។ | n.a. |

n.a. = មិនពាក់ព័ន្ធ

| លទ្ធផលជាយុទ្ធសាស្ត្រនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មនិងសូចនាករវាស់វែងសកម្មភាពតាមសសរស្តម្ភ | | | |
|---|---|---|---|
| ***សសរស្តម្ភទី១៖***ការបង្កើនភាពប្រកួតប្រជែងនៃក្រុមហ៊ុននាំចេញកម្ពុជានៅក្នុងទីផ្សារពិភពលោក តាមរយៈការពង្រឹងបរិយាកាសសម្រាប់ធុរកិច្ចនៃការនាំចេញ | | | |
| <u>លទ្ធផល១៖កំណែទម្រង់គោលនយោបាយពាណិជ្ជកម្មនិងការចរចានានានៃការចូលទីផ្សារ</u> | | | |
| <u>**លទ្ធផល១៖កំណែទម្រង់គោលនយោបាយពាណិជ្ជកម្មនិងការចរចាពាណិជ្ជកម្ម**</u><br>កម្ពុជាសម្រេចបានកាតព្វកិច្ចកែទម្រង់ច្បាប់ពាណិជ្ជកម្មរបស់ខ្លួននៅក្រោម WTO និង អាស៊ាន, ពង្រឹងលទ្ធភាពចូលទីផ្សារតាមរយៈការចរចាពាណិជ្ជកម្ម, ពង្រឹងតម្លាភាពនៃគោលការណ៍និងច្បាប់ពាណិជ្ជកម្មរបស់ខ្លួន | សកម្មភាពចំនួន៨៤ត្រូវបានកំណត់នៅក្នុង *កម្មវិធីការងាររបស់RGC ស្តីពីកាតព្វកិច្ចនៅក្រោម WTO និងបញ្ហាដែលពាក់ព័ន្ធនានា ឆ្នាំ២០១២-២០១៥* | ៧៥% នៃសកម្មភាពចំនួន៨៤ដែលបានកំណត់នៅក្នុង *កម្មវិធីការងាររបស់* RGC *បានអនុវត្តពេញលេញទាំងស្រុងរហូតដល់ឆ្នាំ ២០១៦* | ក្រសួងពាណិជ្ជកម្ម, ក្រសួងពាក់ព័ន្ធដែលមានភារៈទទួលខុសត្រូវលើសកម្មភាពនីមួយៗខាងផ្នែកច្បាប់និងស្ថាប័ន |
| | វិធានប្រភពដើមទំនិញភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់ត្រូវបានចរចា | ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយថ្នាក់តំបន់វិធានប្រភពដើមទំនិញអនុញ្ញាតឲ្យមានការប្រមូលផ្តុំក្នុងចំណោមសមាជិករបស់ខ្លួនទាំងអស់រហូតដល់ឆ្នាំ២០១៨ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្មក្រសួងពាក់ព័ន្ធ |
| **សកម្មភាពរយៈពេលខ្លី៖២០១៤-២០១៦** | | | |
| ***សូចនាករវាស់វែងសកម្មភាព១៖***<br>វិធានប្រភពដើមទំនិញដែលផ្តល់ការអនុគ្រោះនៅតែស្ថិតក្នុងការអនុវត្តនៅក្រោមEBA របស់EUនិង DFQFរបស់កាណាដា | ROsក្នុង EBA និងDFQF របស់កាណាដាផ្តល់ការអនុគ្រោះប៉ុន្តែប្រទេសនានាដែលឈានផុតកម្មវិធី GSP លែងអាចប្រើប្រាស់ចាប់តាំងពីការអនុវត្តរហូតមកដល់ពេលនេះបានទៀតហើយ | កម្ពុជាចរចាជាមួយ EU និងកាណាដាដើម្បីធានាថាប្រទេសណាមួយដែលឈានហួសកម្មវិធីGSP គ្មានឥទ្ធិពលលើការអនុវត្តរហូតមកដល់ពេលនេះរបស់កម្ពុជាសម្រាប់គោលដៅ ROs ឡើយ | MEF, MoC (សកម្មភាពដែលត្រូវអនុវត្តជាបន្ទាន់) |
| ***សូចនាករវាស់វែងសកម្មភាព២៖***<br>រៀបចំជាសេចក្តីព្រាងនិងប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានប្រភពដើមទំនិញ | នៅឆ្នាំ២០១៣គ្មានសេចក្តីព្រាង | ច្បាប់បានអនុម័តដោយរដ្ឋសភានិងចុះហត្ថលេខាប្រកាសឲ្យប្រើនៅឆ្នាំ២០១៦ | MoC, MEF, CoM |
| ***សូចនាករវាស់វែងសកម្មភាព៣៖***<br>បញ្ចប់និងប្រកាសឲ្យប្រើច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម | មានសេចក្តីព្រាងច្បាប់នៅឆ្នាំ២០១៣ | ច្បាប់ត្រូវបានរដ្ឋសភាអនុម័តនិងចុះហត្ថលេខាប្រកាសឲ្យប្រើនៅឆ្នាំ២០១៦ | MoC, CoM, |

| | | | |
|---|---|---|---|
| ***សូចនាករវាស់វែងសកម្មភាព៤៖***<br>បញ្ចប់និងប្រកាសឲ្យប្រើច្បាប់ស្តីពីSEZs | មានសេចក្តីព្រាងច្បាប់នៅឆ្នាំ ២០១៣ | ច្បាប់ត្រូវបានរដ្ឋសភាអនុម័តនិងចុះហត្ថលេខាប្រកាសឲ្យប្រើនៅឆ្នាំ២០១៦ | CDC, CoM, |
| ***សូចនាករវាស់វែងសកម្មភាព៥៖***<br>បញ្ចប់និងប្រកាសឲ្យប្រើច្បាប់ស្តីពីការវិនិយោគដែលបានកែសម្រួល | មានសេចក្តីព្រាងច្បាប់វិសោធនកម្មនៅឆ្នាំ ២០១៣ | ច្បាប់ត្រូវបានរដ្ឋសភាអនុម័តនិងចុះហត្ថលេខាប្រកាសឲ្យប្រើនៅឆ្នាំ២០១៦ | CDC, CoM |
| ***សូចនាករវាស់វែងសកម្មភាព៦៖***<br>បញ្ចប់និងប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង | មានសំណៅដើមដំបូងៗនៃសេចក្តីព្រាងច្បាប់នៅឆ្នាំ ២០១៣ | ច្បាប់ត្រូវបានរដ្ឋសភាអនុម័តនិងចុះហត្ថលេខាប្រកាសឲ្យប្រើនៅឆ្នាំ២០១៦ | MoC, CoM |
| ***សូចនាករវាស់វែងសកម្មភាព៧៖***<br>ធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តិស្តីពីស្តង់ដារដើម្បីឲ្យស្របគ្នាជាមួយ WTO-(ដូចគ្នានឹងលទ្ធផល៤, សកម្មភាពរយៈពេលខ្លី៩) | ច្បាប់ស្តីពីស្តង់ដារមិនស្របជាមួយ WTO | ច្បាប់ស្តីពីស្តង់ដារត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០១៦និងមានលក្ខណៈស្របជាមួយ WTO | MoIH,  CoM |
| ***សូចនាករវាស់វែងសកម្មភាព៨៖***<br>គោលការណ៍និងបទប្បញ្ញត្តិស្តីពីពាណិជ្ជកម្ម (ដែលរួមទាំងតារាងពន្ធ) ដែលអាចទាញយកពីគេហទំព័រដោយមិនគិតថ្លៃ | គ្មានវេបសាយដែលមានបង្ហាញជារួមអំពីច្បាប់និងបទប្បញ្ញត្តិពាណិជ្ជកម្មនានា (ដែលរួមទាំងច្បាប់ស្តីពីSPS និង TBT) គិតដល់ឆ្នាំ២០១៣ | ព័ថលព័ត៌មានជាតិនៅក្នុងគេហទំព័រ www.ocm.gov.kh ជាភាសាខ្មែរនិងអង់គ្លេសបានដាក់ឲ្យដំណើរការពេញលេញនៅឆ្នាំ២០១៦។គេហទំព័រព័ត៌មានពាណិជ្ជកម្មរបស់ MoC (រួមទាំងកន្លែងរក្សាទុកព័ត៌មានពាណិជ្ជកម្មជាតិរបស់អាស៊ាន) ដំណើរការបានពេញលេញ | CoM, MEF, MoC |
| ***សូចនាករវាស់វែងសកម្មភាព៩៖***<br>វិធានការច្បាប់ដើម្បីធានាឲ្យមានភាពស្របជាមួយ ATIGA (មាត្រា៥៦ស្តីពីប្រតិបត្តិករដែលបានទទួលការអនុញ្ញាត, មាត្រា ៦២ ស្តីពីការអនុញ្ញាតជាមុន, មាត្រា៦១ស្តីពីសវនកម្មនៅក្រោយការបញ្ជាក់, មាត្រា ៥៧ ស្តីពីការឲ្យតម្លៃពន្ធគយ) ត្រូវបានអនុម័ត | ប្រកាសស្តីពីការអនុញ្ញាតជាមុនចេញដោយ GDCE នៅខែមករា២០១៣។គ្មានសកម្មភាពឬមានក្នុងកម្រិតកំណត់ដែលអនុវត្តនៅកន្លែងផ្សេងៗ។ | ភាពស្របគ្នាពេញលេញជាមួយ ATIGA សម្រេចបាននៅចុងឆ្នាំ២០១៦ | GDCE, MoC និងស្ថាប័នពាក់ព័ន្ធដទៃទៀត |

| | | | |
|---|---|---|---|
| *សូចនាករវាស់វែងសកម្មភាព១០៖* កម្មវិធីការងាររបស់ជាតិស្តីពីNTMs ដែលមានភាពស្របគ្នាជាមួយលក្ខខណ្ឌរបស់អាស៊ានត្រូវបានដាក់ឲ្យអនុវត្ត | អនុក្រឹត្យដើម្បីបង្កើតគណៈកម្មាធិការអន្តរក្រសួងស្តីពី NTMs រៀបចំជាសេចក្តីព្រាងក្រោមការដឹកនាំរបស់ MEF នៅពាក់កណ្តាលឆ្នាំ២០១៣ | អនុក្រឹត្យនេះបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។ គណៈកម្មាធិការត្រូវបានបង្កើតនិងដាក់ឲ្យដំណើរការ | ក្រសួងពាក់ព័ន្ធត្រូវបានបញ្ចូលនៅក្នុងគណៈកម្មាធិការអន្តរក្រសួង NTM |
| *សូចនាករវាស់វែងសកម្មភាព១១៖* ត្រីកោណអភិវឌ្ឍន៍របស់CLV ផ្តោតលើវិស័យកៅស៊ូបានដំណើរការដូចការគ្រោងទុកដោយមានព័ត៌មានអំពីផែនការសកម្មភាពរបស់ប្រទេសទាំងបី (ដូចលទ្ធផល១៤, សកម្មភាពរយៈពេលខ្លី៧) | កិច្ចប្រជុំកំពូលលើកទី៧នៃប្រធានរដ្ឋស្តីពីត្រីកោណអភិវឌ្ឍន៍CLV បានធ្វើឡើងនៅវៀងច័ន្ទថ្ងៃ១២ខែមីនាឆ្នាំ២០១៣ដែលបានស្នើឲ្យរៀបចំផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍវិស័យកៅស៊ូនៅក្នុងត្រីកោណនេះ | ផែនការសកម្មភាពត្រូវបានរៀបចំពេញលេញសម្រាប់កិច្ចប្រជុំកំពូលត្រីកោណអភិវឌ្ឍន៍លើកទី៨របស់ CLV តាមការស្នើសុំនៅក្នុងកិច្ចប្រជុំកំពូលលើកទី៧ | MEF, MoC, MAFF, SNEC |
| **សកម្មភាពរយៈពេលមធ្យម៖២០១៦-២០១៨** | | | |
| *សូចនាករវាស់វែងសកម្មភាព១៖* ក្របខ័ណ្ឌច្បាប់សម្រាប់សុវត្ថិភាពអាហារត្រូវបានកែលម្អដែលរួមទាំងការអនុម័តនិងប្រកាសឲ្យប្រើច្បាប់ថ្មីស្តីពីសុវត្ថិភាពអាហារ (ដូចលទ្ធផល៤, សកម្មភាពរយៈពេលមធ្យម២) | គ្មានក្របខ័ណ្ឌច្បាប់សមស្របសម្រាប់ការអនុវត្តឡើយ | ក្របខ័ណ្ឌច្បាប់ត្រូវបានអនុម័តដែលស្របគ្នាជាមួយគោលការណ៍របស់ WTO/SPS និងអាស៊ាននិងទម្លាប់ល្អជាអន្តរជាតិរហូតដល់ឆ្នាំ២០១៨ | MoC/កាំកុងត្រូល, MoH, MAFF, MoIH, MoT, MEF, CoM |
| *សូចនាករវាស់វែងសកម្មភាព២៖* ដំណើរការជូនដំណឹងដល់ WTO ត្រូវបានពង្រឹង | គ្មានការជូនដំណឹងគិតមកទល់ឆ្នាំ២០១៣ | សកម្មភាពទាំងអស់ដែលពាក់ព័ន្ធជាមួយWTOស្តីពីច្បាប់និងបទប្បញ្ញត្តិនានាដែលមាននៅក្នុងកម្មវិធីការងារWTOឆ្នាំ២០១២-២០១៥របស់RGCឬនៅក្នុងផែនទីបង្ហាញផ្លូវនេះត្រូវបានជូនដំណឹងទៅ WTO | MoC,MoIH, ICS, MAFF, MoH |
| *សូចនាករវាស់វែងសកម្មភាព៣៖* | | រហូតដល់ឆ្នាំ២០១៦កម្រងទិន្នន័យពេញ | |

| | | | |
|---|---|---|---|
| វិធានការក្រៅពីតារាងពន្ធត្រូវបានចាត់ជាលំដាប់ពិនិត្យកែសម្រួលនិងជូនដំណឹងទៅលេខាធិការដ្ឋានអាស៊ានតាមកាតព្វកិច្ចនៅក្រោមកម្មវិធីការងាររបស់អាស៊ានស្តីពី NTM | គ្មានសកម្មភាពគិតមកទល់ឆ្នាំ២០១៣ | លេញមួយអំពី NTMs ត្រូវបានបង្កើត និងការជូនដំណឹងត្រូវបានធ្វើឡើងជាទៀងទាត់ទៅលេខាធិការដ្ឋានអាស៊ាន។ រហូតដល់ឆ្នាំ២០១៨ ស្តុកបច្ចុប្បន្នអំពី NTM ត្រូវបានពិនិត្យនិងកែសម្រួល។រហូតដល់ឆ្នាំ ២០១៨ ផលប៉ះពាល់នៃ NTMs ថ្មីៗទាំងអស់ត្រូវបានវាយតម្លៃដោយគណៈកម្មាធិការអន្តរក្រសួងស្តីពីNTMs ហើយ NTMs មួយចំនួនត្រូវបានកាត់បន្ថយឬលុបបំបាត់។ | MoC, MEF, ស្ថាប័នពាក់ព័ន្ធ |
| *សូចនាករវាស់វែងសកម្មភាព៣៖* បានកែលម្អលទ្ធភាពទទួលបានការប្រមូលផ្តុំការប្រើប្រាស់ទិន្នន័យស្ថិតិនិងទិន្នន័យពាណិជ្ជកម្មដើម្បីជួយនៅក្នុងការវាយតម្លៃនិងការបង្កើតអន្តរាគមន៍ពាណិជ្ជកម្មសមស្រប (ដូចក្នុងលទ្ធផល១៨, សកម្មភាពរយៈពេលខ្លី៣) | ទិន្នន័យផ្លូវការអំពីពាណិជ្ជកម្មរបស់កម្ពុជាត្រូវបានដកស្រង់ពីកម្រងទិន្នន័យដែល GDCE រក្សាទុក (ទិន្នន័យគយ), MoC (អំពីCOs, ការនាំចូល/នាំចេញ,អាជ្ញាប័ណ្ណ), MEF (កន្លែងរក្សាទុកព័ត៌មានអំពីពាណិជ្ជកម្ម), និង MAFF (វិញ្ញាបនបត្រSPS)។ គ្មានរចនាសម្ព័ន្ធសម្រាប់ប្រៀបធៀប និងធានាសង្គតិភាពរវាងប្រភពនានាឡើយ, ប្រព័ន្ធត្រួតពិនិត្យគុណភាពមានកម្រិតកំណត់, គ្មានឧបករណ៍សម្រាប់ប្រៀបធៀប/កំណត់ចំណុចចាប់ផ្តើមនៃស្ថិតិរបស់កម្ពុជាដើម្បីឆ្លុះបញ្ចាំងពីស្ថិតិទាំងនេះឡើយ។ | ចាប់ផ្តើមនៅឆ្នាំ២០១៦,វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវពាណិជ្ជកម្មនៃMoC (TTRI) ចេញផ្សាយទិន្នន័យពាណិជ្ជកម្មប្រចាំឆ្នាំដែលបូកសរុបនិងសម្របសម្រួលទិន្នន័យដែលស្រង់បានពីប្រភពរដ្ឋាភិបាល និងធានាឲ្យមានសង្គតិភាពកាន់តែខ្លាំងឡើងជាមួយទិន្នន័យពី Comtrade | GDCE, MoC, MEF. MAFF, វិទ្យាស្ថានជាតិស្ថិតិ |
| | លំបាកទទួលបានទិន្នន័យខ្លះពី MoC | ទិន្នន័យទាំងអស់របស់MoC បានធ្វើបច្ចុប្បន្នភាពតាមរយៈគេហទំព័រ កែទម្រង់ជាថ្មីរបស់MoC | MoC |

| លទ្ធផល២៖កំណែទម្រង់កិច្ចសម្រួលពាណិជ្ជកម្ម | | | |
|---|---|---|---|
| **លទ្ធផល២៖កិច្ចសម្រួលពាណិជ្ជកម្ម** កម្ពុជាបង្កើនភាពប្រកួតប្រជែងរបស់ខ្លួនតាមរយៈការកាត់បន្ថយថ្លៃចំណាយសម្រាប់ការនាំចេញ/ការនាំចូល | ថ្លៃចំណាយរបស់កម្ពុជាសម្រាប់ការនាំចេញ/នាំចូលឆ្នាំមាន១៣៦% នៃតួលេខមធ្យមអាស៊ាន-៦ (ពី WB/IFC *ការអនុវត្តធុរកិច្ច*) | ថ្លៃចំណាយរបស់កម្ពុជាសម្រាប់ការនាំចេញ/នាំចូលឆ្នាំ២០១៨កាត់បន្ថយដល់១២០% នៃតួលេខមធ្យមអាស៊ាន-៦(៩៥២ដុល្លា/កុងតឺន័រនៅក្នុង *ការអនុវត្តធុរកិច្ច*២០១២) | ស្ថាប័នទាំងអស់តាមព្រំប្រទល់ |
| | ការចំណាយពេលរបស់កម្ពុជាក្នុងឆ្នាំ២០១១សម្រាប់បែបបទបញ្ចេញទំនិញគឺ២៤ ថ្ងៃ ធៀបនឹង១៦ថ្ងៃ សម្រាប់តួលេខមធ្យមអាស៊ាន-៦ | ពេលវេលាសម្រាប់បែបបទបញ្ចេញទំនិញនៅឆ្នាំ២០១៨ត្រូវបានកាត់បន្ថយមកត្រឹមតួលេខមធ្យមអាស៊ាន-៦ | ទីភ្នាក់ងារទាំងអស់តាមព្រំប្រទល់ |
| **សកម្មភាពសម្រាប់រយៈពេលខ្លី៖ ២០១៤-២០១៦** | | | |
| *សូចនាករវាស់វែងសកម្មភាព១៖* ច្បាប់ និងបទប្បញ្ញត្តិពាណិជ្ជកម្ម(ដែលរួមទាំងតារាងពន្ធគយ) មានដាក់ផ្សាយដោយឥតគិតថ្លៃតាមគេហទំព័រ (ដូចក្នុងលទ្ធផល១, សកម្មភាពរយៈពេលខ្លី៧) | គ្មានគេហទំព័រជាមួយអត្ថបទច្បាប់និងបទប្បញ្ញត្តិអំពីពាណិជ្ជកម្ម(ដែលរួមទាំងសម្រាប់ SPS និង TBT) គិតមកទល់ឆ្នាំ២០១៣ | ព័ថលព័ត៌មានជាតិនៅលើវេបសាយ www.ocm.gov.kh ជាភាសាខ្មែរនិងអង់គ្លេសដំណើរការពេញលេញនៅឆ្នាំ២០១៦។ គេហទំព័រព័ត៌មានពាណិជ្ជកម្មរបស់ MoC (កន្លែងរក្សាទុកព័ត៌មានពាណិជ្ជកម្មជាតិរបស់អាស៊ាន) មានដំណើរការពេញលេញ | CoM, MEF, MoC (2014) |
| *សូចនាករវាស់វែងសកម្មភាព២៖* វឌ្ឍនភាពរបស់កម្ពុជាឆ្ពោះទៅប្រតិបត្តិការតាមកុំព្យូទ័រទាំងស្រុងនូវឯកសារនានាដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម | ការចេញវិញ្ញាបនបត្រប្រភពដើមទំនិញធ្វើឡើងដោយដៃនៅឆ្នាំ២០១៣។ ផែនការកែទម្រង់វិញ្ញាបនបត្រប្រភពដើមទំនិញត្រូវបាន MoC ដាក់ឲ្យប្រើប្រាស់នៅខែវិច្ឆិកា ឆ្នាំ២០១៣ | អាចដាក់ពាក្យសុំនិងពិនិត្យលើពាក្យសុំវិញ្ញាបនបត្រប្រភពដើមទំនិញតាមOnline នៅឆ្នាំ២០១៥ | MoC |
| *សូចនាករវាស់វែងសកម្មភាព៣៖* បង្កើតថ្លៃឈ្នួលសេវាកម្មស្របតាម WTO ពីសំណាក់ស្ថាប័នតាមព្រំដែនទាំងអស់ | GDCE និងMoC/កំពុងត្រូវបានអនុម័តកម្រៃសេវាដែលស្របគ្នាជាមួយ WTO | របនាសម្ព័ន្ធថ្លៃឈ្នួលសេវាស្របគ្នាជាមួយWTO សម្រាប់ទីភ្នាក់ងារតាមព្រំដែនទាំងអស់ត្រូវបានដាក់ឲ្យអនុវត្តនៅឆ្នាំ២០១៦ | ស្ថាប័នពាក់ព័ន្ធទាំងអស់តាមព្រំដែន |

| | | | |
|---|---|---|---|
| *សូចនាករវាស់វែងសកម្មភាព៤៖* កម្ពុជាកំពុងចាត់វិធានការដើម្បីអនុវត្តកិច្ចព្រមព្រៀង WTO ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម | កិច្ចព្រមព្រៀងមួយស្តីពីកិច្ចសម្រួលពាណិជ្ជកម្មត្រូវបានអនុម័តដែលជាផ្នែកមួយនៃ "កញ្ចប់ក្រុងបាលី"ដែលបានទទួលការអនុម័តគាំទ្រនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីនៃ WTO នៅខែធ្នូ២០១៣។កិច្ចព្រមព្រៀងនេះមានមាត្រាពិសេសសម្រាប់ LDCs | ដំណាច់ខែមិថុនាឆ្នាំ២០១៥កម្ពុជាបានជូនដំណឹងទៅWTO អំពីថាតើសកម្មភាពកែទម្រង់កិច្ចសម្រួលពាណិជ្ជកម្មរបស់ខ្លួននឹងត្រូវចាត់ចូលបែបណាទៅក្នុងជំពូក A, B, និង C នៃកិច្ចព្រមព្រៀងទាំងនោះ | MoC, GDCE, ស្ថាប័នតាមព្រំដែន |
| **សកម្មភាពសម្រាប់រយៈពេលមធ្យម៖២០១៦-២០១៨** | | | |
| *សូចនាករវាស់វែងសកម្មភាព១៖* ផែនការសកម្មភាពកិច្ចសម្រួលពាណិជ្ជកម្មដែលបានធ្វើបច្ចុប្បន្នភាពត្រូវបានអនុម័តនិងអនុវត្ត | សេចក្តីព្រាងផែនការសកម្មភាពកិច្ចសម្រួលពាណិជ្ជកម្មដែលបានធ្វើបច្ចុប្បន្នភាពមកដល់ចុងឆ្នាំ២០១៣ | ផែនការសកម្មភាពដែលបានធ្វើបច្ចុប្បន្នភាពត្រូវបានអនុម័តនិងអនុវត្តពេញលេញ | GDCE, MoC, MAFF និងស្ថាប័នតាមព្រំដែនទាំងអស់ |
| *សូចនាករវាស់វែងសកម្មភាព២៖* កម្ពុជាអនុវត្តផែនការសកម្មភាពកិច្ចសម្រួលពាណិជ្ជកម្មរបស់ខ្លួនដែលបានធ្វើបច្ចុប្បន្នភាព រួមទាំងបង្កើតយន្តការជាតិច្រកចេញចូលតែមួយ | គ្មានយន្តការច្រកចេញចូលតែមួយគិតមកទល់ឆ្នាំ២០១៣។ការចេញឯកសារសំខាន់ៗធ្វើឡើងជាស្វ័យប្រវត្តិខ្លះៗ | យន្តការជាតិច្រកចេញចូលតែមួយ (NSW) ដែលស្របគ្នាជាមួយលក្ខខណ្ឌអាស៊ានត្រូវបានអនុវត្តនៅឆ្នាំ២០១៨ | GDCE, MoC, MAFF និងស្ថាប័នតាមព្រំដែនទាំងអស់ |
| *សូចនាករវាស់វែងសកម្មភាព៣៖* កម្ពុជាបានធ្វើឲ្យមានការរីកចម្រើនទៅរកការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រពេញលេញសម្រាប់ឯកសារនានាដែលទាក់ទងនឹងពាណិជ្ជកម្ម | តម្រូវការវិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យសម្រាប់ការនាំចេញត្រូវបានចាត់ចែងដោយដៃតាមវិធីធម្មតា | អាចដាក់ពាក្យសុំវិញ្ញាបនបត្រអនាម័យនិងភូតគាមអនាម័យនិងពិនិត្យសម្រេចតាមប្រព័ន្ធអនឡាញ | MAFF |
| *សូចនាករវាស់វែងសកម្មភាព៤៖* ពង្រីកប្រព័ន្ធគ្រប់គ្រងហានិភ័យទៅដល់ស្ថាប័នក្រៅពីគយ | ការគ្រប់គ្រងហានិភ័យត្រូវគយអនុវត្តពេញលេញគិតត្រឹមឆ្នាំ២០១៣។មានការរីកចម្រើនខ្លះៗក្នុងស្ថាប័នក្រៅពីគយប៉ុន្តែការគ្រប់គ្រងហានិភ័យនៅពុំទាន់បង្កើតបានល្អ | ប្រព័ន្ធគ្រប់គ្រងហានិភ័យត្រូវបានស្ថាប័នទាំងអស់តាមព្រំដែនអនុវត្តពេញលេញហើយឯកសារពាក់ព័ន្ធត្រូវបានគ្រប់គ្រងក្នុងប្រព័ន្ធប្រមូលផ្តុំថ្នាក់កណ្តាលរហូតដល់ឆ្នាំ២០១៨ | GDCE, MoC, MAFF និងស្ថាប័នតាមព្រំដែនទាំងអស់ |
| *សូចនាករវាស់វែងសកម្មភាព៥៖* បង្កើតប្រព័ន្ធអាជ្ញាប័ណ្ណប្រតិបត្តិការសេដ្ឋកិច្ច (AEO) | របបAEO នៅពុំទាន់បានអនុវត្តនៅឡើយ | របបAEO ដែលស្របគ្នាជាមួយតម្រូវការគ្រប់គ្រងអនុលោមភាពរបស់កម្ពុជាត្រូវបានអនុវត្តពេញលេញនៅឆ្នាំ២០១៨ | GDCE |
| *សូចនាករវាស់វែងសកម្មភាព៦* | រហូតដល់ខែមិថុនាឆ្នាំ២០១៥កម្ពុជាបាន | រហូតដល់ខែមិថុនាឆ្នាំ២០១៧កម្ពុជាបាន | MoC, GDCE, |

| | | | |
|---|---|---|---|
| កម្ពុជាចាត់វិធានការអនុវត្តកិច្ចព្រមព្រៀង WTO/បាលីស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម | ជូនដំណឹងដល់ WTO អំពីសកម្មភាពកំណែទម្រង់កិច្ចសម្រួលពាណិជ្ជកម្មណាខ្លះរបស់ខ្លួនដែលស្ថិតក្នុងជំពូកA, B, និង C នៃកិច្ចព្រមព្រៀងនេះ | ជូនដំណឹងដល់ WTO អំពីការចាត់ចែងដែលចូលជាធរមានជាមួយ DPs ដែលទាក់ទងនឹង TA ដែលត្រូវការដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពក្នុងជំពូក C | និងស្ថាប័នតាមព្រំដែន |
| **លទ្ធផល៣៖ ពង្រឹងការដឹកជញ្ជូនពាណិជ្ជកម្ម** | | | |
| <u>**លទ្ធផល៣៖ការដឹកជញ្ជូនពាណិជ្ជកម្ម**</u><br>កម្ពុជាបង្កើនភាពប្រកួតប្រជែងរបស់ខ្លួនតាមរយៈការពង្រឹងការដឹកជញ្ជូនពាណិជ្ជកម្ម | នៅតាមច្រករបៀងពាណិជ្ជកម្មតាមផ្លូវគោកសំខាន់ៗចំនួនពីរល្បឿនជាមធ្យមសម្រាប់ការដឹកជញ្ជូនពាណិជ្ជកម្មគឺ២២,១៥គ.ម/ម៉ ថ្លៃចំណាយគឺ០,១១ដុល្លា/តោន/គ.មនិងថ្លៃដឹកជញ្ជូន ០,២ដុល្លា/តោន/គ.មនៅឆ្នាំ២០១២ | នៅឆ្នាំ២០០៨ល្បឿនសម្រាប់ការដឹកជញ្ជូនពាណិជ្ជកម្មកើនឡើងដល់២៥គ.ម/ម៉, ថ្លៃដឹកជញ្ជូនថយចុះដល់០,៧ដុល្លា/តោន/គ.ម ថ្លៃការដឹកជញ្ជូនថយចុះដល់០,១៥ដុល្លា/តោន/គ.ម (តាមថ្លៃថេរ) | MoPWT, MEF, MoC, MAFF |
| **សកម្មភាពរយៈពេលខ្លី៖ឆ្នាំ២០១៤-២០១៦** | | | |
| ***សូចនាករវាស់វែងសកម្មភាព១៖***<br>ផែនការជាតិដឹកជញ្ជូនត្រូវបានបង្កើតនិងអនុវត្ត | គ្មានផែនការទូលំទូលាយត្រូវបានបង្កើតឡើយ | ផែនការទូលំទូលាយត្រូវបានបង្កើត។ ផែនការនេះមានចំណងទាក់ទងនឹងក្របខ័ណ្ឌអាស៊ានដែលមានស្រាប់ដូចជា "*ផែនទីបង្ហាញផ្លូវសមាហរណកម្មសេវាកម្មការដឹកជញ្ជូន*" | MoPWT, MEF, ក្រសួងនិងស្ថាប័នពាក់ព័ន្ធ |
| ***សូចនាករវាស់វែងសកម្មភាព២៖***<br>កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន(តាមផ្លូវគោកនិងផ្លូវទឹក) ដែលបានកែលម្អស្ថិតក្នុងការចរចាជាមួយប្រទេសជិតខាង និងអង្គការតំបន់សម្រាប់ទីផ្សារដឹកជញ្ជូនចម្រុះ | កិច្ចព្រមព្រៀងមានស្រាប់មានគ្របដណ្តប់ត្រឹមតែមួយផ្នែកនិងមិនបានអនុវត្តពេញលេញឡើយ | កិច្ចព្រមព្រៀងឆ្លងដែន (ទ្វេភាគីនិងពហុភាគី) ត្រូវបានអនុម័តនិងអនុវត្តពេញលេញក្រោមកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង | MEF, MoC, MoPWT, MoFA, ក្រសួង និង ស្ថាប័នពាក់ព័ន្ធទាំងអស់ |
| ***សូចនាករវាស់វែងសកម្មភាព៣៖***<br>ធ្វើការពិនិត្យសន្តិសុខនៅកំពង់ផែព្រះសីហនុនិងភ្នំពេញនិងអនុវត្តផែនការដើម្បីកាត់បន្ថយការលួចបន្លំស្របជាមួយស្តង់ដារសន្តិសុខអន្តរជាតិ | ការលួចបន្លំត្រូវបានប្រតិបត្តិករវិស័យឯកជនរាយការណ៍ថាជាបញ្ហាមួយ | ប្រព័ន្ធមួយដើម្បីប្រមូលស្ថិតិអំពីការលួចបន្លំត្រូវបានដាក់ឲ្យអនុវត្តចាប់ពីឆ្នាំ២០១៤ ហើយការលួចបន្លំត្រូវបានកាត់បន្ថយយ៉ាងច្រើនចាប់ពីឆ្នាំ២០១៦ | អាជ្ញាកំពង់ផែទាំងអស់ក្រោមការសម្របសម្រួលជាមួយស្ថាប័នតាមព្រំដែនដទៃទៀត |

| | | | |
|---|---|---|---|
| *សូចនាករវាស់វែងសកម្មភាព៤៖* ការបន្ថយថ្លៃឈ្នួលកំពង់ផែដើម្បីបង្កើនភាពប្រកួតប្រជែង | កម្រៃកំពង់ផែកំណត់ដោយ RGC | កំពង់ផែកម្ពុជាកំណត់កម្រៃក្នុងកម្រិតប្រកួតប្រជែងធៀបនឹងប្រទេសជិតខាង។ ថ្លៃនៅកំពង់ផែព្រះសីហនុត្រូវបានបញ្ចុះ | MEF, MoPWT, MoC, អាជ្ញាធរកំពង់ផែទាំងអស់ |
| *សូចនាករវាស់វែងសកម្មភាព៥៖* វិស័យឯកជនចូលរួមនៅក្នុងប្រតិបត្តិការនិងការគ្រប់គ្រងកំពង់ផែ | ផែស្ថិតក្រោមការគ្រប់គ្រងដោយរដ្ឋាភិបាល | វិស័យឯកជនចូលរួមពាក់ព័ន្ធនៅក្នុងទិដ្ឋភាពខ្លះៗឬទាំងអស់នៃប្រតិបត្តិការនិងការគ្រប់គ្រងកំពង់ផែ | MEF, អាជ្ញាធរកំពង់ផែទាំងអស់, MoPWT |
| *សូចនាករវាស់វែងសកម្មភាព៦៖* ផ្លូវដែកតភ្ជាប់រវាងភ្នំពេញនិងខេត្តព្រះសីហនុផ្តល់សេវាដឹកជញ្ជូនទំនិញតាមកាលវិភាគជាទៀងទាត់ | ផ្លូវដែកតភ្ជាប់ត្រូវបានសាងសង់ឡើងវិញ/ជួសជុលឡើងវិញនិងមានសេវាកម្មតាមកាលវិភាគក្នុងកម្រិតកំណត់។ | សេវាដឹកទំនិញតាមផ្លូវដែកជាទៀងទាត់និងពេញលេញរវាងទីក្រុងទាំងពីរប្រព្រឹត្តទៅចាប់ពីឆ្នាំ២០១៤ | MoPWT |
| *សូចនាករវាស់វែងសកម្មភាព៧៖* បើកឡើងវិញការតភ្ជាប់ផ្លូវដែករវាងភ្នំពេញនិងប៉ោយប៉ែតដើម្បីប្រកួតប្រជែងជាមួយការដឹកជញ្ជូនតាមផ្លូវថ្នល់ | ការកសាងឡើងវិញឬជួសជុលឡើងវិញនូវផ្លូវដែកដែលតភ្ជាប់នៅពុំទាន់អនុវត្តរួចរាល់ | សេវាដឹកជញ្ជូនទំនិញតាមកាលវិភាគខ្លះៗតាមផ្លូវដែករវាងស៊ីសុផុននិងភ្នំពេញបានចាប់ផ្តើមពីឆ្នាំ២០១៦ | MoPWT |
| *សូចនាករវាស់វែងសកម្មភាព៨៖* បង្កើតទំនាក់ទំនងផ្លូវដែករវាងភ្នំពេញនិងព្រំដែនវៀតណាម | គ្មានផ្លូវដែកតភ្ជាប់ | ផែនការដើម្បីពង្រីកផ្លូវដែកតភ្ជាប់ពីភ្នំពេញទៅព្រំដែនវៀតណាមត្រូវបានរៀបចំរួចរាល់និងមានការប្តេជ្ញាផ្តល់ហិរញ្ញប្បទាន | MoPWT, MEF |
| **សកម្មភាពរយៈពេលមធ្យម៖ឆ្នាំ២០១៦-២០១៨** | | | |
| *សូចនាករវាស់វែងសកម្មភាព១៖* ផែនការជាតិកស្តុភាដឹកជញ្ជូនត្រូវបានអនុវត្ត | ផែនការទូលំទូលាយត្រូវបានបង្កើត | ផែនការជាតិដឹកជញ្ជូនត្រូវបានអនុវត្តរួមជាមួយសូចនាករគុណផល។ការពិនិត្យប្រចាំឆ្នាំនូវសូចនាករនានាត្រូវបានអនុវត្ត | MoPWT, MEF, ក្រសួងនិងស្ថាប័នពាក់ព័ន្ធនានា |
| *សូចនាករវាស់វែងសកម្មភាព២៖* កែលម្អបទប្បញ្ញត្តិដឹកជញ្ជូនអំពីៈការទទួលខុសត្រូវគុណវុឌ្ឍិនិងលក្ខខណ្ឌរបស់អ្នកបើកបរស្តង់ដារសុវត្ថិភាព | បទប្បញ្ញត្តិភាគច្រើននៅខ្វះខាតឬត្រូវការឲ្យពិនិត្យកែលម្អ | បទប្បញ្ញត្តិនានាស្របជាមួយស្តង់ដារអន្តរជាតិត្រូវបានអនុម័តនិងបានអនុវត្ត | MoPWT, GDCE, MoC, MoC/កាំកុងត្រូល, MAFF |

| | | | |
|---|---|---|---|
| *សូចនាករវាស់វែងសកម្មភាព៣៖*<br>ធ្វើការជាមួយអាស៊ានដើម្បីបង្កើតប្រព័ន្ធធានារ៉ាប់រងការទទួលខុសត្រូវលើភាគីទីបីនៅកម្រិតតំបន់ | គ្មានប្រព័ន្ធធានារ៉ាប់រងការទទួលខុសត្រូវលើភាគីទី៣សម្រាប់អនុវត្តឡើយ | មានប្រព័ន្ធធានារ៉ាប់រងការទទួលខុសត្រូវលើភាគីទី ៣ | MEF, MoPWT |
| *សូចនាករវាស់វែងសកម្មភាពទី៤៖*<br>ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធទំនើបកម្មសេវាដឹកជញ្ជូនតាមផ្លូវគោក | គ្មានគោលនយោបាយដើម្បីលើកកំពស់ទំនើបកម្មសេវាដឹកជញ្ជូនតាមផ្លូវគោកឡើយ | RGC បានបង្កើតគោលនយោបាយសម្រាប់ទំនើបកម្មសេវាដឹកជញ្ជូនតាមផ្លូវគោកដោយបានកំណត់អត្តសញ្ញាណចំណុចដៅច្បាស់លាស់ខ្លះៗ | MEF, MoPWT, MoC, ឧស្សាហកម្មដឹកជញ្ជូនតាមរថយន្តដឹកទំនិញ |
| *សូចនាករវាស់វែងសកម្មភាព៥៖*<br>បង្កើនសមត្ថភាពកំពង់ផែខេត្តព្រះសីហនុសម្រាប់នាវាទឹកជ្រៅ | ជម្រៅទឹកបច្ចុប្បន្នសម្រាប់នាវាទឹកជ្រៅនៅមានកម្រិតកំណត់ត្រឹមតិចជាង១.០០០ TEU។ ការជីកស្តារបន្ថែមកំពុងអនុវត្តនិងសម្បទាថ្មីៗកំពុងស្ថិតក្នុងការសាងសង់ | ការជីកស្តារត្រូវបានបញ្ចប់ហើយផែខេត្តព្រះសីហនុផ្តល់លទ្ធភាពសម្រាប់នាវាមានចំណុះធំជាង១.០០០ TEUចូលចតបាន | MoPWT, អាជ្ញាធរផែព្រះសីហនុ, MEF |
| *សូចនាករវាស់វែងសកម្មភាព៦៖*<br>ស្វែងយល់ពីលទ្ធភាពក្នុងការបង្កើតសមត្ថភាពទទួលនាវាធំៗនៅផែភ្នំពេញ | ផែភ្នំពេញអាចទទួលនាវាដឹកទំនិញធំជាង ១២០TEU | សិក្សាលទ្ធភាពជីកស្តារទន្លេមេគង្គរវាងភ្នំពេញនិងផែសៃហ្គនដើម្បីអាចឲ្យនាវាធំជាង១២០ TEU អាចឆ្លងកាត់បាន | MoPWT, ផែភ្នំពេញ |
| *សូចនាករវាស់វែងសកម្មភាព៧៖*<br>កែលម្អផ្លូវថ្នល់រវាងភ្នំពេញនិងខេត្តព្រះសីហនុ | កំណាត់ផ្លូវភាគច្រើននៅតែមានត្រឹមពីរច្រកសម្រាប់រថយន្តធ្វើដំណើរ | ផ្លូវថ្នល់បួនច្រករវាងភ្នំពេញនិងខេត្តព្រះសី-ហនុត្រូវបានបង្កើយ | MoPWT, MEF |
| *សូចនាករវាស់វែងសកម្មភាព៨*<br>បង្កើនលក្ខខណ្ឌផ្លូវជាតិរវាងព្រំដែនប្រទេសថៃនិងវៀតណាម | ការដឹកជញ្ជូនតាមផ្លូវថ្នល់ជាមធ្យមកុងតឺន័រ ២០ហ្វីតរវាងព្រំដែនទាំងពីរត្រូវចំណាយពេល១៥ម៉ោងនៅឆ្នាំ២០១៣ | ការដឹកជញ្ជូនតាមផ្លូវថ្នល់ជាមធ្យមកុងតឺន័រ ២០ហ្វីតរវាងព្រំប្រទល់ទាំងពីរបញ្ចុះមកត្រឹម១៣ម៉ោងនៅឆ្នាំ២០១៨ព្រោះផ្លូវល្អជាងមុន | MoPWT, MEF |
| **<u>លទ្ធផល៤៖បានពង្រឹងសមត្ថភាពក្រុមហ៊ុននាំចេញក្នុងការបំពេញតាមស្តង់ដារបច្ចេកទេសនិងលក្ខខណ្ឌ SPS</u>** | | | |
| **<u>លទ្ធផល៤៖ស្តង់ដារបច្ចេកទេសនិងលក្ខខណ្ឌ SPS</u>**<br>កំណើនសមត្ថភាពរបស់ក្រុមហ៊ុននាំចេញ | បរិមាណការនាំចេញជាផ្លូវការនូវអង្ករដំឡូងនិងពោតជៀបនឹងផលិតផលសរុបក្នុងមួយតោនៗឆ្លុះបញ្ចាំងដោយផ្ទាល់អំពីសមត្ថភាព | ផលធៀបទាំងបីកើនឡើងដប់ដងឬច្រើនជាងគិតចាប់ពីឆ្នាំ២០១៨ដែលបង្ហាញពី | វិស័យឯកជន, MAFF, MoC, MIH |

| | | | |
|---|---|---|---|
| កម្ពុជាក្នុងការបំពេញតាមស្តង់ដារបច្ចេកទេស និងលក្ខខណ្ឌ SPS ដែលកំណត់ដោយក្រុមហ៊ុននាំចូលនិងប្រទេសនាំចូល | របស់ផលិតករ/ក្រុមហ៊ុននាំចេញកម្ពុជាក្នុងការបំពេញតាមស្តង់ដារខ្លះ១៖<br>២០១១ផលជៀបអង្ករ៖០,០១៦៥<br>២០១១ផលជៀបដំឡូង៖០,០០៨៥<br>២០១១ផលជៀបពោត៖០,០៤៩៧<br>(MoC សម្រាប់ការនាំចេញផ្លូវការជាតោន; AFSIS សម្រាប់ផលិតផលសរុបជាតោន) | ការផ្លាស់ប្តូរជាខ្លាំងពីការនាំចេញមិនផ្លូវការទៅផ្លូវការ | |
| **សកម្មភាពរយៈពេលខ្លី៖២០១៤-២០១៦** | | | |
| *សូចនាករវាស់វែងសកម្មភាព១៖*<br>សមត្ថភាពម៉ាស៊ីនស្រូវក្នុងការវិភាគគ្រោះថ្នាក់និងចំណុចត្រួតពិនិត្យសំខាន់ៗ(HACCP) ឬស្តង់ដារទម្លាប់ល្អក្នុងផលិតកម្ម (GMP) ត្រូវបានបង្កើតតាមរយៈកម្មវិធីវិញ្ញាបនបត្រម៉ាស៊ីនស្រូវ | គ្មានរោងម៉ាស៊ីនស្រូវទំនើបដែលបានទទួលការបញ្ជាក់ឡើយមកទល់ឆ្នាំ២០១៣ (ម៉ាស៊ីនស្រូវមួយទទួលការបញ្ជាក់ពី ISC, ប៉ុន្តែ ISC គ្មានការទទួលស្គាល់ជាអន្តរជាតិនៅឡើយទេដូច្នេះការបញ្ជាក់នេះគ្មានតម្លៃសម្រាប់ការនាំចេញឡើយ) | រោងម៉ាស៊ីនស្រូវចំនួន១០បានទទួលការបញ្ជាក់ខាង HACCP ឬ GMP នៅឆ្នាំ២០១៦ | វិស័យឯកជន, MIH, MAFF |
| *សូចនាករវាស់វែងសកម្មភាព២៖*<br>ការអនុវត្តស្តង់ដារ SPS (HACCP ឬGMP) ក្នុងចំណោមអ្នកកែច្នៃផលនេសាទសមុទ្រដែលនាំមកនូវកំណើនភាពប្រកួតប្រជែងក្នុងការនាំចេញ | រោងចក្រកែច្នៃផលនេសាទសមុទ្រ១ទទួលបានការបញ្ជាក់ HACCP/GMP នៅឆ្នាំ២០១៣ | រោងចក្រកែច្នៃផលនេសាទសមុទ្រចំនួន១២បានទទួលការបញ្ជាក់ HACCP/GMP នៅឆ្នាំ២០១៦ | វិស័យឯកជន, MAFF/FiA |
| *សូចនាករវាស់វែងសកម្មភាព៣៖*<br>សមត្ថភាពកែច្នៃដំឡូងស្ងួតក្នុងការបំពេញតាមស្តង់ដារផ្អែកលើ GMPត្រូវបានបង្កើតតាមរយៈកម្មវិធីចេញវិញ្ញាបនបត្របញ្ជាក់ | គ្មានប្រព័ន្ធបញ្ជាក់សម្រាប់អនុវត្តឡើយ | មានប្រព័ន្ធវិញ្ញាបនបត្របញ្ជាក់សម្រាប់ក្រុមហ៊ុនកែច្នៃដែលផលិតសម្រាប់ទីផ្សារនាំចេញរឹតត្បិតនៅឆ្នាំ២០១៦ | វិស័យឯកជន, MIH, MAFF |
| *សូចនាករវាស់វែងសកម្មភាព៤៖*<br>ខ្សែចង្វាក់តម្លៃកៅស៊ូកម្ពុជាបង្កើតផលិតផលដែលមានគុណភាពខ្ពស់សម្រាប់ផ្សារនាំចេញ | គ្មានប្រព័ន្ធសម្រាប់តាមដានគុណភាពកៅស៊ូធម្មជាតិដែលនាំចេញឡើយ | ប្រព័ន្ធចុះបញ្ជីបរិមាណកៅស៊ូធម្មជាតិតាមកម្រិតគុណភាពនិងថ្លៃត្រូវបានដាក់ឲ្យអនុវត្តនៅឆ្នាំ២០១៦ | វិស័យឯកជន, MAFF, MoC, RRIC |

| | | | |
|---|---|---|---|
| *សូចនាករវាស់វែងសកម្មភាព៥៖*<br>ការឃ្លាំមើលកត្តាចង្រៃនិងជម្ងឺលើដំណាំសម្រាប់ការនាំចេញថ្នាំគីមីកសិកម្មនិងជីគីមីដែលប្រើប្រាស់ក្នុងតំបន់ផលិតសម្រាប់នាំចេញ | គ្មានប្រព័ន្ធឃ្លាំមើលជាផ្លូវការនៅឆ្នាំ២០១៣ | មានប្រព័ន្ធឃ្លាំមើលជាផ្លូវការសម្រាប់កត្តាចង្រៃនិងជម្ងឺលើដំណាំនិងថ្នាំគីមីកសិកម្មតាមលក្ខខណ្ឌរបស់ក្រុមហ៊ុននាំចូលធំៗនិងដោយត្រូវគោរពតាមស្តង់ដារអន្តរជាតិនិងការធ្វើរបាយការណ៍ជាទៀងទាត់ទៅ IPPC, អាស៊ាននិងដៃគូពាណិជ្ជកម្មពីឆ្នាំ២០១៦ | MAFF/GDA |
| *សូចនាករវាស់វែងសកម្មភាព៦*<br>ការឃ្លាំមើលជម្ងឺឆ្លងដែនលើសត្វនានា | គ្មានប្រព័ន្ធជាផ្លូវការសម្រាប់ប្រើប្រាស់នៅឆ្នាំ២០១៣លើកលែងតែសម្រាប់ជម្ងឺផ្តាសាយបក្សី | មានប្រព័ន្ធឃ្លាំមើលជាផ្លូវការក្នុងតំបន់គោលដៅសម្រាប់ FMD (ជម្ងឺអុតក្តាម), CSF (ជម្ងឺគ្រុនជ្រូកជម្មតា), និង PRRS (ប្រជុំរោគសញ្ញាប្រដាប់បន្តពូជនិងផ្លូវដង្ហើមលើសត្វជ្រូក)។ភស្តុតាងអំពីការពិនិត្យតាមដាននិងរាយការណ៍ជាទៀងទាត់ទៅ OIE ចាប់ពីឆ្នាំ២០១៦ | MAFF/DAHP |
| *សូចនាករវាស់វែងសកម្មភាព៧*<br>ការឃ្លាំមើលនិងធ្វើតេស្តផលិតផលអាហារ | គ្មានប្រព័ន្ធជាផ្លូវការសម្រាប់អនុវត្តនៅឆ្នាំ២០១៣ | មានប្រព័ន្ធឃ្លាំមើលជាផ្លូវការសម្រាប់ទីផ្សារភោជនីយដ្ឋាននិងអាហារលក់តាមផ្លូវជាមួយរបាយការណ៍ប្រចាំឆ្នាំអំពីសុវត្ថិភាពអាហារនៅកម្ពុជា។ការចូលរួមសកម្មនៅក្នុងបណ្តាញអាជ្ញាធរអន្តរជាតិសុវត្ថិភាពអាហារ(INFOSAN) និងប្រព័ន្ធប្រកាសព័ត៌មានរហ័សអាស៊ានសម្រាប់អាហារនិងចំណីសត្វ (ARASFF) ពីឆ្នាំ២០១៦តទៅ | MoC/កាំកុងត្រូល, MoH |
| *សូចនាករវាស់វែងសកម្មភាព៨៖*<br>ការពិនិត្យលើកឯកសារច្បាប់និងអនុសាសន៍សម្រាប់កែលម្អលិខិតបទដ្ឋានគតិយុត្តិលើ SPS និង TBT | ក្របខ័ណ្ឌច្បាប់សម្រាប់ SPS និងTBT មានភាពខ្វះចន្លោះជាច្រើនគ្មានសង្គតិភាពមានអាណត្តិមិនច្បាស់លាស់និងមានបញ្ហាខាងគុណភាព។វាមិនស្របគ្នាជាមួយគោលការណ៍WTO ឬគោលការណ៍អាស៊ានឡើយ | ការវាយតម្លៃជាមួយអនុសាសន៍ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់ SPS និង TBT ត្រូវបានធ្វើរួចរាល់នៅឆ្នាំ២០១៥ | MoC, MAFF, MoH, MIH, MoT, MEF, CoM, |

| | | | |
|---|---|---|---|
| *សូចនាករវាស់វែងសកម្មភាព៩៖* វិសោធនកម្មច្បាប់ស្តីពីស្តង់ដារដើម្បីធ្វើឲ្យស្របគ្នាជាមួយ WTO | ច្បាប់ស្តីពីស្តង់ដារគ្មានភាពស្របគ្នាជាមួយគោលការណ៍របស់ WTOឡើយ | ច្បាប់ស្តីពីស្តង់ដារត្រូវបានធ្វើវិសោធនកម្មនិងមានភាពស្របគ្នាជាមួយ WTO នៅឆ្នាំ ២០១៦ | MIH, CoM, |
| *សូចនាករវាស់វែងសកម្មភាព១០៖* យុទ្ធសាស្ត្រដើម្បីគាំទ្រដល់ការបង្កើតមន្ទីរពិសោធន៍និយ័តកម្ម SPS | គ្មានផែនការជាតិគ្មានការសម្របសម្រួល | ផែនការសកម្មភាពសម្រាប់បង្កើតមន្ទីរពិសោធន៍ធ្វើតេស្តនិយ័តកម្មអាហារបានរួចរាល់នៅឆ្នាំ២០១៦ | MEF, MoC, MAFF, MIH, MoH |
| **សកម្មភាពរយៈពេលមធ្យម៖២០១៦-២០១៨** | | | |
| *សូចនាករវាស់វែងសកម្មភាព១៖* ក្របខ័ណ្ឌច្បាប់សម្រាប់អនុលោមភាពនៃការវាយតម្លៃការទទួលស្គាល់លើស្តង់ដារបច្ចេកទេសនិង SPS | គ្មានក្របខ័ណ្ឌច្បាស់សមស្របសម្រាប់អនុវត្ត | បានអនុម័តលើក្របខ័ណ្ឌច្បាប់ដែលស្របគ្នាជាមួយគោលការណ៍ WTO/TBT និងអាស៊ាននិងទម្លាប់ល្អជាអន្តរជាតិ នៅឆ្នាំ ២០១៨ | MIH, MAFF, MoH, MoC, CoM |
| *សូចនាករវាស់វែងសកម្មភាព២៖* ក្របខ័ណ្ឌច្បាប់សម្រាប់សុវត្ថិភាពអាហារត្រូវបានពង្រឹងដែលរួមទាំងការអនុម័តនិងប្រកាសឲ្យប្រើច្បាប់ទំនើបស្តីពីអាហារ | គ្មានក្របខ័ណ្ឌច្បាស់សមស្របសម្រាប់អនុវត្ត | បានអនុម័តលើក្របខ័ណ្ឌច្បាប់ដែលស្របគ្នាជាមួយគោលការណ៍ WTO/TBT និងអាស៊ាន និងទម្លាប់ល្អជាអន្តរជាតិនៅឆ្នាំ ២០១៨ | MoC/កាំកុងត្រូល, MoH, MAFF, MIH, MoT, MEF, CoM |
| *សូចនាករវាស់វែងសកម្មភាព៣៖* ការឃ្លាំមើលនិងធ្វើតេស្តផលិតផលអាហារបឋមនៅកម្រិតផលិតកម្មនិងកែច្នៃបឋម | គ្មានក្របខ័ណ្ឌច្បាស់សម្រាប់អនុវត្តនៅឆ្នាំ២០១៣ | MAFFមានប្រព័ន្ធឃ្លាំមើលជាផ្លូវការសម្រាប់អនុវត្តនិងភស្តុតាងលើការតាមដានទៀងទាត់ជាមួយវិភាគទានដល់ MoC និង MoH សម្រាប់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំអំពីស្ថានភាពសុវត្ថិភាពអាហារនៅកម្ពុជានិងរបាយការណ៍ទៅ INFOSAN និង ARASFF ចាប់ពីឆ្នាំ២០១៨តទៅ | MAFF, MoC/កាំកុងត្រូល, MoH |

| | | | |
|---|---|---|---|
| ***សូចនាករវាស់វែងសកម្មភាព៤៖***<br>ការឃ្លាំមើលសំណល់ថ្នាំព្យាបាលសត្វនិងផលិតផលជម្រុញការលូតលាស់របស់សត្វចិញ្ចឹមនៅក្នុងផលិតកម្មសត្វនិងចំណីសត្វ | គ្មានក្របខ័ណ្ឌច្បាស់សម្រាប់អនុវត្តនៅឆ្នាំ២០១៣ | មានប្រព័ន្ធឃ្លាំមើលជាផ្លូវការប្រចាំឆ្នាំសម្រាប់អនុវត្តនិងភស្តុតាងអំពីការតាមដានទៀងទាត់ចាប់ពីឆ្នាំ២០១៨តទៅ | MAFF/DAHP |
| ***សូចនាករវាស់វែងសកម្មភាព៥៖***<br>FiA ត្រូវបានពង្រឹងមានគុណវុឌ្ឍិជា"អាជ្ញាធរមានសមត្ថកិច្ច" សម្រាប់ EU និងអាចគាំទ្រដល់ការនាំចេញផលនេសាទទៅ EU | ការនាំចេញផលនេសាទទៅEU មិនទាន់អាចធ្វើបាន។ការគ្រប់គ្រងជាសាធារណៈលើSPS សម្រាប់ផលនេសាទនៅទន់ខ្សោយ | FiA បានការទទួលស្គាល់ថាជា"អាជ្ញាធរមានសមត្ថកិច្ច"សម្រាប់ EUនិងអាចគាំទ្រដល់ការនាំចេញផលនេសាទទៅទីផ្សារEUចាប់ពីឆ្នាំ២០១៨តទៅ | MAFF/FiA |
| ***សូចនាករវាស់វែងសកម្មភាព៦៖***<br>មានការសម្របសម្រួល SPS ប្រកបដោយប្រសិទ្ធភាព | សមត្ថភាពរបស់អង្គភាពសាកសួរអំពី SPS, អាជ្ញាធរជូនដំណឹង, កូដិច(Codex), IPPC និងជនទំនាក់ទំនង OIE នៅមានកម្រិតកំណត់ជាខ្លាំង | មានអង្គភាពស៊ើបអង្កេតអំពីSPS និងអាជ្ញាធរជូនដំណឹងរួមជាមួយ (i) វេបសាយថ្មីៗអំពីលិខិតបទដ្ឋានគតិយុត្តិអំពី SPS និងលក្ខខណ្ឌនាំចូលនិងនាំចេញ(អាចជាផ្នែកមួយនៃផតថលព័ត៌មានជាតិ) និង (ii)ការជូនដំណឹងអំពីវិធានការ SPS ថ្មីៗដែលបានអនុវត្តតាមការកំណត់របស់ WTO។ គណៈកម្មាធិការជាតិកូដិចជួបប្រជុំជាទៀងទាត់ដើម្បីសម្របសម្រួលសុវត្ថិភាពអាហារ។ កូដិច, IPPC, និងជនទំនាក់ទំនងOIE មានដំណើរការបានល្អចាប់ពីឆ្នាំ២០១៨ | MoC, MAFF, MIH, MoH, វិស័យឯកជន |
| ***សូចនាករវាស់វែងសកម្មភាព៧៖***<br>ស្តង់ដារSPS សម្រាប់ផ្ទះបាយនៅតាមសណ្ឋាគារនិងភោជនីយដ្ឋានត្រូវបានកែលម្អតាមរយៈកំណើនការបណ្តុះបណ្តាលបុគ្គលិកដែលមានស្រាប់និងថ្មីៗនៅតាមផ្ទះបាយ | សន្ទស្សន៍ពីការអង្កេតលក្ខខណ្ឌគោលនៃស្តង់ដារ SPS ក្នុងផ្ទះបាយតាមសណ្ឋាគារ និងភោជនីយដ្ឋាននឹងត្រូវធ្វើឡើងដោយរាជបណ្ឌិតសភាសិល្បៈធ្វើម្ហូបក្រោម CEDEP- | ការអង្កេតទិន្នន័យគោលឡើងវិញ (CEDEP II) នៅឆ្នាំ២០១៦-១៧ | វិស័យឯកជន, MoH, RACA, MoT |

| | | | |
|---|---|---|---|
| | II។ ត្រូវប្រើប្រាស់ព័ត៌មានពីចំណាត់ថ្នាក់ស្ម័គ្រចិត្តនៃទម្លាប់ល្អខាងសុខភាព (GHP) ផងដែរដែលMoHដាក់ឲ្យប្រើប្រាស់ | | |
| | ប្រព័ន្ធចាត់ថ្នាក់ភោជនីយដ្ឋានកំពុងស្ថិតក្នុងការរៀបចំ។ គ្មានភោជនីយដ្ឋានណាមួយបានជាប់ចំណាត់ថ្នាក់ឡើយក្នុងសវនកម្ម GHP/GMP។ស្តង់ដារអនាម័យកម្រិតទាបនៅក្នុងវិស័យនេះ | មានប្រព័ន្ធចំណាត់ថ្នាក់សម្រាប់អនុវត្ត។ភោជនីយដ្ឋានចំនួន២០០ជាប់ចំណាត់ថ្នាក់សវនកម្ម GHP/GMP ចាប់ពីឆ្នាំ២០១៨ | វិស័យឯកជន, MoH, MoT |
| ***សូចនាករវាស់វែងសកម្មភាព៨៖***<br>ការនាំចេញពោតគោរពបានតាមស្តង់ដារSPS | គ្មានកិច្ចព្រមព្រៀងប្រើប្រាស់ទីផ្សារជាមួយប្រទេសដែលតម្រូវឲ្យគោរពតាម SPSឡើយ | មានMoU រវាងកម្ពុជា-ចិនអំពីលក្ខខណ្ឌអនាម័យ និងភូតគាមអនាម័យសម្រាប់ការនាំចេញពោតនិងបានអនុវត្តចាប់ពីឆ្នាំ ២០១៧ | MAFF, MoC |
| ***សូចនាករវាស់វែងសកម្មភាព៩៖***<br>សមត្ថភាពសម្ងួតពោតបកសំបកនិងមធ្យោបាយរក្សាទុកបំពេញបានតាមវិញ្ញាបនកម្ម GMP/HACCP | គ្មានមធ្យោបាយស្របតាមវិញ្ញាបនកម្ម GMP/HACCP | សម្បទា៥កន្លែងដែលបានធ្វើវិញ្ញាបនកម្ម GMP/HACCP រហូតដល់ឆ្នាំ២០១៨ | វិស័យឯកជន, MIH, MAFF |
| ***សូចនាករវាស់វែងសកម្មភាព១០៖***<br>គុណភាពនិងលទ្ធភាពកំណត់ប្រភពដើមនៃសសៃសូត្រនាំចូលត្រូវបានធានា | ខ្វះCOsសម្រាប់សសៃសូត្រនាំចូលភាគច្រើន | ៣០%នៃសសៃសូត្រនាំចូលមាន COច្បាស់លាស់រហូតដល់ឆ្នាំ២០១៨ | វិស័យឯកជន, MoC, MoWA, |
| ***សូចនាករវាស់វែងសកម្មភាព១១៖***<br>សុវត្ថិភាពក្នុងចំណោមសម្បទានាំចេញអាហារកែច្នៃត្រូវបានពង្រឹងដោយបង្កើនការអនុវត្តវិញ្ញាបនកម្ម GMP និង HACCP | សម្បទាកែច្នៃអាហារធំៗចំនួន៧កន្លែងត្រូវបានបញ្ជាក់ក្នុងពេលថ្មីៗនៅក្រោមស្តង់ដារ HACCP, GMP, ISO 22000 ឬ FSSC 22000 | សម្បទាកែច្នៃអាហារ២០កន្លែងថែមទៀតត្រូវបានបញ្ជាក់តាមស្តង់ដារអន្តរជាតិរហូតដល់ឆ្នាំ២០១៨ | វិស័យឯកជន, MIH, MoH |

| | | | |
|---|---|---|---|
